ក្រសួងអប់រំ យុវជន និងកីឡា

# សេដ្ឋកិច្ចវិទ្យា

## ថ្នាក់ទី ១១

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

krou.moeys.gov.kh
youtube.com/moeys
facebook.com/moeys.gov.kh

**គណៈកម្មការនិពន្ធ** លោកស្រី ប៉ែន នាង លោកស្រី ទេព ប៊ុណ្ណារី
លោក ឃ្លោក វីរ៉ា លោក លឹម សុជាតិ

**អ្នកវាយអត្ថបទ** លោកស្រី ម៉ៅ សម្ផស្ស

**វិចិត្រករ** លោក ឡុង សុវណ្ណា

**អ្នករៀបរៀង** លោក ឃ្លោក វីរ៉ា

**អ្នករចនាទំព័រ** លោក ហាក់ វណ្ណថា

**គណៈកម្មការពិនិត្យ** លោកស្រី ជិន យ៉ាហាន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ២៤៧៦ អយក.ប្រក. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី១១ ឆ្នាំ២០២០ ចំនួន១៨ ០០០ច្បាប់

ISBN 9-789-995-001-032

youtube.com/moeys
kroumoeys.gov.kh
facebook.com/moeys.gov.kh

# អារម្ភកថា

សៀវភៅសេដ្ឋកិច្ចវិទ្យាថ្នាក់ទី 11 នេះ បានរៀបចំឡើងជាលើកដំបូងដោយផ្អែកលើកម្មវិធីសិក្សាគោលថ្មី សម្រាប់សាលាមធ្យមសិក្សាទុតិយភូមិនិងគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ 2005-2009 របស់ក្រសួងអប់រំ យុវជន និងកីឡា ។ ខ្លឹមសារក្នុងសៀវភៅនេះ មានចែកចេញជា 3 ជំពូក និង 27 មេរៀន ដែលត្រូវប្រើប្រាស់រយៈពេលសិក្សាចំនួន 152 ម៉ោង ដោយចែកជា 4 ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ 1 ឆ្នាំដែលមាន 38 សប្តាហ៍ ។

ការបង្រៀននិងរៀនមុខវិជ្ជាសេដ្ឋកិច្ចវិទ្យានេះ មានគោលដៅបណ្តុះចំណេះដឹងជាមូលដ្ឋានក្នុងផ្នែកសេដ្ឋកិច្ចវិទ្យា បំប៉នបំណិនក្នុងការគិត វិភាគ ពិចារណា និងចាត់ចែងសកម្មភាពពាក់ព័ន្ធនឹងសេដ្ឋកិច្ចនិងជ្រើសយកឥរិយាបថជាអ្នកគ្រប់គ្រងនិងទទួលខុសត្រូវលើខ្លួនឯងក្នុងការចូលរួមបង្កើនសេដ្ឋកិច្ចផ្ទាល់ខ្លួន សេដ្ឋកិច្ចគ្រួសារ ការត្រៀមបង្កើតមុខរបរចិញ្ចឹមជីវិតនៅពេលអនាគត ឬបន្តការសិក្សាទៅមុខទៀត ។ ទន្ទឹមនឹងនេះ គ្រូបង្រៀននិងអ្នកសិក្សាអាចរៀបចំដំណើរសកម្មភាពសិក្សាក្នុងថ្នាក់ទៅតាមលំនាំលេខរៀងនៃសំណួរដែលមាននៅខាងក្រោមអត្ថបទមេរៀននីមួយៗនិងទីបញ្ចប់ផ្ទៀងផ្ទាត់លទ្ធផលសិក្សារបស់សិស្សទៅតាមវត្ថុបំណងនៃមេរៀននីមួយៗ ។

យើងខ្ញុំជាគណៈកម្មការនិពន្ធ សង្ឃឹមថាសៀវភៅនេះនឹងក្លាយជាឯកសារជំនួយដ៏សំខាន់ក្នុងការរៀបចំកិច្ចតែងការបង្រៀន ការបង្រៀន រៀន និងការវាស់ស្ទង់លទ្ធផលសិក្សា ។ ព្រមជាមួយគ្នានេះ យើងខ្ញុំរង់ចាំទទួលយកនូវរាល់សំណួរនិងមតិចូលរួមផ្សេងៗអំពីសំណាក់លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន ។

**គណៈកម្មការនិពន្ធ**

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# បញ្ជីអត្ថបទ

ទំព័រ


**ជំពូកទី 1 ៖ សេដ្ឋកិច្ចទីផ្សារនិងផលិតកម្ម ........................................ 1**

1. ប្រព័ន្ធសេដ្ឋកិច្ច ........................................ 2
2. ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ........................................ 14
3. ការវាយតម្លៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ........................................ 20
4. ទីផ្សារ ........................................ 28
5. រចនាសម្ព័ន្ធទីផ្សារ ........................................ 34
6. គ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា ........................................ 40
7. កម្មសិទ្ធិឯកជននិងសេរីភាពក្នុងការជ្រើសរើស ........................................ 48
8. ផលិតផលជាតិ ........................................ 54
9. ផលិតកម្ម ........................................ 60
10. ព្រំដែនសមត្ថភាពផលិតកម្ម ........................................ 66

**ជំពូកទី 2 ៖ រដ្ឋនិងសេដ្ឋកិច្ច ........................................ 73**

1. មីក្រូនិងម៉ាក្រូសេដ្ឋកិច្ច ........................................ 74
2. គោលនយោបាយសេដ្ឋកិច្ច ........................................ 80
3. សេដ្ឋកិច្ចកម្ពុជា ........................................ 84
4. តួនាទីរដ្ឋក្នុងដំណើរសេដ្ឋកិច្ច ........................................ 96
5. អន្តរាគមន៍រដ្ឋក្នុងទីផ្សារ ........................................ 104
6. ចំណូលជាតិ ........................................ 112
7. គោលនយោបាយចំណាយនិងសារពើពន្ធ ........................................ 118
8. ជាតូបនីយកម្មនិងឯកជនូបនីយកម្ម ........................................ 128
9. ពលកម្មនិងប្រាក់បៀវត្ស ........................................ 132
10. ភាពគ្មានការងារធ្វើ ........................................ 138
11. វិបត្តិសេដ្ឋកិច្ច ........................................ 144
12. កម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ ........................................ 152

**ជំពូកទី 3 ៖ ប្រវត្តិគំនិតសេដ្ឋកិច្ច ........................................ 159**

1. បណ្ដាគំនិតផ្ដួចផ្ដើមដំបូង ........................................ 160
2. បណ្ដាគំនិតតន្ដឹ ........................................ 168
3. គំនិតលោកកាល់ម៉ាក្សនិងគំនិតតន្ដឹ ........................................ 176
4. បណ្ដាគំនិតតន្ដឹថ្មីនិងសមតាទូទៅ ........................................ 182
5. កេនជាមួយនិងគំនិតបូរណនិយោជន៍ ........................................ 192


youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

# ជំពូកទី 1 សេដ្ឋកិច្ចទីផ្សារនិងផលិតកម្ម



*ផ្សារលក់ផលិតផលខ្មែរ*

នៅក្នុងជំពូកនេះ សិក្សាពីអត្ថន័យនៃបញ្ញត្តិប្រព័ន្ធសេដ្ឋកិច្ច ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ការវាយតម្លៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ទីផ្សារនិងថ្លៃ រចនាសម្ព័ន្ធទីផ្សារ គ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា កម្មសិទ្ធិឯកជន សេរីភាពក្នុងការជ្រើសរើស ផលិតផលជាតិ ផលិតកម្ម និងព្រំដែនសមត្ថភាពផលិតកម្ម ។

ការសិក្សានៅជំពូកនេះ សិស្សនឹងអាចពន្យល់និងបកស្រាយបណ្តាបញ្ញត្តិខាងលើបាន ។

facebook.com/moeys.gov.kh

មេរៀនទី

# 1 ប្រព័ន្ធសេដ្ឋកិច្ច

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់បកស្រាយសញ្ញាណទូទៅនៃសេដ្ឋកិច្ច និយមន័យសេដ្ឋកិច្ច និងប្រភេទសេដ្ឋកិច្ច ។
- បង្ហាញអត្ថន័យនៃបញ្ញត្តិ "វិទ្យាសាស្ត្រសេដ្ឋកិច្ច" ។
- ប្រាប់អំពីផលប៉ះពាល់នៃការអភិវឌ្ឍសង្គមចំពោះបរិស្ថានធម្មជាតិនិងសង្គម ។



ការយល់ពីសញ្ញាណ អត្ថន័យនៃសេដ្ឋកិច្ច និងការកំណត់បានអំពីប្រភេទនៃប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសដែលខ្លួនរស់នៅ ជួយឱ្យអ្នកសិក្សារកឃើញវិធីជាក់លាក់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនផ្ទាល់ដោយភាពសមស្រប ។

# 1. សេចក្តីផ្តើមនៃការសិក្សាសេដ្ឋកិច្ច

ការរស់នៅរបស់មនុស្សក្នុងក្រុមគ្រួសារ សហគមន៍ និងសង្គមនីមួយៗត្រូវមានជាចាំបាច់របស់របរប្រើប្រាស់គ្រប់បែបយ៉ាង ដែលឆ្លុះបញ្ចាំងឱ្យឃើញទំនាក់ទំនងរវាងការរស់នៅរបស់មនុស្សជាមួយនឹងធម្មជាតិ ឬ*ទំនាក់ទំនងរវាងមនុស្សនិងមនុស្ស*។

ដើម្បីរស់ មនុស្សត្រូវមានអាហារ ត្រូវស្លៀកពាក់ ត្រូវមានទីជម្រក។ តម្រូវការចាំបាច់ដំបូងបំផុតរបស់មនុស្ស គឺអាហារ សម្លៀកបំពាក់ និងជម្រក។ បន្ទាប់មកទៀត ក្នុងការរស់នៅ មនុស្សតែងមានលេចចេញនូវសេចក្តីត្រូវការផ្សេងៗទៀត ដែលមានលក្ខណៈស្មុគស្មាញទាក់ទងទៅនឹងការរីកចម្រើននៃវិយរបស់ខ្លួននិងស្ថានភាពផលិតកម្មសង្គម។ មិនតែប៉ុណ្ណោះ ដោយសារមនុស្សរស់នៅក្នុងសង្គម មនុស្សត្រូវការការអប់រំ(ផ្តល់ចំណេះដឹង) វប្បធម៌ប្រពៃណី វិទ្យាសាស្រ្ត បច្ចេកទេស បទពិសោធន៍ និងច្បាប់សង្គម ... ។



ដើម្បីបំពេញសេចក្តីត្រូវការខាងលើ មនុស្សត្រូវតែមានការភ្ញាក់រលឹក ហើយខិតខំធ្វើការស្រាវជ្រាវឬរកគ្រប់មធ្យោបាយ ដើម្បីប្រកបមុខរបរផ្សេងៗសម្រាប់ចិញ្ចឹមជីវិត មានដូចជា ប្រមាញ់ នេសាទ សិប្បកម្ម កសិកម្ម ផលិតកម្មទ្រព្យសម្ភារៈ សេវាកម្មផ្សេងៗជាដើម។ នេះបញ្ជាក់ឱ្យឃើញថា *មនុស្សរស់នៅយ៉ាងជិតស្និទ្ធជាមួយនឹងធម្មជាតិ* ហើយយកធម្មជាតិនៅជុំវិញខ្លួនមកបំពេញសេចក្តីត្រូវការរបស់ខ្លួន។ *ឧទាហរណ៍* មនុស្សចេះកាប់ឈើធ្វើផ្ទះ មនុស្សចេះដាំដើមឈើ ចេះចាប់ត្រី ប្រមាញ់សត្វធ្វើម្ហូប មនុស្សប្រើប្រាស់ឧបករណ៍ទំនើបៗ ដើម្បីបំពេញតម្រូវការរបស់ខ្លួនក្នុងការរស់នៅនិងកែច្នៃធម្មជាតិបន្តទៀត។

youtube.com/moeys facebook.com/moeys moeys.gov.kh

សកម្មភាពការងារទាំងនេះរបស់មនុស្សគឺជា *បាតុភូតនៃដំណើរវិវឌ្ឍន៍សេដ្ឋកិច្ច* ។

ដំណើរសេដ្ឋកិច្ចបានវិវឌ្ឍទៅរកការរីកចម្រើនកាន់តែប្រសើរឡើង ធ្វើឱ្យមនុស្សកាន់តែមានជីវភាពសមរម្យនិងមានឧបករណ៍សម្ភារៈប្រើប្រាស់គ្រប់បែបយ៉ាងតាំងពីសម្ភារៈតូចតាចរហូតដល់ម៉ាស៊ីនដែលអាចជួយសម្រួលការងាររបស់មនុស្សបាន(ការងារខ្លះមនុស្សមិនអាចធ្វើបាន ម៉ាស៊ីនអាចធ្វើបានប្រកបដោយប្រសិទ្ធភាពនិងល្អឥតខ្ចោះ) ។

គ្រប់ទំនិញទាំងអស់ដូចជា សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ក្នុងគេហដ្ឋាន រថយន្ត កុំព្យូទ័រ ម៉ាស៊ីនថត ...ជា**កម្មវត្ថុនៃសេដ្ឋកិច្ច** ព្រោះវាត្រូវបានគេទិញនិងលក់ ។

## 2. សញ្ញាណទូទៅនៃសេដ្ឋកិច្ច

សេដ្ឋកិច្ចត្រូវបានបង្កើតឡើងដូចវិទ្យាសាស្ត្រសង្គមរយៈពេលជាង 200 ឆ្នាំមកហើយនៅប្រទេសជឿនលឿន ។ សេដ្ឋកិច្ចគ្របដណ្តប់លើប្រធានបទគ្រប់ប្រភេទ ប៉ុន្តែប្រធានបទសំខាន់ដែលត្រូវបកស្រាយគឺ តើសង្គមមួយបានប្រើប្រាស់ប្រភពធនធានដ៏កម្ររបស់ខ្លួនតាមរបៀបណា ? ហើយសេដ្ឋកិច្ចក៏ព្យាយាមដោះស្រាយចម្ងល់និងបញ្ហាស្មុគស្មាញក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ។

ជាទូទៅ សេដ្ឋកិច្ចមាននាទីសិក្សាបញ្ហាផលិតកម្មនិងសេវាកម្ម ចរាចរណ៍ទំនិញ ថ្លៃទំនិញ ថ្លៃពលកម្ម អតិផរណា ភាពគ្មានការងារធ្វើ ភាពខុសគ្នារវាងសេដ្ឋកិច្ចសង្គមនិយមនិងសេដ្ឋកិច្ចទីផ្សារនិងការបង្កើតឱ្យមានឱកាសការងារ ។

ក្នុងឆ្នាំ 1776 សេដ្ឋវិទូ អាដាមស្ម៊ីត (Adam Smith) ( 1723-1790 ) ជាតិអង់គ្លេស បានសរសេរនិងបោះពុម្ពផ្សាយសៀវភៅលើកដំបូងរបស់គាត់ដែលមានឈ្មោះថា "**ការសិក្សាស្រាវជ្រាវស្តីពីធម្មជាតិនិងមូលហេតុកើតមានធនធានរបស់ប្រជាពលរដ្ឋ**" ហើយនៅឆ្នាំដដែលនោះលោកបានរៀបរៀងសៀវភៅមួយទៀត តែមិនអាចបោះពុម្ពផ្សាយបានគឺសៀវភៅឈ្មោះ"**សេចក្តីប្រកាសឯករាជ្យ**" ។ នៅពេលដែលសៀវភៅទាំងពីរមិនទាន់បានបោះពុម្ព មានការផ្ទុះឡើងចលនាទាមទារសេរីភាពខាងផ្នែកនយោបាយ ពីការជិះជាន់សង្កត់សង្កិនរបស់សក្តិភូមិអឺរ៉ុប ។ ស្របពេលនោះក៏មានចលនាទាមទារឱ្យមានស្ថិរភាពលើថ្លៃទំនិញនិងប្រាក់បៀវត្ស ការចូលរួមវិភាគទានទៅលើទីផ្សារដែលបានរៀបចំចាត់ចែងជីវភាពសេដ្ឋកិច្ចនិងបានបង្កើតឡើងនូវខឿនអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ។ លោកបានបង្ហាញថា ប្រព័ន្ធនៃថ្លៃនិងទីផ្សារអាចសម្រួលដល់អ្នកប្រើប្រាស់និងអ្នកផ្គត់ផ្គង់ ដោយមិនចាំបាច់មានការគ្រប់គ្រងដោយផ្នែកកណ្តាលណាមួយទេ ។ ជិតមួយសតវត្សក្រោយមក បណ្តាសហគ្រាសមូលធននិយមជាច្រើនមានសកម្មភាពរស់រវើកនៅក្នុងវិស័យនានា ដូចជាវិស័យផ្លូវដែក តម្បាញ និងវិស័យដទៃទៀត និងបានពង្រីកនូវឥទ្ធិពលរបស់ខ្លួនទៅក្នុងតំបន់សេដ្ឋកិច្ចនានានៅក្នុងពិភពលោក ។

ក្រោយមក លោក**កាល់ម៉ាក្ស** (ជាទស្សនវិទូ ប្រវត្តិវិទូ សេដ្ឋវិទូ និងទ្រឹស្តីវិទូសង្គមនិយម អាល្លឺម៉ង់ កើតនៅទីក្រុងត្រែវ ឆ្នាំ 1818 ស្លាប់នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ឆ្នាំ 1883)និងលោក ម៉ាក្ស លេនីន (ហៅ វ្លាដេមៀ អេលិច អ៊ូល្យ៉ាណូ ជាទស្សនវិទូជាតិរុស្ស៊ី កើតនៅស៊ីមប៊ីស ឆ្នាំ 1870 ស្លាប់នៅហ្គកគី ឆ្នាំ 1924) បានផ្សព្វផ្សាយឯកសារទ្រឹស្តីវិវេចនាដែលរិះគន់យ៉ាងខ្លាំងក្លាទៅលើលទ្ធិមូលធនក្នុងឆ្នាំ 1867 1885 និង 1894 បានប្រកាសថា លទ្ធិមូលធននិយមនឹងត្រូវវិនាស ហើយក្នុងពេលដ៏ឆាប់ខាងមុខ លទ្ធិនេះនឹងត្រូវដើរតាមគន្លងនៃវិបត្តិសេដ្ឋកិច្ច ។ ការផ្ទុះឡើងនូវចលនាបដិវត្ត និងការទាមទារ គឺដើម្បីឆ្ពោះទៅកាន់លទ្ធិសង្គមនិយម ។ នៅប៉ុន្មានទសវត្សរ៍ក្រោយមកព្រឹត្តិការណ៍ទាំងឡាយបានកើតមានឡើងហាក់ដូចជាត្រូវតាមការព្យាករណ៍របស់លោកកាល់ម៉ាក្ស ។ នៅទសវត្សរ៍ឆ្នាំ 1980 ជិត 1 ភាគ 3 នៃបណ្តាប្រទេសនៅក្នុងពិភពលោក បានដើរតាមលទ្ធិម៉ាក្សនិយម ។ ប៉ុន្តែក្នុងការដើរតាមលទ្ធិម៉ាក់និយម លោក **ចន មេណាតកេន** (John Maynard Keynes) ជាសេដ្ឋវិទូជាតិអង់គ្លេស បានមើលឃើញថា គោលនយោបាយសារពើពន្ធនិងរូបិយវត្ថុរបស់រដ្ឋាភិបាល បានរាតត្បាតយ៉ាងធ្ងន់ធ្ងរនៅក្នុងដំណើរការសេដ្ឋកិច្ច ។ ដើម្បីដោះស្រាយបញ្ហានេះ នៅឆ្នាំ 1936 លោកបានបោះពុម្ពផ្សព្វផ្សាយទ្រឹស្តីថ្មីមួយឈ្មោះថា "**ទ្រឹស្តីរួមស្តីពីអនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ**" ។

នៅក្នុងទសវត្សរ៍នៃឆ្នាំ 1980 បណ្តាប្រទេសអ្នកដើរតាមលទ្ធិមូលធននិយមនៅលោកខាងលិច និងបណ្តាប្រទេសនៃអ្នកដើរតាមលទ្ធិសង្គមនិយមនៅលោកខាងកើតបានរកឃើញជាថ្មីនូវអានុភាពរបស់ទីផ្សារ ដែលបង្កើតឡើងនូវការផ្លាស់ប្តូរយ៉ាងឆាប់រហ័សលើបច្ចេកវិទ្យានិងរបៀបរបបរស់នៅឆ្ពោះទៅរកវឌ្ឍនភាពឬសុភមង្គល ។

## 3. និយមន័យសេដ្ឋកិច្ច

ការកំណត់និយមន័យសេដ្ឋកិច្ចមានលក្ខណៈផ្សេងៗគ្នា ដោយផ្អែកលើដំណើរប្រព្រឹត្តទៅរបស់សង្គម ដែលមាននៅក្នុងសម័យកាលនីមួយៗនិងតាមការពិសោធជាក់ស្តែងរបស់សេដ្ឋវិទូម្នាក់ៗក៏ដូចជាការផ្តល់និយមន័យដោយលោក **អាដាមស្មីត** ដូចខាងក្រោម

- សេដ្ឋកិច្ចគឺជាការសាកសួរថា តើទំនិញអ្វីដែលគេត្រូវផលិត ? ហើយផលិតឡើងយ៉ាងដូចម្តេច ? និងផលិតឡើងសម្រាប់នរណា ?
- សេដ្ឋកិច្ច គឺជាការវិភាគនូវរាល់សកម្មភាពរបស់មនុស្សដែលមាននៅក្នុងសង្គមទាំងមូលរួមមាន និន្នាការថ្លៃ និន្នាការនៃការបាត់អាជីព ពាណិជ្ជកម្មក្រៅប្រទេសជាដើម ។ នៅក្នុងពេលនោះ

ដែរ មាននិន្នាការជាច្រើនបានពន្យល់ថា សេដ្ឋកិច្ចបានជួយលើកបញ្ហានានាពាក់ព័ន្ធនឹងច្បាប់ក្នុងបំណងឱ្យរដ្ឋាភិបាលកែលម្អការរៀបចំសកម្មភាពសេដ្ឋកិច្ច ។

- សេដ្ឋកិច្ច គឺជាការសិក្សាពីពាណិជ្ជកម្មដែលជាបញ្ហារបស់ជាតិនានា ។ វាក៏ជួយពន្យល់ថា ហេតុអ្វីបណ្ដាជាតិនានានាំចេញនូវមុខទំនិញខ្លះ ហើយក៏នាំចូលនូវមុខទំនិញដទៃទៀតមកវិញ ។ សេដ្ឋកិច្ចក៏បានជួយធ្វើការសិក្សាវិភាគនូវឥទ្ធិពលនៃការដាក់បម្រាមហាមប្រាមនូវការធ្វើសេដ្ឋកិច្ចដោយអន្លើ ។
- សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រនៃជម្រើស ដោយត្រូវសិក្សាថា តើគេត្រូវជ្រើសរើសការប្រើប្រាស់ប្រភពផលិតកម្ម ប្រភពពលកម្ម ប្រភពសម្ភារៈ ប្រភពចំណេះដឹង និងបច្ចេកវិទ្យា ដែលក្រខ្សត់ក្នុងកម្រិតណាដើម្បីធ្វើការផលិត ហើយបែងចែកយ៉ាងដូចម្ដេច ។
- សេដ្ឋកិច្ច គឺជាការសិក្សារូបិយវត្ថុនានា មូលធន និងទ្រព្យសម្បត្តិ ។

និយមន័យខាងលើទាំងអស់នេះ សុទ្ធសឹងមានអត្ថន័យគ្រប់គ្រាន់ ព្រោះរាល់ការពន្យល់នេះបានឆ្លងកាត់ពេលវេលាកន្លងមករហូតដល់បច្ចុប្បន្ន ។ ប៉ុន្តែបើគេធ្វើការវិភាគនិយមន័យទាំងអស់ឱ្យបានល្អិតល្អន់ គេអាចទាញយកនិយមន័យរួមមួយគឺ

**សេដ្ឋកិច្ច គឺជាការសិក្សាអំពីរបៀបដែលបុគ្គល ក្រុមគ្រួសារ សង្គម ចេះលៃលកប្រើប្រាស់នូវធនធានដែលមាននៅក្នុងការផលិតចេញជាផលិតផលនិងបង្កើតសេវាកម្មផ្សេងៗ ដើម្បីបំពេញនូវសេចក្ដីត្រូវការឥតព្រំដែនរបស់មនុស្ស ។**

## 4. ប្រភេទសេដ្ឋកិច្ច

### 4.1. សេដ្ឋកិច្ចទីផ្សារសេរី

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី កម្មសិទ្ធិលើធនធានសេដ្ឋកិច្ច ឬកត្តាផលិតកម្មមួយភាគធំស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជានិតិបុគ្គលឬរូបវន្តបុគ្គល ។ ឯការគ្រប់គ្រងនិងការសម្របសម្រួល ដែលផ្អែកទាំងស្រុងលើយន្តការសេដ្ឋកិច្ចទីផ្សារតាមទ្រឹស្ដីក្លាស៊ិក (តន្តីនិយម) ហៅថា “សេដ្ឋកិច្ចដែលធ្វើនិយ័តកម្មដោយខ្លួនឯង” ។ ក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបនេះ សេចក្ដីសម្រេចចិត្តក្នុងការបែងចែកធនធាន ជាសេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ ។

ជាការពិត សេរីភាពនេះអាស្រ័យទៅនឹងសេចក្ដីត្រូវការនិងការផ្គត់ផ្គង់របស់សង្គមសេដ្ឋកិច្ច ។ មុននឹងផលិតរបស់អ្វីមួយ ភ្នាក់ងារសេដ្ឋកិច្ចដែលជាផលិតករត្រូវសិក្សាអំពីសេចក្ដីត្រូវការរបស់អតិថិជន ឬអ្នកប្រើប្រាស់ ។ ករណីនេះ សកម្មភាពផលិតកម្ម ការផ្លាស់ប្ដូរ ការប្រើប្រាស់ទំនិញ និងសេវាកម្ម ជាទូទៅត្រូវមានសេរីភាពបរិបូរនិងគ្មានការធ្វើអន្តរាគមន៍ពីរដ្ឋឡើយ ។ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារសេរី ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗគ្រប់គ្រងអត្ថប្រយោជន៍ផ្ទាល់ខ្លួនដោយខ្លួនឯងនិងប្រឹងប្រែងធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ខ្លួនកាន់តែល្អប្រសើរឡើងតាមរយៈការប្រកួតប្រជែង ។

ក្នុងស្នាដៃដ៏ល្បីល្បាញឈ្មោះ "ការសិក្សាស្រាវជ្រាវស្ដីពីធម្មជាតិនិងមូលហេតុកើតមានប្រភពផ្ទាំធនធានរបស់ប្រជាពលរដ្ឋ"ដែលបាននិពន្ធក្នុង 1776 ដោយលោក **អាដាមស្ម៊ីត** (Adam Smith) សេដ្ឋវិទូក្លាស៊ិកបានអះអាងថា"ក្នុងជីវភាពសេដ្ឋកិច្ចសកម្មភាពរបស់បុគ្គលម្នាក់ៗប្រព្រឹត្តទៅតាមអត្ថប្រយោជន៍ផ្ទាល់ខ្លួន" ដែលពិនិត្យមើលទៅហាក់ដូចជា "ដៃអរូប" សម្រាប់ចូលរួមបង្កើតអត្ថប្រយោជន៍សង្គមទាំងមូល ។ ដូចនេះ "ដៃអរូប" ជាសកម្មភាពសេដ្ឋកិច្ច ដែលនាំឱ្យការបែងចែកធនធានសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ។ ប្រការនេះ រដ្ឋមិនចាំបាច់ធ្វើអន្តរាគមន៍ទេ ។

លោក **អាដាមស្ម៊ីត** បានអះអាងទៀតថា ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបទីផ្សារសេរីមានលក្ខណៈអំណោយផលល្អ ពីព្រោះ

- ការប្រើប្រាស់ធនធានសេដ្ឋកិច្ចប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពខ្ពស់ ។
- ផលិតកម្មមានកំណើននិងអាចដោះស្រាយបញ្ហានិកម្មភាពបាន ។
- សេដ្ឋកិច្ចមានស្ថិរភាព (មានកំណើនរហ័ស) ។

ដូចនេះហើយអ្នកនិយមសេដ្ឋវិទូក្លាស៊ិកនៅតែមានជំនឿថា ក្នុងសកម្មភាពសេដ្ឋកិច្ច រដ្ឋពុំចាំបាច់លូកដៃធ្វើអន្តរាគមន៍ទេ ។

## 4.2. សេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចផែនការ

ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា រដ្ឋមានកម្មសិទ្ធិលើធនធាននិងកត្តាផលិតកម្មស្ទើរតែទាំងអស់ ឯយន្តការគ្រប់គ្រងនិងសម្របសម្រួលផ្អែកលើមូលដ្ឋានផែនការរបស់រដ្ឋ មានន័យថា ដំណើរការផលិតកម្មស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋស្ទើរតែទាំងស្រុង ។ ដំណោះស្រាយបញ្ហាធំៗទាក់ទងទៅនឹងផលិតកម្ម ការប្រើប្រាស់ ការបែងចែកធនធានផ្សេងៗត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ ។

និយាយរួម ផែនការផលិតកម្មរបស់សហគ្រាសនីមួយៗចាត់ចែងនិងត្រួតពិនិត្យដោយរដ្ឋដែលមានក្រុមប្រឹក្សាផែនការជាតំណាង ហើយជាទូទៅផែនការទាំងនោះជាអ្នកកំណត់ចំពោះសហគ្រាស

facebook.com/moeys.gov.kh khmer.moeys.gov.kh youtube.com/moeys

នីមួយៗអំពីបរិមាណធនធាន បរិមាណផលិតផល និងមានការគិតគូរជាមុនថា តើផលិតអ្វី ? ផលិតយ៉ាងដូចម្ដេច ? ផលិតសម្រាប់អ្នកណា ? ចំនួនប៉ុន្មាន ? ក្នុងតម្លៃណា ?

ដូចនេះ សហគ្រាសនីមួយៗត្រូវមានសមាមាត្ររវាងបរិមាណផលិតកម្មទំនិញវិនិយោគនិងទំនិញប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ ដែលត្រូវបានគ្រប់គ្រងនិងកំណត់ដោយផែនការរដ្ឋ ។

ទន្ទឹមនឹងនេះ គួរកត់សម្គាល់ថា ប្រព័ន្ធសេដ្ឋកិច្ចបញ្ជាឬក៏សេដ្ឋកិច្ចទីផ្សារសេរីសុទ្ធសាធពុំមានអត្ថិភាពប្រាកដឡើយ ។ ការបកស្រាយខាងលើ មានអត្ថប្រយោជន៍សម្រាប់ការយល់ដឹងជារួមតែប៉ុណ្ណោះ ។ បណ្ដាបទពិសោធក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកន្លងមកបានបង្ហាញឱ្យឃើញថា ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចទាំងអស់ក្នុងពិភពលោកនេះមានលក្ខណៈជាប្រព័ន្ធសេដ្ឋកិច្ចចម្រុះមួយ គឺប្រព័ន្ធសេដ្ឋកិច្ចចម្រុះបែបផែនការឬប្រព័ន្ធសេដ្ឋកិច្ចចម្រុះបែបទីផ្សារ ។

## 4.3. សេដ្ឋកិច្ចចម្រុះ

ក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចចម្រុះ យន្តការរដ្ឋ និងយន្តការទីផ្សារ មានតួនាទីសំខាន់ដូចគ្នាក្នុងការដោះស្រាយបញ្ហា តើត្រូវផលិតអ្វី ? ផលិតយ៉ាងដូចម្ដេច ? សម្រាប់អ្នកណា ? ។ ក្នុងការអនុវត្តកន្លងមក ប្រព័ន្ធសេដ្ឋកិច្ចចម្រុះច្រើនស្ថិតនៅចន្លោះរវាងសេដ្ឋកិច្ចចម្រុះបែបទីផ្សារសេរីនិងសេដ្ឋកិច្ចចម្រុះបែបសេដ្ឋកិច្ចបញ្ជា ។ *ឧទាហរណ៍* សេដ្ឋកិច្ចសហរដ្ឋអាមេរិកជាសេដ្ឋកិច្ចចម្រុះបែបទីផ្សារ ពីព្រោះ មុខសញ្ញាសេដ្ឋកិច្ចជាច្រើនដើរតួដោយផ្នែកឯកជន ហើយសកម្មភាពមួយចំនួនទៀតដើរតួដោយរដ្ឋខ្លួនឯង តាមរយៈការអនុវត្តបញ្ញត្តិផ្សេងៗ មានការកំណត់ពន្ធ ការយកពន្ធ និងការឧបត្ថម្ភធនធានជាដើម ។ ជាងនេះទៀត រដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃសម្រាប់សម្របសម្រួលដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីរក្សាស្ថិរភាពការផ្គត់ផ្គង់និងជំរុញកំណើនសេដ្ឋកិច្ច ជាពិសេស ការផ្គត់ផ្គង់ទំនិញនិងសេវាណាដែលអវត្តមាននៅទីផ្សារឬពុំមានគ្រប់គ្រាន់ជាដើម ។ តាមរយៈតួនាទីនេះ ការធ្វើអន្តរាគមន៍របស់រដ្ឋអាចកែសម្រួលនិងបំពេញចន្លោះនូវកង្វះខាតរបស់យន្តការទីផ្សារ និងដើម្បីផ្ទេរសកម្មភាពទាំងនេះ ឱ្យក្លាយទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល ។

ផ្ទុយពីសេដ្ឋកិច្ចសហរដ្ឋអាមេរិក សេដ្ឋកិច្ចអតីតសហភាពសូវៀត និងបណ្ដាប្រទេសនៅអឺរ៉ុបខាងកើតមានលក្ខណៈជាសេដ្ឋកិច្ចចម្រុះដែរ ប៉ុន្តែជាសេដ្ឋកិច្ចចម្រុះបែបផែនការ ។ ក្នុងករណីនេះ ពិតមែនតែអ្វីៗស្ថិតនៅក្នុងកណ្ដាប់ដៃរបស់រដ្ឋ (ទាំងកម្មសិទ្ធិធនធានសេដ្ឋកិច្ច ទាំងការរៀបចំផែនការអនុវត្ត និងការត្រួតពិនិត្យ) តែក្នុងការអនុវត្តជាក់ស្ដែង សេដ្ឋកិច្ចចម្រុះបែបផែនការនេះ ចៀសមិនផុតពីការប្រើប្រាស់យន្តការទីផ្សារនោះទេ ។ ជាពិសេស ក្នុងសេដ្ឋកិច្ចចម្រុះបែបផែនការនេះ នៅតែ

មានសេសសល់កម្មសិទ្ធិឯកជនលើធនធានសេដ្ឋកិច្ចមួយចំនួន ។ បច្ចុប្បន្ននេះ មានតែប្រទេសកូរ៉េខាងជើងនិងប្រទេសគុយបាទេ ដែលអាចចាត់ទុកថាជាប្រទេសដែលមានសេដ្ឋកិច្ចចម្រុះបែបផែនការ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេអាចកត់សម្គាល់បានថា នៅអឺរ៉ុបខាងលិច រដ្ឋមានតួនាទីបញ្ជាក្នុងសកម្មភាពសេដ្ឋកិច្ចធំជាងនៅសហរដ្ឋអាមេរិក ។ *ឧទាហរណ៍* នៅប្រទេសបារាំង រដ្ឋាភិបាលមានតួនាទីយ៉ាងធំក្នុងសកម្មភាពសេដ្ឋកិច្ច រួមមានការផលិតរថយន្ត អគ្គិសនី និងយន្តហោះជាដើម ។ ម្យ៉ាងទៀត ទោះបីជាក្នុងទសវត្សរ៍ឆ្នាំ 80 មាននិន្នាការធ្វើឯកជនូបនីយកម្មសហគ្រាសរដ្ឋក៏ដោយក៏តួនាទីសេដ្ឋកិច្ចរបស់រដ្ឋនៅបណ្ដាប្រទេសក្នុងអឺរ៉ុបជាទូទៅនៅតែមានទំហំធំជាងតួនាទីរបស់រដ្ឋនៅសហរដ្ឋអាមេរិកដែរ ។

គួរកត់សម្គាល់ថា រវាងកម្មសិទ្ធិឯកជនលើធនធានសេដ្ឋកិច្ចនិងការគ្រប់គ្រងឈរលើមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ រវាងកម្មសិទ្ធិសង្គមលើធនធានសេដ្ឋកិច្ចនិងការគ្រប់គ្រងឈរលើសេដ្ឋកិច្ចផែនការជានិច្ចកាលមិនមានភាពស្របគ្នាទេ ។ *ឧទាហរណ៍* សេដ្ឋកិច្ចក្នុងប្រទេសហុងគ្រីនិងប្រទេសយូហ្គោស្លាវីពិតមែនតែមានកម្មសិទ្ធិសង្គមលើធនធាននិងកត្តាផលិតកម្ម ប៉ុន្តែរបៀបគ្រប់គ្រងមាននិន្នាការខិតទៅរកយន្តការសេដ្ឋកិច្ចទីផ្សារ ។ ផ្ទុយពីនេះ សេដ្ឋកិច្ចប្រទេសអាល្លឺម៉ង់ សម័យហ្វាស៊ីសនិយមមានកម្មសិទ្ធិឯកជនលើធនធានសេដ្ឋកិច្ច ប៉ុន្តែការគ្រប់គ្រងមានលក្ខណៈបញ្ជានិងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ។ ក្នុងប្រទេសស៊ុយអែត ប្រហែល 90 ភាគរយនៃសកម្មភាពសេដ្ឋកិច្ចស្ថិតក្នុងកណ្ដាប់ដៃឯកជន ប៉ុន្តែរដ្ឋលូកដៃធ្វើអន្តរាគមន៍ក្នុងការទំនុកបម្រុងស្ថិរភាពសេដ្ឋកិច្ចនិងយកចិត្តទុកដាក់ក្នុងការបែងចែកចំណូលក្នុងគោលបំណងពង្រីកសមធម៌ក្នុងសង្គម ។ សេដ្ឋកិច្ចប្រទេសជប៉ុនជាក់ស្ដែងមានលក្ខណៈជាសេដ្ឋកិច្ចផែនការមានការរីកចម្រើន ក៏ប៉ុន្តែទាំងរដ្ឋ ទាំងឯកជនធ្វើការសម្របសម្រួលជាមួយគ្នាយ៉ាងសកម្មដោយឈរលើមូលដ្ឋានទទួលអត្ថប្រយោជន៍ទាំងសងខាង ។

## 5. និយមន័យវិទ្យាសាស្ត្រសេដ្ឋកិច្ច

ធនធានដែលមានក្នុងប្រទេសមួយឬក្នុងពិភពលោកទាំងមូល មិនមានតុល្យភាពទៅនឹងសេចក្ដីត្រូវការ ដែលចេះតែកើនឡើងរបស់មនុស្សទេ ជាពិសេសក្នុងករណីមនុស្សមានកំណើនយ៉ាងឆាប់រហ័សនិងចេះតែកើនជារៀងរាល់ថ្ងៃថែមទៀតផង ។

វិទ្យាសាស្ត្រសេដ្ឋកិច្ច មាននាទីស្រាវជ្រាវរកប្រសិទ្ធភាពក្នុងការប្រើប្រាស់កត្តាផលិតកម្មដែលមាន ដើម្បីផលិតទំនិញសម្រាប់បំពេញសេចក្ដីត្រូវការរបស់មនុស្ស ។



ក្នុងការឱ្យនិយមន័យ "វិទ្យាសាស្ត្រសេដ្ឋកិច្ច" ដោយមានការគិតប្រហាក់ប្រហែលគ្នាដូចខាងក្រោម

- លោក**ហ្សង់ បាបទីសេ** (Jean Beptiste Say 1767-1832) សេដ្ឋវិទូជាតិអង់គ្លេស បានសរសេរថា "កម្មវត្ថុសិក្សានៃវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺការធ្វើឱ្យដឹងថា តើធនធានធម្មជាតិ កកើតឡើងដូចម្តេច ហើយត្រូវប្រើប្រាស់យ៉ាងដូចម្តេច ដើម្បីបំពេញសេចក្តីត្រូវការរបស់សង្គមជាតិ"។
- លោក**កាល់ ម៉ាក្ស** បានសរសេរថា "វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រសិក្សាអំពីក្រឹត្យក្រមមុខងារនិងការអភិវឌ្ឍទំនាក់ទំនងរវាងមនុស្សនិងមនុស្ស តាមរយៈផលិតកម្ម ការបែងចែក ការផ្លាស់ប្តូរ និងការប្រើប្រាស់ធនធានទាំងនេះ ក្នុងដំណាក់កាលនៃការអភិវឌ្ឍសង្គម"។
- លោក**អាល់ហ្វ្រេដ ម៉ាសាល់** (Alfred Marchal 1842-1924) សេដ្ឋវិទូជាតិអង់គ្លេស បានសរសេរថា "វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រសិក្សាអំពីសកម្មភាព ជីវភាពធម្មតារបស់មនុស្ស"។ ក្នុងន័យនេះ លោកចង់បញ្ជាក់ថា ក្នុងសេដ្ឋកិច្ច បញ្ហាជ្រើសរើសក្នុងការប្រើប្រាស់ភោគទ្រព្យធម្មជាតិ ដើម្បីបំពេញសេចក្តីត្រូវការរបស់សង្គមមនុស្ស គឺជារឿងធម្មតាដែលមនុស្សតែងជួបជាប្រចាំក្នុងជីវភាពរស់នៅរបស់គេ។
- លោក**ប៉ូល សាម៉ូអែលសុន** (Paul Samoelson កើតឆ្នាំ 1915) សេដ្ឋវិទូជាតិអាមេរិកកាំង បានសរសេរថា "កម្មវត្ថុសិក្សារបស់វិទ្យាសាស្ត្រសេដ្ឋកិច្ច គឺការប្រើប្រាស់ធនធានភោគទ្រព្យដែល

មានកំណត់សម្រាប់ផលិតទំនិញនិងសេវា ហើយបែងចែកទំនិញនិងសេវាទាំងនោះ ទៅតាមវណ្ណៈនិងក្រុមមនុស្សផ្សេងគ្នា" ។

តាមបណ្តានិយមន័យខាងលើ យើងអាចសន្និដ្ឋានបានថា "វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រសិក្សាស្រាវជ្រាវរកវិធីដោះស្រាយបញ្ហាប្រើប្រាស់ធនធានសេដ្ឋកិច្ចដែលយើងមានដោយកម្រនិងគ្រប់គ្រងខ្សែចង្វាក់ផលិតកម្មទាំងអស់ឱ្យចំទីកន្លែង ត្រូវពេលវេលា និងប្រកបដោយប្រសិទ្ធភាពដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការរបស់សង្គមមនុស្ស" ។

## 6. ការអភិវឌ្ឍសង្គមនិងផលប៉ះពាល់ចំពោះបរិស្ថានធម្មជាតិនិងសង្គម

ការអភិវឌ្ឍសង្គម មានន័យថាធ្វើឱ្យសង្គមទទួលបាននូវការផ្គត់ផ្គង់ទាំងផ្នែកសម្ភារៈនិងទាំងផ្នែកស្មារតី ទៅតាមសេចក្តីត្រូវការ ។ ការផ្គត់ផ្គង់ផ្នែកសម្ភារៈមានដូចជា ជំនួយផ្នែកសម្ភារៈ ចំណីអាហារ សម្លៀកបំពាក់ ទីជម្រកជាដើម ។ ឯការផ្គត់ផ្គង់ផ្នែកស្មារតី មានជំនួយផ្នែកស្មារតី មានដូចជាបណ្ណាល័យ សារមន្ទីរ ទីកន្លែងកំសាន្ត ទីមហោស្រពជាដើម ។ សរុបរួម ការផ្គត់ផ្គង់ធនធានសម្ភារៈនិងធនធានស្មារតី គឺដើម្បីបម្រើសុខុមាលភាពក្នុងការរស់នៅរបស់មនុស្ស ។ ឯសេចក្តីត្រូវការរបស់មនុស្ស ក៏ចេះតែទាមទារឱ្យការផ្គត់ផ្គង់មានការរីកចម្រើនជាប្រចាំទាំងបរិមាណនិងគុណភាព ។

### 6.1. ផលប៉ះពាល់ចំពោះបរិស្ថានធម្មជាតិ

បរិស្ថានធម្មជាតិ សំដៅលើសម្បត្តិឬធនធានធម្មជាតិមានដូចជា ថាមពលព្រះអាទិត្យ ថាមពលជំនោរសមុទ្រ ថាមពលចរន្តទឹក ថាមពលចំហាយទឹក ធនធានទឹក ដី ព្រៃឈើ ធនធានសត្វ និងធនធានរ៉ែ (ក្នុងនោះមានធនធានប្រេងឥន្ធនៈ) ។ ធនធានធម្មជាតិជាមធ្យោបាយផលិតកម្មសកលនិងជាលក្ខខណ្ឌចាំបាច់នៃសកម្មភាពផលិតរបស់សង្គម ។ ប៉ុន្តែធនធានធម្មជាតិមានពីរប្រភេទ គឺធនធានដែលអាចបង្កើតឡើងវិញបាននិងធនធានមិនអាចបង្កើតមកវិញបានបន្ទាប់ពីបានទាញយកទៅប្រើប្រាស់ ។

ក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច បញ្ហាការពារនិងគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របមានសារៈសំខាន់ណាស់ ។ ការខ្ជះខ្ជាយនិងការប្រើប្រាស់ដោយគ្មានសនិទានភាពនូវប្រភេទធនធានធម្មជាតិដែលមិនអាចបង្កើតមកវិញបាន តែងកាត់ផ្តាច់និរន្តភាពនៃការអភិវឌ្ឍនិងនាំមកនូវភាពក្រីក្រនិងបដិវាទកម្មនៅក្នុងសេដ្ឋកិច្ចប្រទេសជាតិ ។

## 6.2. ផលប៉ះពាល់ចំពោះបរិស្ថានសង្គម

ក្នុងការបម្រើសេចក្ដីត្រូវការផ្នែកស្មារតី ការបង្ហូរចូលនូវទំនិញប្រណីត វប្បធម៌ឆេតឆាយ និងរបៀបរបបរស់នៅថ្មីមកពីខាងក្រៅ បានកាត់បន្ថយមួយផ្នែកធំនៃការសន្សំរបស់ជាតិសម្រាប់ការអភិវឌ្ឍ ។ ក្នុងកាលៈទេសៈដែលប្រទេសកំពុងត្រូវការទំនិញវិនិយោគសម្រាប់ពង្រឹងនិងពង្រីកវិស័យផលិតកម្ម ចំណាយមួយផ្នែកធំត្រូវបានផ្ទេរយកមកប្រើប្រាស់លើសេវាបម្រើការកំសាន្ត មានដូចជា រង្គសាល ក្លឹបរាត្រី ការផឹកស៊ី រាំរែក ល្បែងស៊ីសង ពេស្យាចារជាដើមនិងលើទំនិញប្រណីតផ្សេងៗ ដូចជា រថយន្តទំនើបៗ គ្រឿងអលង្ការ ទូរទស្សន៍ពណ៌ វីដេអូ ... ដែលអ្នកសេដ្ឋកិច្ចហៅថា ការផ្គត់ផ្គង់មិនចាំបាច់ ។

ការបំពេញសេចក្ដីត្រូវការខាងផ្នែកស្មារតី គឺជាកត្តាសំខាន់សម្រាប់លើកទឹកចិត្តនិងជំរុញដំណើរការផលិតកម្ម ។ ប៉ុន្តែនៅក្នុងលក្ខខណ្ឌដំបូងនៃប្រទេសកំពុងអភិវឌ្ឍ ដែលមួយផ្នែកធំនៃសេដ្ឋកិច្ចជាតិពឹងផ្អែកលើជំនួយនិងការវិនិយោគទុនពីក្រៅប្រទេស សេចក្ដីត្រូវការខាងផ្នែកទំនិញប្រណីត ចំណង់ក្នុងការរស់នៅបែបហ៊ឺហា ការចាយវាយខ្ជះខ្ជាយ មិនទាន់ជាកត្តាធានានូវការកើនឡើងនៃផលិតកម្មនោះឡើយ ។ ម្យ៉ាងទៀត សេចក្ដីត្រូវការក្នុងការបង្កើតមូលដ្ឋានផលិតទំនិញប្រណីតក៏មិនទាន់អាចកើតមាននៅឡើយ ។

ដូចនេះគេអាចពោលបានថា ការប្រើប្រាស់ធនធានដោយគ្មានប្រសិទ្ធភាពនិងគ្មានប្រសិទ្ធផលគឺជាកំហុសដ៏ធំនៅពេលដែលប្រទេសជាតិកំពុងខ្វះខាតធនធានសេដ្ឋកិច្ច ។

## ? សំណួរ

1. ចូរអ្នកនិយាយប្រាប់ដៃគូពិភាក្សាឬក្រុមរបស់អ្នក ឬថ្នាក់រៀនទាំងមូលអំពីចម្ងល់របស់អ្នកលើបញ្ហាណាមួយដែលទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច ។ ករណីដៃគូពិភាក្សាមិនអាចដោះស្រាយចម្ងល់នោះបាន ចូរអ្នកកត់ត្រាចម្ងល់នោះទុក ។
2. ចូរអ្នកស្រាវជ្រាវរកចម្លើយ ដើម្បីឆ្លើយតបនឹងសំណួរពិភាក្សាខាងក្រោម
   ក. អ្វីដែលហៅថា "សេដ្ឋកិច្ច" ? ចូរពន្យល់សញ្ញាណរបស់វាឱ្យបានច្បាស់លាស់ ។
   ខ. តើសេដ្ឋកិច្ចមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
   គ. ដូចម្ដេចហៅថា សេដ្ឋកិច្ចទីផ្សារសេរី ?
   ឃ. ដូចម្ដេចហៅថា សេដ្ឋកិច្ចបញ្ជា ?
   ង. ដូចម្ដេចហៅថា សេដ្ឋកិច្ចចម្រុះ ?

ច. តើ "វិទ្យាសាស្ត្រសេដ្ឋកិច្ច" មានន័យដូចម្តេច ?

ឆ. ដូចម្តេចហៅថា "ការអភិវឌ្ឍសង្គម" ? ក្នុងពេលធ្វើការអភិវឌ្ឍសង្គម តើគេតែងប្រទះឃើញសកម្មភាពអ្វីខ្លះលេចធ្លោឡើង ? តើសកម្មភាពទាំងនោះ មានផលប៉ះពាល់ចំពោះបរិស្ថានជាតិនិងបរិស្ថានសង្គមដែរឬទេ ? ប្រសិនបើមាន តើអ្វីជាផលប៉ះពាល់ទាំងនោះ ?

ជ. តើគេត្រូវធ្វើការអភិវឌ្ឍសង្គមតាមវិធីណា ដើម្បីកុំឱ្យប៉ះពាល់ចំពោះបរិស្ថានធម្មជាតិនិងបរិស្ថានសង្គម ?

3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចទាំងឡាយណាដែលអ្នកគិតថាសំខាន់ ដើម្បីយកមកសរសេរផ្គុំគ្នាជាមេរៀនសង្ខេបរបស់អ្នក ។

## ប្រតិបត្តិ

ក្នុងស្មារតីចូលរួមអភិវឌ្ឍសង្គមជាតិកម្ពុជា តើអ្នកមានមតិយ៉ាងណាខ្លះទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច ? ចូររៀបរាប់ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 2 ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់បញ្ហាដែលអាជីវករត្រូវគិត ដើម្បីការរីកចម្រើននៃអាជីវកម្មរបស់ខ្លួន ។
- ❑ ពន្យល់បែបបទនៃការគិតលើបញ្ហានីមួយៗ ។
- ❑ បង្ហាញគំនិតជ្រើសរើសក្នុងការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចទីផ្សារ ។

ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ ក្នុងសេដ្ឋកិច្ចទីផ្សារ ប្រជាជនគ្រប់រូបមានសេរីភាពទូលំទូលាយក្នុងការជ្រើសរើសមុខរបរអាជីវកម្មផលិតទំនិញនិងបង្កើតសេវាកម្មផ្សេងៗ ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់អតិថិជន ។ អាជីវករ ត្រូវមានព័ត៌មានគ្រប់គ្រាន់ក្នុងសកម្មភាពសេដ្ឋកិច្ច មុននឹងសម្រេចចិត្តជ្រើសរើសយកអាជីវកម្មឬសេវាកម្មណាមួយ ។

## 1. ត្រូវផលិតអ្វី ?



នៅក្នុងអាជីវកម្មផលិតកម្ម ផលិតករតែងគិតថាត្រូវផលិតមុខទំនិញអ្វីដើម្បីលក់ក្នុងទិសដៅទទួលប្រាក់ចំណូលជាអតិបរមានិងខាតបង់ជាអប្បបរមា ។ ដើម្បីអាចសម្រេចចិត្តបាន គេត្រូវទទួលស្គាល់ថា តម្លៃលក់ទំនិញដែលផលិតបានស្ថិតក្រោមឥទ្ធិពលនៃក្រឹត្យក្រមសេចក្តីត្រូវការនិងការផ្គត់ផ្គង់ក្នុងទីផ្សារ ។ ***ឧទាហរណ៍*** មុខទំនិញណាមួយដែលមានសេចក្តីត្រូវការច្រើន ហើយមិនសូវមានគេលក់ទំនិញនោះពិតជាលក់បានថ្លៃ ។ ប៉ុន្តែចំពោះមុខទំនិញណាដែលមានដាក់លក់សម្បូរហូរហៀរហើយទំនិញនោះនឹងត្រូវចុះតម្លៃឬលក់មិនដាច់ ។

យោងតាមករណីខាងលើ យើងឃើញថាអាជីវករនឹងផលិតតែទំនិញឬបម្រើសេវាកម្មណាដែលផ្តល់ដល់គេនូវប្រាក់ចំណូល ជាពិសេសប្រាក់ចំណូលជាអតិបរមា ។ ចំណែកឯផលិតកម្មឬសេវាកម្មដែលមិនផ្តល់ប្រាក់ចំណូល គេពិតជាពុំផលិតឬពុំបម្រើទេ ។ ដើម្បីដឹងថានឹងមានប្រាក់ចំណូលឬទេ អាជីវករត្រូវពិនិត្យមើលថា តើគេត្រូវចំណាយលើផលិតកម្មឬសេវាកម្មសរុបអស់ប៉ុន្មាន ? ហើយតើគេនឹងទទួលបានប្រាក់ចំណូលសរុបប៉ុន្មាន ?

## 2. ការរៀបចំផលិតកម្ម

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ តើគេត្រូវរៀបចំផលិតកម្មតាមរបៀបណា ?



*ម៉ាស៊ីនតម្បាញ*



*កីតម្បាញ*

ជាទូទៅ ទីផ្សារជាអ្នកជំរុញនិងបញ្ចូលធនធានសេដ្ឋកិច្ចទៅក្នុងវិស័យផលិតកម្មទំនិញឬសេវាដែលមានតម្រូវការខ្ពស់និងជាពិសេសដើម្បីទទួលប្រាក់ចំណូលក្នុងការផលិតទំនិញឬសេវានោះ ។ តាមការជាក់ស្តែង សហគ្រាសដែលអាចធ្វើឱ្យដំណើរការផលិតកម្មបានទទួលចំណូលគឺសហគ្រាសដែលចេះកែច្នៃនិងមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងទាន់សម័យ ។ ***ឧទាហរណ៍*** មានសហគ្រាសតម្បាញហូលពីរនៅក្បែរគ្នា ។ សហគ្រាសមួយប្រើម៉ាស៊ីនតម្បាញមួយប្រភេទដែលផលិតហូល ក្នុងមួយថ្ងៃបាន 50 ។ សហគ្រាសមួយទៀតផលិតហូលតាមរយៈតម្បាញដោយដៃដែលប្រើកី

តម្បាញ 10 ហើយផលិតហូលក្នុងមួយថ្ងៃគិតជាមធ្យមបាន 3 ។ នៅលើទីផ្សារ ហូលដាក់លក់ដោយប្រកួតប្រជែងថ្លៃ ពោលគឺអ្នកប្រើប្រាស់នឹងទិញយកហូលដែលមានគុណភាពល្អ ហើយមានតម្លៃថោក ។ តើអ្នកគិតថាសហគ្រាសមួយណានឹងទទួលបានប្រាក់ចំណូលច្រើន ?

- **ការប្រើប្រាស់បច្ចេកទេសទំនើប :** គឺការជ្រើសរើសដ៏ប៉ិនប្រសប់នូវវិធានការចាត់ចែងកត្តាផលិតកម្មដោយប្រើប្រាស់បច្ចេកទេសទំនើប ដែលជួយផ្គត់ផ្គង់បង្កើនផលិតកម្មយ៉ាងរហ័ស ។
- **ថ្លៃធនធានសេដ្ឋកិច្ច :** សំដៅលើការចំណាយតិចលើវត្ថុធាតុដើម ទំនិញវិនិយោគ (គ្រឿងម៉ាស៊ីន...) កម្លាំងពលកម្ម (វិស្វករ កម្មករ ...) ។

រួមមក វិធានការចាត់ចែងធនធានសម្រាប់ដំណើរការផលិតកម្មដែលប្រកបដោយប្រសិទ្ធភាពមិនត្រឹមតែស្ថិតនៅលើការជ្រើសយកទេពកោសល្យនិងបច្ចេកវិទ្យាទំនើបតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគិតលើចំណាយផលិតកម្មប្រកបដោយភាពស័ក្តិសិទ្ធិថែមទៀត មានន័យថាត្រូវចំណាយលើធនធានទាំងឡាយក្នុងកម្រិតទាប ប៉ុន្តែត្រូវទទួលបានទិន្នផលកម្រិតខ្ពស់ ។

## 3. ការបែងចែកទំនិញ

ក្នុងសេដ្ឋកិច្ចទីផ្សារ ផលិតករត្រូវគិតថាតើត្រូវបែងចែកទំនិញឬសេវាយ៉ាងដូចម្តេច ? អ្នកណាជាអ្នកប្រើប្រាស់ទំនិញ ឬសេវាទាំងនោះ ?

ជាទូទៅ ការបែងចែកទំនិញត្រូវផ្អែកលើមូលដ្ឋានលទ្ធភាពនិងការចង់បានរបស់អ្នកទិញ ។



*ហាងលក់គ្រឿងអលង្ការ*



*ហាងលក់រថយន្តទំនើប*

### 3.1. លទ្ធភាព

លទ្ធភាពសំដៅលើបរិមាណចំណូលដែលអ្នកទិញរកបានសម្រាប់ចំណាយលើសេចក្តីត្រូវការបាន ។ ***ឧទាហរណ៍*** ពលរដ្ឋម្នាក់ដែលរកចំណូលបានត្រឹម 1 ពាន់ដុល្លារអាមេរិក មិនមានលទ្ធភាពទិញរថយន្តតូចដ៏ទំនើបដែលមានតម្លៃ 1 ម៉ឺនដុល្លារអាមេរិកទេ ។

### 3.2. ការចង់បាន ឬការប៉ងប្រាថ្នារបស់អ្នកទិញ

សំដៅលើសេរីភាពក្នុងការជ្រើសរើសមុខទំនិញដែលគេយល់ថាមានតម្លៃសមស្របនិងបំពេញនូវសេចក្ដីត្រូវការរបស់គេ ។ ***ឧទាហរណ៍*** កសិករឬកម្មករ មិនមានការចង់បាន ឬការប៉ងប្រាថ្នាទិញសម្លៀកបំពាក់រាត្រីសមោសរនិងគ្រឿងអលង្ការទាន់សម័យ ដែលប្រើសម្រាប់ចូលរួមក្នុងពិធីជប់លៀងរាត្រីសមោសរទេ ។

### 3.3. ចំណុចគួរកត់សម្គាល់

ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារ ពុំមានគោលការណ៍សីលធម៌ទេ ។ សេដ្ឋកិច្ចទីផ្សារពុំមានគោលការណ៍យុត្តិធម៌ សមធម៌ សប្បុរសធម៌ ការឧបត្ថម្ភ ឬសង្គ្រោះជនក្រីក្រ ឬបំពេញសេចក្ដីត្រូវការក្នុងការអភិវឌ្ឍសង្គមជាតិយ៉ាងណានោះទេ ។ អតិថិជនដែលមានចំណូលច្រើន តែងទិញបានផលិតផលច្រើន ។ ឯអតិថិជនដែលមានចំណូលទាប ត្រូវតែទិញបានផលិតផលតិច ។ ម្យ៉ាងទៀត អ្នកមានចំណូលច្រើន គេសំដៅលើអ្នកដែលមានទ្រព្យធនច្រើន មិនថាទ្រព្យធននោះមានប្រភពពីកេរដំណែល ឬសមត្ថភាពនិងភាពឈ្លាសវៃក្នុងមុខរបរអាជីវកម្មរបស់ខ្លួន ឬពីការសន្សំសំចៃ ការអត់ធ្មត់ និងការព្យាយាម ឬពីប្រភពណាផ្សេងទៀតឡើយ ។

## 4. ការសម្របខ្លួនទៅនឹងការផ្លាស់ប្ដូរ

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានការគិតថា តើយន្តការសេដ្ឋកិច្ចទីផ្សារអាចសម្របបានទៅនឹងការផ្លាស់ប្ដូរនៃសេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់ដែរឬទេ ?

ជាទូទៅ ការផ្លាស់ប្ដូរតម្រូវការរបស់អ្នកប្រើប្រាស់ ឬអតិថិជនមានឥទ្ធិពលលើថ្លៃទំនិញនិងសេវាតាមលក្ខណៈដូចខាងក្រោម



*អតិថិជនទិញទំនិញ "ថ្លៃទាប"*



*អតិថិជនទិញទំនិញ "ថ្លៃខ្ពស់"*

### 4.1. ការផ្លាស់ប្តូរតម្រូវការអាស្រ័យដោយកម្រិតថ្លៃទំនិញ ឬសេវានិងប្រាក់ចំណូល

នៅពេលទំនិញឬសេវាមានថ្លៃខ្ពស់ តម្រូវការរបស់អ្នកប្រើប្រាស់ក៏មានការថយចុះដែរ ។ តម្រូវការមានការថយចុះនេះហើយ ជាសញ្ញាបញ្ជាក់ប្រាប់ផលិតករឱ្យកាត់បន្ថយផលិតកម្ម ។ ប្រសិនបើផលិតករបញ្ចេញទំនិញរបស់ខ្លួនបានរហ័ស ទាន់ពេលមានតម្រូវការខ្ពស់គេនឹងទទួលចំណូលបានច្រើន បន្ទាប់មកផលិតកម្មក៏ត្រូវកើនឡើងបន្តទៀតដែរ ។ កំណើនផលិតកម្មវាអាស្រ័យនឹងចំណូល ។

### 4.2. ការប្រឈមមុខទៅនឹងការប្រកួតប្រជែង

ការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចទីផ្សារ បានលើកទឹកចិត្តអាជីវករឱ្យប្រើប្រាស់បច្ចេកវិទ្យាទំនើប ។ ជាទូទៅ ការប្រើប្រាស់បច្ចេកវិទ្យាទំនើប តែងកាត់បន្ថយចំណាយផលិតកម្មមានដូចជា កាត់បន្ថយចំនួនកម្លាំងពលកម្មជាដើម ហើយធ្វើឱ្យសហគ្រាសមួយមានប្រៀបលើសហគ្រាសមួយទៀត ។ ការកាត់បន្ថយចំណាយផលិតកម្មនាំឱ្យសហគ្រិនអាចផ្គត់ផ្គង់ទំនិញក្នុងតម្លៃទាបនិងក្នុងបរិមាណច្រើនជាងសហគ្រិនដទៃទៀត ដែលប្រើប្រាស់បច្ចេកវិទ្យាធម្មតា ។

ក្រៅពីនេះ ការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចទីផ្សារ បានជំរុញឱ្យមានការផ្សព្វផ្សាយយ៉ាងឆាប់រហ័សនូវការប្រើប្រាស់បច្ចេកវិទ្យាទំនើប ។ សហគ្រិនត្រូវប្រឈមមុខនឹងការជ្រើសរើសនិងប្រើប្រាស់បច្ចេកវិទ្យាទំនើប ប្រសិនបើចង់ឱ្យអាជីវកម្មរបស់ខ្លួន មានដំណើរការទៅមុខទៀត បើពុំនោះសោតសហគ្រិននឹងត្រូវប្រឈមនឹងការក្ស័យធន ។

## 5. សន្និដ្ឋាន

ថ្វីបើប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ មានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមិនអាចធ្វើការងារជំនួសស្ថាប័នរដ្ឋ ក្នុងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចជាតិបានឡើយ ។ តួយ៉ាងដូចជា ការផ្គត់ផ្គង់តម្រូវការរបស់ជនក្រីក្រ ការកាត់បន្ថយគម្លាតរវាងអ្នកមាននិងអ្នកក្រ ការពិនិត្យគុណភាពទំនិញ ការពិនិត្យគុណភាពនៃការអប់រំក្នុងសាលារៀនឯកជនជាដើម មានតែស្ថាប័នរដ្ឋប៉ុណ្ណោះ ដែលមានតួនាទីនិងភារកិច្ចបំពេញការងារទាំងនោះប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

## សំណួរ

1. ចូរអ្នកធ្វើការសម្ភាសជាមួយអាជីវករណាម្នាក់ក្នុងសហគមន៍របស់អ្នក ថាតើគាត់បានគិតគូរលើបញ្ហាអ្វីខ្លះនៅក្នុងអាជីវកម្មផលិតកម្ម ឬសេវាកម្មរបស់គាត់ ? ហើយយកលទ្ធផលនៃការសម្ភាសមករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោម

   ក. មុននឹងសម្រេចចិត្តជ្រើសយកអាជីវកម្មផលិតកម្មឬសេវាកម្មណាមួយ តើមានបញ្ហាអ្វីខ្លះដែលអាជីវករ ឬសហគ្រិនត្រូវគិត ?

   ខ. តើអាជីវករ ឬសហគ្រិនត្រូវគិតដូចម្ដេចខ្លះលើបញ្ហាត្រូវផលិតអ្វី ?

   គ. ហេតុអ្វីគេនិយាយថា ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារពុំមានគោលការណ៍សីលធម៌ ?

   ឃ. តើអាជីវករត្រូវការជ្រើសយកអ្វីខ្លះ ដើម្បីបានជោគជ័យក្នុងការប្រកួតប្រជែងលើសេដ្ឋកិច្ចទីផ្សារ ?
3. ចូរអ្នកអានអត្ថបទខាងលើ ដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចសំខាន់ៗ ដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

### ប្រតិបត្តិ

ស្ថិតក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ ចូរអ្នកបង្ហាញការគិតរបស់អ្នកទៅលើការជ្រើសរើសយកមុខរបរអាជីវកម្មផលិតកម្មឬសេវាកម្មណាមួយដែលអ្នកគិតថា នឹងអាចមានជោគជ័យក្នុងការប្រកួតប្រជែង ។

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

មេរៀនទី

# 3 ការវាយតម្លៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ បកស្រាយទឡ្ហីករណ៍ពីរដែលមួយគាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារនិងមួយទៀតប្រឆាំងនឹងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។
- ❑ វិភាគរកគុណសម្បត្តិនិងគុណវិបត្តិនៃសេដ្ឋកិច្ចទីផ្សារ ។
- ❑ បង្ហាញទស្សនៈរបស់ខ្លួនលើទ្រង់ទ្រាយនៃការអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន ។

នៅពេលបច្ចុប្បន្ននេះ នៅបណ្តាប្រទេសស្ទើរតែទូទាំងពិភពលោកទទួលស្គាល់ថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ ប្រទេសដែលបានអនុវត្តរបៀបគ្រប់គ្រងតាមប្រព័ន្ធសេដ្ឋកិច្ចបញ្ជា កំពុងខិតខំរិះរកមធ្យោបាយ ដើម្បីកែទម្រង់របៀបគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចនេះ មកសេដ្ឋកិច្ចទីផ្សារ ។

ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានទាំងគុណសម្បត្តិនិងគុណវិបត្តិ ។ ខាងក្រោមនេះមានទឡ្ហីករណ៍ពីរដែលជួយគាំទ្រសេដ្ឋកិច្ចទីផ្សារនិងមួយទៀតប្រឆាំងនឹងសេដ្ឋកិច្ចទីផ្សារ ។

## 1. ទឡ្ហីករណ៍គាំទ្រសេដ្ឋកិច្ចទីផ្សារ

### 1.1. ការប្រកួតប្រជែង

**ការប្រកួតប្រជែង** គឺជាការដណ្តើមយកឧត្តមភាពក្នុងការលក់ផលិតផល ។ ការប្រកួតប្រជែងមានពីរប្រភេទគឺ “ការប្រកួតប្រជែងពេញលេញនិងការប្រកួតប្រជែងផ្តាច់មុខ ។

ការប្រកួតប្រជែងពេញលេញ គឺជាទីផ្សារមួយដែលនៅក្នុងនោះ អ្នកលក់និងអ្នកទិញជឿថាគេមិនអាចគ្រប់គ្រងលើថ្លៃទំនិញ សេវា និងបរិមាណផលិតផលក្នុងទីផ្សារបានឡើយ ។

ប៉ុន្តែក្នុងរង្វង់ទីផ្សារ ច្រើនមានការប្រកួតប្រជែងផ្ដាច់មុខតែឯង ។ សហគ្រាសជាច្រើនចូលរួមក្នុងការប្រកួតប្រជែងផ្ដាច់មុខ ហើយមានឥទ្ធិពលទៅលើថ្លៃនៃផលិតផលរបស់ខ្លួន ពីព្រោះគេអាចធ្វើឱ្យអ្នកទិញជឿថាផលិតផលរបស់គេ ខុសគ្នាពីផលិតផលរបស់គូប្រជែង ។



## 1.2. ដៃអរូប

“**ដៃអរូប**” គឺកម្លាំងសម្របសម្រួលដំណើរការសេដ្ឋកិច្ចសង្គម ដែលគេមិនអាចមើលឃើញ ។ ទ្រឹស្ដីនេះរកឃើញដោយអ្នកប្រាជ្ញសេដ្ឋកិច្ច ជនជាតិអង់គ្លេសដ៏ល្បីឈ្មោះ អាដាមស្មីត (1723-1790) ដែលពន្យល់អំពីប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ។ ដៃអរូប គឺជាភ្នាក់ងារនីមួយៗក្នុងសកម្មភាពសេដ្ឋកិច្ចពិតមែនតែគេអាចទាញយកផលប្រយោជន៍រៀងៗខ្លួនពីការដាក់ទុន តែធាតុពិត សកម្មភាពប្រកួតប្រជែងរបស់គេបម្រើឱ្យយន្តការទីផ្សារមានដំណើរការបានតាមលំដាប់លំដោយ ។ ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ មានតួនាទីក្នុងការជំរុញឱ្យការអភិវឌ្ឍសេដ្ឋកិច្ចមានថាមភាព ។ ម្យ៉ាងទៀត ការរីកចម្រើនរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗរួមគ្នា គឺជាការរីកចម្រើននៃសង្គមសេដ្ឋកិច្ចទាំងមូល ។



facebook.com/moeys

## 1.3. ការបកស្រាយទឡ្ហីករណ៍គាំទ្រសេដ្ឋកិច្ចទីផ្សារ



សេដ្ឋវិទូគាំទ្រសេដ្ឋកិច្ចទីផ្សារអះអាងថា ជាទូទៅប្រព័ន្ធសេដ្ឋកិច្ចទីផ្សារមានប្រសិទ្ធភាពក្នុងការបែងចែកធនធានសេដ្ឋកិច្ច ពីព្រោះការប្រកួតប្រជែងក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារជំរុញឱ្យមានការបញ្ជូនធនធានសេដ្ឋកិច្ចទៅក្នុងផលិតកម្មដែលផលិតទំនិញនិងសេវាដើម្បីបំពេញតម្រូវការសង្គម ។ ការប្រកួតប្រជែងជំរុញឱ្យមានការប្រើប្រាស់វិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានក្នុងដំណើរការផលិត រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងជាពិសេសក្នុងការប្រើប្រាស់ប្រភពធនធាននានាឱ្យមាននិរន្តរភាព ។ និយាយរួម ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ "ដៃអរូប" ដែលគ្រប់គ្រងអត្ថប្រយោជន៍បុគ្គល ជាអ្នកជំរុញឱ្យមានការផ្គត់ផ្គង់ទំនិញនិងសេវានានាដល់សង្គម ។ ប្រការដ៏សំខាន់នេះហើយ ដែលជំរុញឱ្យសេដ្ឋវិទូមួយចំនួនពុំមានជំនឿលើប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ចំណុចសំខាន់មួយទៀតដែលជាទឡ្ហីករណ៍ការពារប្រព័ន្ធសេដ្ឋកិច្ចទីផ្សារគឺសេរីភាព ។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ដំណោះស្រាយបញ្ហាសង្គមជាចម្បង គឺសេរីភាពក្នុងការចាត់ចែងនិងសម្របសម្រួលទំនាក់ទំនងរវាងផលិតករនិងអ្នកប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច ។ គេអាចប្រៀបធៀបមធ្យោបាយសំខាន់សម្រាប់ធ្វើនិយ័តកម្មសេដ្ឋកិច្ចដូចខាងក្រោមនេះ

## 1.4. ការធ្វើនិយ័តកម្មសេដ្ឋកិច្ចតាមរបៀបរដ្ឋបាលប្រមូលផ្តុំ ឬបញ្ជា



ផ្ទុយនឹងសេដ្ឋកិច្ចទីផ្សារសេរីក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបញ្ជា រដ្ឋមានកម្មសិទ្ធិលើធនធាននិងកត្តាផលិតកម្មស្ទើរតែទាំងអស់ ។ ឯយន្តការគ្រប់គ្រងនិងសម្របសម្រួលត្រូវផ្អែកលើមូលដ្ឋានសេដ្ឋកិច្ចផែនការ មានន័យថាដំណើរការផលិតកម្មស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋាភិបាល ។ ដំណោះស្រាយធំៗទាក់ទងទៅនឹងផលិតកម្ម ការប្រើប្រាស់ ការបែងចែក ត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ ។

សហគ្រាសជាកម្មសិទ្ធិរបស់រដ្ឋ ដូច្នេះហើយសកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងក្នុងផលិតកម្ម ការបែងចែក ការផ្លាស់ប្តូរទំនិញ និងសេវាស្ថិតនៅក្រោមការត្រួតពិនិត្យនិងត្រូវអនុវត្តតាមផែនការរបស់រដ្ឋ ។ និយាយរួម ផែនការផលិតកម្មរបស់សហគ្រាសនីមួយៗគ្រប់គ្រងនិងត្រួតពិនិត្យដោយរដ្ឋដែលមានក្រុមប្រឹក្សាផែនការជាតំណាង ។ ជាទូទៅ ផែនការទាំងនេះ ជាអ្នកកំណត់ចំពោះសហគ្រាសនីមួយៗអំពីបរិមាណធនធាន បរិមាណផលិតផលនិងមុខងារតើត្រូវផលិតអ្វី ? ផលិតដូចម្តេច ? សម្រាប់អ្នកណា ? ក្នុងបរិមាណណា ? ដូចនេះ សមាមាត្ររវាងបរិមាណផលិតកម្មទំនិញវិនិយោគ និងទំនិញប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋ ត្រូវគ្រប់គ្រងនិងកំណត់ឡើងដោយផែនការរដ្ឋ ។

ដូច្នេះ ក្នុងសេដ្ឋកិច្ចបញ្ជា រដ្ឋមានតួនាទីស្ទើរតែទាំងស្រុងលើផលិតកម្ម ការប្រើប្រាស់ ការបែងចែកនូវធនធានសេដ្ឋកិច្ចក្នុងប្រទេស ។

## 1.5. ការធ្វើនិយ័តកម្មសេដ្ឋកិច្ចតាមបែបសេដ្ឋកិច្ចទីផ្សារ



ការធ្វើនិយ័តកម្មសេដ្ឋកិច្ចតាមបែបសេដ្ឋកិច្ចទីផ្សាររៀបចំឡើងដោយផ្អែកលើកិច្ចសហប្រតិបត្តិការដោយការស្ម័គ្រចិត្តនិងសេរីភាពក្នុងការជ្រើសរើស ។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសហគ្រិននិងកម្មករអាចមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសនិងបង្កើនអត្ថប្រយោជន៍របស់ខ្លួន ។ ខុសប្លែកពីសេដ្ឋកិច្ចបញ្ជាដែលសហគ្រិនបុគ្គលិកនិងកម្មករត្រូវផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត ពីវិស័យមួយទៅវិស័យមួយទៀតតាមតម្រូវការរបស់រដ្ឋដើម្បីបំពេញផែនការផលិតកម្មដែលរៀបចំឡើងដោយក្រសួងឬស្ថាប័នណាមួយ ។

ក្នុងគំនិតគាំទ្រសេដ្ឋកិច្ចទីផ្សារ សេដ្ឋវិទូដ៏ល្បីឈ្មោះ ហ្វ្រីដម៉ាណ មីលតុន (Friedman Milton) ជនជាតិអាមេរិកាំង (កើតនៅទីក្រុងញូវយ៉ក ឆ្នាំ 1912) សរសេរថា“ក្នុងពេលដែលមានការផ្លាស់ប្តូរដោយសេរីក្នុងប្រព័ន្ធសេដ្ឋកិច្ច អ្នកទិញគ្មានការបង្ខិតបង្ខំពីអ្នកលក់ ដូចគ្នានឹងអ្នកលក់គ្មានការបង្ខិតបង្ខំពីអ្នកទិញ ។ ក្នុងទីផ្សារ អ្នកលក់និងអ្នកទិញមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសតាមលទ្ធភាពនិងការប៉ងប្រាថ្នារបស់ខ្លួន ឬក្នុងការជ្រើសរើសសហគ្រិនដែលគេពេញចិត្តនិងយល់ថាត្រូវលក់កម្លាំងពលកម្មឱ្យ” ។ និយាយរួម ទីផ្សារមានដំណើរសកម្មភាពដោយគ្មានការគាបសង្កត់ពីរដ្ឋអំណាចណាមួយ ។ ភ្នាក់ងារគាំទ្រទាំងឡាយអាចជួយជំរុញការផ្គត់ផ្គង់និងការចែកចាយធនធានឱ្យមានប្រសិទ្ធភាព ជាពិសេសភ្នាក់ងារសេដ្ឋកិច្ចនីមួយៗមានសិទ្ធិសេរីភាពយ៉ាងទូលំទូលាយក្នុងការប្រកបអាជីវកម្ម ។

## 2. ទឡ្ហីករណ៍ប្រឆាំងនឹងសេដ្ឋកិច្ចទីផ្សារ

សេដ្ឋវិទូក្នុងក្រុមទី 2 ដែលមិនគាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានលើកទឡ្ហីករណ៍ប្រឆាំង ។ ក្នុងទឡ្ហីករណ៍នោះពួកគេរិះគន់ថា **មនោគមវិជ្ជាសេដ្ឋកិច្ចទីផ្សារមានការខ្វះខាតឬជំរុញឱ្យផុតរលត់នូវការប្រកួតប្រជែង** ។ ពួកគេយល់ថាមានមូលហេតុមួយចំនួនដែលនាំឱ្យសេដ្ឋកិច្ចទីផ្សារចុះខ្សោយ ។

### 2.1. បំណងប្រាថ្នារកចំណូល



ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ សេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗប្រព្រឹត្តទៅដោយមានបំណងប្រាថ្នារកចំណូល ។ ដោយមាននិន្នាការស្របគ្នាក្នុងការពង្រឹងស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួន សហគ្រិននីមួយៗព្យាយាមរំដោះខ្លួនចេញពីការប្រកួតប្រជែងតាមរយៈការរួមគ្នាព្រមព្រៀងដោយអាថ៌កំបាំង ដើម្បីធ្វើអាជីវកម្មផ្តាច់មុខ ។ល ។ នេះជាមូលហេតុចម្បងដែលអ្នកទិតៀនសេដ្ឋកិច្ចទីផ្សារយល់ឃើញថានឹងមានការបញ្ចប់និយ័តភាពសេដ្ឋកិច្ចទីផ្សារ ។

តាមធម្មតា រាល់ចលនាសេដ្ឋកិច្ចទាំងអស់តែងចៀសមិនផុតពីសកម្មភាពនៃការប្រកួតប្រជែងគ្នាឡើយ ។ ផលិតករតែងតែរិះរកគ្រប់មធ្យោបាយ ដើម្បីគ្រប់គ្រងទីផ្សារតាមរយៈការធ្វើយ៉ាងណាផានាឱ្យបាននូវការលក់ចេញផលិតផលរបស់ខ្លួនទទួលបានជោគជ័យ ។ ក្នុងករណីនេះ ផលិតករទាំងឡាយមានការប្រកួតប្រជែងគ្នាយ៉ាងស្រួចស្រាល់បំផុត ដើម្បីដណ្តើមយកអំណាចគ្រប់គ្រងការលក់ផលិតផលរបស់ខ្លួននៅលើទីផ្សារ ។ អំណាចគ្រប់គ្រងទីផ្សារនេះ ជាឧបសគ្គរារាំងមិនឱ្យមានការហាក់ចូលនៃផលិតករថ្មី ដើម្បីឱ្យការផលិតរបស់ខ្លួនមានដំណើរការជាប្រក្រតីធានាបាននូវស្ថេរភាពនៃការលក់ចេញផង និងអាចឈានទៅរកការគ្រប់គ្រងទីផ្សារទាំងស្រុងផង ដើម្បីទទួលបានចំណូលខ្ពស់ ។

facebook.com/moeysgov.kh youtube.com/moeys

## 2.2. ការរីកចម្រើននៃបច្ចេកវិទ្យាទំនើបនាំឱ្យការប្រកួតប្រជែងចុះខ្សោយ

ជាទូទៅ ការរីកចម្រើននៃបច្ចេកវិទ្យាទំនើប ទាមទារការប្រើប្រាស់មូលនិធិច្រើន ទីផ្សារធំនិងមានការប្រមូលផ្តុំនូវធនធាននិងមានប្រភពច្បាស់លាស់ ។ ក្នុងន័យនេះ សហគ្រាសផលិតកម្មចាំបាច់ត្រូវមានទុនសម្រាប់វិនិយោគក្នុងបរិមាណនិងទ្រង់ទ្រាយធំ ។ ដូច្នេះ ក្នុងក្របខ័ណ្ឌទីផ្សារទាំងមូលមិនមានការចូលរួមអំពីសំណាក់សហគ្រាសតូចៗនិងមធ្យមជាច្រើនដែលជាមូលដ្ឋាននៃសេដ្ឋកិច្ចទីផ្សារទៀតទេ ។

ដោយមូលហេតុនេះអ្នកសេដ្ឋកិច្ចយល់ថាយន្តការទីផ្សារត្រូវបាត់បង់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈការចុះខ្សោយនៃការប្រកួតប្រជែង ។

## 2.3. វិសមភាពក្នុងការបែងចែកផលិតផល



អ្នកគាំទ្រសេដ្ឋកិច្ចបញ្ជាអះអាងថា “ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារផ្តត់ផ្គង់តែសហគ្រិនដែលមានសមត្ថភាពនិងកលល្បិចខ្ពស់ក្នុងអាជីវកម្ម និងសហគ្រិនដែលមានធនធានស្តុកស្តម្ភ ។ ដូច្នេះអ្នកមានចេះតែមាន អ្នកក្រចេះតែក្របន្តទៅទៀត” ។ ផលអវិជ្ជមាននេះ ធ្វើឱ្យមានគម្លាតគ្នាកាន់តែខ្លាំងនៅក្នុងការបែងចែកនិងទទួលចំណូល ។ ជាមួយគ្នានោះ សេចក្តីត្រូវការរបស់សមាជិកម្នាក់ៗក្នុងសង្គមក៏កាន់តែមានភាពខុសគ្នាជាលំដាប់ ។ ជាងនេះទៀត សេដ្ឋកិច្ចទីផ្សារគ្មានគោលការណ៍សីលធម៌និងគ្មានសមធម៌ក្នុងការបែងចែកផលិតផលសង្គមឡើយ ពីព្រោះ “អ្នកមានប្រើប្រាស់ទំនិញប្រណីត អ្នកក្រប្រើប្រាស់ទំនិញសម្រាប់តែរស់ប៉ុណ្ណោះ” ។

## 2.4. កង្វះការផ្គត់ផ្គង់សេវាសាធារណៈ

អ្នកប្រឆាំងសេដ្ឋកិច្ចទីផ្សារបានលើកយកឧទាហរណ៍អំពីកត្តាដែលធ្វើឱ្យទីផ្សារប្រព្រឹត្តទៅមិនប្រក្រតី ។ ពួកគេយល់ថា យន្តការសេដ្ឋកិច្ចទីផ្សារយកចិត្តទុកដាក់តែនឹងការបំពេញសេចក្តីត្រូវការដែលមានលក្ខណៈបុគ្គលប៉ុណ្ណោះ ។

នៅក្នុងជីវភាពសង្គមមានតម្រូវការជាច្រើនលើសេវាសាធារណៈ ក្នុងនោះមានដូចជា ការកសាងថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ សំណង់ធំៗ ទីរមណីយដ្ឋាន សួនច្បារសាធារណៈ ។ល ។ ភ្នាក់ងារសេដ្ឋកិច្ចឯកជន ជាទូទៅ មិនមានការចាប់អារម្មណ៍ទៅលើការបំពេញសេចក្តីត្រូវការសេវាសាធារណៈទេ ។ ភ្នាក់ងារសេដ្ឋកិច្ចឯកជន ជារួមពុំគិតដល់ការសង្គ្រោះពេលមានគ្រោះទុរ្ភិក្ស ទឹកជំនន់ ការរាំងស្ងួត ការចំណាយលើកងទ័ព និងដោះស្រាយបញ្ហាសង្គមផ្សេងៗជាច្រើនទៀតនោះទេ ។ ម្យ៉ាងទៀត ភ្នាក់ងារសេដ្ឋកិច្ចឯកជនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចឱ្យមានស្ថេរភាពប្រកបដោយចីរភាពទេ យូរឬឆាប់សេដ្ឋកិច្ចទីផ្សារនឹងជួបវិបត្តិក្នុងករណីរដ្ឋមិនលូកដៃចូលធ្វើអន្តរាគមន៍ ។

# 3. សេចក្តីសន្និដ្ឋាន

យោងតាមអត្ថន័យនៃទ្រឹស្តីករណ៍គាំទ្រនិងទ្រឹស្តីករណ៍ប្រឆាំងសេដ្ឋកិច្ចទីផ្សារដែលបានរៀបរាប់ខាងលើនិងដោយផ្អែកលើព្រឹត្តិការណ៍ថ្មីៗដែលបណ្តាប្រទេសអឺរ៉ុបខាងកើតនិងអតីតសហភាពសូវៀតបាននិងកំពុងស្ថិតក្នុងអន្តរកាលនៃការផ្លាស់ប្តូររបបគ្រប់គ្រងសេដ្ឋកិច្ចបញ្ជាមកសេដ្ឋកិច្ចទីផ្សារ យើងអាចសន្និដ្ឋានបានថា អ្នកសេដ្ឋកិច្ចភាគច្រើនផ្តល់អាទិភាពដល់យន្តការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារក្នុងការអភិវឌ្ឍប្រទេសជាតិ ។

យើងត្រូវទទួលស្គាល់ថា សេដ្ឋកិច្ចទីផ្សារសេរីសុទ្ធសាធមិនអាចគ្រប់គ្រងឬមានតួនាទីគ្រប់គ្រាន់ក្នុងការជំរុញសេដ្ឋកិច្ចឱ្យមានស្ថិរភាពជានិរន្តរ៍នោះទេ ។ រដ្ឋត្រូវបំពេញតួនាទីរបស់ខ្លួននៅត្រង់ទីខ្វះចន្លោះរបស់យន្តការទីផ្សារ ដើម្បីធានានូវប្រសិទ្ធភាពការងារក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិជាពិសេស នៅបណ្តាប្រទេសក្រីក្រ ។

facebook.com/moeys.gov.kh
ebou.moeys.gov.kh
youtube.com/moeys

## សំណួរ

1. បច្ចុប្បន្នប្រព័ន្ធសេដ្ឋកិច្ចទីផ្សារកំពុងត្រូវបានអនុវត្តក្នុងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍមួយចំនួន ហើយក៏កំពុងទទួលការគាំទ្រពីបណ្ដាប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ផងដែរ ។ ក្នុងនាមជាពលរដ្ឋម្នាក់ តើអ្នកបានមើលឃើញទិដ្ឋភាពទីផ្សារនៅសហគមន៍របស់អ្នកយ៉ាងដូចម្ដេចខ្លះ ? ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូឬជាមួយសមាជិកក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម

   ក. តើក្រុមអ្នកគាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានផ្ដល់ទឡ្ហីករណ៍ដូចម្ដេចខ្លះ ?

   ខ. តើក្រុមអ្នកប្រឆាំងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានផ្ដល់ទឡ្ហីករណ៍ដូចម្ដេចខ្លះ ?

   គ. តើអ្នកគាំទ្រទឡ្ហីករណ៍ណាមួយ ? ហេតុអ្វី ?
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ ហើយដកស្រង់យកចំណុចសំខាន់ៗដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន តើវិស័យណាខ្លះដែលគ្រប់គ្រងនិងបញ្ជាដោយរដ្ឋ ? តើវិស័យណាខ្លះដែលគ្រប់គ្រងនិងបញ្ជាដោយសេដ្ឋកិច្ចទីផ្សារ ? តើអ្នកយល់ថា ការរៀបចំនេះមានប្រសិទ្ធភាពកម្រិតណា ? ចូរពន្យល់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 4 ទីផ្សារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ កំណត់និយមន័យទីផ្សារនិងបកស្រាយលក្ខខណ្ឌសំខាន់ៗដែលធ្វើឱ្យទីផ្សារមានសកម្មភាព ។
- ❑ បង្ហាញការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារ ។
- ❑ បកស្រាយទំនាក់ទំនងរវាងតម្លៃទំនិញនិងបរិមាណតម្រូវការនៃផលិតផល ។

ការទាក់ទងរវាងមនុស្សនិងមនុស្សក្នុងការដោះដូរផលិតផលគឺជាការចាំបាច់សម្រាប់បម្រើតម្រូវការដ៏សម្បូរបែបរបស់ខ្លួន ។ ដើម្បីងាយស្រួលក្នុងការដោះដូរផលិតផល ប្រជាជនក៏បានកំណត់យកកន្លែងមួយច្បាស់លាស់ ដើម្បីដោះដូរទំនិញរបស់ពួកគេ នោះគឺទីផ្សារ ។

## 1. ទីផ្សារ



ទីផ្សារ គឺជាការរៀបចំឱ្យអ្នកលក់និងអ្នកទិញជួបគ្នា ក្នុងគោលបំណងដោះដូរទំនិញ ឬសេវាកម្មទៅវិញទៅមក ។ ទីផ្សារមានតួនាទីសម្រួលការដោះដូរទំនិញនិងសេវាកម្មរវាងមនុស្សដែលមានទំនិញឬសេវាកម្មសម្រាប់លក់ និងមនុស្សដែលត្រូវការទិញទំនិញឬសេវាកម្មទាំងនោះ ។ ទីផ្សារ គឺជាការជួបគ្នារវាងអ្នកទិញនិងអ្នកលក់ដើម្បីចរចាអំពីថ្លៃ ។ ក្នុងន័យនេះ ផលិតករនិងអ្នកធ្វើអាជីវកម្ម គឺជាអ្នកលក់ ឯអ្នកប្រើប្រាស់ជាអ្នកទិញ ឬជាកម្លាំងទិញដ៏សំខាន់ ។

ទីផ្សារអាចមានសកម្មភាពបានលុះត្រាមាន

## 1.1. ការដោះដូរពលកម្ម

ពលកម្ម ជាកម្លាំងចលករសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច ។ ពលកម្មជាកម្មសិទ្ធិរបស់មនុស្ស ហើយត្រូវបានមនុស្សលក់ពលកម្មនេះតាមតម្រូវការទីផ្សារ ។ ឯតម្លៃពលកម្មប្រែប្រួលទៅតាមឯកទេសដែលផលិតកម្មត្រូវការ ។

ទីផ្សារពលកម្ម ជាអ្នកកំណត់ឯកទេសឬជំនាញដែលត្រូវការ ។ កម្រិតប្រាក់ឈ្នួលពលកម្មតែងអាស្រ័យទៅនឹងកម្រិតអប់រំជំនាញ ។ ដើម្បីទទួលបាននូវប្រាក់ចំណូលពលកម្មខ្ពស់ មនុស្សត្រូវតែខិតខំធ្វើការសិក្សាស្រាវជ្រាវ បង្កើនចំណេះដឹងនិងជំនាញឱ្យកាន់តែប្រសើរ ។ ក្នុងវិស័យសេដ្ឋកិច្ចផលិតកម្មសង្គមត្រូវការជំនាញឯកទេសជាច្រើន ដើម្បីផលិតបានផលិតផលច្រើនមុខនិងច្រើនកម្រិតគុណភាព ។ ក្នុងផលិតកម្មគ្រឿងអេឡិចត្រូនិច គេត្រូវការមនុស្សដែលមានជំនាញអគ្គិសនី គ្រឿងយន្ត ជំនាញទីផ្សារ គណនេយ្យ គ្រប់គ្រងធនធាន ។ល ។

## 1.2. ការដោះដូរផលិតផល

ផលិតផល ជាទំនិញដែលបង្ហូរចេញពីសហគ្រាសផលិតនានាមកដល់ទីផ្សារ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់អតិថិជន ។ នៅទីផ្សារ ផលិតផលត្រូវបានកំណត់ថ្លៃនិងចែកចាយតាមរយៈចរាចរណ៍ទំនិញ ។ បរិមាណនិងគុណភាពនៃផលិតផលណាមួយបញ្ជាក់ពីសមត្ថភាពនិងគុណភាពនៃការងារផលិតកម្មរបស់វា ហើយត្រូវបានបង្ហាញដោយថ្លៃនៃផលិតផលនោះ ។

ទំនិញមានគុណភាពល្អ អាចសម្គាល់បានដោយភាពមានអនាម័យក្នុងការវេចខ្ចប់ ស្លាកយីហោត្រឹមត្រូវ ទំនិញមានកាលបរិច្ឆេទផលិតនិងរយៈកាលប្រើប្រាស់ច្បាស់លាស់ មានភាពងាយស្រួលក្នុងការប្រើប្រាស់ ហើយប្រើប្រាស់បានយូរនិងលក់ក្នុងតម្លៃទាប ។ កត្តាទាំងនេះជួយឱ្យអាជីវកម្មទទួលបានជោគជ័យក្នុងការប្រកួតប្រជែងនិងមានការគាំទ្រពីអតិថិជនកាន់តែច្រើនឡើងៗ ។

facebook.com/moeys.gov.kh youtube.com/moeys

អាជីវកម្មទាំងឡាយត្រូវព្យាយាមបំពេញរាល់តម្រូវការរបស់អតិថិជននិងរៀបចំឱ្យមានស្លាកសញ្ញាសម្គាល់ផលិតផលរបស់ខ្លួន ដើម្បីជៀសវាងភាពក្លែងបន្លំដែលនឹងនាំទៅរកភាពបាត់បង់អតិថិជននិងកិត្តិយសរបស់ខ្លួន ។



## 1.3. សិទ្ធិជាម្ចាស់កម្មសិទ្ធិនិងសិទ្ធិសហគ្រិន

ទីផ្សារបើកចំហសិទ្ធិជាម្ចាស់កម្មសិទ្ធិនិងសិទ្ធិសហគ្រិន ។

### ក. កម្មសិទ្ធិ

ក្នុងន័យសេដ្ឋកិច្ច កម្មសិទ្ធិសំដៅលើការមានជារបស់ខ្លួននូវមធ្យោបាយផលិតកម្មនិងទ្រព្យសម្ភារៈផលិតបាន ។ ឯសិទ្ធិជាម្ចាស់លើកម្មសិទ្ធិមានន័យថា សេរីភាពគ្រប់យ៉ាង ដែលអាចធ្វើឱ្យម្ចាស់កម្មសិទ្ធិទិញ ត្រួតពិនិត្យ ប្រើប្រាស់ លក់ ឬផ្ទេរធនធានសម្ភារៈ ដែលជាកម្មសិទ្ធិរបស់ខ្លួន សម្រាប់បំពេញសេចក្តីត្រូវការរបស់គេដោយសេរី ។

### ខ. សហគ្រិន

មានន័យថា អ្នកផ្តួចផ្តើមបង្កើតនូវសហគ្រាសពាណិជ្ជកម្មណាមួយ ជាពិសេសកិច្ចការជំនួញដែលមានទាក់ទិនទៅនឹងហានិភ័យហិរញ្ញវត្ថុ ។ សហគ្រិនជាអ្នកច្នៃប្រឌិត ហ៊ានប្រថុយប្រថានរាល់គ្រោះថ្នាក់និងហ៊ានទទួលយកនូវគ្រោះថ្នាក់ជាយថាហេតុ ។ ដូចនេះ សហគ្រិនមានសិទ្ធិធ្វើជាម្ចាស់និងគ្រប់គ្រងត្រួតពិនិត្យមូលដ្ឋានអាជីវកម្មរបស់ខ្លួនដោយខ្លួនឯង ។

## 1.4. ថ្លៃទំនិញនិងសេវាត្រូវបានកំណត់

ដើម្បីបានផលិតផលទំនិញមួយ អ្នកផលិតត្រូវចំណាយលើវត្ថុធាតុដើម មធ្យោបាយផលិតកម្ម និងកម្លាំងផលិតកម្ម ។ ជាទូទៅ ថ្លៃទំនិញត្រូវបានកំណត់ឱ្យមានការទូទាត់ចំណាយលើវត្ថុធាតុដើម មធ្យោបាយផលិតកម្ម និងកម្លាំងផលិតកម្ម រួមទាំងការចំណាយផ្សេងៗទៀត ដូចជា ការបង់ពន្ធ ការជួលអគារ ឬទីកន្លែង ការវេចខ្ចប់ និងការដឹកជញ្ជូន ។

ទោះបីមានការកំណត់ថ្លៃតាមលក្ខណៈផលិតកម្មយ៉ាងណាក៏ដោយ នៅទីផ្សារ ប្រសិនបើទំនិញមានតម្រូវការខ្ពស់ ទំនិញនោះអាចលក់បានថ្លៃខ្ពស់ ។ មានន័យថា គេអាចកាត់ថ្លៃខ្ពស់ចំពោះទំនិញណាដែលមានតម្រូវការខ្ពស់ ដោយសារពុំមានអ្នកផលិតច្រើន ហើយមិនមានគូប្រជែង ។




*ក្រាហ្វិកនិយាយពីតម្រូវការនិងបរិមាណ*

## 1.5. ការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារ

រដ្ឋមានតួនាទីតិចតួចណាស់ក្នុងការធ្វើអន្តរាគមន៍លើទីផ្សារ ព្រោះទីផ្សារមានយន្តការមួយចំនួនសម្រាប់សម្របសម្រួលការងារដោយឯកឯង ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋនៅមានមុខងារសំខាន់ៗបីដែរគឺ

- **មុខងារធ្វើនិយ័តកម្ម :** រដ្ឋជាអ្នកបង្កើតនិងជំរុញការអនុវត្តច្បាប់គ្រឹះនានា ដូចជាច្បាប់កិច្ចសន្យា ច្បាប់កម្មសិទ្ធិ ក្រមសីលធម៌សេដ្ឋកិច្ច ច្បាប់ពន្ធ ច្បាប់ចរាចរណ៍ ច្បាប់រូបិយប័ណ្ណជាដើម ដើម្បីផលប្រយោជន៍អតិថិជន សហគ្រិនអាជីវកម្ម និងសង្គមជាតិ ។
- **មុខងារលើកទឹកចិត្ត :** រដ្ឋជាអ្នកធ្វើឱ្យមានប្រសិទ្ធភាពក្នុងការរក្សាស្ថេរភាពសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីកាត់បន្ថយនូវវិបត្តិផ្សេងៗ ដូចជាការបាត់បង់ការងារ អតិផរណាជាដើម ។
- **មុខងារត្រួតពិនិត្យ :** រដ្ឋជាអ្នកទប់ស្កាត់ការប៉ះពាល់ទៅលើបរិស្ថាន មានដូចជាការបង្ហូរកាកសំណល់ដែលមានជាតិគីមីឬកាកសំណល់ផ្សេងៗទៅក្នុងទឹក... ការផលិតនិងលក់សារជាតិដែលបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមានថ្នាំញៀនជាដើម ការផលិតនិងលក់ចំណីអាហារ ឬអាវុធដែលមានជាតិគីមី ឬការផលិត ឬប្រើប្រាស់ឧបករណ៍ ឬអាវុធទំនិញដែលមានជាតិវិទ្យុសកម្មជាដើម ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys

## 2. ថ្លៃ



*ក្រាហ្វិកនិយាយពីកម្លាំងទិញរបស់អ្នកទិញ*

ថ្លៃជាអ្នកប្រាប់តម្លៃរបស់ទំនិញឬសេវាកម្មដល់អ្នកលក់និងអ្នកទិញ ។ ដើម្បីឱ្យមានការដោះដូរអ្នកលក់និងអ្នកទិញត្រូវការថ្លៃទំនិញ ឬថ្លៃសេវាកម្មមានលក្ខណៈសមហេតុផល ។ ចំពោះអ្នកទិញ ការចំណាយទៅលើថ្លៃនៃមុខទំនិញមួយនឹងកាត់បន្ថយនូវកម្លាំងទិញដែលមានចំពោះមុខទំនិញដទៃទៀត ។ ចំពោះអ្នកលក់វិញ ប្រាក់ចំណូលជាសញ្ញាបង្ហាញកម្រិតនៃការលក់ចេញនិងប្រាក់ចំណេញ ។

ដូចនេះ ចំណូលរបស់អ្នកលក់មានកម្រិតទៅតាមកម្រិតនៃការទិញនៅក្នុងទីផ្សារ ប្រសិនបើផលិតផលលក់បានច្រើន ចំណូលក៏បានច្រើនដែរ តែបើផលិតផលលក់បានតិច ចំណូលក៏បានតិចទៅតាមនោះដែរ ។

### 2.1. ថ្លៃនិងឥទ្ធិពលចំណូល

ដោយចំណូលមានព្រំដែន អ្នកទិញបានទិញទំនិញតិចជាងមុននៅពេលដែលថ្លៃទំនិញមានការកើនឡើង ។ម្យ៉ាងទៀត តម្រូវការអ្នកទិញអាចមានការប្រែប្រួលទៅតាមចំណូលជាក់ស្ដែងរបស់គេ ។

### 2.2. ថ្លៃនិងឥទ្ធិពលជំនួស

ប្រសិនបើទំនិញមួយឡើងថ្លៃ អ្នកទិញអាចបន្ថយការទិញទំនិញនោះ ហើយទៅទិញទំនិញដទៃទៀតដែលគេចាត់ទុកថាមានឥទ្ធិពលជំនួស ។ នេះជាការប្រែប្រួលបរិមាណតម្រូវការ ដែលបណ្ដាលមកពីថ្លៃទំនិញមួយប្រែប្រួល ។

## 3. សន្និដ្ឋាន

ទីផ្សារជាមជ្ឈមណ្ឌលផ្ដោះប្ដូរទំនិញនិងសេវាកម្ម ជាប្រភពរីកចម្រើននៃជីវភាពសេដ្ឋកិច្ចសង្គមទៅតាមថ្លៃដែលស្ថិតក្រោមឥទ្ធិពលចំណូលនិងឥទ្ធិពលជំនួស ។

facebook.com/moeys.gov.kh khmer.moeys.gov.kh youtube.com/moeys

## សំណួរ

1. ចូរអ្នករៀបរាប់ទំនិញ 5 មុខដែលអ្នកត្រូវការនិងប្រាប់ពីថ្លៃរបស់វាទៅលើទីផ្សារក្នុងសហគមន៍របស់អ្នក ។ បន្ទាប់មក ចូរបង្ហាញថា តើថ្លៃទំនិញនីមួយៗនោះសមរម្យចំពោះអ្នកឬទេ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ

   ក. ដូចម្ដេចហៅថាទីផ្សារ ?

   ខ. តើមានលក្ខខណ្ឌអ្វីខ្លះដែលធ្វើឱ្យទីផ្សារមានសកម្មភាព ? ចូរពន្យល់ ។

   គ. តើមានអន្តរាគមន៍របស់រដ្ឋដែរឬទេក្នុងទីផ្សារ ? បើមាន តើរដ្ឋបានបំពេញមុខងារអ្វីខ្លះ ?

   ឃ. នៅទីផ្សារ តើថ្លៃទំនិញ ឬសេវាកម្មត្រូវបានកំណត់ដោយវិធីណា ? ចូរពន្យល់ ។

   ង. តើថ្លៃទំនិញស្ថិតក្រោមឥទ្ធិពលអ្វីខ្លះ ? ចូររៀបរាប់និងពន្យល់ ។
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចសំខាន់ៗដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

### ប្រតិបត្តិ

ចូរអ្នករៀបរាប់ទំនិញ 5 មុខដែលលក់ដាច់ជាងគេលើទីផ្សារក្នុងសហគមន៍របស់អ្នកនិងបង្ហាញថា ហេតុអ្វីបានជាទំនិញទាំងនោះលក់ដាច់ជាងគេ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 5 រចនាសម្ព័ន្ធទីផ្សារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីទ្រង់ទ្រាយនៃរចនាសម្ព័ន្ធទីផ្សារ ។
- ❑ បង្ហាញលក្ខណៈនៃការប្រកួតប្រជែងពេញលេញនិងមិនពេញលេញ ។
- ❑ ពន្យល់ពីគុណវិបត្តិនិងផលប៉ះពាល់នៃការលក់ផ្ដាច់មុខ ។

រចនាសម្ព័ន្ធទីផ្សារ ជាសកម្មភាពសេដ្ឋកិច្ចដែលទ្រទ្រង់របបទីផ្សារសេរី ។ ក្នុងសេដ្ឋកិច្ចទីផ្សារតែងតែមានរចនាសម្ព័ន្ធទីផ្សារ ដែលរួមមានការប្រកួតប្រជែងពេញលេញនិងការប្រកួតប្រជែងមិនពេញលេញ ។

## 1. ការប្រកួតប្រជែងពេញលេញ

ការប្រកួតប្រជែងក្នុងសកម្មភាពសេដ្ឋកិច្ច គឺជាការប្រឹងប្រែងបំពេញតម្រូវការរបស់អតិថិជនឱ្យបានច្រើនបំផុតនៅលើទីផ្សារ ហើយរក្សាបាននិរន្តរភាពនិងកិត្តិនាមនៃអាជីវកម្មរបស់ខ្លួន ។ ការប្រកួតប្រជែងពេញលេញ មានលក្ខណៈដូចខាងក្រោម

### 1.1. មានអ្នកលក់និងអ្នកទិញច្រើន

ការប្រកួតប្រជែង តែងកើតមានឡើងនៅទីផ្សារដែលមានអ្នកលក់និងអ្នកទិញច្រើន ។

### 1.2. ការប្រៀបធៀបផលិតផលក្នុងប្រភេទតែមួយ

គេមើលឃើញការប្រកួតប្រជែងដោយពិនិត្យទៅលើការផលិតនិងការលក់ដូរផលិតផលប្រភេទតែមួយដូចគ្នា ។ អតិថិជន អាចប្រៀបធៀបបានថា ផលិតផលនេះមានគុណភាពជាងផលិតផលនោះ ឬផលិតផលនេះមានតម្លៃសមរម្យជាងផលិតផលនោះ ។ ក្នុងគោលបំណងទាក់ទាញអតិថិជនឱ្យបានច្រើន អ្នកលក់ម្នាក់ៗព្យាយាមប្រកួតប្រជែងគ្នាតាមរយៈការបញ្ចុះថ្លៃទំនិញរៀងៗខ្លួន ។

និយាយរួម នៅក្នុងការប្រកួតប្រជែងលើទីផ្សារ អាជីវករម្នាក់ៗមិនមានឥទ្ធិពលទៅលើការកំណត់ថ្លៃបានឡើយ ។

### 1.3. សេរីភាពក្នុងការចូលទីផ្សារ

ការប្រកួតប្រជែងនៅលើទីផ្សារតម្រូវឱ្យមានការបើកទូលាយឱ្យទំនិញទាំងឡាយមានសេរីភាពក្នុងការនាំចូលមកទីផ្សារ ដើម្បីផ្តល់ជម្រើសសម្រាប់អតិថិជន ។

### 1.4. កត្តាផលិតកម្ម

ជាទូទៅ ការប្រកួតប្រជែងគឺជាសមាសភាពនៃរចនាសម្ព័ន្ធទីផ្សារ ។ ក្នុងសេដ្ឋកិច្ចទីផ្សារ បំណងប្រកួតប្រជែងជំរុញឱ្យសហគ្រាសនីមួយៗរៀបចំដំណើរផលិតកម្មឱ្យមានប្រសិទ្ធភាពខ្ពស់បំផុតពោលគឺគេត្រូវការកាត់បន្ថយថ្លៃដើមឱ្យនៅតិចបំផុតនិងបញ្ចូលបច្ចេកទេសថ្មី ដើម្បីធ្វើឱ្យផលិតផលមានគុណភាពខ្ពស់ ហើយអាចលក់ក្នុងតម្លៃសមរម្យ ។

## 2. ការប្រកួតប្រជែងមិនពេញលេញ

ការប្រកួតប្រជែងមិនពេញលេញ ជារចនាសម្ព័ន្ធទីផ្សារដែលគ្មានការប្រកួតប្រជែងពេញលេញ ។ ការប្រកួតប្រជែងមិនពេញលេញ មានកម្រិតផ្សេងៗ ដូចជារបបផ្តាច់មុខពីរនាក់ របបរួមគ្នាផ្តាច់មុខ និងការប្រកួតប្រជែងផ្តាច់មុខ ។

### 2.1. របបផ្តាច់មុខពីរនាក់

របបផ្តាច់មុខពីរនាក់ ជាទម្រង់នៃការរួមគ្នាផ្តាច់មុខប្រភេទសាមញ្ញ ដែលមានផលិតករតែពីរនាក់ប៉ុណ្ណោះបានឈរនៅលើទីផ្សារ ហើយកាន់កាប់ការត្រួតត្រាទីផ្សារ ។ របបផ្តាច់មុខពីរនាក់ ច្រើនកើតមានក្នុងប្រទេសឧស្សាហកម្ម ។

ក្នុងសេដ្ឋកិច្ចទីផ្សារ គេឃើញមានគំរូ 2 យ៉ាងនៃរបបផ្តាច់មុខពីរនាក់ គឺគំរូកួរណុត (Cournot) និងគំរូប៊ឺត្រែន (Bertrand) ដូចខាងក្រោម

- **គំរូកួរណុត :** សហគ្រាសទាំងពីរបានធ្វើកិច្ចសន្យាជាមួយគ្នាថានឹងផលិតទំនិញក្នុងបរិមាណណាមួយ ដែលមានកំណត់ក្នុងកិច្ចសន្យា ហើយក៏បានអនុវត្តយ៉ាងត្រឹមត្រូវ ។
- **គំរូប៊ឺត្រែន :** សហគ្រាសទាំងពីរចូលប្រឡូកក្នុងល្បែងមួយ ។ ម្នាក់ៗសន្មតថា ដៃគូរបស់ខ្លួនមិនបញ្ចុះថ្លៃផលិតផលរបស់ខ្លួនទេ ទោះជាផលិតផលនោះធ្លាក់ថ្លៃក៏ដោយ ។ នៅពេលដែលអ្នកទាំងពីរគោរពគោលការណ៍នេះបាន ថ្លៃផលិតផលក៏ស្ថិតនៅថេរជាទូទៅក្នុងទីផ្សារ ។

ផលិតផលលក់ផ្តាច់មុខពីរនាក់ដែលគេឃើញមានជាទូទៅក្នុងពិភពលោកមានដូចជា

- ប័ណ្ណឥណទានអេឡិចត្រូនិចវីសានិងម៉ាស្ទ័រកាត (Visa and Master card) ដែលគ្របដណ្តប់មួយភាគធំនៃការចាយវាយតាមប្រព័ន្ធអេឡិចត្រូនិចនៅក្នុងទីផ្សារក្នុងពិភពលោក ។

- ប៉ិបស៊ីនិងកូកាកូឡា (Pepsi and Coca-cola) ដែលអាចចរាចរក្នុងទីផ្សារភេសជ្ជៈ ។
- អ៊ែរប៊ីសនិងប៊ូអ៊ីង (Airbus and Boeing) នៅក្នុងទីផ្សារពាណិជ្ជកម្មយន្តហោះ ។
- កូដាកនិងហ្វូជីហ្វីម (Kodak and Fuji film) នៅក្នុងទីផ្សារហ្វីលពណ៌ ។
- កាណុងនិងនីកុង (Canon and Nikon) នៅក្នុងទីផ្សារឧបករណ៍ថតរូប ។ល ។

របបផ្តាច់មុខពីរនាក់ មិនមែនកើតមានក្នុងទីផ្សារផលិតផលប៉ុណ្ណោះទេ គឺគេឃើញកើតមានក្នុងការប្រកួតប្រជែងផ្តាច់មុខផ្នែកនយោបាយ(ឧ. មានគណបក្សធំៗពីរលេចធ្លោ) ផ្នែកប្រព័ន្ធផ្សាយព័ត៌មាន(ឧ. នៅប្រទេសហ្វាំងឡង់ពីឆ្នាំ 1950 ដល់ 1993 រដ្ឋបានកាន់កាប់ដោយផ្តាច់មុខនិងស្របច្បាប់នូវក្រុមហ៊ុនវិទ្យុ Yleisradio និងក្រុមហ៊ុនទូរទស្សន៍ Mainos.TV ) និងផ្នែកផលិតទំនិញ 2 មុខរបស់សហគ្រាសតែមួយផងដែរ (ឧ. នៅសហរដ្ឋអាមេរិក ឧស្សាហកម្មផលិតវិទ្យុនិងទូរទស្សន៍ផ្តាច់មុខជាកម្មសិទ្ធិរបស់ម្ចាស់តែមួយ) ។

## 2.2. របបរួមគ្នាផ្តាច់មុខ

ការរួមគ្នាផ្តាច់មុខជារចនាសម្ព័ន្ធទីផ្សារដែលមានក្រុមហ៊ុនតែមួយចំនួនប៉ុណ្ណោះ ។ លក្ខណៈសម្គាល់ដ៏សំខាន់នៃការរួមគ្នាលក់ផ្តាច់មុខនេះ គឺភាពអាស្រ័យគ្នាទៅវិញទៅមកពិតៗ ឬជាក់ស្តែងក្នុងចំណោមសហគ្រាសទាំងនេះ មានដូចជាឧស្សាហកម្មរថយន្តនិងយន្តហោះជាដើម ។ ការរួមគ្នាផ្តាច់មុខ កើតមានដោយសារការដាក់កំហិតដោយច្បាប់ ដូចជាការកំណត់សិទ្ធិចម្លង ពន្ធអាករ ការកំណត់បរិមាណផលិតផលជាដើម ។

*ឧទាហរណ៍ :* ក្រុមហ៊ុនដែកថែបធំៗមួយចំនួនតូច បានគ្រប់គ្រងរ៉ែដែកដ៏ច្រើនក្នុងសហរដ្ឋអាមេរិក ។

ការរួមគ្នាផ្តាច់មុខជាទ្រង់ទ្រាយរចនាសម្ព័ន្ធដែលមានជាទូទៅក្នុងសេដ្ឋកិច្ចទីផ្សារ ដោយមានធាតុជារបបផ្តាច់មុខតែម្នាក់ឯងផងនិងជាការប្រកួតប្រជែងពេញលេញផង ។ មានសហគ្រាសជាច្រើនបានចូលរួមក្នុងការប្រកួតប្រជែងផ្តាច់មុខនេះ ដោយអ្នកលក់នីមួយៗមានភាពងាយស្រួលក្នុងការចូលនិងចេញពីទីផ្សារ ហើយម្នាក់ៗមានឥទ្ធិពលខ្លះទៅលើថ្លៃនៃផលិតផលរបស់ខ្លួន ពីព្រោះគេអាចធ្វើឱ្យអ្នកទិញជឿថា ផលិតផលរបស់គេខុសៗគ្នានិងខុសពីផលិតផលរបស់គូប្រជែងរបស់ខ្លួន ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys

# 3. របបលក់ផ្តាច់មុខ ឬរបបម៉ូណូប៉ូល

របបលក់ផ្តាច់មុខ គឺសិទ្ធិពិសេសរបស់បុគ្គល សហគ្រាស ឬស្ថាប័នសាធារណៈក្នុងការផលិត ការលក់ ឬធ្វើអាជីវកម្មទៅលើទំនិញ ឬសេវាណាមួយ ។ របបលក់ផ្តាច់មុខមិនស្ថិតក្នុងរង្វង់រចនាសម្ព័ន្ធទីផ្សារទេ ។

របបលក់ផ្តាច់មុខ កើតមាននៅពេលដែលមានអ្នកលក់តែម្នាក់គត់ចំពោះផលិតផល ដោយគ្មានទំនិញជំនួស ។ ដោយសារមានការដាក់កំហិតក្នុងការនាំចេញ ឬនាំចូលទំនិញក្នុងទីផ្សារ ប្រជាជនគ្រប់គ្នាត្រូវទិញផលិតផលពីអ្នកលក់ផ្តាច់មុខតែម្នាក់ ។ ក្នុងករណីនេះ អ្នកលក់ផ្តាច់មុខមានអំណាចកំណត់ថ្លៃតាមចំណង់របស់ខ្លួនក្នុងការលក់ទំនិញ ពោលគឺគាត់ជាអ្នកកំណត់ថ្លៃ ។

## 3.1. ប្រភពអំណាចនៃរបបលក់ផ្តាច់មុខ

ការលក់ផ្តាច់មុខអាចកើតឡើងដោយសារសហគ្រាសមួយមានលក្ខណសម្បត្តិដូចខាងក្រោម

- មានការគ្រប់គ្រងកត្តាផលិតកម្ម ឬវត្ថុធាតុដើមផ្តាច់មុខតែឯង ។
- មានសិទ្ធិស្របច្បាប់ ដូចជាប័ណ្ណប៉ាតង់ សិទ្ធិចម្លង ឬការទិញសិទ្ធិផ្តាច់មុខពីផលិតករដទៃជាដើម ។
- មានឧត្តមភាពសេដ្ឋកិច្ច ពោលគឺមានមូលធនច្រើនដាច់គេសម្រាប់ធ្វើការដាក់ទុនវិនិយោគ ។ ប្រទេសកម្ពុជាមានឧត្តមភាពសេដ្ឋកិច្ចផ្នែករមណីយដ្ឋានធម្មជាតិសុទ្ធសាធដូចជាទេសភាពព្រៃភ្នំ ទន្លេ បឹង ទឹកជ្រោះជាដើមដែលអាចបង្កើតរមណីយដ្ឋានទេសចរណ៍ធម្មជាតិបន្ថែមទៀត ។ កន្លងមក ប្រទេសកម្ពុជាមានរមណីយដ្ឋានទឹកជ្រោះនៅខេត្តរតនគិរី មណ្ឌលគិរី និងនៅខេត្តដទៃទៀត រមណីយដ្ឋានឆ្នេរសមុទ្រនៅខេត្តកែបនិងខេត្តព្រះសីហនុ ប្រាសាទបូរាណនៅខេត្តសៀមរាប បាត់ដំបង និងខេត្តផ្សេងៗទៀតជាដើម ។
- មានគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការផ្តល់សិទ្ធិលក់ផ្តាច់មុខក្នុងទីផ្សារ ។

ទោះបីក្នុងការលក់ផ្តាច់មុខត្រូវគេមើលឃើញថា អ្នកលក់បានយកចិត្តទុកដាក់ចំពោះអតិថិជនយ៉ាងណាក៏ដោយ ក៏ការលក់ផ្តាច់មុខនេះអាចបង្កើតគុណវិបត្តិដល់អតិថិជនផងដែរ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## 3.2. គុណវិបត្តិនៃការលក់ផ្តាច់មុខ

### ក. លទ្ធភាពមានឥទ្ធិពលលើថ្លៃផលិតផល

ដោយសារគ្មានអ្នកលក់ផ្សេងទៀតអាចចូលក្នុងទីផ្សារបាន អ្នកលក់ផ្តាច់មុខអាចកំណត់ឱ្យបរិមាណផលិតផលរបស់ខ្លួនទាបជាងបរិមាណតម្រូវការរបស់អតិថិជន ។ ក្នុងករណីធ្វើបានដូចនេះ អ្នកលក់ផ្តាច់មុខអាចដំឡើងថ្លៃផលិតផលតាមចិត្តរបស់ខ្លួន ដើម្បីបានប្រាក់ចំណេញលើសពីធម្មតា ។

ករណីខ្លះទៀត អ្នកលក់ផ្តាច់មុខអាចលក់ទំនិញរបស់ខ្លួនដោយតម្លៃខុសគ្នាទៅឱ្យអតិថិជនផ្សេងគ្នា ។ រូបភាពបែបនេះហៅថា**ការលក់ផ្តាច់មុខរើសមុខ** ។

### ខ. លទ្ធភាពមានឥទ្ធិពលលើតម្រូវការ

តាមធម្មតា តម្រូវការលើទំនិញស្ថិតនៅក្រោមឥទ្ធិពលថ្លៃ ប្រាក់ចំណូលរបស់អ្នកប្រើប្រាស់និងថ្លៃលើមុខទំនិញដទៃទៀត ។ ជាទូទៅ នៅពេលដែលទំនិញឡើងថ្លៃ អ្នកប្រើប្រាស់តែងកាត់បន្ថយតម្រូវការរបស់ខ្លួន ហើយនៅពេលដែលទំនិញចុះថ្លៃ អ្នកប្រើប្រាស់តែងបង្កើនតម្រូវការរបស់ខ្លួន ។ ក្នុងករណីមានការលក់ផ្តាច់មុខ តម្រូវការរបស់អ្នកប្រើប្រាស់មិនមានកំណើនទេ ហើយគេត្រូវទូទាត់ថ្លៃទំនិញខ្ពស់ជាងថ្លៃទំនិញដូចគ្នាក្នុងទីផ្សារប្រកួតប្រជែង ។

### គ. ការប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចទាំងមូល

ការឡើងថ្លៃទំនិញណាមួយតាមរយៈការលក់ផ្តាច់មុខ អាចធ្វើឱ្យប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចទាំងមូល ។

*ឧទាហរណ៍ :* ការដំឡើងថ្លៃប្រេងដោយវិធីផ្គត់ផ្គង់ប្រេងឥន្ធនៈផ្តាច់មុខធ្វើឱ្យទំនិញដទៃទៀតក៏ឡើងថ្លៃដែរ ។




*ក្រាហ្វិកនៃការផ្គត់ផ្គង់ប្រេងឥន្ធនៈផ្តាច់មុខ*

ទោះយ៉ាងណាក៏ដោយគឺមានតែរដ្ឋទេដែលមានមធ្យោបាយមួយចំនួនសម្រាប់គ្រប់គ្រងនិងធ្វើនិយ័តកម្មលើអ្នកលក់ផ្តាច់មុខ ដើម្បីធានាថាអ្នកលក់ផ្តាច់មុខមិនអាចបំពានឬកាត់បន្ថយបរិមាណផ្គត់ផ្គង់ឬបន្ថយគុណភាពទំនិញបានឡើយ ។

## សំណួរ

1. ចូរអ្នកជ្រើសរើសមុខទំនិញ 5 មុខដែលមានលក់នៅទីផ្សារក្នុងសហគមន៍របស់អ្នក ។ បន្ទាប់មក ចូររៀបរាប់មុខទំនិញនីមួយៗ ដោយបញ្ជាក់ថា ជាទំនិញផលិតក្នុងស្រុក ឬទំនិញនាំចូល ហើយចេញពីប្រភពផលិតកម្មតែមួយ ឬផ្សេងគ្នានិងមានតម្លៃដូចគ្នា ឬខុសគ្នា ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ

   ក. ដូចម្ដេចហៅថា រចនាសម្ព័ន្ធទីផ្សារ ? តើរចនាសម្ព័ន្ធទីផ្សារមានអ្វីខ្លះ ?

   ខ. ដូចម្ដេចហៅថាការប្រកួតប្រជែងពេញលេញ ? ចូរពន្យល់ ។

   គ. ដូចម្ដេចហៅថាការប្រកួតប្រជែងមិនពេញលេញ ? ចូរពន្យល់ ។

   ឃ. តើរបបលក់ផ្ដាច់មុខ ជារចនាសម្ព័ន្ធទីផ្សារឬទេ ? ហេតុអ្វី ?

   ង. តើអំណាចនៃរបបលក់ផ្ដាច់មុខមានប្រភពពីណា ?

   ច. តើរបបលក់ផ្ដាច់មុខមានគុណវិបត្តិអ្វីខ្លះ ? ចូរពន្យល់ ។
3. ចូរអ្នកអានអត្ថបទនិងដកស្រង់ចំណុចសំខាន់ៗដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ក្នុងរចនាសម្ព័ន្ធទីផ្សារ រវាងការប្រកួតប្រជែងពេញលេញនិងការប្រកួតប្រជែងមិនពេញលេញ តើការប្រកួតប្រជែងប្រភេទណា ដែលផ្ដល់ផលប្រយោជន៍ច្រើនជាងដល់អ្នកប្រើប្រាស់ ? ចូរពន្យល់ និងផ្ដល់ឧទាហរណ៍ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 6 គ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ការរៀបចំយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី ។
- ពន្យល់ផលប្រយោជន៍នៃការរីកចម្រើននៃយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី ។
- បង្ហាញអត្ថប្រយោជន៍នៃការស្ថាបនាមូលដ្ឋានសម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងការបណ្តុះបណ្តាលធនធានមនុស្ស ។



*ការចាប់ឡានដឹកឈើខុសច្បាប់*

ផ្អែកលើចរិតលក្ខណៈរួមនៃប្រព័ន្ធសេដ្ឋកិច្ចនៅកម្ពុជានិងនិន្នាការរីកចម្រើនតាមដំណើរនៃសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន គេត្រូវសិក្សាថា តើកិច្ចការសំខាន់ៗនៃការកសាងនិងពង្រឹងគ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជាមានអ្វីខ្លះ ? ហើយតើវាជាបន្ទុករបស់ផ្នែកឯកជន ឬរបស់រដ្ឋ ?

# 1. ការរៀបចំយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី

## 1.1. ធម្មជាតិនៃយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ច

យន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ច គឺជាបាតុភូតសេដ្ឋកិច្ច ប៉ុន្តែវាជាផ្នែកមួយនៃបាតុភូតវប្បធម៌ ប្រពៃណី សីលធម៌ និងចិត្តសាស្ត្រ ។ សម្រាប់ប្រទេសដែលមានប្រព័ន្ធសេដ្ឋកិច្ចមិនសូវរីកចម្រើន យន្តការសេដ្ឋកិច្ចទីផ្សារសេរីមិនគ្រាន់តែជាបាតុភូតសេដ្ឋកិច្ចថ្មីប៉ុណ្ណោះទេ តែវាមានលក្ខណៈជាវប្បធម៌ថ្មី របៀបរស់នៅថ្មី សីលធម៌នៃការរស់នៅថ្មី និងចិត្តសាស្ត្រសង្គមថ្មីថែមទៀតផង ។

*ឧទាហរណ៍ :* នៅពេលដែលសេដ្ឋកិច្ចទីផ្សារសេរីមិនទាន់កើតមាន ទំនិញនៅទីផ្សារក៏មិនទាន់មានភាពសម្បូរបែប ហើយក៏មិនទាន់ធានាបាននូវគុណភាពតាមសេចក្តីត្រូវការរបស់អតិថិជនដែរ ។ ឯអ្នកផលិត ច្រើនផលិតតាមការបញ្ជាទិញរបស់រដ្ឋ ហើយក៏មិនមានចិត្តកែច្នៃផលិតផលទៅរកគុណភាពប្រសើរជាងមុនដែរ ។ លុះសេដ្ឋកិច្ចទីផ្សារកើតមានឡើង បញ្ហាខាងលើក៏មានភាពប្រែប្រួលខុសពីមុន ដោយហេតុមានការប្រកួតប្រជែងលើទីផ្សារ ។

## 1.2. បញ្ហារៀបចំយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី




*ស្ថាប័នរដ្ឋសភា*

ការអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីនៅក្នុងប្រទេសនិងការធ្វើឱ្យមានយន្តការនេះ  មានដំណើរការប្រកបដោយជោគជ័យ  តែងអាស្រ័យលើសក្តានុពលប្រភពធនធាននិងកម្លាំងចលករជាក់ស្តែងនៃប្រទេស ។

ការរៀបចំយន្តការសម្រាប់រចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី គឺជាការកែប្រែមួយដែលប៉ះពាល់ដល់គ្រប់ផ្នែកនៃជីវភាពសង្គម ទាំងសេដ្ឋកិច្ច នយោបាយ ច្បាប់ វប្បធម៌ សីលធម៌ ចិត្តសាស្ត្រ ។ល ។ ដើម្បីសម្រេចបាននូវភារកិច្ចនេះ ទាមទារឱ្យរដ្ឋមាន

- កម្មវិធីច្បាស់លាស់សម្រាប់អនុវត្តន៍រយៈពេលយូរអង្វែង ។
- ការជំរុញឱ្យយន្តការសេដ្ឋកិច្ចទីផ្សារកើតមានឡើងនិងប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- ការកែប្រែជីវភាពថ្មីរបស់ប្រជាកសិករនៅតំបន់ជនបទដ៏ធំធេងនៃប្រទេសកម្ពុជា ។

ការងារនេះអាចសម្រេចបានតាមរយៈការអនុវត្តកម្មវិធីអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រជាជំហានៗរបស់រាជរដ្ឋាភិបាលស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចពិភពលោក ។



## 2. យន្តការជាមូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី

ការរៀបចំយន្តការសម្រាប់រចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី ត្រូវផ្សារភ្ជាប់ទៅនឹងការកសាងមូលដ្ឋានសម្រាប់ការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធថ្មីនេះ ពោលគឺត្រូវកសាងមជ្ឈដ្ឋានមីក្រូនិងម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ វប្បធម៌ អភិបាលកិច្ច ចិត្តសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់យន្តការនោះ ។



*មជ្ឈមណ្ឌលអគារពាណិជ្ជកម្មទំនើប*

ក្នុងដំណាក់កាលដំបូងនៃការកសាងមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ត្រូវមានការងាររៀបចំបរិបទទូទៅមួយ សម្រាប់ឱ្យប្រព័ន្ធសេដ្ឋកិច្ចថ្មីមានដំណើរការនិងរីកលូតលាស់បាន ។

ការងារនេះ មានពាក់ព័ន្ធនឹង

- បញ្ហាស្ថេរភាវូបនីយកម្មស្ថានភាពសេដ្ឋកិច្ចនិងនយោបាយ ។
- ការកសាងធនធានមនុស្សនៅក្នុងប្រទេសតាមការរីកចម្រើននៃបច្ចេកវិទ្យាថ្មី ។
- ការកែលំអប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនិងពង្រឹងអភិបាលកិច្ចល្អ ។
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារធនធានធម្មជាតិ ។
- ការកែលំអប្រព័ន្ធសេដ្ឋកិច្ចនិងពាណិជ្ជកម្ម (តាមសមាគមពាណិជ្ជកម្មពិភពលោក WTO) ។
- ការរៀបចំនិងកែលំអប្រព័ន្ធច្បាប់វិនិយោគសាធារណៈជាដើម ដើម្បីឱ្យសមស្របតាមយន្តការទីផ្សារសេរី ។

youtube.com/moeys
facebook.com/moeys.gov.kh

ក្នុងករណីដែលគ្មានមូលដ្ឋានសមស្របសម្រាប់ដំណើរការរីកលូតលាស់នៃយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មីទេ ការអនុវត្តយន្តការសេដ្ឋកិច្ចទីផ្សារសេរីគឺវាមិនគ្រាន់តែមិនផ្តល់ផលប្រយោជន៍ឱ្យសង្គមប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចនាំមកនូវផលវិបាកប្រកបដោយគ្រោះថ្នាក់ដ៏ច្រើនដល់សង្គមទៀតផង ។ *ឧទាហរណ៍* ប្រសិនបើមានបញ្ហាខ្វះធនធានមនុស្សនិងខ្វះបច្ចេកទេសថ្មី នោះនឹងនាំឱ្យកើតមានបញ្ហាកង្វះផលិតផលឬផលិតផលខ្វះគុណភាព ដែលជាហេតុតម្រូវឱ្យមានការនាំចូលទីផ្សារឬនាំឱ្យមានការនាំចូលច្រើនជាងការនាំចេញ ដែលជាហេតុនាំឱ្យបាត់តុល្យភាពជញ្ជីងពាណិជ្ជកម្មក្នុងប្រទេស ។ ម្យ៉ាងទៀត ក្នុងករណីមានការប្រកួតប្រជែងដណ្តើមធនធានផលិតកម្ម ដោយគ្មានកិច្ចអន្តរាគមន៍តាមផ្លូវច្បាប់នោះនឹងនាំឱ្យសង្គមជួបគ្រោះបាត់បង់ធនធានធម្មជាតិ (ដូចជារ៉ែ ព្រៃឈើជាដើម) ដោយមិនអាចរកខុសត្រូវចំពោះអ្នករំលោភបំពានបានឡើយ ។

ដូចនេះ លុះត្រាតែមានការកសាងមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ទើបធានាបាននូវការរីកចម្រើននៃសេដ្ឋកិច្ចថ្មី ។

## 3. ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធនិងធនធានមនុស្ស

### 3.1. តួនាទីនៃហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងធនធានមនុស្សគឺជាគ្រោងឆ្អឹង ជាសរសៃឈាមនិងជាសាច់ដុំនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ។ វាជាមូលដ្ឋានបង្អែកនៃប្រព័ន្ធសេដ្ឋកិច្ចថ្មីនិងជាបណ្តាញតភ្ជាប់បណ្តាកត្តាផលិតកម្មរបស់ភ្នាក់ងារសេដ្ឋកិច្ចនានា ដើម្បីធានាបាននូវសមាហរណកម្មផ្ទៃក្នុងនៃប្រព័ន្ធសេដ្ឋកិច្ចនិងជាកម្លាំងចលករជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិផង ។

### 3.2. កិច្ចការចំពោះមុខ

កិច្ចការនេះ ត្រូវការការរៀបចំនិងបណ្តុះបណ្តាលធនធានមនុស្សឱ្យបានច្រើន និងមានសមត្ថភាពស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ ដើម្បីឱ្យគេចេះគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិឱ្យចំទិសនិងមានប្រសិទ្ធភាព ។ គួរកត់សម្គាល់ថា ការងារបណ្តុះបណ្តាលធនធានមនុស្សជាការងារយូរអង្វែង ព្រោះគ្មាននរណាម្នាក់អាចរកបានឬផ្តល់នូវប្រភពធនធានចាំបាច់និងគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ប្រទេសកម្ពុជាបច្ចុប្បន្នក្នុងរយៈពេលដ៏ខ្លីបានឡើយ ជាពិសេសការរកបានធនធានមនុស្សដែលមានសមត្ថភាពសមស្របសម្រាប់បម្រើសេចក្តីត្រូវការនៃការស្តារនិងកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចថ្មីរបស់ប្រទេស ។

ធនធានមនុស្សជាធនធានដ៏កម្រមួយ ដែលអាចបង្កើតបានតាមរយៈការអប់រំបណ្តុះបណ្តាលថែបំប៉នដ៏យូរអង្វែង ។ កន្លងមក ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រសេដ្ឋកិច្ចច្បាស់លាស់ ដោយឈរលើមូលដ្ឋាននៃការធ្វើវិចារណកម្ម ការប្រើប្រាស់ធនធានក្នុងនិងក្រៅប្រទេស មានដូចជា គោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាជាដើម ។

## 3.3. យថាទស្សន៍នៃការងារកសាងនិងពង្រឹងគ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា

តាមរយៈការវិភាគលើខ្លឹមសារនៃការងារកសាងនិងពង្រឹងគ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជាកន្លងមក គេអាចសន្និដ្ឋានបានថា ប្រទេសកម្ពុជានឹងទទួលជោគជ័យលើការងារកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចដូចបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបនិងនៅសហរដ្ឋអាមេរិកដែរ ក្នុងករណីរដ្ឋដើរតួយ៉ាងសំខាន់ក្នុងការរៀបចំគ្រឹះសេដ្ឋកិច្ចទីផ្សារ ព្រោះថា



*ការសាងសង់ក្នុងទីក្រុង*

- ភាពអន់ថយនៃរបៀបផលិតពឹងផ្អែកលើធម្មជាតិក្នុងផ្នែកកសិកម្មនិងភាពប្រែប្រួលនៃលក្ខខណ្ឌធម្មជាតិ ដែលមាននៅក្នុងប្រទេស ទាមទារឱ្យរដ្ឋដើរតួនាទីដឹកនាំយ៉ាងសំខាន់ក្នុងជីវិតសេដ្ឋកិច្ចជាតិ ។ តាមបទពិសោធនៃការដឹកនាំរបស់រដ្ឋនាសម័យនគរ ការរៀបចំនយោបាយទឹកបានបម្រើឱ្យវិស័យកសិកម្មមានការលូតលាស់ ។

- ចរិតឯកវប្បកម្មនិងភាពអន់ថយនៃទំនាក់ទំនងទីផ្សារនៅក្នុងប្រទេស ក៏ទាមទារឱ្យរដ្ឋរៀបចំនិងធ្វើអន្តរាគមន៍ក្នុងការពង្រឹងសេដ្ឋកិច្ចដើម្បីធានានូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងសមាហរណកម្មផ្ទៃក្នុងនៃប្រព័ន្ធសេដ្ឋកិច្ចជាតិ ។
- ភាពខ្ទេចខ្ទាំនិងក្រខ្សត់នៃសេដ្ឋកិច្ចជាតិ ទាមទារឱ្យមានការស្តារឡើងវិញគ្រប់ជ្រុងជ្រោយនិងគ្រប់វិស័យ ពិសេសការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត ព្រមទាំងការបណ្តុះបណ្តាលធនធានមនុស្ស ។ ដោយសារការងារនេះត្រូវការនូវប្រភពធនធានដ៏ធំធេង ដែលសមាសភាពសេដ្ឋកិច្ចឯកជនពុំអាចមានលទ្ធភាពបំពេញបាន រដ្ឋត្រូវដើរតួនាទីជាគន្លឹះក្នុងការដោះស្រាយបញ្ហាទាំងនេះផងដែរ ។
- ផ្នែកឯកជននៅខ្សោយ ទាមទារឱ្យរដ្ឋធ្វើការកំណត់ទិសនិងមានផែនការមេរយៈពេលយូរសម្រាប់ធ្វើការអភិវឌ្ឍផ្នែកឯកជន មានការបង្កើតច្បាប់ការពារប្រយោជន៍ឯកជន ការលើកទឹកចិត្តដល់សហគ្រិនក្នុងការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចនិងទីផ្សារជាដើម ។ ក្នុងនោះដែរ រដ្ឋត្រូវមានការធានារកទីផ្សារសម្រាប់នាំចេញផលិតផលដែលផលិតបាន តាមរយៈការពង្រឹងសហប្រតិបត្តិការជាមួយប្រទេសនានា ។
- ភាពមិនទាន់សុក្រឹតនៃបរិស្ថានដែលជួយដល់ការប្រព្រឹត្តនិងការរីកលូតលាស់នៃយន្តការសេដ្ឋកិច្ចទីផ្សារសេរី ទាមទារឱ្យរដ្ឋយកចិត្តទុកដាក់កសាងឡើងវិញនិងកែលំអក្នុងផ្នែកជាច្រើនទាំងផ្នែករចនាសម្ព័ន្ធនៃស្ថាប័នរដ្ឋបាល ទាំងផ្នែកសេវាកម្ម និងទាំងផ្នែកទ្រទ្រង់នានា ។ល ។ ដើម្បីឱ្យផ្នែកឯកជនរីកលូតលាស់បានល្អ ។
- ផ្នែកឯកជននិងផ្នែករដ្ឋ ពុំទាន់មានទំនាក់ទំនងជាគូសន្ទនានឹងគ្នានៅឡើយ ។ បញ្ហានេះទាមទារឱ្យរដ្ឋកសាងប្រព័ន្ធយន្តការការងារមួយ ដែលមានរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នារវាងរដ្ឋនិងឯកជន ។

បទពិសោធប្រកបដោយជោគជ័យក្នុងការកសាងនិងពង្រីកមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីនៅបណ្តាប្រទេសមួយចំនួនក្នុងទ្វីបអាស៊ីដូចជា ជប៉ុន សិង្ហបុរី តៃវ៉ាន់ ជាដើម ក៏បានបង្ហាញឱ្យឃើញថា ដើម្បីធានានូវប្រសិទ្ធភាពការងារនៅក្នុងដំណើរការដ៏លំបាកស្មុគស្មាញនេះ រដ្ឋត្រូវប្រកាន់យកនូវតួនាទីដ៏សំខាន់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។

## 4. សន្និដ្ឋាន

ក្នុងដំណាក់កាលដំបូងនៃការកសាងគ្រឹះសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ និងការបណ្តុះបណ្តាលធនធានមនុស្ស ។

## សំណួរ

1. នៅសហគមន៍ដែលអ្នករស់នៅ តើអ្នកសង្កេតឃើញថាអ្នកប្រកបការងារអាជីវកម្មផ្សេងៗមានជួបប្រទះនឹងបញ្ហាអ្វីខ្លះ ? តើអ្នកគិតថាស្ថាប័នរដ្ឋ ឬឯកជន ដែលមានតួនាទីដោះស្រាយបញ្ហាទាំងនោះ ? ចូរប្តូរយោបល់ជាមួយមិត្ត ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ
   ក. តើយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាអ្វី ?
   ខ. អ្វីទៅជាការរៀបចំយន្តការសម្រាប់រចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី ?
   គ. តើរដ្ឋត្រូវមានភារកិច្ចរៀបចំអ្វីខ្លះក្នុងដំណាក់កាលដំបូងនៃការកសាងមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ?
   ឃ. តើអ្វីជាគ្រោងឆ្អឹង សរសៃឈាម និងជាសាច់ដុំនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ?
   ង. តើអ្វីជាកិច្ចការចំពោះមុខ ក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ? ចូរពន្យល់ ។
   ច. តើប្រទេសកម្ពុជាបច្ចុប្បន្ននេះ នឹងអាចសម្រេចបានលើការងារកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចដូចបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបនិងសហរដ្ឋអាមេរិកដែរឬទេ ? ហេតុអ្វី ?
3. ចូរអ្នកអានអត្ថបទនិងដកស្រង់ចំណុចសំខាន់ៗដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ក្នុងការកសាងគ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា រដ្ឋបានដើរតួនាទីយ៉ាងសំខាន់និងបានបំពេញសកម្មភាពការងារជាច្រើនតាំងពីពេលកន្លងមករហូតដល់បច្ចុប្បន្ន ។ ចូរអ្នកធ្វើការដកស្រង់និងរៀបរាប់ឡើងវិញនូវសកម្មភាពជាក់ស្តែងរបស់រដ្ឋដែលបានអនុវត្តនៅសហគមន៍ដែលអ្នករស់នៅ ឬដែលអ្នកបានឃើញនៅតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 7 កម្មសិទ្ធិឯកជននិងសេរីភាពក្នុងការជ្រើសរើស

**ចប់មេរៀននេះ សិស្សអាច**

- ឱ្យនិយមន័យ កម្មសិទ្ធិឯកជន ។
- រៀបរាប់គោលដៅនៃការប្រើប្រាស់កម្មសិទ្ធិឯកជន ។
- រៀបរាប់សារៈសំខាន់នៃសេរីភាពនិងការជ្រើសរើសរបស់សហគ្រិន ។
- រៀបរាប់សារៈសំខាន់នៃសេរីភាពនិងការជ្រើសរើសរបស់កម្លាំងពលកម្មនិងអ្នកប្រើប្រាស់ ។
- ឱ្យនិយមន័យ ការប្រកួតប្រជែងនិងបង្ហាញតួនាទីរបស់វា ។
- ឱ្យតម្លៃការផ្តល់សេរីភាពនិងសិទ្ធិជ្រើសរើសក្នុងសេដ្ឋកិច្ចទីផ្សារ ។

លក្ខខណ្ឌនៃសេដ្ឋកិច្ចទីផ្សារតែងផ្សារភ្ជាប់ទៅនឹងកម្មសិទ្ធិឯកជននិងសេរីភាពក្នុងការជ្រើសរើស ។

## 1. កម្មសិទ្ធិឯកជន

ក្នុងការប្រកបរបរអាជីវកម្ម ម្ចាស់អាជីវកម្មតែងតែចង់បានសេរីភាពធ្វើជាម្ចាស់កម្មសិទ្ធិ ដើម្បីគ្រប់គ្រងផលិតផលដែលគេបានផលិតឡើងដើម្បីគេអាចស្វែងរកប្រាក់ចំណូលឱ្យបានកាន់តែច្រើន ។

កម្មសិទ្ធិឯកជន ក្នុងន័យសេដ្ឋកិច្ចមានន័យថា ការយកមកធ្វើជារបស់ខ្លួននូវមធ្យោបាយផលិតកម្មនិងទ្រព្យសម្ភារៈដែលផលិតបាន ។ ការប្រើប្រាស់កម្មសិទ្ធិឯកជនត្រូវមានគោលការណ៍ដូចខាងក្រោម

### 1.1. សេរីភាពរបស់ម្ចាស់កម្មសិទ្ធិ

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ធនធានសម្ភារៈស្ទើរតែទាំងអស់ជាកម្មសិទ្ធិឯកជនរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ហើយធនធានសម្ភារៈមួយផ្នែកទៀតជាកម្មសិទ្ធិសាធារណៈ ។ កម្មសិទ្ធិឯកជន តែងផ្សារភ្ជាប់ជាមួយនឹងសេរីភាពគ្រប់យ៉ាងរបស់ម្ចាស់កម្មសិទ្ធិ ពោលគឺ ម្ចាស់កម្មសិទ្ធិមានសេរីភាពពេញលេញក្នុងការទិញ ឬលក់ ត្រួតពិនិត្យ ប្រើប្រាស់ ឬផ្លាស់ប្តូរធនធានសម្ភារៈដែលជាកម្មសិទ្ធិរបស់ខ្លួនក្នុងគោលបំណងស្វែងរកប្រាក់ចំណូលសម្រាប់បំពេញសេចក្តីត្រូវការរបស់គេ ។ ជាមួយគ្នានេះ រដ្ឋជាអ្នក

ទទួលស្គាល់និងធានាការពារសិទ្ធិក្នុងការគ្រប់គ្រង ប្រើប្រាស់ ឬការផ្ទេរកម្មសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិ ។ បន្ថែមលើនេះ រដ្ឋជាអាជ្ញាកណ្ដាល ជាអ្នកពិន័យ ឬលើកទឹកចិត្តដល់ភ្នាក់ងារសេដ្ឋកិច្ចទាំងឡាយ ។

### 1.2. ព្រំដែនសេរីភាពរបស់ម្ចាស់កម្មសិទ្ធិ

ស្របនឹងសេរីដ៏ទូលំទូលាយក្នុងការប្រើប្រាស់កម្មសិទ្ធិឯកជន ក៏មានការកំណត់ខ្លះដែរចំពោះការប្រើប្រាស់ធនធានកម្មសិទ្ធិណាមួយដែលនាំឱ្យប៉ះពាល់ដល់បរិស្ថានសង្គមនិងបរិស្ថានធម្មជាតិ ។ *ឧទាហរណ៍* ការប្រើប្រាស់ម៉ាស៊ីនធំៗដែលលាន់ឮរំពងបង្កការរំខានដល់អ្នករស់នៅជុំវិញត្រូវមានការដោះស្រាយ កាកសំណល់ស្អុយរលួយឬកាកសំណល់ជាតិគីមីផ្សេងៗត្រូវបានហាមឃាត់មិនឱ្យបង្ហូរចូលក្នុងស្ទឹង ទន្លេ សមុទ្រ ...ឡើយ ។

### 1.3. ប្រសិទ្ធភាពក្នុងការហាមឃាត់

ទោះស្ថិតក្នុងសេដ្ឋកិច្ចទីផ្សារសេរីក៏ដោយ រដ្ឋត្រូវតែគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិលើធនធានសេដ្ឋកិច្ចសាធារណៈមួយចំនួនជាចាំបាច់ ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពការប្រើប្រាស់ធនធានសេដ្ឋកិច្ចទាំងនោះដោយមានលក្ខខណ្ឌ ។ *ឧទាហរណ៍* ដើម្បីជំរុញការទប់ស្កាត់ការកាប់ព្រៃឈើឱ្យមានប្រសិទ្ធភាព ព្រៃឈើត្រូវតែជាកម្មសិទ្ធិរបស់រដ្ឋ ។ ដើម្បីជំរុញការងារអប់រំនៅសាលារៀនសាធារណៈឱ្យមានគុណភាព សាលារៀននិងគ្រូបង្រៀនត្រូវតែជាកម្មសិទ្ធិនិងជាបុគ្គលិករបស់រដ្ឋ ។

## 2. សេរីភាពក្នុងការជ្រើសរើស

### 2.1. សេរីភាពនិងការជ្រើសរើសរបស់សហគ្រិន

ក្នុងសេដ្ឋកិច្ចទីផ្សារ សហគ្រិនត្រូវមានការសម្រេចចិត្តនិងការទទួលខុសត្រូវ ក្នុងការប្រើប្រាស់ធនធានដែលមានឱ្យមានប្រសិទ្ធភាពជាអតិបរមា តាមមធ្យោបាយនិងនីតិវិធីដែលមាននៅក្នុងរង្វង់យន្តការសេដ្ឋកិច្ចទីផ្សារ ។ ដូចនេះ ការផ្ដល់សេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសដល់សហគ្រិនមានសារៈសំខាន់ ។

ការផ្ដល់សេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសដល់សហគ្រិនជាការបង្កលក្ខណៈឱ្យ

- សហគ្រិនអាចទិញដូរដោយសេរីនូវធនធានសេដ្ឋកិច្ចសម្រាប់ចាត់ចែងនិងប្រើប្រាស់ក្នុងដំណើរការផលិតទំនិញ ឬសេវាក្នុងអាជីវកម្មរបស់ខ្លួនក្នុងនាមជាម្ចាស់កម្មសិទ្ធិ ។ *ឧទាហរណ៍* ក្នុងអាជីវកម្មបោះពុម្ព សហគ្រិនអាចទិញម៉ាស៊ីនបោះពុម្ពពីបរទេសបានដោយសេរី ដោយគ្មានការហាមឃាត់ពីរដ្ឋ ។

- សហគ្រិន មានសិទ្ធិលក់ដូរទំនិញទាំងនេះក្នុងទីផ្សារតាមតម្លៃនិងបរិមាណផលិតផល ឬសេវា ។
- សហគ្រិន មានសិទ្ធិសម្រេចចិត្តចូលធ្វើអាជីវកម្មក្នុងវិស័យណាមួយ ដែលជាផ្នែករបស់សេដ្ឋកិច្ចជាតិ ឬចាកចេញពីអាជីវកម្មនោះ ។

### 2.2. សេរីភាពក្នុងការជ្រើសរើសរបស់ម្ចាស់កម្មសិទ្ធិ កម្លាំងពលកម្ម និងអ្នកប្រើប្រាស់

សេរីភាពនិងការជ្រើសរើសមានន័យថា

- ម្ចាស់កម្មសិទ្ធិលើធនធានធម្មជាតិនិងទំនិញវិនិយោគអាចប្រើប្រាស់ ជួល ឬលក់ធនធានទាំងនោះទៅតាមការយល់ឃើញរបស់ខ្លួន ។
- អ្នកមានកម្លាំងពលកម្ម អាចព្រមព្រៀងឬមិនព្រមព្រៀងលក់កម្លាំងពលកម្មរបស់ខ្លួនដោយផ្អែកលើកម្រិតសមត្ថភាពរបស់ខ្លួនទៅតាមការសម្រេចចិត្តផ្ទាល់ខ្លួន ។
- អ្នកប្រើប្រាស់ មានសេរីភាពក្នុងការប្រើប្រាស់ក្របខណ្ឌថវិកា ឬចំណូលដែលខ្លួនមាន ដើម្បីទិញទំនិញឬសេវាកម្មក្នុងតម្លៃនិងបរិមាណដែលត្រូវនឹងបំណងរបស់ខ្លួន ។

*សម្គាល់ :* សេរីភាពរបស់អ្នកប្រើប្រាស់មានលក្ខណៈទូលំទូលាយណាស់ ដោយគ្របដណ្ដប់លើសេរីភាពរបស់ផលិតករ ពោលគឺអ្នកប្រើប្រាស់ជាអ្នកសម្រេចឱ្យផលិតករ ផលិតអ្វី ផលិតដូចម្ដេច និងផលិតចំនួនប៉ុន្មាន ។ ផលិតករនឹងមិនផលិតអ្វីដែលអ្នកប្រើប្រាស់មិនប្រាថ្នានោះទេ ។

## 3. ការប្រកួតប្រជែង

សេរីភាពនិងការជ្រើសរើស នាំមកនូវការប្រកួតប្រជែង ។

### 3.1. និយមន័យ

ក្នុងន័យសេដ្ឋកិច្ច ការប្រកួតប្រជែងគឺការប្រជែងគ្នាក្នុងការស្វែងរកទីផ្សារ វត្ថុធាតុដើម ឱកាសសម្រាប់ការបណ្ដាក់ទុនឬការរកប្រាក់ចំណេញឱ្យបានច្រើនជាអតិបរមា ។ ការប្រកួតប្រជែងអាចប្រព្រឹត្តទៅបានក្នុងករណី

- មានអ្នកលក់និងអ្នកទិញច្រើនក្នុងទីផ្សារ ។
- អ្នកលក់និងអ្នកទិញមានសេរីភាពពេញលេញ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## 3.2. តួនាទីនៃការប្រកួតប្រជែង

ការប្រកួតប្រជែងមានតួនាទីច្រើនយ៉ាង

- **ទប់ស្កាត់ការដំឡើងថ្លៃទំនិញ ឬសេវា :** ជាទូទៅ នៅពេលដែលមានអ្នកលក់និងអ្នកទិញច្រើននៅក្នុងទីផ្សារ មិនអាចមានអ្នកលក់ឬអ្នកទិញណាម្នាក់ប៉ាន់ស្មានបានត្រឹមត្រូវអំពីបរិមាណតម្រូវការឬការផ្គត់ផ្គង់លើមុខទំនិញណាមួយបានឡើយ ជាពិសេស គេមិនអាចមានឥទ្ធិពលក្នុងការកំណត់ថ្លៃទំនិញបានទេ ។

ជាធម្មតា កាលណាមុខទំនិញ ឬសេវាចាំបាច់ណាមួយមានចំនួនតិច មុខទំនិញឬសេវានោះតែងតែមានថ្លៃខ្ពស់ ។ ប៉ុន្តែក្នុងករណីមុខទំនិញឬសេវាកម្មមួយមានដាក់លក់ក្នុងចំនួនច្រើនលើទីផ្សារលើសពីសេចក្ដីត្រូវការ ផលិតករមួយចំនួនអាចពួតដៃគ្នាកាត់បន្ថយការផ្គត់ផ្គង់ ហើយបន្ទាប់ពីនោះ គេដំឡើងថ្លៃទំនិញ ឬសេវានោះ ។ បែបនេះមិនមែនជាការប្រកួតប្រជែងទេ ។

អត្ថន័យនៃការប្រកួតប្រជែង សំដៅទៅលើករណីដែលមានអ្នកលក់និងអ្នកទិញច្រើន ហើយភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ មិនអាចដំឡើងថ្លៃទំនិញ ឬសេវាបាន ។ ម្យ៉ាងវិញទៀត នៅពេលដែលមានអ្នកប្រើប្រាស់ច្រើនលើសលុបក្នុងទីផ្សារ ដោយហេតុអ្នកទាំងនោះមានចំណង់ចំណូលចិត្តដោយឡែកៗពីគ្នា គេមិនអាចប៉ាន់ប្រមាណបានអំពីស្ថានភាពតម្រូវការលើមុខទំនិញឬសេវាកម្មណាមួយបានឡើយ ។ ហេតុនេះហើយ គេក៏មិនអាចកាត់បន្ថយការផ្គត់ផ្គង់លើមុខទំនិញឬសេវាកម្មណាមួយ ដើម្បីដំឡើងថ្លៃបានទេ ។

**សម្គាល់ :** ការផ្ដល់សេរីភាពក្នុងការប្រកួតប្រជែង គឺជាមូលដ្ឋានរស់របស់សេដ្ឋកិច្ចទីផ្សារ ។ សេរីភាពក្នុងការប្រកួតប្រជែងអាចទប់ស្កាត់ជម្លោះនិងការវិវាទគ្នារវាងផលិតករនិងអ្នកប្រើប្រាស់ក្នុងការស្វែងរកផលប្រយោជន៍រៀងៗខ្លួន ។ ការប្រកួតប្រជែងបង្កើតឡើងនូវព្រំដែននៃដំណើរស្វែងរកអត្ថប្រយោជន៍បុគ្គល ។ ជារួម ការប្រកួតប្រជែងជាកម្លាំង ឬយន្តការដ៏សំខាន់ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ។

- **រក្សានិរន្តរភាពសេដ្ឋកិច្ចទីផ្សារដ៏យូរអង្វែង :** តាមរយៈការប្រើសេរីភាពក្នុងការប្រកួតប្រជែង ផលិតករអាចចូលនិងចេញនៅក្នុងអាជីវកម្មឬក្នុងវិស័យណាមួយនៃសេដ្ឋកិច្ចជាតិបានតាមចំណង់ ។ ចំណុចនេះ មានសារប្រយោជន៍ក្នុងការផ្ដល់លទ្ធភាព សម្របសម្រួលការផ្គត់ផ្គង់សេចក្ដីត្រូវការរបស់អតិថិជន ការលើកកម្ពស់ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីនិងការបង្កើនធនធានសេដ្ឋកិច្ច ។
- **ត្រួតពិនិត្យថ្លៃ :** ក្នុងសេដ្ឋកិច្ចទីផ្សារ ការប្រកួតប្រជែងមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យថ្លៃ ។ ជាទូទៅ ក្រឹត្យក្រមនៃការផ្គត់ផ្គង់និងតម្រូវការជាភ្នាក់ងារផ្ដល់ព័ត៌មានដល់ផលិតករអំពី

តម្រូវការរបស់អតិថិជន ។ ក៏ប៉ុន្តែ ការប្រកួតប្រជែងបង្ខំឱ្យសហគ្រិនបំពេញតម្រូវការរបស់អតិថិជន ពីព្រោះថា ទំនិញមានតម្រូវការខ្ពស់ ថ្លៃក៏មានកំណើនកើនឡើងដែរ ។ ផលិតផលមានការកើនឡើង បន្ទាប់មកក៏ធ្លាក់ចុះថ្លៃ ។

- **លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ៖** ការប្រើប្រាស់បច្ចេកវិទ្យាទំនើបអាចឱ្យផលិតករកាត់បន្ថយចំណាយផលិតកម្ម ហើយធ្វើឱ្យគេមានប្រៀបក្នុងការប្រកួតប្រជែង ។ បន្ថែមលើនេះគេអាចលក់ទំនិញក្នុងតម្លៃទាប ហើយអាចកាត់បន្ថយការលំបាកបានយ៉ាងច្រើន ។ ឃើញដូចនេះ ផលិតករដទៃទៀតត្រូវតែយកគំរូតាម ។ នេះជាហេតុនាំឱ្យមានការផ្សព្វផ្សាយយ៉ាងឆាប់រហ័សនូវរាល់ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងចំណោមផលិតករ ។

**សម្គាល់ ៖** ការកាត់បន្ថយចំណាយផលិតកម្ម ដោយការប្រើប្រាស់បច្ចេកវិទ្យាទំនើបជាប្រភពនៃការបង្កើនវិស័យផលិតកម្មថ្មីនោះគឺការផលិតឧបករណ៍ សម្ភារៈបច្ចេកវិទ្យាថ្មីៗមិនឈប់ឈរ ។

- **ធ្វើឱ្យស្របគ្នារវាងផលប្រយោជន៍របស់បុគ្គលនិងផលប្រយោជន៍សង្គម ៖** ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗខិតខំបង្កើនចំណូលឱ្យបានច្រើនជាអតិបរមាតាមរយៈការផលិតទំនិញនិងសេវា ។ ក្នុងការងារនេះ ផលិតករប្រើវិធានការចាត់ចែងប្រើប្រាស់ធនធានដែលមានដោយកម្រប្រកបដោយប្រសិទ្ធភាព ក្នុងការផលិតទំនិញឱ្យមានគុណភាព និងមានបរិមាណសមស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ ។ ដូចនេះ ដោយសារការប្រកួតប្រជែង ផលប្រយោជន៍របស់សហគ្រិនដើរស្របគ្នានឹងផលប្រយោជន៍សង្គម ។

រួមមក ការប្រកួតប្រជែងមានតួនាទីដ៏សកម្មជាច្រើនដែលសុទ្ធសឹងមានគោលដៅរួម គឺធ្វើឱ្យផលប្រយោជន៍បុគ្គលដើរស្របគ្នានឹងផលប្រយោជន៍សង្គម ។

## 4. សេចក្តីសន្និដ្ឋាន

ក្នុងសេដ្ឋកិច្ចទីផ្សារសេរី វត្តមាននិងការរីកចម្រើននៃកម្មសិទ្ធិឯកជនត្រូវតែដើរទន្ទឹមគ្នានឹងការរីកចម្រើននៃសេរីភាពនិងការជ្រើសរើសរបស់សហគ្រិន ផលិតករ និងអ្នកប្រើប្រាស់ ។ នៅពេលដែលសេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសមានការកើនឡើង ការប្រកួតប្រជែងក៏មានដំណើរការទៅមុខ ។ ដោយសារការប្រកួតប្រជែង ទំនិញ ឬសេវាពុំមានការឡើងថ្លៃ ទំនិញឬសេវាដែលមានតម្លៃខ្ពស់ត្រូវធ្លាក់ថ្លៃ ការប្រើប្រាស់បច្ចេកវិទ្យាទំនើបមានការកើនឡើង ហើយផលប្រយោជន៍បុគ្គលនឹងត្រូវដើរស្របគ្នានឹងផលប្រយោជន៍សង្គម ជាហេតុនាំឱ្យសេដ្ឋកិច្ចជាតិមានកំណើនជានិរន្តរ៍ ។

## សំណួរ

1. នៅសហគមន៍ដែលអ្នករស់នៅ តើមានសហគ្រិន ឬផលិតករដែលកំពុងធ្វើអាជីវកម្មលើទ្រព្យសម្ភារៈជាកម្មសិទ្ធិឯកជនរបស់ខ្លួនឬទេ ? ប្រសិនបើមាន ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុម ដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. កម្មសិទ្ធិឯកជនជាអ្វី ?
   ខ. តើមានគោលការណ៍អ្វីខ្លះ ក្នុងការប្រើប្រាស់កម្មសិទ្ធិឯកជន ?
   គ. តើការផ្តល់សេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសដល់សហគ្រិនមានសារៈសំខាន់ដូចម្តេចខ្លះ ?
   ឃ. តើសេរីភាពក្នុងការជ្រើសរើសរបស់កម្លាំងផលិតកម្មនិងអ្នកប្រើប្រាស់មានសារៈសំខាន់ដូចម្តេចខ្លះ ?
   ង. តើការប្រកួតប្រជែងជាអ្វី ?
   ច. តើការប្រកួតប្រជែងមានតួនាទីអ្វីខ្លះ ?
3. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

មានករណីសិក្សាមួយត្រូវបានលើកឡើង ។ មានផលិតករពីរនាក់ កំពុងប្រកបអាជីវកម្មចិញ្ចឹមគោនៅកសិដ្ឋានរៀងៗខ្លួនដែលស្ថិតនៅទន្ទឹមគ្នា ។ តើមានលក្ខណៈសម្គាល់អ្វីដែលអាចបញ្ជាក់ថា ផលិតករទាំងពីរនាក់កំពុងមានការប្រកួតប្រជែងគ្នា ? ចូរពន្យល់ ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 8 ផលិតផលជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់អត្ថន័យនៃបញ្ញត្តិ "ផលិតផលក្នុងស្រុកសរុប" "ផលិតផលជាតិ" និង"ផលិតផលជាតិសរុប ។
- បង្ហាញទំនាក់ទំនងរវាងផលិតផលជាតិសរុបជាមួយនឹងសុខុមាលភាពប្រជាពលរដ្ឋ ។
- បកស្រាយសក្តានុពលនៃផលិតកម្មរបស់ជាតិមួយ ។

ពាក្យផលិតផលជាតិនៅក្នុងសេដ្ឋកិច្ច គេប្រើប្រាស់ដើម្បីប្រាប់ពីតម្លៃសរុបនៃទំនិញនិងសេវាកម្មដែលបានផលិតនៅក្នុងសេដ្ឋកិច្ចមួយ ក្នុងរយៈពេលមួយឆ្នាំ ។

## 1. ផលិតផលក្នុងស្រុកសរុប

ផលិតផលក្នុងស្រុកសរុប គឺជាតម្លៃសរុបនៃទំនិញនិងសេវាកម្ម ដែលសម្រេចបានដោយប្រើប្រាស់កត្តាផលិតកម្មដែលជាកម្មសិទ្ធិក្នុងស្រុកក្នុងអំឡុងពេលមួយមានកំណត់ ។ ប្រទេសភាគច្រើនគេយកផលិតផលក្នុងស្រុកសរុបជាទិន្នន័យផ្លូវការសម្រាប់វាស់វែងសេដ្ឋកិច្ចរបស់គេ ពីព្រោះ

- ផលិតផលក្នុងស្រុកសរុបងាយប្រៀបធៀបពីពេលមួយទៅពេលមួយ ។
- វាងាយគណនាដោយមិនបាច់គិតអំពីប្រាក់ចំណូលសុទ្ធពីបរទេស ។

ផលិតផលក្នុងស្រុកសរុបគឺជាទិន្នន័យឆ្លុះបញ្ចាំងសក្តានុពលក្នុងការបង្កើតការងារក្នុងស្រុក ។

រីឯផលិតផលក្នុងស្រុកសុទ្ធសាចគឺជាតម្លៃសរុបនៃទំនិញនិងសេវាទាំងឡាយណាដែលផលិតដោយជាតិមួយស្ថិតនៅក្រោមកម្មសិទ្ធិរបស់ជាតិនោះ ។

## 2. ផលិតផលជាតិ

### 2.1. និយមន័យ

ផលិតផលជាតិ (NP) គឺជាតម្លៃសរុបនៃទំនិញនិងសេវាកម្មទាំងអស់ទាំងក្នុងស្រុក ទាំងជាអំណោយពីបរទេសដែលមាននៅក្នុងសេដ្ឋកិច្ចជាតិមួយក្នុងពេលជាក់លាក់មួយ ។ ផលិតផលជាតិរួមផ្សំដោយ

- តម្លៃនៃធនធានដែលយកមកប្រើប្រាស់ក្នុងដំណើរផលិតកម្មនិងសេវាកម្ម មានវត្ថុធាតុដើម ធនធានមនុស្ស មធ្យោបាយផលិតកម្ម ធនធានហិរញ្ញប្បទាន ... ។ល ។
- គុណភាពនៃធនធានទាំងនោះ សំដៅលើផលទុនដែលធនធានទាំងនោះបង្កើតបាន ។ ***ឧទាហរណ៍*** មូលធនបង្កើតប្រាក់ចំណេញ ឬការប្រាក់ ។
- ប្រសិទ្ធភាពប្រើប្រាស់នៃធនធានទាំងនោះ ពោលគឺការប្រើអស់លទ្ធភាពក្នុងដំណើរការផលិតកម្មមួយ ។ ***ឧទាហរណ៍*** ត្រាក់ទ័រមួយមានប្រសិទ្ធភាពប្រើប្រាស់ក្នុងរយៈពេល 10ឆ្នាំទើបប្តូរយកត្រាក់ទ័រថ្មី ។



## 2.2. អ្វីដែលគេមិនរាប់បញ្ចូលក្នុងផលិតផលជាតិ

ខាងក្រោមនេះ បង្ហាញពីផ្នែកនៃដំណាក់កាលទីផ្សារឬសេវាកម្មដែលមិនបានរាប់បញ្ចូលទៅក្នុងផលិតផលជាតិ

- ផលិតផលមិនទាន់សម្រេច ។
- អាជីវកម្មលួចលាក់និងទំនិញគេចពន្ធ មានដូចជា ការធ្វើអាជីវកម្មខុសច្បាប់ ការរត់ពន្ធ ការលក់ទំនិញខុសច្បាប់ ការលក់គ្រឿងញៀន ល្បែងស៊ីសងជាដើម ។
- ការងារមេផ្ទះ ។
- អចលនវត្ថុ ការចំណាយជាទំនិញ រួមមានការចំណាយក្នុងផលិតកម្មក្នុងទម្រង់ជាទំនិញឬសម្ភារៈប្រើប្រាស់ដូចជាស្បៀងដែលប្រើដោយកសិករនៅពេលធ្វើកសិកម្មឬលំនៅដ្ឋានជួលសម្រាប់អ្នកចាត់ចែងក្រុមហ៊ុន ឬម្ចាស់ក្រុមហ៊ុនស្នាក់អាស្រ័យ ឬជាការិយាល័យសម្រាប់ធ្វើការនិងសេវាកម្មផ្ទៃក្នុងជាដើម ។

youtube.com/moeys
facebook.com/moeys.gov.kh

## 3. ផលិតផលជាតិសរុប

ផលិតផលជាតិសរុប (GNP) គឺការបូកសរុបការចំណាយទាំងអស់របស់រដ្ឋាភិបាល រួមនឹងទុនវិនិយោគឯកជនដែលមានប្រភពនៅក្នុងស្រុកនិងក្រៅស្រុក ។ វាគឺជាតម្លៃមួយដ៏ច្បាស់លាស់នៃផលិតកម្មទំនិញនិងសេវាកម្មរបស់ប្រទេសមួយ ។ ផលិតផលជាតិសរុបរួមមានតម្លៃនៃទំនិញប្រើប្រាស់គិតជាដុល្លារ (C) តម្លៃសរុបនៃវិនិយោគឯកជនក្នុងប្រទេស (I) ថ្លៃជាទំនិញនិងសេវាកម្មរបស់រដ្ឋាភិបាល (G) និងតម្លៃនីហរ័ណសុទ្ធសាធ (X) ។

ដូចនេះ $GNP = \overline{C} + \overline{I} + \overline{G} + \overline{X}$

GNP គឺជាឈ្មោះដែលយើងឱ្យសម្រាប់តម្លៃសរុបនៃផលិតផលសម្រេចនិងសេវាកម្មដែលផលិតដោយប្រទេសមួយក្នុងអំឡុងពេលមួយឆ្នាំ ។

## 4. ផលិតផលជាតិសរុបនិងសុខុមាលភាពប្រជាពលរដ្ឋ

ផលិតផលជាតិសរុបគឺជាតម្លៃសរុបដែលបានពីការវាស់កម្រិតផលិតកម្មសេដ្ឋកិច្ច ។ វាមិនត្រឹមតែបង្ហាញនូវកម្រិតគុណភាពនៃសុខុមាលភាពសង្គមប៉ុណ្ណោះទេ តែវាបង្ហាញនូវសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមផងដែរ ។ សេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋគឺមានជីវភាពរស់នៅសមរម្យហូបចុកគ្រប់គ្រាន់ មានរបស់របរប្រើប្រាស់គ្រប់គ្រាន់ មានជម្រកនិងមានការលំហែកាយក្នុងការថែទាំសុខភាព ។ ការបំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋដោយការបង្កើនផលិតផលទំនិញនិងសេវាកម្មតាមតម្រូវការ នាំមកនូវការលូតលាស់នៃសេដ្ឋកិច្ចជាតិនិងការកាត់បន្ថយវិបត្តិផ្សេងៗនៅក្នុងសង្គម ។ ផលិតផលជាតិសរុបមិនមែនវាស់ស្ទង់នូវសុខុមាលភាពសង្គមទេ តែវាបានធ្វើការបែងចែកដ៏ធំធេងសម្រាប់សុខុមាលភាព ។ គេសម្គាល់សុខុមាលភាពសង្គមទៅលើគុណភាពបរិយាកាស ពេលវេលាសម្រាកលំហែ និងបរិមាណផលិតផលជាតិសម្រាប់មនុស្សម្នាក់ៗ ។

### 4.1. គុណភាពបរិយាកាស

ដំណើរការបង្កើនផលិតកម្មនានា ពិសេសផលិតកម្មឧស្សាហកម្មតែងប៉ះពាល់ដល់គុណភាពបរិយាកាស បានបញ្ចេញនូវកាកសំណល់វត្ថុធាតុដើមនិងជាតិពុលចូលទៅក្នុងខ្យល់អាកាសនិងទឹក ប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ។ ចំពោះផលិតកម្មខ្លះដែលតម្រូវឱ្យមានការកាប់បំផ្លាញព្រៃឈើ ក៏ធ្វើឱ្យបរិស្ថានមានការប្រែប្រួលទៅរកគ្រោះធម្មជាតិ ។ ដូចនេះការបង្កើនផលិតផលជាតិត្រូវតែផ្សារភ្ជាប់នឹងការបង្កើនសុខុមាលភាពប្រជាពលរដ្ឋ ។

youtube.com/moeys
facebook.com/moeys.gov.kh
t.me/groupmoeys.gov.kh



## 4.2. ពេលវេលាសម្រាកលំហែ

ការផ្តល់ពេលវេលាសម្រាកលំហែ គឺជាការពង្រឹងសុខុមាលភាពរបស់និយោជិត ដើម្បីទទួលបាននូវផលត្រឡប់មកវិញ គឺការបង្កើនទិន្នផលការងារ ។ គេអាចសម្គាល់បានថា និយោជិតម្នាក់មានសុខុមាលភាពល្អ កាលបើគេមើលឃើញថា និយោជិតនោះមានពេលសម្រាកលំហែ មានការដើរលំហែជាក្រុមការងារឬជាគ្រួសារនៅតាមរមណីយដ្ឋាននានាជាដើម ។



## 4.3. បរិមាណផលិតផលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ

ជាទូទៅ ដើម្បីវាយតម្លៃសុខុមាលភាពប្រជាពលរដ្ឋគេតែងតែគណនាតាមរង្វាស់សេដ្ឋកិច្ចមួយដែលរកឃើញតម្លៃផលិតផលជាតិសរុបគិតជាមធ្យមសម្រាប់មនុស្សម្នាក់ៗ ដោយយកតម្លៃចំនួនផលិតផលជាតិសរុបចែកនឹងចំនួនប្រជាពលរដ្ឋសរុបនៅក្នុងប្រទេសមួយ ។ តាមរយៈការគិតជាមធ្យម យើងមិនអាចវាយតម្លៃថាមនុស្សទាំងអស់នៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចជាតិទទួលបាននូវផលិតផលក្នុងកម្រិតស្មើៗគ្នានោះទេ ។ ជាការពិតណាស់ ប្រសិនបើការបែងចែកផលិតផលជាតិសរុបជាក់ស្តែងមានភាពលំអៀងច្រើនហួសហេតុ នោះនឹងបណ្តាលឱ្យមានគម្លាតដ៏ធំធេងរវាងអ្នកមាននិងអ្នកក្រ ហើយនឹងបណ្តាលឱ្យមានផលវិបាកជាច្រើនកើតឡើងដោយប៉ះពាល់ដល់សុខុមាលភាពប្រជាពលរដ្ឋទូទៅ ។

# 5. សន្និដ្ឋាន

ផលិតផលជាតិគឺជាតម្លៃសរុបនៃទំនិញនិងសេវាកម្មទាំងអស់ដែលមាននៅក្នុងសេដ្ឋកិច្ចជាតិមួយ ។ ឯផលិតផលជាតិសរុប គឺការបូកសរុបការចំណាយរបស់រដ្ឋាភិបាល រួមនឹងទុនវិនិយោគឯកជនដែលមានប្រភពនៅក្នុងស្រុកនិងក្រៅស្រុក ។ កម្រិតកើនឡើង ឬថយចុះនៃផលិតផលជាតិសរុប ឆ្លុះបញ្ចាំងឱ្យឃើញពីកម្រិតកើនឡើង ឬថយចុះនៃសុខុមាលភាពប្រជាពលរដ្ឋ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## សំណួរ

1. មានទស្សនៈមួយលើកឡើងថា "កិច្ចការដែលយើងកំពុងតែធ្វើសុទ្ធសឹងជាមាសប្រាក់" ។ តើទស្សនៈនេះមានអត្ថន័យដូចម្តេច ? ចូរអ្នកបកស្រាយប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុម ដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. ដូចម្តេចហៅថាផលិតផលក្នុងស្រុកសរុប ?
   ខ. ដូចម្តេចហៅថាផលិតផលជាតិ ?
   គ. ដូចម្តេចហៅថាផលិតផលជាតិសរុប ?
   ឃ. ផលិតផលជាតិសរុបមានទំនាក់ទំនងយ៉ាងណាជាមួយនឹងសុខុមាលភាពប្រជាពលរដ្ឋ ?
   ង. រវាងផលិតផលក្នុងស្រុកសរុបនិងផលិតផលជាតិសរុប តើមួយណាជាអ្នកបង្ហាញសក្តានុពលនៃផលិតកម្មរបស់ជាតិមួយ ? ហេតុអ្វី ?
3. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ចូរអ្នកស្រាវជ្រាវរកព័ត៌មានពីប្រភពផ្សេងៗតាមលទ្ធភាព តើផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាមានប្រភពពីផលិតកម្ម ឬសេវាកម្មណាខ្លះ ?

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 9 ផលិតកម្ម

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយនិយមន័យផលិតកម្ម ។
- បកស្រាយអត្ថន័យនៃបញ្ញត្តិមួយចំនួនទាក់ទងនឹងផលិតកម្ម ។

ជាទូទៅ ពីមួយថ្ងៃទៅមួយថ្ងៃ ធនធានមនុស្សតែងបង្កើនផលិតកម្ម ដើម្បីធ្វើឱ្យជីវភាពបុគ្គល គ្រួសារ និងសង្គមជាតិមានការរីកចម្រើនឡើងឥតឈប់ឈរ ។ ទន្ទឹមនឹងនេះ សេចក្តីត្រូវការរបស់ប្រជាករក៏កាន់តែកើនឡើងជាលំដាប់ រហូតដល់អ្នកសេដ្ឋកិច្ចមួយចំនួនធ្វើការសន្និដ្ឋានថា តម្រូវការរបស់ប្រជាករក្នុងប្រទេសមួយក៏ដូចជាក្នុងពិភពលោកគ្មានព្រំដែនកំណត់ទេ ។ ចំណែកឯបរិមាណនិងគុណភាពនៃធនធានធម្មជាតិ ផលិតផលទំនិញ និងសេវាកម្មផ្សេងៗមានដែនកំណត់ ។



## 1. និយមន័យផលិតកម្ម

ផលិតកម្មជាការផលិតទ្រព្យសម្ភារៈចាំបាច់សម្រាប់អត្ថិភាពនិងអភិវឌ្ឍន៍សង្គម ។ ផលិតកម្ម ជាដំណើរការបញ្ចូលគ្នានូវកត្តាសំខាន់ទាំងបីរបស់ផលិតកម្ម គឺធនធានមនុស្ស ធនធានធម្មជាតិ និងទំនិញវិនិយោគក្នុងការបង្កើតទំនិញនិងសេវា ដើម្បីបំពេញសេចក្ដីត្រូវការរបស់សង្គមមនុស្ស ។

ផលិតកម្ម មានធាតុផ្សំ 3 យ៉ាងគឺ

- **ពលកម្ម :** សកម្មភាពប្រកបដោយវិចារណញ្ញាណរបស់មនុស្ស ។
- **កម្មវត្ថុពលកម្ម :** អ្វីៗដែលត្រូវផលិត ឬកែច្នៃ ឬវត្ថុធាតុដើម ។
- **មធ្យោបាយផលិតកម្ម :** ឧបករណ៍ពលកម្មនិងធនធានធម្មជាតិ ។ ឧបករណ៍ពលកម្មមានដូចជាម៉ាស៊ីន ប្រដាប់ប្រដានិងបរិក្ខារ ប្រដាប់ផ្សេងៗ ម៉ូទ័រ និងប្រដាប់ត្រួតពិនិត្យ ។ នៅក្នុងបរិបទនៃបដិវត្តន៍វិទ្យាសាស្ត្រនិងបច្ចេកទេសសម័យថ្មី គេឃើញមានការកើនឡើងនូវឧបករណ៍ពលកម្មថ្មីៗដូចជាម៉ាស៊ីនបញ្ជាស្វ័យប្រវត្តិ កុំព្យូទ័រ ម៉ាស៊ីនប្រដាប់បញ្ជា កម្មវិធីម៉ាស៊ីន និងមេកានិកទំនើបៗផ្សេងៗទៀត ។ នៅក្នុងប្រវត្តិនៃដំណើរការផលិតកម្ម មានការប្រើប្រាស់បញ្ញត្តិមួយចំនួនដូចខាងក្រោម ។

## 2. ផលិតកម្មមិនទាន់សម្រេច



ជាផលិតផលដែលស្ថិតនៅក្នុងដំណាក់កាលជាអន្តរការីនៃដំណើរការផលិតកម្ម មុននឹងធ្វើពាណិជ្ជកម្ម ។ ទំហំនៃផលិតកម្មមិនទាន់សម្រេចក្នុងន័យរូបិយវត្ថុ ជាការរួមផ្សំថ្លៃនៃវត្ថុធាតុដើមទាំងឡាយ សម្ភារៈទាំងឡាយ ប្រេងឥន្ធនៈនិងថាមពល ចំណាយនានា សំវិធានវត្ថុនៃការរំលោះ ប្រាក់បៀវត្សដែលបានចំណាយចំពោះដំណាក់កាលណាមួយនៃផលិតកម្ម ។ វាជាផ្នែកមួយនៃមូលនិធិចរាចរណ៍របស់សហគ្រាសមួយ ។ ភាគចំណាយរបស់វាយោងទៅតាមរយៈពេលនៃខួបរបស់ផលិតកម្ម ។ នៅក្នុងសំណង់មេកានិកនានា ផលិតកម្មមិនទាន់សម្រេចមានពី 25% ទៅ 40% នៃមូលនិធិចរាចរណ៍ ។ នៅក្នុងឧស្សាហកម្មតម្បាញនិងម្ហូបអាហារ វាមានពី 5% ទៅ 20% នៃដំណើរការផលិតកម្ម ។ ជាទូទៅមិនមានផលិតកម្មមិនទាន់សម្រេចទេនៅក្នុងវិស័យមួយចំនួននៃឧស្សាហកម្មជីកយករ៉ែ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 3. ផលិតកម្មទំនិញ



ផលិតកម្មទំនិញជាផលិតកម្មទ្រព្យសម្ភារៈសម្រាប់ប្តូរផ្តោះតាមរយៈការទិញ និងការលក់ ។ ការបែងចែកពលកម្មសង្គម ជាលក្ខខណ្ឌនៃអត្ថិភាពរបស់ផលិតកម្មទំនិញ ។ ក្នុងសេដ្ឋកិច្ចទំនិញ ផលិតផលនានាត្រូវបានបង្កើតដោយផលិតករឯកជនដាច់ៗពីគ្នា គ្មានទាក់ទងពីមួយទៅមួយ ។ ផលិតកម្មទំនិញបានលេចឡើងនៅក្នុងដំណាក់កាលនៃការបែងចែករបបនៃសហគមន៍បុព្វកាលនិងដំណាក់កាលលេចឡើងនូវទំនាក់ទំនងទាសកម្ម ។ ផលិតកម្មទំនិញមានអត្ថិភាពនៅក្នុងទម្រង់សេដ្ឋកិច្ចសង្គមសក្តិភូមិ និងមូលធននិយម ។ តាមអត្ថន័យសង្គម តួនាទីនៃផលិតកម្មនិងព្រំដែនសកម្មភាពត្រូវបានកំណត់ដោយទម្រង់នៃការប្រមូលផ្តុំពលករចំពោះមធ្យោបាយផលិតកម្ម ។ ផលិតកម្មទំនិញមានពីរប្រភេទ គឺផលិតកម្មទំនិញបង្កើតឡើងនៅលើកម្មសិទ្ធិឯកជននៃមធ្យោបាយផលិតកម្មទំនិញសាមញ្ញ និងផលិតកម្មទំនិញបង្កើតឡើងនៅលើកម្មសិទ្ធិឯកជននៃមធ្យោបាយផលិតកម្មទំនិញមូលធន ។

## 4. ផលិតកម្មទំនិញសាមញ្ញ





ផលិតកម្មទំនិញសាមញ្ញជាផលិតកម្មនៃទំនិញ របស់របរ សម្រាប់ប្តូរផ្តោះតាមរយៈការលក់និងការទិញ ហើយត្រូវបានបង្កើតឡើងដោយឈរលើកម្មសិទ្ធិឯកជនរបស់ពលករតូចៗនិងពលកម្មផ្ទាល់ខ្លួន ។ ផលិតកម្មទំនិញសាមញ្ញបានកើតមានឡើងតាំងតែពីពេលដ៏យូរលង់កន្លងមកដែលមានការផ្លាស់ប្តូរសហគមន៍បុព្វកាល ដោយការចាប់កំណើតនៃសង្គមទាសករ ។ ផលិតកម្មទំនិញសាមញ្ញស្ថិតក្រោមទម្រង់នៃសហគ្រាសផលិតកម្មនិងកសិកម្ម ។ គោលបំណងរបស់ផលិតកម្ម គឺដើម្បីបំពេញសេចក្តីត្រូវការក្នុងជីវភាពរបស់អ្នកផលិត ។ គ្រប់ទំនិញ សិប្បកម្មនិងមួយចំណែកនៃផលិតកម្មកសិករ ត្រូវបានទុកសម្រាប់ប្តូរផ្តោះជាមួយនឹងផលិតផលនៃពលកម្មរបស់អ្នកដទៃ ដែលចាំបាច់សម្រាប់ផ្គត់ផ្គង់ជួយសេចក្តីត្រូវការផ្ទាល់ខ្លួន ឬជាមួយនឹងផលិតផលរបស់សិប្បករ ឬកសិករផ្សេងទៀត ។

## 5. ផលិតកម្មមេកានិក

ផលិតកម្មមេកានិក បានលេចចេញឡើងក្រោមការជំរុញរបស់បដិវត្តន៍ឧស្សាហកម្មដំបូងក្នុងសម័យមួយភាគបីចុងក្រោយនៃសតវត្សទី 18 នៅប្រទេសអង់គ្លេស បន្ទាប់មក នៅបណ្ដាប្រទេសមូលធនផ្សេងទៀត ។



បដិវត្តន៍នេះ បានចាប់ផ្ដើមដោយការបង្កបង្កើតម៉ាស៊ីនឧបករណ៍ដែលមានផ្សំដោយម៉ាស៊ីន 3 ប្រភេទគឺ ម៉ូទ័រ ម៉ាស៊ីនបញ្ជូន និងម៉ាស៊ីនប្រតិបត្តិការ ដើម្បីជាក់ជំនួសប្រដាប់ប្រដាសិប្បកម្មតូចតាច ។ បន្ទាប់មក មានការធ្វើសហប្រតិបត្តិការសាមញ្ញរវាងម៉ាស៊ីនដែលមានប្រភេទដូចគ្នា ។

ប្រព័ន្ធស្វ័យប្រវត្តិនៃម៉ាស៊ីនដែលចេះតែវិវឌ្ឍនៅក្នុងលក្ខខណ្ឌនៃបដិវត្តន៍វិទ្យាសាស្ត្រ បច្ចេកទេសនាសម័យនោះបានដោះលែងកម្មករចេញអំពីការងារដោយផ្ទាល់ក្នុងផលិតកម្ម ។ ការឆ្លងកាត់ការផលិតដោយដៃទៅកាន់ផលិតកម្មដោយប្រើម៉ាស៊ីនបានបង្កើតឱ្យមានមូលដ្ឋានសម្ភារៈនិងបច្ចេកទេស និងធ្វើឱ្យមានជោគជ័យដ៏ត្រចះត្រចង់ដល់របបសម័យនោះ ។ ម៉ាស៊ីន គ្រឿងចក្រ គឺជាមធ្យោបាយដ៏មានអានុភាពដែលអាចផ្ដល់ការសន្សំសំចៃនិងជួយសម្រួលការងារ ។

## 6. ផលិតកម្មសរុប

ផលិតកម្មសរុបជាសន្ទស្សន៍ស្តែងឡើងក្រោមទម្រង់ជារូបិយវត្ថុដែលបង្ហាញនូវទំហំផលិតកម្ម របស់សហគ្រាស ក្រុមផលិតកម្មណាមួយ ផ្នែកណាមួយ ឬសំណុំនៃសេដ្ឋកិច្ចជាតិទាំងមូល ។ សន្ទស្សន៍ នេះ ត្រូវបានគិតសម្រាប់មែកធាងនានានៃផលិតកម្មសម្ភារៈ (ឧស្សាហកម្ម កសិកម្ម អាគារ ការដឹក ជញ្ជូន និងគមនាគមន៍ ពាណិជ្ជកម្ម ការផ្គត់ផ្គង់សម្ភារៈ និងតិចនិច)ជាថ្លៃប្រៀបធៀបនឹងថ្លៃជាក់ស្តែង ។ ផលិតកម្មសរុបនៃសហគ្រាសឧស្សាហកម្មមួយ ជាលទ្ធផលចាំបាច់និងផ្ទាល់ ស្តែងឡើងក្រោមទម្រង់ ផលិតផល ឬការងារឧស្សាហកម្មនានា ។

## 7. ផលិតកម្មសុទ្ធ

ផលិតកម្មសុទ្ធជាសន្ទស្សន៍សេដ្ឋកិច្ច បង្ហាញនូវតម្លៃបង្កើតថ្មី ដែលជាលទ្ធផលសំខាន់បំផុតនៃ សកម្មភាពរបស់សហគ្រាស ក្រុមប្រមូលផ្តុំនានា និងវិស័យនានានៃផលិតកម្មសម្ភារៈនៅក្នុងប្រទេស មួយ (ច្រើនប្រើនៅប្រទេសសង្គមនិយម) ។ ផលបូកនៃផលិតកម្មសុទ្ធ គ្រប់ផ្នែកនៃផលិតកម្មសម្ភារៈ បង្ហាញឡើងជាផលទុនជាតិរបស់ប្រទេស ។ ផ្ទុយទៅនឹងផលិតកម្មសរុបដែលជាតំណាងចំណាយនៃ ពលកម្មនិងសម្ភារៈ ផលិតកម្មសុទ្ធតំណាងតែចំណាយនៃពលកម្មតែប៉ុណ្ណោះ ។

គេកំណត់ផលិតកម្មសុទ្ធដោយដកយកចេញពីផលិតកម្មសរុប(សហគ្រាសនានា ក្រុមផលិតនានា សាខានានា) នូវចំណាយសម្ភារៈរបស់ផលិតកម្ម(ចំណាយវត្ថុធាតុដើម សម្ភារៈនានា ពាក់កណ្តាល ផលិតផលសម្រេច ប្រេងឥន្ធនៈ ថាមពល ការប្រើប្រាស់នៃមូលនិធិអចល័ត) ។ គេគិតចេញជាថ្លៃលក់ ដុំរបស់សហគ្រាស(ដោយមិនរាប់បញ្ចូលពន្ធលើផលរបរ) ។ ផលិតផលសុទ្ធត្រូវបែងចែកទៅជាប្រាក់ បៀវត្សនិងប្រាក់ចំណេញនៅក្នុងទំនាក់ទំនងទាំងឡាយ កំណត់ដោយលក្ខខណ្ឌនានានៃផលិតកម្មនិង ការបែងចែក ។

## 8. សន្និដ្ឋាន

ការយល់ច្បាស់អត្ថន័យនៃបញ្ញត្តិនានាដែលទាក់ទងនឹងដំណើរការផលិតកម្មនឹងជួយឱ្យអ្នក សិក្សាមានភាពងាយស្រួលក្នុងការគណនាតម្លៃអញ្ញត្រទាំងឡាយដែលមានក្នុងសមីការផលិតកម្ម ។

facebook.com/moeys.gov.kh youtube.com/moeys

## សំណួរ

1. ចូរអ្នករៀបរាប់អ្វីខ្លះជាផលិតផលក្នុងស្រុកដែលមានដាក់លក់នៅទីផ្សារក្នុងសហគមន៍របស់អ្នក ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. ដូចម្តេចហៅថា ផលិតកម្មមិនទាន់សម្រេច ?
   ខ. ដូចម្តេចហៅថា ផលិតកម្មទំនិញ ?
   គ. ដូចម្តេចហៅថា ផលិតកម្មទំនិញសាមញ្ញ ?
   ឃ. ដូចម្តេចហៅថា ផលិតកម្មមេកានិក ?
   ង. ដូចម្តេចហៅថា ផលិតកម្មសរុប ?
   ច. ដូចម្តេចដែលហៅថា ផលិតកម្មសុទ្ធ ?
3. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ចូរអ្នកធ្វើការសង្កេតនិងសម្គាល់ម៉ាស៊ីនឬគ្រឿងចក្រផ្សេងៗដែលអ្នកបានជួប ហើយកំណត់យកម៉ាស៊ីនចំនួន 5 ដើម្បីលើកយកមករៀបរាប់អំពីសារប្រយោជន៍របស់វា ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 10 ព្រំដែនសមត្ថភាពផលិតកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ន័យនៃបញ្ញត្តិព្រំដែនសមត្ថភាពផលិតកម្ម ។
- ❑ ពន្យល់និងបង្ហាញអំពីព្រំដែនសមត្ថភាពផលិតកម្ម ។



បញ្ហាសេដ្ឋកិច្ច ជាបញ្ហាដែលត្រូវមានដំណោះស្រាយអំពីសំណាក់រដ្ឋាភិបាលនៃប្រទេសនីមួយៗក្នុងពិភពលោក ដោយផ្អែកលើសក្តានុពលធនធានធម្មជាតិនិងធនធានមនុស្សក្នុងប្រទេសរបស់ខ្លួន ។ ចំណោទដែលសំខាន់ជាងគេគឺ តើត្រូវមានផលិតកម្មបែបណាដើម្បីបង្កើនផលិតផលឱ្យបានតាមសេចក្តីត្រូវការរបស់សង្គម ហើយអាចនាំចេញទៅលក់នៅប្រទេសក្រៅថែមទៀត ដើម្បីបង្កើនចំណូលជាតិ ។ តាមធម្មតា សមត្ថភាពផលិតកម្មជាក់ស្តែងនៃប្រទេសនីមួយៗ តែងមានបរិមាណនិងគុណភាពក្នុងកម្រិតខុសៗគ្នា ពោលគឺ ប្រទេសនីមួយៗតែងមានព្រំដែនសមត្ថភាពនៃផលិតកម្មរបស់ខ្លួនយ៉ាងជាក់លាក់ ។

## 1. និយមន័យ

ផលិតកម្ម ជាដង្ហើមនៃសេដ្ឋកិច្ចជាតិ ។ ផលិតកម្មនាំឱ្យមានពាណិជ្ជកម្ម ។ គ្មានផលិតកម្ម ក៏គ្មានពាណិជ្ជកម្ម ។ **សមត្ថភាពផលិតកម្ម** សំដៅលើលទ្ធភាពរបស់ប្រទេសជាតិ ក្នុងការបង្កើតផលិតផលដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រទេសខ្លួន ។ សមត្ថភាពផលិតកម្ម តែងអាស្រ័យលើកត្តាសំខាន់ទាំងបីរបស់ផលិតកម្ម គឺធនធានធម្មជាតិ ធនធានមនុស្សនិងទំនិញវិនិយោគដែលប្រទេសនីមួយៗមាន ។

នៅពេលណាដែលបរិមាណធនធានធម្មជាតិ មធ្យោបាយផលិតកម្មនិងគុណភាពនៃធនធានមនុស្សមាននៅកម្រិតណាមួយ ពេលនោះការងារផលិតកម្មក៏នឹងមានសមត្ថភាពត្រឹមកម្រិតនោះដែរ ។ ***ឧទាហរណ៍*** នៅប្រទេសកម្ពុជា កសិករម្នាក់មានដីស្រែទំហំ 1ហិចតា ភ្ជួររាស់ដោយគោ ក្របី ហើយធ្វើស្រែតាមរបៀបយថាផល គេអាចនិយាយបានថា ការងារផលិតកម្មក្នុងអាជីវកម្មរបស់កសិករនោះមានសមត្ថភាពត្រឹមផលិតស្រូវជាអតិបរិមាបាន 1.5តោនប៉ុណ្ណោះក្នុង 1ហិចតា ។ 1.5តោន/1ហិចតា ហៅថា ព្រំដែនសមត្ថភាពផលិតកម្មរបស់កសិករនោះ ។

youtube.com/moeys
facebook.com/moeys.gov.kh

## 2. ចំណោទបញ្ហាលើការងារផលិតកម្ម

ធនធានធម្មជាតិ ទំនិញវិនិយោគ និងធនធានមនុស្សមានត្រឹមកម្រិតណា ការងារផលិតកម្មក៏មានត្រឹមកម្រិតនោះដែរ ។ ប៉ុន្តែសេចក្តីត្រូវការរបស់សង្គមទៅលើផលិតផលនានាមានទំហំធំធេងណាស់ ។ ដូច្នេះ អ្នកសេដ្ឋកិច្ច ត្រូវតែដោះស្រាយបញ្ហាសេដ្ឋកិច្ច ដោយការជ្រើសរើស តើត្រូវផលិតអ្វី ? ផលិតយ៉ាងដូចម្តេច ? ផលិតសម្រាប់អ្នកណា ? ផលិតប៉ុន្មាន ដើម្បីដោះស្រាយបញ្ហានេះបានគេត្រូវជ្រើសរើសទីតាំងនៃសមត្ថភាពផលិតកម្ម តើត្រូវជ្រើសរើសឱ្យសមត្ថភាពផលិតកម្មស្ថិតនៅក្រោម ឬស្ថិតនៅលើ ឬស្ថិតនៅក្រៅខ្សែព្រំដែនសមត្ថភាពផលិកម្ម ?

## 3. ដំណោះស្រាយបញ្ហាលើសមត្ថភាពផលិតកម្ម

### 3.1. ផលិតកម្មស្ថិតនៅលើខ្សែព្រំដែនសមត្ថភាពផលិតកម្ម




ក្នុងក្រាហ្វិកនេះ ខ្សែកោង (AD) បង្ហាញពី “**ព្រំដែនសមត្ថភាពផលិតកម្ម**” ដែលនៅលើខ្សែនេះបរិមាណជាអតិបរមានៃផលិតកម្មទំនិញវិនិយោគនិងទំនិញប្រើប្រាស់អាចផលិតទៅបាន អាស្រ័យតាមកម្រិតធនធានទំនិញវិនិយោគ ធនធានធម្មជាតិ និងធនធានមនុស្ស ដែលមាននៅក្នុងប្រទេសមួយ ។ យើងឃើញថាអ័ក្សអាប់ស៊ីស (Ox) តាង**បរិមាណ ផលិតកម្មទំនិញប្រើប្រាស់** ។ អ័ក្សអរដោនេ (Oy) តាង**បរិមាណ ផលិតកម្មទំនិញវិនិយោគ** ។ គ្រប់ចំណុចនៃខ្សែកោង (AD) តាងឱ្យសមត្ថភាពព្រំដែនមួយ ការផលិតទំនិញវិនិយោគនិងទំនិញប្រើប្រាស់ ។ គេថាផលិតកម្មនៅលើខ្សែព្រំដែនសមត្ថភាពផលិតកម្មក្នុងលក្ខខណ្ឌប្រើប្រាស់អស់លទ្ធភាពនូវធនធានសេដ្ឋកិច្ចដែលមាននិងមានលក្ខណៈសមស្របតាមលក្ខខណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**ក្រាហ្វិកទី 1 ៖ ផលិតកម្មស្ថិតនៅលើខ្សែកោងព្រំដែនសមត្ថភាពផលិតកម្ម (AD)**

- ចំណុច A,B,C,D នៅលើខ្សែកោងបង្ហាញឱ្យឃើញអំពីគោលការណ៍គ្រប់គ្រងផលិតកម្មទាំងពីរមុខ គឺផលិតកម្មទំនិញប្រើប្រាស់និងផលិតកម្មទំនិញវិនិយោគ ។
- ចំណុច B លើខ្សែកោង (AD) បង្ហាញឱ្យឃើញអំពីការយកចិត្តទុកដាក់ផលិតទំនិញវិនិយោគ [OM'] ច្រើនជាងទំនិញប្រើប្រាស់ [ON'] ។
- ចំណុច C លើខ្សែកោង (AD) បង្ហាញឱ្យឃើញអំពីការយកចិត្តទុកដាក់ផលិតទំនិញប្រើប្រាស់ [ON] ច្រើនជាងទំនិញវិនិយោគ [OM] ។
- ការសម្រេចចិត្តជ្រើសរើសផលិតកម្មត្រង់ចំណុចណាមួយ គឺជាការជ្រើសរើសផលិតកម្មមួយដោយកាត់បន្ថយ ឬលះបង់ផលិតកម្មមួយទៀត ។ ការលះបង់ផលិតកម្មទំនិញវិនិយោគ ដើម្បីផលិតកម្មទំនិញប្រើប្រាស់ គេហៅថា ការលះបង់តម្លៃកាលានុវត្តភាព ។ ក្រាហ្វិកទី1 តាងផលិតកម្មលើខ្សែព្រំដែនសមត្ថភាពផលិតកម្ម នាំមកនូវសេចក្តីសន្និដ្ឋានលើ 3ចំណុចសំខាន់ៗ ។

គ្រប់ចំណុចដែលស្ថិតនៅលើខ្សែកោងសមត្ថភាពផលិតកម្ម បង្ហាញឱ្យឃើញពីការប្រើប្រាស់ដោយចំកន្លែងត្រឹមត្រូវតាមពេលវេលា និងសមស្របទៅនឹងលក្ខខណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ច ។

## 3.2. ផលិតកម្មនៅក្រោមខ្សែព្រំដែនសមត្ថភាពផលិតកម្ម

ក្រាហ្វិកដដែល ផលិតកម្មត្រង់ចំណុច F ស្ថិតនៅក្រោមខ្សែព្រំដែនសមត្ថភាពផលិតកម្ម មានន័យថា ស្ថិតក្នុងមជ្ឈដ្ឋានដែលផលិតកម្មទទួលផលតិចជាងការដែលអាចផលិតទៅបាន ។ កត្តានេះបណ្តាលមកពីការប្រើប្រាស់ធនធានសេដ្ឋកិច្ចមិនទាន់អស់លទ្ធភាព ដោយមូលហេតុ

- ខ្វះបច្ចេកវិទ្យាទំនើប *ឧទាហរណ៍* ការខ្វះបច្ចេកវិទ្យាក្នុងផលិតកម្មកសិកម្ម ។
- ការងារចាត់ចែងនិងការគ្រប់គ្រងមិនសមស្របទៅនឹងការអភិវឌ្ឍ *ឧទាហរណ៍* ការប្រើប្រាស់ធនធានមនុស្សមិនចំទីកន្លែង ការបាត់បង់ពេលម៉ោងធ្វើការជាដើម ។

## 3.3. ផលិតកម្មនៅក្រៅខ្សែព្រំដែនសមត្ថភាពផលិតកម្ម

ក្រាហ្វិកដដែល ប្រសិនបើគេជ្រើសរើសយកផលិតកម្មត្រង់ចំណុច E ដែលស្ថិតនៅក្រៅ "ខ្សែព្រំដែនសមត្ថភាពផលិតកម្ម"មានន័យថា គេជ្រើសរើសយកវិធានការចាត់ចែងមួយ ដែលធ្វើឱ្យផលិតកម្មមានសមត្ថភាពខ្ពស់ហួសពីសមត្ថភាពផលិតកម្មធម្មតាដែលបានកំណត់ទុក ។ វិធានការនេះគឺមិនត្រឹមតែអាចប្រើប្រាស់ធនធានដែលមានដោយចំទីកន្លែងប្រើប្រាស់ពេលវេលាឱ្យមានប្រសិទ្ធភាព

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

និងស្របតាមលក្ខខណ្ឌនៃការអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែការប្រើប្រាស់ធនធាននោះមានភាពស័ក្តិសិទ្ធិថែមទៀត មានដូចជាការប្រើរបៀបគ្រប់គ្រងសេដ្ឋកិច្ចសមស្រប ការប្រើបច្ចេកវិទ្យាទំនើប ការធ្វើសុក្រឹតកម្មធនធាន ដូចជា ការរកឃើញទីកន្លែងធនធានធម្មជាតិថ្មីដែលអាចប្រើប្រាស់បាន ហើយសមស្របដូចជា រ៉ែ វត្ថុធាតុដើម ការប្រមូលផ្តុំកម្លាំងពលកម្មថ្មី ដែលពីដើមជាកម្លាំងអសកម្ម ការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាតិទៅក្នុងសេដ្ឋកិច្ចតំបន់ ពិភពលោកជាដើម ។

ដោយសារការជ្រើសរើសយកផលិតកម្មដែល នៅក្រៅខ្សែព្រំដែនសមត្ថភាពផលិតកម្ម ខ្សែកោង (AD)នឹងហក់ឡើងទៅដល់ខ្សែកោង (A1D1) (ក្នុងក្រាហ្វិកទី 2) មានន័យថា ទាំងទំនិញវិនិយោគ ទាំងទំនិញប្រើប្រាស់មានកំណើនប្រហាក់ប្រហែលគ្នា នៅពេលដែលមានការប្រមូលផ្តុំធនធានធម្មជាតិ ទុនវិនិយោគ ធនធានមនុស្ស បច្ចេកវិទ្យា និងរបៀបគ្រប់គ្រងសេដ្ឋកិច្ចសមស្រប កើតមានក្នុងពេលតែមួយនិងចែកចាយស្មើគ្នាក្នុងគ្រប់វិស័យ ។




*ខ្សែព្រំដែនសមត្ថភាពផលិតកម្មថ្មី (A1D1)*
*ផលិតកម្មស្ថិតនៅក្រៅខ្សែព្រំដែនសមត្ថភាពផលិតកម្ម (AD)*

ម្យ៉ាងទៀត ដូចដែលបានរៀបរាប់ខាងលើ គេអាចបង្កើនសមត្ថភាពផលិតកម្មឱ្យហួសខ្សែព្រំដែនសមត្ថភាព តាមរយៈការផលិតទំនិញ វិនិយោគជំហានដំបូង [OP] ដោយកាត់បន្ថយ

ផលិតកម្មទំនិញប្រើប្រាស់ឱ្យនៅត្រឹម [OQ] (ក្រាហ្វិកទី 3) ។ នៅពេលនោះ ផលិតកម្មចេញពី




*ខ្សែព្រំដែនសមត្ថភាពផលិតកម្មថ្មី (A1D1)*
*ការកាត់បន្ថយផលិតកម្មទំនិញប្រើប្រាស់*

ចំណុច B នៅលើខ្សែកោង (AD) សំដៅទៅចំណុច E នៅលើខ្សែកោង (A1D1) តែម្តង ដោយការសន្សំភាគច្រើន គឺសម្រាប់បណ្តាក់ទុនលើទំនិញវិនិយោគនិងកាត់បន្ថយទុន សម្រាប់វិនិយោគលើផលិតកម្មទំនិញប្រើប្រាស់ ។

## 4. សន្និដ្ឋាន

ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការជ្រើសរើសរបៀបគ្រប់គ្រងផលិតកម្ម ដើម្បីជំរុញការអភិវឌ្ឍមានសារៈសំខាន់ណាស់ ។ ដូចនេះហើយ ទើបនៅក្នុងបណ្តាប្រទេសនីមួយៗក្នុងសកលលោក គេឃើញមានការជួបប្រជុំគ្នារវាងបណ្តាអ្នកសេដ្ឋកិច្ចនៅក្នុងជួររដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហា តើអ្នកណាជាអ្នកជ្រើសរើសនិងកំណត់លើការបង្កើន "សមត្ថភាពផលិតកម្ម ?" តើត្រូវធ្វើការជ្រើសរើសអ្វីខ្លះ ដើម្បីបង្កើនសមត្ថភាពផលិតកម្ម ពីចំណុច C ទៅចំណុច B? ឬដើម្បីបង្កើនសមត្ថភាពផលិតកម្មពីចំណុច B ទៅចំណុច G? ឬត្រូវការបន្ថយមកនៅត្រឹមចំណុច F? ដើម្បីផ្តល់ជាលទ្ធផលចុងក្រោយ គឺការបែងចែកធនធានឱ្យដល់មនុស្សគ្រប់វណ្ណៈក្នុងសង្គមជាតិ ។ ប្រវត្តិសាស្ត្រនៃការអភិវឌ្ឍសង្គមមនុស្សបានចារទុកព្រឹត្តិការណ៍នៃការបែងចែកធនធានតាមរបៀបគ្រប់គ្រងសេដ្ឋកិច្ចបីផ្សេងគ្នាគឺតាមរបៀបគ្រប់គ្រងសេដ្ឋកិច្ចតាមបែបបញ្ជា តាមបែបទីផ្សារសេរី និងតាមបែបចម្រុះ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## សំណួរ

1. ចូរអ្នកនិយាយប្រាប់សិស្សក្នុងថ្នាក់របស់អ្នកអំពីសមត្ថភាពផលិតឬ អានុភាពនៃឧបករណ៍គ្រឿងម៉ាស៊ីនណាមួយដែលអ្នកបានស្គាល់ ។ ***ឧទាហរណ៍*** ខ្ញុំបានដឹងថាម៉ាស៊ីនកិនស្រូវនៅភូមិខ្ញុំមានសមត្ថភាពកិនស្រូវក្នុង 1 ថ្ងៃបាន 300 បាវ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. ដូចម្តេចហៅថាសមត្ថភាព និងព្រំដែនសមត្ថភាពផលិតកម្ម ? ចូរផ្តល់ឧទាហរណ៍ ។
   ខ. តើសមត្ថភាពផលិតកម្មមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
   គ. តើអ្វីដែលជាចំណោទបញ្ហាសំខាន់ចំពោះអ្នកសេដ្ឋកិច្ចចំពោះការងារផលិតកម្ម ?
3. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

**ការងារប្រតិបត្តិ**

ចូរអ្នកធ្វើការបកស្រាយក្រាហ្វិកនេះលើចំណុច A,B,C,E និង F ដោយឧបមាថា អ្នកជាអ្នកគ្រប់គ្រងផលិតកម្មមួយ ។

*ក្រាហ្វិកទី 1*




*ខ្សែកោងព្រំដែនសមត្ថភាពផលិតកម្ម (AD)*

## សំណួរបញ្ចប់ជំពូកទី១

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ**

1. សេដ្ឋកិច្ច គឺជាការសាកសួរថា

☐ ក. តើទំនិញអ្វីដែលគេត្រូវផលិត ? ☐ ខ. តើផលិតឡើងយ៉ាងដូចម្ដេច ?

☐ គ. តើផលិតឡើងសម្រាប់អ្នកណា ? ☐ ឃ. តើផលិតនៅពេលណា ?

2. មុខទំនិញដែលលក់បានច្រើន ជាមុខទំនិញដែល

☐ ក. មានតម្រូវការច្រើន ☐ ខ. ប្រើប្រាស់បានយូរ

☐ គ. ពិបាករក ☐ ឃ. មានគុណភាពខ្ពស់ ។

3. ក្នុងការដោះដូរ ថ្លៃស្ថិតក្រោមៈ

☐ ក. ឥទ្ធិពលចំណូល ☐ ខ. ឥទ្ធិពលជំនួស

☐ គ. ឥទ្ធិពលចំណាយ ☐ ឃ. ឥទ្ធិពលតម្រូវការ ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រស្រាវជ្រាវរក ..............................បញ្ហាប្រើប្រាស់ធនធានសេដ្ឋកិច្ច ឬ.......................... ដែលយើងមានដោយកម្រនិងគ្រប់គ្រងផលិតកម្មទាំងអស់ឱ្យចំទីកន្លែង ពេលវេលា និងប្រកបដោយចភាពស័ក្តិសិទ្ធិ ដើម្បីបំពេញឱ្យបាននូវតម្រូវការរបស់សង្គមមនុស្ស ។

**III. ចូរឆ្លើយសំណួរខាងក្រោម**

1. ហេតុអ្វីបានជាគេថា ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារ ពុំមានគោលការណ៍សីលធម៌ ?
2. មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចផលិតកម្មមានអ្វីខ្លះ ? ចូរអ្នករៀបរាប់ ។
3. តើមតិដែលគាំទ្រសេដ្ឋកិច្ចបញ្ជាមានទឡ្ហីករណ៍ដូចម្ដេចខ្លះ ?
4. នៅទីផ្សារ តើថ្លៃទំនិញ ឬថ្លៃសេវាកម្មត្រូវបានកំណត់ឡើងដោយវិធីណា ? ចូរពន្យល់ ។
5. រវាងផលិតផលក្នុងស្រុកសរុបនិងផលិតផលជាតិសរុប តើមួយណាជាអ្នកបង្ហាញសក្ដានុពលនៃផលិតកម្មរបស់ជាតិ ? ហេតុអ្វី ?
6. តើសមត្ថភាពផលិតកម្មជាអ្វី ? មានប៉ុន្មានប្រភេទ ? ចូរពន្យល់ប្រភេទនីមួយៗ ។

youtube.com/moeys kinfo.moeys.gov.kh facebook.com/moeys.gov.kh

# ជំពូកទី 2 រដ្ឋនិងសេដ្ឋកិច្ច




*ប្រជុំថ្នាក់តំបន់ផ្អែកលើបទពិសោធន៍ ASEAN នៅខេត្តសៀមរាប 2009*

នៅក្នុងជំពូកនេះ សិស្សសិក្សាអត្ថន័យនៃបញ្ញត្តិ ម៉ាក្រូសេដ្ឋកិច្ច មីក្រូសេដ្ឋកិច្ច ការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច សេដ្ឋកិច្ចកម្ពុជា តួនាទីរដ្ឋក្នុងដំណើរការសេដ្ឋកិច្ច ប្រភេទតួនាទីរបស់រដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារ ចំណូលជាតិ គោលនយោបាយប្រាក់ចំណូលនិងសារពើពន្ធ ជាតូបនីយកម្មនិងឯកជនូបនីយកម្ម ពលកម្មនិងប្រាក់បៀវត្ស ភាពគ្មានការងារធ្វើ វិបត្តិសេដ្ឋកិច្ច កម្មវិធីជាតិសម្រាប់និតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ។

facebook.com/moeys.gov.kh

មេរៀនទី

# 1 មីក្រូនិងម៉ាក្រូសេដ្ឋកិច្ច

**ចប់មេរៀននេះ សិស្សអាច**

- ❑ បកស្រាយទស្សនវិស័យមីក្រូនិងម៉ាក្រូសេដ្ឋកិច្ច ។
- ❑ បង្ហាញអត្ថន័យមីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច ។
- ❑ បង្ហាញភាពខុសគ្នារវាងមីក្រូនិងម៉ាក្រូសេដ្ឋកិច្ច ។

ដើម្បីសិក្សាម៉ាក្រូសេដ្ឋកិច្ច គេត្រូវមានការយល់ដឹងអំពីមីក្រូសេដ្ឋកិច្ច ។ តើមីក្រូសេដ្ឋកិច្ចសិក្សាអំពីបញ្ហាអ្វី ? តើម៉ាក្រូសេដ្ឋកិច្ចមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយមីក្រូសេដ្ឋកិច្ច ? ហើយវាមានភាពខុសគ្នាដូចម្តេចខ្លះ ?

## 1. ទស្សនទានរបស់វិទ្យាសាស្ត្រសេដ្ឋកិច្ចអំពីមីក្រូនិងម៉ាក្រូសេដ្ឋកិច្ច

តាមការសិក្សាស្តីពីជីវភាពសេដ្ឋកិច្ច គេរកឃើញថា វិទ្យាសាស្ត្រសេដ្ឋកិច្ចមានទំនាក់ទំនងជាឫសគល់យ៉ាងជ្រៅនៅក្នុងទស្សនវិជ្ជាស្តីពីសង្គម ។ ទស្សនៈនេះ មានគោលបំណងវែកញែកនិងពន្យល់អំពីដំណើរការផលិតនិងចែកចាយផលិតផលទៅលើទីផ្សារ ។ តើគេត្រូវធ្វើដូចម្តេច ដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការដែលគ្មានព្រំដែនក្នុងលក្ខខណ្ឌដែលធនធានធម្មជាតិមានកំណត់? ហេតុដូចម្តេចបានជាគេនិយាយថា សេដ្ឋកិច្ចទីផ្សារមានយុត្តិធម៌ ប៉ុន្តែគ្មានសីលធម៌ ?

## 2. មីក្រូសេដ្ឋកិច្ច

មីក្រូសេដ្ឋកិច្ចជាផ្នែកនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាអំពី

- ដំណើរការរបស់ផលិតកម្ម ការប្រើប្រាស់ធនធាន ការកំណត់ថ្លៃលើផលិតផលទំនិញ ចំនួនកម្មករនិងប្រាក់បៀវត្ស ប្រាក់ចំណូលនិងចំណាយរបស់សហគ្រាសមួយ ។ បាតុភូតនៃផ្នែកនីមួយៗរបស់សេដ្ឋកិច្ច ផលិតកម្ម ការប្រើប្រាស់មូលនិធិសម្រាប់វិនិយោគ ទីផ្សារការសន្សំ សំចៃធនធានសេដ្ឋកិច្ចដែលស្តែងឡើងអំពីការគ្រប់គ្រងនិងការត្រួតពិនិត្យសកម្មភាពសេដ្ឋកិច្ច ។

ការសិក្សាមីក្រូសេដ្ឋកិច្ច ជាការចាំបាច់សម្រាប់ស្វែងយល់ឱ្យបានកាន់តែជិតនូវយន្តការសំខាន់ៗរបស់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ការរៀបចំសហគ្រាសតាមទម្រង់ផ្សេងៗ ស្ថានភាពទីផ្សារ ការចងក្រងថ្លៃទំនិញដែលឆ្លុះបញ្ចាំងទៅនឹងថ្លៃដើម ការធ្វើផែនការហិរញ្ញវត្ថុ និងវត្ថុធាតុដើមជាដើម ។

តារាងខាងក្រោមនេះ ជារបាយការណ៍ស្ដីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាព ។ របាយការណ៍នេះផ្ដល់សារៈសំខាន់ដល់ការសិក្សាមីក្រូសេដ្ឋកិច្ច ។ វាបង្ហាញថ្លៃទំនិញមួយមុខៗនៅលើទីផ្សារក្នុងប្រទេស ។

**របាយការណ៍សន្ទស្សន៍ថ្លៃទំនិញ ចាំបាច់ប្រចាំជីវភាពលើទីផ្សារភ្នំពេញ ប្រចាំថ្ងៃ 30 ខែមេសា ឆ្នាំ 2009**
**Commodities Price Report in Phnom Penh Markets on 30 April 2009**

| ល.រ Nº | វាយមុខទំនិញ Item | ឯកតាគិត Unit | ថ្លៃគ្រាគោល Base Price 01.01.2009 | ថ្លៃ | | | | | មធ្យម Average | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ផ្សារថ្មី New Market | ច្បារអំពៅ Chbar Ampov | ផ្សារដើមគ Domkor | អូរឬស្សី Orussey | កណ្ដាល Kandal | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
| ក. ម្ហូបអាហារ គ្រាប់ធញ្ញជាតិ បន្លែ ផ្លែឈើ(Food-Cereal-Vegetable-frults) | | | | | | | | | | |
| 1 | អង្ករផ្កាខ្ញីឬប្រហាក់ប្រហែលRice 1 | R/Kg | 2500 | 2600 | 2300 | 2500 | 2400 | 2500 | 2460 | -1.60% |
| 2 | អង្ករនាងមិញឬប្រហាក់ប្រហែល Rice 2 | - | 2000 | 2000 | 1800 | 2000 | 2000 | 2000 | 1960 | -2.00% |
| 3 | ស្រូវចម្រុះ Paddy | - | 1000 | 1100 | 1000 | 1100 | 1100 | 1100 | 1080 | 8.00% |
| 4 | សណ្ដែកបាយ Mung Been | - | 4000 | 4000 | 3000 | 3200 | 4000 | 3800 | 3600 | -10.00% |
| 5 | សណ្ដែកសៀង Been | - | 3900 | 3800 | 3000 | 3200 | 3500 | 3200 | 3340 | -14.36% |
| 6 | សណ្ដែកដីគ្រាប់ Peanuts | - | 7000 | 5000 | 4200 | 4200 | 5000 | 4200 | 4520 | -35.43% |
| 7 | ពោតក្រហមលេខ 2 Maize 2 | - | 1200 | 1200 | 1000 | 1200 | 1100 | 1100 | 1120 | -6.67% |

*ប្រភព សារព័ត៌មាន "កោះសន្តិភាព"ចុះថ្ងៃទី30 ខែ មេសា ឆ្នាំ2009*

ការសិក្សាមីក្រូសេដ្ឋកិច្ចមានទំហំតូច ប៉ុន្តែបានផ្ដោតទៅលើក្រុមហ៊ុន ឬសហគ្រាសធុនតូចនិងមធ្យម ហើយភាគច្រើនមានលក្ខណៈជាតិ ច្រើនជាងលក្ខណៈអន្តរជាតិ ។ រាល់បញ្ហាដែលកើតមានក្នុងមីក្រូសេដ្ឋកិច្ច ត្រូវបានដោះស្រាយក្នុងរង្វង់ជាតិ ។ បញ្ហាទាំងនោះមានដូចជា ការប្រកួតប្រជែងគ្នាក្នុងការដណ្ដើមអតិថិជន ប្រភពធនធាននិងបច្ចេកទេសផ្សេងៗក្នុងដំណើរការផលិតកម្មជាដើម ។ ប៉ុន្តែភាគច្រើននៃបញ្ហាកើតមាននៅលើទីផ្សារផ្ទាល់តែម្ដង នៅពេលដែលមានផលិតផលច្រើនលើសពីសេចក្ដីត្រូវការរបស់អតិថិជន ។ កត្តានេះ ធ្វើឱ្យមានវិបត្តិក្នុងការផលិតដូចជា គេត្រូវបន្ថយការផលិត បន្ថយចំនួនកម្លាំងពលកម្ម បន្ថយការប្រើប្រាស់ធនធានដែលជាវត្ថុធាតុដើម ។ល ។

## 3. ម៉ាក្រូសេដ្ឋកិច្ច

ម៉ាក្រូសេដ្ឋកិច្ចបង្កើតឡើងដោយសេដ្ឋវិទូម្នាក់ឈ្មោះ អ៊ែព្រិច (R.Frich) គឺជាផ្នែកមួយ នៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាអំពីបរិមាណសរុបនានាដែលទាក់ទងទៅនឹងសេដ្ឋកិច្ចក្នុងកម្រិតតំបន់ប្រទេស ឬតំបន់ ។ ***ឧទាហរណ៍*** ផលិតផលជាតិសរុប ការវិនិយោគ ចំណាយសរុបលើផលិតកម្ម តុល្យភាពជញ្ជីងទូទាត់ ចរន្តពាណិជ្ជកម្មក្រៅប្រទេស ចំណូលពន្ធនិងចំណាយរបស់រដ្ឋាភិបាល ជាដើម ។ល ។

ម៉ាក្រូសេដ្ឋកិច្ច គឺជាការសិក្សាវិភាគរកមូលហេតុនិងផលវិបាកនៃការអភិវឌ្ឍសេដ្ឋកិច្ច ។ ដូច្នេះ គេត្រូវយល់ដឹងអំពី

- ចរិតសេដ្ឋកិច្ចជាតិ ការរីកចម្រើននិងការមានវិបត្តិកើតឡើង បរិមាណសរុបថ្លៃទំនិញ និងសេវា កំណើនសរុបនៃផលិតផល អត្រាអតិផរណា អត្រាគ្មានការងារធ្វើ អត្រាប្តូរប្រាក់អត្រាការប្រាក់ក្នុងចរន្តសេដ្ឋកិច្ច ។ កំណើនសេដ្ឋកិច្ចទាំងរយៈពេលវែង ទាំងការប្រែប្រួលរយៈពេលខ្លី ។
- បញ្ហាសេដ្ឋកិច្ចចម្បងក្នុងជីវភាពសង្គម មានន័យថាបញ្ហាកែទម្រង់សេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងទីផ្សារទំនិញ ទីផ្សារពលកម្ម និងទីផ្សារហិរញ្ញវត្ថុ ។ល ។
- ទំនាក់ទំនងរវាងសេដ្ឋកិច្ចជាតិនិងអន្តរជាតិ ។ ការសិក្សាតាមដានវិបត្តិសេដ្ឋកិច្ចពិភពលោកនិងផលប៉ះពាល់ចំពោះសេដ្ឋកិច្ចកម្ពុជា ។
- ទីផ្សារពលកម្មនិងការពាក់ព័ន្ធនឹងជំនាញឯកទេស កម្រិតជំនាញ និងតម្រូវការទីផ្សារ ។ល ។

តារាងខាងក្រោមនេះ ជារបាយការណ៍ស្តីពីចំនួនប្រជាពលរដ្ឋនិងកម្លាំងពលកម្មនៅប្រទេសកម្ពុជា ពីឆ្នាំ 2004 ដល់ 2007 ។ របាយការណ៍នេះ មានសារៈសំខាន់សម្រាប់ការសិក្សាម៉ាក្រូសេដ្ឋកិច្ច ។ វាបង្ហាញពីចំនួនប្រជាពលរដ្ឋសរុបនិងចំនួនកម្លាំងពលកម្មសរុបតាមឆ្នាំនីមួយៗ ។

| ប្រជាពលរដ្ឋនិងកម្លាំងពលកម្មនៅកម្ពុជា(គិតជាពាន់នាក់) | | | | |
|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 |
| ប្រជាពលរដ្ឋសរុប | 13 550 | 13 829 | 14 164 | 14 446 |
| កម្លាំងពលកម្មសរុប | 7 646 | 7 907 | 8 165 | 8 402 |
| អ្នកមានការងារធ្វើសរុប | 5 677 | 5 879 | 6 085 | 6 231 |
| អ្នកធ្វើការក្នុងប្រព័ន្ធ | 371 | 411 | 463 | 499 |
| - វិស័យកាត់ដេរ | 294 | 323 | 368 | 398 |
| - វិស័យទេសចរណ៍ | 78 | 88 | 95 | 101 |
| - វិស័យរដ្ឋបាលសាធារណៈ | 335 | 335 | 335 | 335 |
| អ្នកធ្វើការក្រៅប្រព័ន្ធ | 5 306 | 5 468 | 5 622 | 5 731 |
| - នៅជនបទ | 3 973 | 4 061 | 4 145 | 4 215 |
| - នៅទីក្រុង | 1 333 | 1 407 | 1 477 | 1 516 |

ប្រភព ៖ Economic Today, Cambodia´s Business Magazine, page 26

នៅក្នុងកម្រិតអនុវត្តជាក់ស្តែង ម៉ាក្រូសេដ្ឋកិច្ចដោះស្រាយបញ្ហាសំខាន់ៗ ដូចជាវិភាគមូលហេតុនៃការរីកចម្រើនរបស់សេដ្ឋកិច្ចជាតិទាំងមូលនិងព្យាករណ៍អំពីផលប៉ះពាល់នានាដែលបណ្តាលមកពី

ការអភិវឌ្ឍនៅពេលបច្ចុប្បន្ននិងពេលអនាគតជាដើម ។ នៅក្នុងន័យនេះ មុននឹងវិភាគអំពីមូលហេតុនិងផលប៉ះពាល់នៃការអភិវឌ្ឍសេដ្ឋកិច្ច ជាបឋមគេត្រូវយល់ឱ្យបានច្បាស់និងគ្រប់ជ្រុងជ្រោយអំពីអ្វីដែលបាននឹងកំពុងកើតឡើងនៅក្នុងសង្គមសេដ្ឋកិច្ច ។

និយាយរួម ទំហំនៃការសិក្សាម៉ាក្រូសេដ្ឋកិច្ចផ្ទុយពីទំហំនៃការសិក្សារបស់មីក្រូសេដ្ឋកិច្ច ។ អ្វីៗដែលម៉ាក្រូសេដ្ឋកិច្ចសិក្សាគេប្រៀបប្រដូចទៅនឹងព្រៃឈើ ឯអ្វីៗដែលមីក្រូគេប្រដូចទៅនឹងដើមឈើ ។

ជាមួយគ្នានេះ ការកំណត់ការវិភាគក្នុងម៉ាក្រូសេដ្ឋកិច្ច ឬមីក្រូសេដ្ឋកិច្ចមិនមែនមានន័យថា ជាការវិភាគបាតុភូតសេដ្ឋកិច្ចឬការអភិវឌ្ឍសេដ្ឋកិច្ចទាំងមូល ត្រូវចែកដាច់ពីគ្នាដោយដាច់ខាតនោះទេ ។ តាមភាពជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចមួយ គេត្រូវសិក្សាវិភាគទាំងក្នុងម៉ាក្រូសេដ្ឋកិច្ចនិងក្នុងមីក្រូសេដ្ឋកិច្ច ។ បច្ចុប្បន្ននេះ ម៉ាក្រូសេដ្ឋកិច្ចមានទំនាក់ទំនងកាន់តែខ្លាំងទៅនឹងការវិភាគរួមអំពីទីផ្សារ ដូចជា ទំនិញ សេវាកម្ម ពលកម្ម ផ្សារហ៊ុនជាដើម ដើម្បីយល់ថា "ក្នុងទីផ្សារមានសកម្មភាពយ៉ាងដូចម្តេច ?" ដែលជាបឋមគេត្រូវសិក្សាអំពីឥរិយាបថរបស់សហគ្រាស ផលិតករ(អ្នកផ្គត់ផ្គង់) អតិថិជន(អ្នកទិញ ឬអ្នកប្រើប្រាស់)ពលករ ។ល ។

## 4. ភាពខុសគ្នារវាងមីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច

មីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ចមានភាពខុសគ្នាលើការសិក្សាកម្មវត្ថុសំខាន់ៗបីគឺ

- **ថ្លៃទំនិញ :** មីក្រូសេដ្ឋកិច្ចសិក្សាថ្លៃធៀប(*ឧទាហរណ៍* ថ្លៃអង្ករធៀបនឹងថ្លៃទំនិញផ្សេងៗទៀត) ចំណែកម៉ាក្រូសេដ្ឋកិច្ចវិញ គឺសិក្សាពីការកំណត់ថ្លៃមធ្យម ដោយរាប់គ្រប់ទំនិញនិងសេវា ។
- **ប្រាក់ចំណូល :** ក្នុងការសិក្សាមីក្រូសេដ្ឋកិច្ច គេសន្មតប្រាក់ចំណូលសរុបរបស់អ្នកប្រើប្រាស់ថេរ ហើយគេសិក្សាពីរបៀបដែលអ្នកប្រើប្រាស់ចាយប្រាក់ចំណូលរបស់ខ្លួន ក្នុងការទិញទំនិញផ្សេងៗ ។ ចំណែកឯនៅក្នុងការសិក្សាម៉ាក្រូសេដ្ឋកិច្ចវិញ កម្រិតនៃប្រាក់ចំណូលសរុប ឬចំណាយ គឺស្ថិតនៅក្នុងចំណោមអថេរសំខាន់ៗដែលត្រូវសិក្សា ។
- **ទិដ្ឋភាពសេដ្ឋកិច្ច :** មីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ចសិក្សាពីទិដ្ឋភាពសេដ្ឋកិច្ចផ្សេងពីគ្នា ។ ម៉ាក្រូសេដ្ឋកិច្ចសិក្សានិងវិភាគលើទិដ្ឋភាពរួម ឯមីក្រូសេដ្ឋកិច្ចសិក្សានិងវិភាគលើទិដ្ឋភាពតាមផ្នែក ។

## 5. សេចក្តីសន្និដ្ឋាន

ក្នុងការរៀបចំគោលនយោបាយផ្សេងៗ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ឬជំរុញការងារផលិតកម្ម សេវាកម្មនានា គេត្រូវមានការសិក្សាក្នុងក្របខ័ណ្ឌមីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច ។ កម្មវត្ថុម៉ាក្រូសេដ្ឋកិច្ចគឺជាការសិក្សាវិភាគបន្តពីមីក្រូសេដ្ឋកិច្ច ។

facebook.com/moeys.gov.kh youtube.com/moeys

## ? សំណួរ

1. ចូលអ្នកអានសៀវភៅសិក្សាដែលមានចំណងជើងថា "មីក្រូសេដ្ឋកិច្ច" ឬ "ម៉ាក្រូសេដ្ឋកិច្ច" ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ តើមានពាក្យណាខ្លះដែលអ្នកអាចយល់បាន ។
2. ចូរប្អូនពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោម
   ក. តើវិទ្យាសាស្ត្រសេដ្ឋកិច្ចមានទស្សនទានដូចម្ដេចខ្លះចំពោះមីក្រូនិងម៉ាក្រូសេដ្ឋកិច្ច ?
   ខ. ដូចម្ដេចដែលហៅថា មីក្រូនិងម៉ាក្រូសេដ្ឋកិច្ច ? ចូរអ្នកពន្យល់ ។
   គ. តើ "មីក្រូសេដ្ឋកិច្ច"និង"ម៉ាក្រូសេដ្ឋកិច្ច" មានភាពខុសគ្នាយ៉ាងដូចម្ដេចខ្លះ ?
   ឃ. តារាង "ប្រជាពលរដ្ឋនិងកម្លាំងពលកម្មនៅកម្ពុជា" តើព័ត៌មានអ្វី ដែលអ្នកចាប់អារម្មណ៍ជាងគេ?
   ង. ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចមួយ តើគេត្រូវសិក្សាទៅលើអ្វី ?
3. ចូរអានមេរៀននិងដកស្រង់យកចំណុចសំខាន់ៗដើម្បីចងក្រងជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

កិច្ចការប្រតិបត្តិ

តើតារាងខាងក្រោមនេះ បង្ហាញព័ត៌មានក្នុងកម្រិតមីក្រូសេដ្ឋកិច្ច ឬម៉ាក្រូសេដ្ឋកិច្ច ?

ក. តារាងផលទុន (ចំណូល) របស់រដ្ឋាភិបាលកម្ពុជា (ពាន់លានរៀល)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| **ចំណូលក្នុងស្រុកសរុប** | 1 762 | 1 769 | 2 127 | 2 626 | 2 918 | 3 286 |
| **ចំណូលពន្ធ** | 1 249 | 1 220 | 1 577 | 1 911 | 2 271 | 2 605 |
| - ពន្ធលើប្រាក់កម្រៃ | 97 | 110 | 117 | 172 | 262 | 303 |
| - ពន្ធលើគ្រឿងឧបភោគបរិភោគ (ពន្ធអាករ) | 210 | 198 | 304 | 380 | 418 | 463 |
| - ពន្ធលើតម្លៃលើស | 452 | 460 | 598 | 730 | 870 | 1 012 |
| - ពន្ធពាណិជ្ជកម្មអន្តរជាតិ | 424 | 395 | 513 | 573 | 645 | 743 |
| - ចំណូលពន្ធដទៃទៀត | 66 | 57 | 44 | 56 | 76 | 84 |
| **ចំណូលមិនមែនពន្ធ** | 513 | 545 | 549 | 715 | 647 | 681 |
| - សកម្មភាពទេចរណ៍ | 93 | 83 | 118 | 160 | 190 | 224 |

| | | | | | | |
|---|---|---|---|---|---|---|
| - អាជ្ញាប័ណ្ណនាំចេញនិងកូតាដេញថ្លៃ | 103 | 146 | 76 | 1213 | 123 | 123 |
| - ប្រៃសណីយ៍និងទូរទមនាគមន៍ | 121 | 120 | 94 | 123 | 83 | 94 |
| - ចំណូលមិនមែនពន្ធដទៃទៀត | 192 | 196 | 261 | 310 | 251 | 240 |
| **មុខចំណូលតាមអនុសញ្ញារណៈផ្សេងៗ** | | | | | | |
| - ពន្ធលើផលិតផលប្រេងឥន្ធនៈ | 377 | 445 | 442 | 460 | 500 | 580 |
| - ចំណូលរបស់នាយកដ្ឋានពន្ធដារ | 298 | 345 | 405 | 556 | 727 | 860 |
| - ចំណូលរបស់នាយកដ្ឋានគយ | 952 | 875 | 1 173 | 1 355 | 1 544 | 1 744 |

ប្រភព ៖ ដកស្រង់ពីទស្សនាវដ្ដី Cambodia Economic Watch, April 2007, EIC, p.22

ខ. តារាងអត្រានៃការឡើងថ្លៃអាហារនៅចន្លោះខែឧសភា ឆ្នាំ 2007 និងខែឧសភា ឆ្នាំ 2008

| មុខទំនិញ | អង្ករ | សាច់ជ្រូក | សាច់គោ | មាន់ ទា | ត្រី | ស៊ុត | បន្លែ |
|---|---|---|---|---|---|---|---|
| អត្រានៃការឡើងថ្លៃ(%) | 100 | 50 ទៅ 70 | 16 | 54 | 5 ទៅ 30 | 20 ទៅ 40 | 0 ទៅ 30 |

ប្រភព ៖ ដកស្រង់ពីទស្សនាវដ្ដី Cambodia Economic Watch, January 2009, EIC, p.22

គ. របាយការណ៍ស្ដីពីលទ្ធផលនៃការអង្កេត ការផ្គត់ផ្គង់អាហារមានកម្រិតទាបនៅក្នុងគ្រួសារមួយចំនួន ។

ការអង្កេតដែលបានធ្វើឡើងក្នុងរយៈពេលពី 4 ទៅ 5 ខែ មុនពេលបញ្ចប់ការច្រូតកាត់នេះ បានព្យាករណ៍ថា ចំនួនគ្រួសារប្រមាណ 74% នឹងអស់ស្រូវអង្ករ ដែលនឹងធ្វើឱ្យពួកគេបង្ខំចិត្តត្រូវទិញស្រូវអង្ករពីផ្សារបន្ថែម ដើម្បីបំពេញសេចក្ដីត្រូវការក្នុងគ្រួសារ ។

លោក ចាន់ សុផល មានប្រសាសន៍ថា "កសិករនឹងទិញអាហារនិងអង្ករដែលមានតម្លៃថោកបើពុំដូចនោះទេ ពួកគេនឹងត្រូវខ្ចីប្រាក់គេដើម្បីទិញអាហារ" គ្រួសារដែលងាយរងគ្រោះដោយការខ្វះអាហារ គឺគ្រួសារដែលរស់នៅតាមបឹងទន្លេសាបនិងតំបន់ទំនាបកណ្ដាល ។

តាមទ្រឹស្ដី ការឡើងថ្លៃផលិតផលកសិកម្មនឹងធ្វើឱ្យចំណូលរបស់កសិករដែលបានប្រឹងប្រែងផលិតលើសពីសេចក្ដីត្រូវការ មានការកើនឡើង ។ ប៉ុន្តែ ដោយហេតុថា ការងារកសិកម្មដ៏ច្រើននៅប្រទេសកម្ពុជាធ្វើឡើងក្នុងទ្រង់ទ្រាយតូច មានតែកសិករខ្មែរចំនួនមួយភាគបួនប៉ុណ្ណោះដែលធ្វើស្រែប្រាំង ពោត សណ្ដែកសៀង ដែលពេលនោះ យើងមើលឃើញថាពួកគេកំពុងតែប្រមូលផលិតផលដែលមានតម្លៃខ្ពស់ ។ (រកឃើញដោយ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍកម្ពុជា)

ប្រភព ៖ ដកស្រង់ពីទស្សនាវដ្ដី Cambodia Economic Watch, April 2007, EIC, p.22

មេរៀនទី

# 2 គោលនយោបាយសេដ្ឋកិច្ច

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់គោលបំណងសំខាន់ៗនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។
- ❑ បង្ហាញអ្វីដែលជាប្រសិទ្ធភាពនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច ។
- ❑ បង្ហាញផលប៉ះពាល់នៃការអនុវត្ត ឬមិនអនុវត្តគោលនយោបាយសេដ្ឋកិច្ច ។

ការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច មានន័យថា ការរៀបចំគោលនយោបាយនានាដែលពាក់ព័ន្ធនឹងបញ្ហាម៉ាក្រូសេដ្ឋកិច្ចឱ្យមានលក្ខណៈសមស្របតាមដំណើរអភិវឌ្ឍន៍ជាក់ស្ដែងនៃសេដ្ឋកិច្ចរបស់ប្រទេសមួយ ។ គោលនយោបាយសេដ្ឋកិច្ច សម្របសម្រួលលើគោលនយោបាយសារពើពន្ធ គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀត ដែលមានទំនាក់ទំនងនឹងម៉ាក្រូសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ។

## 1. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ជាទូទៅ គោលបំណងសំខាន់ៗនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចមានដូចតទៅ

- កាត់បន្ថយភាពគ្មានការងារធ្វើឱ្យនៅកម្រិតទាបបំផុតគឺ នៅត្រឹម "**អត្រានិកម្មភាពធម្មជាតិ**" ។
- រក្សាអត្រាអតិផរណាឱ្យនៅនឹងឬក្រោមពីរខ្ទង់(ក្រោម 10%) ។
- កាត់បន្ថយអតុល្យភាពជញ្ជីងទូទាត់ឱ្យនៅទាបបំផុតឬសម្រេចឱ្យបានជញ្ជីងទូទាត់មួយ ដែលមានលំនឹងប្រកបដោយចីរភាព ។
- គ្រប់គ្រងអត្រាប្ដូរប្រាក់បរទេសឱ្យមានលក្ខណៈតាមទីផ្សារសេរី ។
- កាត់បន្ថយការធ្វើអន្តរាគមន៍របស់រដ្ឋឱ្យនៅតិចបំផុតក្នុងការបែងចែកធនធាននិងជំរុញឱ្យថ្លៃទំនិញនិងសេវាផ្សេងៗកំណត់ដោយទីផ្សារ ។
- កាត់បន្ថយភាពក្រីក្រនិងធានាឱ្យមានសមធម៌ក្នុងការបែងចែកប្រាក់ចំណូល ។
- សម្រេចឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាព ។

ជាទូទៅ គោលបំណងជាអាទិភាពនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺធានាឱ្យមានកំណើនសេដ្ឋកិច្ច ភាពរុងរឿងប្រកបដោយចីរភាពនិងឱ្យមានការងារធ្វើពេញលេញ ។ គោលបំណងនៃគោល

នយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងបណ្ដាប្រទេសជឿនលឿនធានាឱ្យមានកំណើនសេដ្ឋកិច្ចដោយផ្អែកលើដំណើរការផលិតកម្ម ភាពមានការងារធ្វើពេញលេញ និងធ្វើឱ្យអត្រាអតិផរណាស្ថិតក្នុងកម្រិតទាប ។ ចំណែកឯគោលបំណងនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍវិញមានការកំណត់ទៅតាមបញ្ហាជាអាទិភាពជាច្រើន រួមមានកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នច្បាប់ តុលាការ និងកំណែទម្រង់ផ្នែករដ្ឋបាលសាធារណៈជាដើម ។

ប្រទេសកំពុងអភិវឌ្ឍ ដំណោះស្រាយបញ្ហាសេដ្ឋកិច្ច គឺជា "ការកំណត់អាទិភាព" គឺធ្វើយ៉ាងណារក្សាអតិផរណាឱ្យនៅកម្រិតទាប និងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចឆាប់រហ័សជាអាទិភាពចម្បង ។

ក្នុងសហរដ្ឋអាមេរិក គេអនុញ្ញាតឱ្យទីផ្សារពលកម្មមានការកែតម្រូវ ដោយយោងតាមតម្រូវការនិងការផ្គត់ផ្គង់សេរី ដើម្បីឱ្យនិកម្មភាពមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកំណើន ឬការថយចុះនៃសេដ្ឋកិច្ច ។ ប៉ុន្តែនៅបណ្ដាប្រទេសអឺរ៉ុប អ្នកសេដ្ឋកិច្ចមានកង្វល់ខ្លាំងក្នុងការរក្សាកម្រិតខ្ពស់នៃប្រាក់បៀវត្ស ដែលជាលទ្ធផលធ្វើឱ្យនិកម្មភាពមានកម្រិតខ្ពស់ជាងនៅសហរដ្ឋអាមេរិក ។ នៅប្រទេសចិនមានកំណើនសេដ្ឋកិច្ចដែលមិនធ្លាប់មានពីមុនមក ពោលគឺលើស 10% ក្នុងរយៈពេលមួយទសវត្សរ៍ ឥឡូវនេះគេភ័យខ្លាចក្រែងមានវិបត្តិសេដ្ឋកិច្ចដែលនាំឱ្យមានអតិផរណា ។

***ឧទាហរណ៍ :*** គោលនយោបាយ ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច រមែងត្រូវគេចោទថាមានផលមិនល្អទៅលើការបែងចែកប្រាក់ចំណូល ។

## 2. ប្រសិទ្ធភាពនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច

ដើម្បីសម្រេចគោលបំណងនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច រដ្ឋត្រូវប្រើប្រាស់ឧបករណ៍គោលនយោបាយសារពើពន្ធ រូបិយវត្ថុ ពាណិជ្ជកម្មក្រៅប្រទេស និងគោលនយោបាយប្រាក់ចំណូលជាដើមដែលបានសម្របសម្រួលរួចហើយ ។ ប៉ុន្តែក្នុងការប្រើប្រាស់ឧបករណ៍ខាងលើ រដ្ឋអាចជួបបញ្ហាជាច្រើន ដែលអាចធ្វើឱ្យការអនុវត្តគោលនយោបាយនោះមិនទទួលបានជោគជ័យ គឺបណ្ដាលមកពីមូលហេតុជាច្រើនដូចជា

- កង្វះប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនសូវមានការអភិវឌ្ឍ ។
- ប្រព័ន្ធផ្ដល់ព័ត៌មានមិនទាន់សម័យ ឬការផ្ដល់ព័ត៌មានមិនទាន់ហេតុការណ៍ ។
- យឺតយ៉ាវក្នុងការសម្រេចចិត្តខុស ឬអនុវត្តគោលនយោបាយ ។
- កង្វះប្រសិទ្ធភាពក្នុងការប្រតិបត្តិការងាររបស់រដ្ឋបាលសាធារណៈ ។
- អំពើគេចពន្ធនិងចរាចរណ៍ទំនិញខុសច្បាប់ ។

• ឱនភាពថវិការដ្ឋដែលកើតមានដោយសារការប្រមូលពន្ធមិនតាមគោលការណ៍កំណត់ ។

• ភាពអនាធិបតេយ្យក្នុងសកម្មភាពសេដ្ឋកិច្ច ។

ចំពោះប្រទេសកំពុងអភិវឌ្ឍ ពុំមានលក្ខខណ្ឌសេដ្ឋកិច្ច ដែលអាចអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពទេ ។ ***ឧទាហរណ៍*** កង្វះទីផ្សារហិរញ្ញវត្ថុ កង្វះទុននៃធនាគារកណ្តាល ដែលធ្វើឱ្យការអនុវត្តគោលនយោបាយរូបិយវត្ថុមិនមានប្រសិទ្ធភាព ។

## 3. ផលប៉ះពាល់នៃកង្វះការអនុវត្តគោលនយោបាយសេដ្ឋកិច្ច



*ការបំផ្លាញធនធានធម្មជាតិ*



*សំណង់អនាធិបតេយ្យនិងវិបត្តិបរិស្ថាន*



*ការរញ្ជួយដីនៅហៃទី 2010*

កង្វះការអនុវត្តគោលនយោបាយសេដ្ឋកិច្ចមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះសុខុមាលភាពសង្គម ។ ផលប៉ះពាល់ទាំងនោះមានដូចជា

• អាជីវកម្មបំពានច្បាប់និងរំលោភក្រមសីលធម៌របស់សេដ្ឋកិច្ច ។

• ការបំពុលបរិយាកាស ទឹកប្រើប្រាស់ ដែលបង្កដោយកាកសំណល់មានជាតិវិទ្យុសកម្ម ជាហេតុនាំឱ្យមានជំងឺផ្សេងៗរាលដាលពេញសហគមន៍ ។

• កង្វះប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ ។

• គ្រោះធម្មជាតិ មានភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះជាដើម ។

• ការប្រើប្រាស់ពលកម្មកុមារធ្ងន់ធ្ងរក្នុងផលិតកម្ម ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការដោះស្រាយផលប៉ះពាល់ទាំងឡាយ គឺជាបន្ទុករបស់រដ្ឋាភិបាល ។ ការសម្របសម្រួលនិងអន្តរាគមន៍របស់រដ្ឋាភិបាលចូលក្នុងបញ្ហាសេដ្ឋកិច្ចចាំបាច់ត្រូវមាន ដើម្បីការពារមិនឱ្យមានវិបត្តិអតិផរណា ភាពគ្មានការងារធ្វើ ទំនិញឡើងថ្លៃខុសធម្មតាជាដើម ។ ***ឧទាហរណ៍*** កាលពីថ្ងៃទី 7 ឧសភា ឆ្នាំ 2009 ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងតំណាងប្រទេសដៃគូអភិវឌ្ឍន៍និងក្រសួង ស្ថាប័នពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា បានបើកកិច្ចប្រជុំមួយ ដើម្បីធ្វើការពិនិត្យវាយតម្លៃស្ថានភាពប្រមូលថវិការយៈពេល 3 ខែ ដើមឆ្នាំ 2009 និងលើកទិសដៅបន្ត ។

## 4. សេចក្ដីសន្និដ្ឋាន

ការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ចមានគោលបំណងធានាកំណើនសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាព ។

ដើម្បីសម្រេចបានគោលបំណងនេះ រដ្ឋត្រូវការមានយុទ្ធសាស្ត្រចំពោះការងារសារពើពន្ធ រូបិយវត្ថុ ពាណិជ្ជកម្មក្រៅប្រទេស និងការប្រើប្រាស់ប្រាក់ចំណូលឱ្យមានប្រសិទ្ធភាព ។

### ? សំណួរ

1. វគ្គសិក្ខាសាលាមួយត្រូវបានរៀបចំឡើងនៅទីកន្លែងផ្សេងពីគ្នា ។ មុននឹងចាប់ផ្ដើមសិក្សា សិក្ខាកាមនៃវគ្គនីមួយៗត្រូវរៀបចំសម្របសម្រួលបង្កើតបទវិន័យផ្ទៃក្នុងដើម្បីអនុវត្តទាំងអស់គ្នា ។ តើអ្នកគិតថា បទវិន័យផ្ទៃក្នុងរបស់វគ្គទាំងពីរមានខ្លឹមសារដូចគ្នាដែរឬទេ ? ហេតុអ្វី ?
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. ដូចម្ដេចហៅថា ការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច ?
   ខ. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារដូចគ្នាឬទេ ? ហេតុអ្វី ?
   គ. តើអ្វីជាប្រសិទ្ធភាពនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច ? ចូរពន្យល់ ។
   ឃ. តើនឹងមានផលប៉ះពាល់យ៉ាងដូចម្ដេច ប្រសិនបើការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ចមិនទទួលជោគជ័យ ?
3. ចូរអ្នកអានអត្ថបទខាងក្រោមដោយយកចិត្តទុកដាក់និងដកស្រង់យកចំណុចសំខាន់ៗដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

### ប្រតិបត្តិ

ចូរអ្នកស្រាវជ្រាវព័ត៌មានតាមរយៈកាសែត ទស្សនាវដ្ដី វិទ្យុ ឬទូរទស្សន៍ ដើម្បីលើកឡើងអំពីការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបច្ចុប្បន្ន ។

youtube.com/moeys grade.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 3 សេដ្ឋកិច្ចកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ដំណើររីកចម្រើននៃសេដ្ឋកិច្ចកម្ពុជានៅមុនសម័យសង្គ្រាមនិងក្រោយសម័យសង្គ្រាម ។
- ❑ បង្ហាញកំណែទម្រង់ពីចរិតអភិរក្សទៅរកចរិតជឿនលឿននៃសេដ្ឋកិច្ចកម្ពុជា ។
- ❑ បង្ហាញធនធានជាមួយមូលដ្ឋាននៃសក្តានុពលសេដ្ឋកិច្ចកម្ពុជា ។

ក្រោយពីបានទទួលឯករាជ្យពីរបបអាណានិគមនិយម(ឆ្នាំ 1951 )មកទល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានការផ្លាស់ប្តូររបបគ្រប់គ្រងជាច្រើនដង ជាហេតុនាំឱ្យរដ្ឋាភិបាលនីមួយៗប្រកាន់យកមនោគមវិជ្ជាផ្សេងៗពីគ្នា ហើយក៏បានដឹកនាំកែទម្រង់សេដ្ឋកិច្ចតាមបែបផ្សេងៗពីគ្នាដែរ ។ ការរុះរើនិងការផ្លាស់ប្តូរជាច្រើនលើកច្រើនសា បានបង្ហាញថា ប្រព័ន្ធសេដ្ឋកិច្ចមានភាពច្របូកច្របល់ជាច្រើនដែលបណ្តាលឱ្យកើតមានបាតុភូតពហុសមាសភាពក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។ ជាមួយគ្នានេះដែរ ការរុះរើជាបន្តបន្ទាប់និងសង្គ្រាមស៊ីវិលជាប់មិនដាច់ក្នុងរយៈពេលជាងពីរទសវត្សរ៍(1968-1991 )ចុងក្រោយនេះបានធ្វើឱ្យប្រព័ន្ធសេដ្ឋកិច្ចជាតិទទួលរងនូវកំហូចទ្រង់ទ្រាយយ៉ាងខ្លាំងនិងបានបំផ្លាញខ្ទេចខ្ទីនូវមូលដ្ឋានសម្ភារៈបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិទៀតផង ។

## 1. សេដ្ឋកិច្ចកម្ពុជាមុនសម័យសង្គ្រាម



តាមប្រវត្តិនៃដំណើរវិវឌ្ឍរបស់ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីសម័យនៅក្រោមនឹមអាណានិគមនិយមបារាំងរហូតមកដល់សម័យសាធារណរដ្ឋខ្មែរ ចរិតលក្ខណៈសេដ្ឋកិច្ចទំនើបបានជ្រៀតចូលជាបណ្តើរៗមកក្នុងសង្គមកម្ពុជា ។ បច្ចេកទេសការងារក្នុងគ្រប់វិស័យ ជាពិសេសបច្ចេកទេសក្នុងការងារធារាសាស្ត្រ ការដាំដុះនិងចិញ្ចឹមសត្វត្រូវបានកែលំអទៅរកភាពជឿនលឿនបន្តិចម្តងៗ ។ ការប្រើម៉ាស៊ីនយន្តក្នុងកសិកម្ម បានកើតមានឡើងជាដំបូងនៅឆ្នាំ 1967 ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមការដឹកនាំរបស់

ព្រះករុណាព្រះបាទនរោត្តមសីហនុ ។ ទន្ទឹមនឹងនោះ ព្រះរាជាណាចក្រកម្ពុជាបានកសាងនិងដាក់ឱ្យមានដំណើរការរោងចក្រឧស្សាហកម្មមួយចំនួន មានរោងចក្រតម្បាញក្រចៅ តម្បាញកំណាត់ទេសឯក រោងចក្រធ្វើកៅស៊ូ ក្រែប រោងចក្រកែវ ស៊ីម៉ង់ត៍ ក្តារបន្ទះ បារី ស្ករស ត្រីខប្រអប់ ...ល. ដែលមានសមត្ថភាពផលិតដើម្បីបម្រើសេចក្តីត្រូវការក្នុងប្រទេសនិងអាចនាំផលិតផលចេញទៅក្រៅប្រទេសទៀតផង ។



ប៉ុន្តែទោះជាយ៉ាងនេះក្តី ជាទូទៅសេដ្ឋកិច្ចកម្ពុជានៅតែជាសេដ្ឋកិច្ចដែលពឹងផ្អែកលើខឿនសេដ្ឋកិច្ចឧស្សាហកម្មអន់ថយ មានលក្ខណៈបូរាណ និងប្រពៃណីនិយម និងជាប្រភេទសេដ្ឋកិច្ចឯកវប្បកម្ម ។ ការបែងចែកពលកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ចមានកម្រិតទាបបំផុត ។ ក្នុងចំណោមមនុស្ស 10 នាក់ គឺមានមនុស្ស 8 នាក់ទៅហើយ ដែលប្រកបមុខរបរកសិកម្ម នៅសល់តែ 2 នាក់ប៉ុណ្ណោះ ដែលប្រកបមុខរបរផ្សេងទៀត ។

ប្រជាកសិករភាគច្រើនលើសលប់ ប្រកបមុខរបរកសិកម្ម តាមបែបផែនផលិតកម្មបូរាណដោយពឹងផ្អែកទាំងស្រុងលើធម្មជាតិ និងគ្មានប្រើប្រាស់បច្ចេកទេសទំនើប ។

ជាទូទៅ សក្តានុពលសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកជាចម្បងលើការនាំចេញផលិតផលកសិកម្មស្រូវ ។ ក្រៅពីនេះមានការនាំចេញផលិតផល និងអនុផលព្រៃឈើ ផលិតផលនេសាទ រ៉ែត្បូងថ្ម និងផលិតផលវាយនភណ្ឌផ្សេងៗ ។

## 2. សេដ្ឋកិច្ចកម្ពុជាក្រោយសម័យសង្គ្រាម

### 2.1. ស្ថានភាពទូទៅនៃការរីកចម្រើន

បន្ទាប់ពីការដួលរលំភ្លាមនៃរបបប្រល័យពូជសាសន៍នាថ្ងៃ 7 មករា ឆ្នាំ 1979 សេដ្ឋកិច្ចប្រទេសកម្ពុជាស្ថិតនៅកម្រិតសូន្យ ។ នាពេលវិលត្រឡប់មកភូមិស្ថានកំណើតវិញ ប្រជាពលរដ្ឋកម្ពុជាជាទូទៅស្ថិតក្នុងភាពទុគ៌តខ្វះទីលំនៅ ចំណីអាហារ សម្លៀកបំពាក់ ថ្នាំសង្កូវ ហើយថែមទាំងមានជំងឺរាំរ៉ៃ ។ ប៉ុន្តែដោយការខិតខំស្តារនិងកសាងជាតិឡើងវិញរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប និងរួមទាំងឧបត្ថម្ភជាសម្ភារៈ ថវិកា និងស្មារតីពីសហគមន៍អន្តរជាតិផងពីមួយឆ្នាំទៅមួយឆ្នាំ ប្រទេសកម្ពុជាមានការលូតលាស់រីកចម្រើនជាលំដាប់មានដូចជាការលូតលាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

សេដ្ឋកិច្ច- សង្គម វប្បធម៌ សាសនាជាដើម ដែលសុទ្ធសឹងជាមូលដ្ឋានសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការទ្រទ្រង់សិទ្ធិសេរីភាព និងប្រជាធិបតេយ្យ ។

ជាការពិត ផលិតផលក្នុងស្រុកសរុបមានកំណើនរហូតដល់ 7% ពីឆ្នាំ 1999 ដល់ 2005 ហើយផលិតផលក្នុងស្រុកប្រចាំមនុស្សម្នាក់ៗមានកំណើន 4.5% ប្រចាំឆ្នាំ ។ ការលូតលាស់នេះ ភាគច្រើនបានមកពីវិស័យកសិកម្មដែលមានអត្រាកំណើន 1.2% នៃអត្រាកំណើនផលិតផលក្នុងស្រុកសរុប ដោយសារតែការអនុវត្តគោលនយោបាយទឹករបស់រាជរដ្ឋាភិបាលនិងដោយសារភាពអំណោយផលនៃកត្តាលក្ខខណ្ឌធម្មជាតិ ។ នៅឆ្នាំ 2005 អត្រាកំណើនសេដ្ឋកិច្ចជាតិមានរហូតដល់ 13.4% ក្នុងនោះអត្រាកំណើនក្នុងវិស័យកសិកម្ម 17.3% ដែលមានអត្រាកំណើនផលិតផលស្រូវដល់ទៅ 27% ។ នៅឆ្នាំ 2005 នោះ ប្រទេសកម្ពុជាបាននាំចេញជាលើកដំបូងនូវអង្ករចំនួន 800 000 តោន ដែលជាចំនួនច្រើនបំផុតក្នុងប្រវត្តិសាស្ត្រនាំអង្ករចេញគិតពីឆ្នាំ 1968 មក ដែលកាលពីឆ្នាំនោះមានការនាំចេញអង្ករច្រើនជាងបណ្តាឆ្នាំមុនៗគឺ 500 000 តោន ។

ប៉ុន្តែ ទោះបីមានការឧបត្ថម្ភគាំទ្រពីមូលនិធិអន្តរជាតិយ៉ាងណាក្តី ក៏សក្តានុពលសេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើវិស័យមួយចំនួន មានវិស័យកាត់ដេរ សំណង់ សេវាកម្ម និងទេសចរណ៍ ហើយចរិតសេដ្ឋកិច្ចមានលក្ខណៈតាមទម្លាប់ពីមុនមក ។ ប្រទេសកម្ពុជាមានផ្ទៃដីដាំដុះបង្គរប្រមាណ 4 ហិចតា និងមានមុខសញ្ញាដំណាំសំខាន់គឺ ស្រូវ និងកៅស៊ូ ។ ក្រៅពីនេះនៅមានដំណាំរួមផ្សំ និងដំណាំធញ្ញជាតិមួយចំនួនទៀត ដែលអាចប្រើប្រាស់បានសម្រាប់ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកែច្នៃ ពិសេសគឺឧស្សាហកម្មអាហារ មានដូចជាដំណាំ អំពៅ កាហ្វេ ត្នោត ដំឡូងមីជាដើម ។ ដោយឡែកព្រៃឈើដែលមានទំហំប្រមាណ 73% តាមស្ថិតិចាស់នៃប្រទេសកម្ពុជាបច្ចុប្បន្ននេះបានទទួលរងនូវការខូចខាតយ៉ាងដំណំនៅសល់តិចជាង 40% នៃផ្ទៃប្រទេសប៉ុណ្ណោះ (តាមការប៉ាន់ស្មានរបស់អ្នកជំនាញការមួយចំនួន) ។ រីឯជលផលក៏ជាមុខសញ្ញាធនធានធម្មជាតិមួយដ៏សំខាន់ហើយក៏កំពុងតែប្រឈមមុខនឹងការថយចុះផងដែរ ។

ក្រៅពីនេះ ប្រទេសកម្ពុជានៅមានធនធានផ្នែកប្រព័ន្ធជលសាស្ត្រ ដែលអាចជួយសម្រួលយ៉ាងច្រើនដល់ផ្នែកដឹកជញ្ជូន និងអាចក្លាយជាមូលដ្ឋានផលិតថាមពលវារីអគ្គិសនីដ៏សំខាន់ថែមទៀតផង ។

បន្ថែមលើនេះ ប្រទេសកម្ពុជាមានធនធានរ៉ែមួយចំនួនសំខាន់គឺ ត្បូងថ្ម ដែលបានបម្រើអាជីវកម្មរបស់ប្រជាពលរដ្ឋមួយចំនួន តាំងពីសម័យដើមរហូតដល់បច្ចុប្បន្ន ។ ក្រៅពីនេះនៅមានធនធានរ៉ែក្នុងដី និងក្រោមដី មានប្រេងកាត មាស ដែក សំណប៉ាហាំង និងបុកស៊ីតដែលភាគច្រើនកំពុងស្ថិត

ក្នុងការស្រាវជ្រាវរុករកនៅឡើយ ។ លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាភោគទ្រព្យរ៉ែខ្លះទៀតស្ថិតនៅរប៉ាត់រប៉ាយដាច់ពីគ្នា ដែលជាកត្តាពុំសូវអំណោយផលដល់ការធ្វើអាជីវកម្ម ។



ប៉ុន្តែប្រទេសកម្ពុជា ជាប្រទេសមានសក្តានុពលសេដ្ឋកិច្ចដ៏ពិសិដ្ឋផ្នែកទេសចរណ៍ ដោយសារប្រទេសនេះមានអរិយធម៌ដ៏ចំណាស់ ដែលបានបន្សល់ទុកនូវមរតកវប្បធម៌ដ៏មានតម្លៃជាច្រើនក្នុងនោះមានបេតិកភណ្ឌជា ប្រាសាទបូរាណ និងរមណីយដ្ឋានធម្មជាតិជាច្រើនកន្លែងជាដើម ដែលទាំងអស់សុទ្ធសឹងជាប្រភពធនធានមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

## 2.2. ចរិតអភិរក្សរបស់សេដ្ឋកិច្ចកម្ពុជា

ទោះបីមានការអភិវឌ្ឍជាជំហានៗជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅមានជិតជាមដោយចរិតអភិរក្សដែលជាទម្លាប់ និងជាដំណែលពីសម័យមុនៗដែលការរីកចម្រើននៅមានកម្រិត ។ ចរិតអភិរក្សទាំងនោះ មានដូចខាងក្រោម

- **ជាសេដ្ឋកិច្ចគ្រួសារតូចតាច :** ជាទូទៅ នៅក្នុងដំណើរការផលិតកម្ម គេមិនសូវឃើញមានការប្រើកម្លាំងពលកម្មស៊ីឈ្នួលទេ ជាពិសេសគឺនៅតាមតំបន់ជនបទ ។ តាមធម្មតាក្នុងជម្រើសដំបូងគឺគេប្រើកម្លាំងពលកម្មក្នុងគ្រួសារ ។
- **ជាសេដ្ឋកិច្ចបែបយថាផល :** ភាគច្រើនដំណើរការផលិតកម្មតែងតែប្រព្រឹត្តទៅដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនក្នុងគ្រួសារ ហើយមិនសូវមានទំនាក់ទំនងជាមួយទីផ្សារ ទោះបីក្នុងរយៈពេលកន្លងមកផ្នែកកសិកម្មអាចផ្គត់ផ្គង់ការនាំចេញនូវកសិផលមួយចំនួនធំក៏ដោយ ។ លើសពីនេះទំនាក់ទំនងទីផ្សារក្នុងប្រទេសកម្ពុជា ជាទំនាក់ទំនងទីផ្សារតូចតាច ដែលភាគច្រើនមាននៅតែតាមទីក្រុង និងទីប្រជុំជនធំៗប៉ុណ្ណោះ ហើយទីផ្សារក៏នៅមិនទាន់អាចបំពេញតួនាទីគ្របដណ្តប់លើយន្តការសេដ្ឋកិច្ចយថាផលនៅឡើយ ។
- ជាសេដ្ឋកិច្ច ដែលស្ទើរតែគ្មានការផ្លាស់ប្តូរសោះនៅក្នុងបែបផែនផលិតកម្មកសិកម្ម : អស់រយៈពេលរាប់សតវត្សមកហើយ ជីវភាពរបស់ប្រជាជនភាគច្រើន ច្រើនផ្អែកលើសេដ្ឋកិច្ចប្រពៃណីដែលប្រព្រឹត្តទៅដោយពុំសូវមានការទាក់ទងជាមួយនឹងស្ថាប័នឥណទានហិរញ្ញវត្ថុឡើយ ។ កន្លងមក ការវិនិយោគទុនរបស់រដ្ឋទៅលើផ្នែកសេដ្ឋកិច្ចប្រពៃណីជាពិសេសផ្នែកកសិកម្មពុំសូវ

facebook.com/moeys.gov.kh

មានលទ្ធផលល្អប្រសើរឡើយ ដោយហេតុផ្ទត់គំនិតរបស់ជនជាតិខ្មែរ មិនសូវចូលចិត្ត និងមិនសូវផ្តល់តម្លៃដល់សហាគ្រិនភាព ការធ្វើជំនួញ ធ្វើពាណិជ្ជកម្ម ការទាក់ទងជាមួយនឹងស្ថាប័នឥណទាន និងដល់វប្បធម៌បរទេសជាទូទៅតែម្តង ។

- **សេដ្ឋកិច្ចកម្ពុជាជាសេដ្ឋកិច្ចបែបវិបុលកម្ម :** កំណើនសេដ្ឋកិច្ចពឹងផ្អែកលើការលូតលាស់ខាងផ្នែកបរិមាណ ។ ***ឧទាហរណ៍*** ទិន្នផលស្រូវជាមធ្យមស្ថិតនៅកម្រិតប្រមាណពី 1តោនទៅ 1តោនកន្លះ ក្នុង 1ហិចតា ។ ជាទូទៅ បើគិតពីដើមសតវត្សមកដល់ឆ្នាំ 2009 កម្រិតទិន្នផលស្រូវជាមធ្យមនេះ គឺស្ទើរតែគ្មានការកើនឡើងឡើយ ។ ចំណែកផលធៀបជាភាគរយនៃចំនួនប្រជាជនដែលប្រកបរបរកសិកម្មក៏នៅមានតម្លៃថេរ គឺប្រមាណ 80% នៃប្រជាជនសរុប ។ ទាំងនេះមានន័យថា កំណើនស្បៀងក្នុងរយៈពេលជាច្រើនសតវត្សកន្លងមក កើតមានដោយសារកំណើនដាច់ខាតនៃចំនួនប្រជាជន និងការបង្កើតផ្ទៃដីដាំដុះប៉ុណ្ណោះ ។ ខាងក្រោមនេះ ជាក្រាហ្វិកតាងកំណើនផលិតផលកសិកម្មតាមឆ្នាំនីមួយៗដែលមានកំណើនជាបន្តបន្ទាប់ស្របគ្នានឹងកំណើនប្រជាជន ។




*ប្រភព : វែបសាយក្រសួងកសិកម្ម(ដកស្រង់ 02 កុម្ភៈ 2010 )*

## 2.3. ផលិតផលនាំចេញ

| | | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | មករា Jan. | កុម្ភៈ Feb. | Unit | |
| សម្លៀកបំពាក់ | ពាន់ឡូ | 2403.1 | 3106.6 | 2884.0 | 3704.6 | 4332.1 | 6981.8 | 7189.7 | 6692.4 | 6517.9 | 7041.1 | 5911.1 | 000.Doz | Clothing (all kind) |
| ស្បែកជើង | ពាន់គូ | 1782.0 | 1508.3 | 1523.9 | 1409.2 | 1156.0 | 1113.7 | 1734.9 | 1474.7 | 1670.4 | 2784.8 | 1642.8 | 000.Pair | Shoes |
| ផលិតផលវាយណភ័ណ្ឌ | ពាន់ឡូ | 93.3 | 236.6 | 164.8 | 131.4 | 185.8 | 95.3 | 97.5 | 222.1 | 395.9 | 578.3 | 598.6 | 000.Doz | Other Textile Product |
| ឈើមូល | ពាន់ម$^3$ | 6.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 000.M$^3$ | Timber |
| ឈើកែច្នៃផ្សេងៗ | ពាន់ម$^3$ | 90.1 | 11.3 | 10.8 | 9.2 | 9.1 | 6.8 | 7.0 | 6.0 | 2.2 | 1.6 | 2.0 | 000.M$^3$ | Other Wood Airticles |
| ផលត្រី | ពាន់តោន | 57.6 | 0.2 | 0.0 | 0.2 | 1.0 | 1.2 | 0.3 | 0.2 | 0.3 | 0.3 | 0.2 | 000.T | Fishing Products |
| កៅស៊ូ | តោន | 5872.2 | 6225.0 | 4293.0 | 3980.0 | 3980.0 | 3644.0 | 4865.0 | 2716.0 | 655.0 | 3935.0 | 3264.0 | T | Rubber |
| អង្ករ | តោន | 0.0 | 1000.0 | 3989.0 | 455.0 | 645 | 88 | 648 | 230 | 2080 | 454 | 1194 | T | Rice |
| បារី | តោន | 0.0 | 49.6 | 27.0 | 10.0 | 35.0 | 66.0 | 108.0 | 137.0 | 134.0 | 126.0 | 91.0 | T | Cigarettes |
| ផ្សេងៗ | ពាន់តោន | 2.8 | 0.4 | 2.6 | 1.1 | 2.2 | 2.6 | 3.1 | 35.2 | 1196.3 | 700.4 | 1237.5 | 000.T | Others |

*ប្រភព : ទីចាត់ការគយនិងរដ្ឋាករ*

ចាប់ពីឆ្នាំ 1980 រហូតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាបាននាំចេញផលិតផលមួយចំនួនដូចខាងក្រោម ។

### ក. ផលិតផលសំខាន់ៗនៃវិស័យកសិកម្ម នេសាទ និងព្រៃឈើ

មានដូចជា ស្រូវ ថ្នាំជក់ ត្រី សត្វចិញ្ចឹម និងឈើ ។ ក្រៅពីនេះ ផលិតផលដែលមានតម្រូវការក្នុងការនាំចេញមាន ពោត សណ្តែក ល្ង ក្តួច ដំឡូង អំពៅ គ្រាប់ស្វាយចន្ទី ម្រេច កាហ្វេ និងផ្លែឈើ ។ គួរចាប់អារម្មណ៍ថា ការធ្វើអាជីវកម្មព្រៃឈើដោយគ្មានតុល្យភាពនឹងការដាំឡើងវិញ និងការធ្វើអាជីវកម្មលើផលិតផលថ្នាំជក់ គឺជាសកម្មភាពចូលរួមផ្តល់វិបត្តិដល់បរិស្ថានធម្មជាតិនិងសុខភាពមនុស្ស ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## ខ. ផលិតផលឧស្សាហកម្ម

ផលិតផលឧស្សាហកម្មសំខាន់ដែលបម្រើការនាំចេញនៅកម្ពុជាគឺ សម្លៀកបំពាក់ និងកៅស៊ូក្រែប ។ ក្រៅពីនេះ មានផលិតផលសិប្បកម្មតម្បាញសូត្រ និងសិប្បកម្មកែច្នៃជាវត្ថុអនុស្សាវរីយ៍ ជាគ្រឿងអលង្ការជាដើម ។

## 2.4. ផលិតផលនាំចូល

| | | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | ធ្នូ Dec. | មករា Jan. | កុម្ភៈ Feb. | Unit | |
| ថ្នាំពេទ្យ | តោន | 525 | 527 | 983 | 516 | 895 | 725 | 888 | 830 | 673 | 362 | Tons | Medicine |
| បារី | 000ប៊ិច | 95 | 136 | 133 | 182 | 35 | 104 | 150 | 219 | 125 | 228 | 000ctn | Cigarettes |
| ស្រាបៀរ | 000កេស | 110 | 74 | 109 | 102 | 373 | 125 | 256 | 139 | 142 | 761 | 000ctn | Beer,Alco-hol, Soft Drinks |
| គ្រឿងឧបភោគបរិភោគ | 000តោន | 24 | 6 | 8 | 12 | 10 | 9 | 12 | 12 | 11 | 7 | 000tons | Food& Ingredients |
| បរិក្ខារសំណង់ | 000តោន | 8 | 6 | 9 | 11 | 19 | 23 | 21 | 21 | 16 | 19 | 000tons | Other Costruct Meterials |
| ស៊ីម៉ង់ត៍ | 000តោន | 72 | 76 | 83 | 101 | 80 | 109 | 87 | 75 | 37 | 72 | 000tons | Cement |
| ដែក | 000តោន | 23 | 11 | 10 | 3 | 7 | 8 | 6 | 7 | 5 | 7 | 000tons | Steel |
| គ្រឿងអគ្គិសនី | 000គ្រឿង | 23 | 32 | 20 | 12 | 14 | 18 | 22 | 12 | 8 | 8 | 000units | Electrics |
| សម្លៀកបំពាក់ប្រើប្រាស់ហើយ | 000តោន | 5 | 6 | 5 | 6 | 5 | 6 | 8 | 6 | 6 | 5 | 000tons | Clothing used |
| កំណាត់ | 000តោន | 400.4 | 0.9 | 0.9 | 0.7 | 1.1 | 0.6 | 0.8 | 0.3 | 7.6 | 0.3 | 000tons | Febric |
| យានយន្ត, ទោចក្រយានយន្ត, គ្រឿងបន្លាស់ | 000គ្រឿង | 6 | 11 | 10 | 12 | 16 | 25 | 28 | 21 | 9 | 9 | 000units | Vehicle, Motorbike, Parts |
| ប្រេងឥន្ធនៈ | 000តោន | 175 | 61 | 75 | 59 | 58 | 82 | 87 | 91 | 100 | 99 | 000tons | Petroleum |
| ផ្សេងៗទៀត | 000តោន | 0 | 32 | 39 | 30 | 68 | 40 | 60 | 57 | 51 | 96 | 000tons | Others |

*ប្រភព : ទីចាត់ការគយនិងរដ្ឋាករ*

ប្រទេសកម្ពុជា បានទទួលការនាំចូលនូវផលិតផលឧស្សាហកម្ម សិប្បកម្ម និងកសិកម្មមួយចំនួន ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ។ ផលិតផលនាំចូលសំខាន់គឺ ប្រេងឥន្ធនៈ ស៊ីម៉ង់ត៍ ដែក និងយានយន្ត ។ គួរកត់សម្គាល់ថា តម្លៃសរុបនៃទំនិញនាំចូលនៅកម្ពុជានៅមានទំហំធំជាងតម្លៃសរុបនៃទំនិញនាំចេញនៅឡើយ ***ឧទាហរណ៍*** តាមប្រភពទិន្នន័យ នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាគិតត្រឹមខែកុម្ភៈ ឆ្នាំ 2009 តម្លៃនាំចូលមាន 4 427.7 លានដុល្លារអាមេរិក ឯតម្លៃនាំចេញមាន 3 097.8 លានដុល្លារអាមេរិក ។

## 2.5. កំណែលំអចរិតអភិរក្ស និងការកាត់បន្ថយភាពក្រីក្រ

តាមរយៈការរៀបរាប់មកខាងលើយើងឃើញថា ចរិតអភិរក្សនិយមនៃប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាមិនអាចធានាបាននូវការផ្គត់ផ្គង់តម្រូវការដែលចេះតែកើនឡើងបានឡើយ ។ ដើម្បីឱ្យការអភិវឌ្ឍសេដ្ឋកិច្ចមានសន្ទុះលឿនទៅមុខទាមទារការធ្វើកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចឱ្យមានលក្ខណៈដូចខាងក្រោម

- មានមូលដ្ឋានបច្ចេកទេស និងវិទ្យាសាស្ត្រ មានបែបផែនផលិតកម្ម ដែលពឹងផ្អែកទៅលើបច្ចេកវិទ្យាទំនើប និងមានរៀបចំចាត់ចែងគ្រប់គ្រងផលិតកម្មនិងបែងចែកផលិតផលតាមបែបវិទ្យាសាស្ត្រ ។
- មានការបែងចែកពលកម្មក្នុងកម្រិតខ្ពស់ ។
- មានយន្តការគ្របដណ្តប់ និងនាំមុខដាច់ខាតនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលឈរលើមូលដ្ឋានកម្មសិទ្ធិឯកជនសេរីភាពក្នុងការជ្រើសរើស និងការប្រកបមុខរបរ មានការផលិតសម្រាប់បម្រើឱ្យទីផ្សារ ។ ក្នុងការសម្របសម្រួលដំណើរការសេដ្ឋកិច្ច រដ្ឋប្រើឧបករណ៍ប្រយោលដូចជា យន្តការច្បាប់ គោលនយោបាយសារពើពន្ធ គោលនយោបាយពន្ធដារ គោលនយោបាយវិនិយោគ និងរូបិយវត្ថុ គោលនយោបាយលើកទឹកចិត្តជាដើម ។
- ជាសេដ្ឋកិច្ចបែបប្រពលវប្បកម្ម ។ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ត្រូវពឹងផ្អែកសំខាន់លើការផ្លាស់ប្តូរផ្នែកគុណភាព ដែលផ្សារភ្ជាប់ទៅនឹងការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច ការជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យ ចំណេះដឹង និងចំណេះធ្វើថ្មីៗដើម្បីធានាកំណើនផលិតកម្ម ។

ក្នុងការអនុវត្តជាក់ស្តែង ចាប់តាំងពីឆ្នាំ 1992 ស្ថានភាពសេដ្ឋកិច្ចជាតិកម្ពុជាត្រូវបានកែទម្រង់ពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារ ។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានបើកចំហឱ្យមានការវិនិយោគទុនឯកជនក្នុងស្រុក និងដាក់ទុនបរទេសនៅក្នុងវិស័យជាច្រើន ជាពិសេសក្នុងវិស័យកសិកម្ម ។ នៅក្នុងវិស័យកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើការវិនិយោគលើដីសម្បទាន

សេដ្ឋកិច្ចសម្រាប់ការដាំដំណាំកសិឧស្សាហកម្ម ហើយនិងផលិតកម្មបម្រើការនាំចេញ ។ គោលដៅចំបងនៃការផ្តួចផ្តើមនេះ គឺដើម្បីផ្តល់ដីទំនេរសម្រាប់ការដាំដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម ដែលនិងបង្កើតការងារ និងចំណូលដល់ប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានលើកទឹកចិត្តការអប់រំបណ្តុះបណ្តាលបច្ចេកទេសកសិកម្មបែបប្រពលវប្បកម្មដើម្បីលើកកម្ពស់ទិន្នផលដំណាំគ្រប់ប្រភេទពិសេសដំណាំស្រូវ ដោយធានាបាននូវការរក្សាគុណភាពដី និងលើកកម្ពស់គុណភាពអង្ករសរីរាង្គ តាមវិធីប្រើប្រាស់ធនធាននិងផលិតផលធម្មជាតិ និងឈានទៅលុបបំបាត់ការប្រើជាតិគីមីគ្រប់ប្រភេទ ។

- គំរូកិច្ចការប្រពលវប្បកម្មដំណាំស្រូវ

ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវមានការអភិវឌ្ឍជាទូទៅនិងជាផ្លូវការនៅប្រទេសម៉ាដាកាស្កា ។ គេបានរកឃើញថាប្រព័ន្ធនេះជាបច្ចេកវិទ្យាកសិកម្មដំណាំស្រូវដែលធានាបាននូវការអភិវឌ្ឍជានិរន្តរ៍ ដែលអាចជួយដល់កសិករក្នុងការបង្កើតផលស្រូវលើដីតូចតាចរបស់គេឱ្យបានជាង 10 តោនក្នុងមួយហិចតា ដោយមិនពឹងផ្អែកលើពូជបង្កាត់ ជីគីមី និងថ្នាំគីមីកម្ចាត់សត្វល្អិត ។

នៅរដូវវស្សាឆ្នាំ 2000 អង្គការសេដាក់ (CEDAC, a Cambodian NGO, Centre d’Etudes et de Development Agricole Cambodgien) បានយកកម្មវិធីប្រពលវប្បកម្មដំណាំស្រូវទៅអនុវត្តសាកល្បងនៅខេត្តចំនួន 4 (ព្រៃវែង កណ្តាល ស្វាយរៀង កំពង់ចាម) នៃប្រទេសកម្ពុជា ដោយមានការចូលរួមពីកសិករចំនួន 28 នាក់ នៅលើដីជីវចម្រុះពឹងផ្អែកទឹកភ្លៀង ។ នៅឆ្នាំ 2009 មានកសិករជាង 80 000 នាក់ បានប្រើប្រាស់បច្ចេកទេសប្រពលវប្បកម្មនេះ ។

ខាងក្រោមនេះជារូបភាពនៃការអនុវត្តសាកល្បងកម្មវិធីប្រពលវប្បកម្មដំណាំស្រូវនៅខេត្តព្រៃវែង ។



*ការរៀបចំថ្នាល*



ការដកសំណាប



ការធ្វើដី



ការស្ទូងសំណាប



ការដកស្មៅ



ការច្រូតកាត់

## 3. សេចក្តីសន្និដ្ឋាន

ជាទូទៅ ដំណើររីកចម្រើននៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន (គិតត្រឹមឆ្នាំ 2010)ជាលទ្ធផលនៃការចូលរួមអំពីវិស័យកសិកម្ម សិប្បកម្ម សំណង់ ទេសចរណ៍ និងសេវាកម្ម ។ ភាពក្រីក្ររបស់ប្រជាជនកម្ពុជាត្រូវបានកាត់បន្ថយពី 47% មកនៅ 34.67% នៅឆ្នាំ 2004 ហើយតាមការវាយតម្លៃជាបឋម ភាពក្រីក្របានចុះមកត្រឹម 31% នៅឆ្នាំ 2007 ដោយសម្រេចបានគោលដៅកាត់បន្ថយភាពក្រីក្រជាមធ្យមជាង 1% ក្នុងមួយឆ្នាំ ស្របតាមទិសដៅអភិវឌ្ឍសហសវត្សរបស់កម្ពុជា ។ ថ្វីត្បិតក្នុងអំឡុងឆ្នាំ 2009 សេដ្ឋកិច្ចពិភពលោកបានជួបវិបត្តិយ៉ាងណាក្តី ក៏សេដ្ឋកិច្ចកម្ពុជានៅតែរក្សាបាននូវទម្រង់ដើមដ៏ល្អប្រសើរដោយសារការមានគ្រឹះកំណើន ការវិនិយោគទុនក្នុងវិស័យកសិកម្ម ការរីកលូតលាស់នៃវិស័យមិនមែនកសិកម្ម ស្ថេរភាពនយោបាយ ការចូលរួមដ៏សកម្មអំពីវិស័យឯកជន ការខិតខំធ្វើកំណែទម្រង់រដ្ឋបាលនិងអភិបាលកិច្ចលើគ្រប់វិស័យ កំណើននៃជំនួយឧបត្ថម្ភជាផ្លូវការនិងនិរន្តរភាពនៃការវិនិយោគទុនដោយផ្ទាល់ពីបរទេស ។ ម៉្យាងទៀត អាស្រ័យដោយការរៀបចំអនុវត្តគម្រោងយុទ្ធសាស្ត្រចតុកោណឆ្នាំ 2010 របស់រាជរដ្ឋាភិបាលកម្ពុជា សេដ្ឋកិច្ចកម្ពុជានៅរក្សាបានកំណើន 2% នៅឆ្នាំ 2009 និង 2010 ។ បន្ថែមលើនេះ ដើម្បីធានានូវនិរន្តភាពនៃការរីកចម្រើនសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែខិតខំយ៉ាងសកម្មក្នុងការជំរុញនិងលើកទឹកចិត្តការអនុវត្តកម្មវិធីកំណែនទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តគម្រោងយុទ្ធសាស្ត្រអភិវឌ្ឍជាតិសម្រាប់រយៈពេល 5ឆ្នាំ ដោយផ្តល់អាទិភាពទៅលើការធ្វើឱ្យប្រសើរឡើងនូវជីវភាពអ្នកក្រីក្រនៅតាមជនបទ ។

facebook.com/moeys.gov.kh
youtube.com/moeys
khou.moeys.gov.kh

## សំណួរ

1. ចូរអ្នកនិយាយប្រាប់សិស្សក្នុងថ្នាក់ទៅតាមការយល់ដឹងរបស់អ្នក រវាងជនដែលផលិតបានជាផលិតផលប្រភេទណាមួយសម្រាប់លក់និងជនដែលមិនមានការផលិតនូវផលិតផលអ្វីមួយសម្រាប់លក់ តើជនណាមួយមានប្រៀបខាងសេដ្ឋកិច្ច?
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីឆ្លើយសំណួរដូចខាងក្រោមនេះ
   ក. ចូររៀបរាប់ស្ថានភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា មុនសម័យសង្គ្រាម ។
   ខ. ចូររៀបរាប់ភាពទូទៅនៃការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក្រោយសម័យសង្គ្រាម ។
   គ. តើសកម្មភាពអ្វីខ្លះជាកំណែទម្រង់ចរិតអភិរក្សនៃសេដ្ឋកិច្ចកម្ពុជា?
   ឃ. ចូរបង្ហាញធនធានជាមូលដ្ឋាននៃការសក្ដានុពលសេដ្ឋកិច្ចកម្ពុជា ។
3. ចូរអ្នកអានអត្ថបទមេរៀនឡើងវិញ ដោយយកចិត្តទុកដាក់ និងកត់ត្រាដោយសង្ខេបនូវចំណុចទាំងឡាយណាដែលអ្នកយល់ថាសំខាន់ ។

## ប្រតិបត្តិ

ចូរអ្នកសង្កេតរកចំណុចណាខ្លះដែលត្រូវធ្វើកំណែលំអ ដើម្បីជំរុញការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅសហគមន៍ដែលអ្នករស់នៅ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 4 តួនាទីរដ្ឋក្នុងដំណើរសេដ្ឋកិច្ច

## ចប់មេរៀននេះ សិស្សអាច

- បង្ហាញតួនាទីទូទៅរបស់រដ្ឋនិងតួនាទីរដ្ឋក្នុងសេដ្ឋកិច្ច ។
- បង្ហាញតួនាទីរដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារនិងក្នុងសេដ្ឋកិច្ចបញ្ជា ។
- ពន្យល់តួនាទីក្នុងសេដ្ឋកិច្ចចម្រុះ ។
- បង្ហាញតួនាទីរដ្ឋក្នុងប្រទេសកំពុងអភិវឌ្ឍ ។



*មន្ត្រីកាំកុងត្រូលកំពុងពិនិត្យគុណភាពទំនិញនៅតាមផ្សារ*

រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងយន្តការសេដ្ឋកិច្ច ។ នាសតវត្សទី 18 សេដ្ឋវិទូបារាំង ដែលមាននិន្នាការខាងពាណិជ្ជកម្មបានអះអាងថា "**រដ្ឋគួរផ្ដោតការយកចិត្តទុកដាក់លើការជំរុញផ្នែកពាណិជ្ជកម្មនិងឧស្សាហកម្ម**" ។ ចំណែកលោក អាដាមស្មីត យល់ថា "**នៅក្នុងសកម្មភាពសេដ្ឋកិច្ចរដ្ឋត្រូវកំណត់តួនាទីរបស់ខ្លួន**" ។

youtube.com/moeys
facebook.com/moeys

# 1. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ច

រដ្ឋ មានតួនាទីពីរក្នុងសេដ្ឋកិច្ច គឺតួនាទីរួមនិងតួនាទីដោយឡែក ។

## 1.1. តួនាទីរួម

ការពារយន្តការសេដ្ឋកិច្ច ដោយបង្កើតឡើងនូវមូលដ្ឋានច្បាប់និងបរិស្ថានសង្គមចាំបាច់សម្រាប់ជំរុញនិងសម្របសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ច ។ តួនាទីនេះ ផ្សារភ្ជាប់ទៅនឹងការការពារការប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ច ការសម្របសម្រួលការងារស្ថាប័ននិងភ្នាក់ងារសេដ្ឋកិច្ចនានា ដោយឈរលើមូលដ្ឋានច្បាប់និងការធានានូវស្ថិរភាពនិងសន្តិសុខសង្គមផងដែរ ។

ធ្វើស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច ពោលគឺ ជំរុញឱ្យមានកំណើនផលិតផលក្នុងស្រុកសរុបតាមដានអត្រាអតិផរណានិងកាត់បន្ថយអត្រានិកម្មភាព ដែលកើតមានឡើងដោយសារការផ្លាស់ប្តូរស្ថានភាពនិងបញ្ហាជំរុញការលូតលាស់សេដ្ឋកិច្ច ។

កែតម្រូវការបែងចែកទ្រព្យសម្បត្តិ សម្ភារៈ និងធនធានរវាងស្រទាប់វណ្ណៈផ្សេងៗគ្នានិងរវាងសាខាសេដ្ឋកិច្ច ព្រមទាំងរវាងបណ្តាតំបន់នានា នៅក្នុងក្របខ័ណ្ឌប្រទេសទាំងមូល ដើម្បីធានានូវស្ថិរភាព សមភាព យុត្តិធម៌សង្គម និងដើម្បីបង្កើតឡើងនូវតុល្យភាព ព្រមទាំងសមាមាត្រក្នុងការរីកចម្រើនសម្រាប់សេដ្ឋកិច្ចជាតិទាំងមូល ហើយនិងជំរុញឱ្យមានការកែសម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងគោលដៅធានាប្រសិទ្ធភាពនៃការអភិវឌ្ឍជាតិប្រកបដោយចីរភាព ។

## 1.2. តួនាទីដោយឡែក

តួនាទីដោយឡែករបស់រដ្ឋក្នុងសេដ្ឋកិច្ច គឺអាស្រ័យទៅលើប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ច ប្រសិនបើសង្គមនោះមានប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបសេដ្ឋកិច្ចបញ្ជា រដ្ឋមានតួនាទីស្ទើរទាំងស្រុងលើដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ។ ក្នុងករណីនេះ រដ្ឋដោះស្រាយបញ្ហាសំខាន់ៗ ទាក់ទងទៅនឹងផលិតកម្ម កំណត់ការប្រើប្រាស់ និងការបែងចែកធនធានសេដ្ឋកិច្ច ។

ផ្ទុយពីនេះ ប្រសិនបើសង្គមនោះមានប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបសេដ្ឋកិច្ចសេរី រដ្ឋមានតួនាទីតិចតួចក្នុងសេដ្ឋកិច្ច ។ ជាទូទៅ ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការធ្វើអន្តរាគមន៍របស់រដ្ឋ មានទិសដៅបំពេញភាពខ្វះចន្លោះរបស់យន្តការទីផ្សារ ។

## 2. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារ

ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ កម្មសិទ្ធិលើមធ្យោបាយផលិតកម្មមួយផ្នែកធំស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងផ្នែកឯកជន ។ ឯយន្តការគ្រប់គ្រងនិងសម្របសម្រួលផ្អែកទាំងស្រុងលើយន្តការទីផ្សារ ។ សេចក្តីសម្រេចក្នុងការបែងចែកធនធានអនុម័តដោយភ្នាក់ងារសេដ្ឋកិច្ចឯកជន ។ ក្នុងទីផ្សារ សកម្មភាពផលិតកម្មនិងការផ្លាស់ប្តូរទំនិញ សេវាកម្មទូទៅមានសេរីភាពបរិបូរ ។ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ គ្រប់គ្រងដោយខ្លួនឯងនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួននិងប្រឹងប្រែងធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ខ្លួនកាន់តែប្រសើរឡើង ។ លោក អាដាមស្ម៊ីត សេដ្ឋវិទូក្លាស៊ិក បានអះអាងក្នុងស្នាដៃរបស់លោកឈ្មោះ "ការសិក្សាស្រាវជ្រាវស្តីពីធម្មជាតិនិងមូលហេតុកើតមាននូវប្រភពធនធានប្រជាពលរដ្ឋ ដែលបាននិពន្ធក្នុងឆ្នាំ 1776" ក្នុងជីវភាពសេដ្ឋកិច្ច សកម្មភាពមនុស្សម្នាក់ៗអនុលោមតាមអត្ថប្រយោជន៍ផ្ទាល់ខ្លួន ដែលមើលទៅហាក់ដូចជា ដៃអរូបសម្រាប់ចូលរួមបង្កើតអត្ថប្រយោជន៍សង្គមទាំងមូល ។ ប្រសិនបើដៃអរូបមានសកម្មភាពក្នុងសេដ្ឋកិច្ចនាំឱ្យការបែងចែកធនធានសេដ្ឋកិច្ចមានប្រសិទ្ធភាព តើចាំបាច់មានការធ្វើអន្តរាគមន៍របស់រដ្ឋធ្វើអ្វី ?

ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបទីផ្សារមានលក្ខណៈអំណោយផលល្អប្រសើរ ពីព្រោះ

- មានប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ច ។
- ផលិតកម្មមានស្ថិរភាពនិងអាចដោះស្រាយបញ្ហានិកម្មភាពបាន ។
- សេដ្ឋកិច្ចមានកំណើនឆាប់រហ័ស ។

ដូចនេះ គេយល់ថាក្នុងសកម្មភាពសេដ្ឋកិច្ចរដ្ឋពុំចាំបាច់ធ្វើអន្តរាគមន៍ទេ ។ រដ្ឋមានតួនាទីត្រឹមជាអ្នកការពារកម្មសិទ្ធិ ជាអ្នកបង្កើតនិងចាត់ចែងស្ថាបន័សង្គម មូលដ្ឋានច្បាប់ផ្សេងៗដែលចាំបាច់សម្រាប់ជំរុញនិងសម្របសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ ។

## 3. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចផែនការ

ក្នុងប្រព័ន្ធគ្រប់គ្រងបែបសេដ្ឋកិច្ចផែនការឬសេដ្ឋកិច្ចបញ្ជា រដ្ឋមានកម្មសិទ្ធិលើកត្តាផលិតកម្មស្ទើរតែទាំងអស់ ។ ឯយន្តការគ្រប់គ្រងនិងការសម្របសម្រួលផ្អែកទៅលើមូលដ្ឋានសេដ្ឋកិច្ចផែនការមានន័យថាដំណើរការផលិតកម្ម ស្ថិតនៅក្រោមការកំណត់របស់រដ្ឋ ។ ដំណោះស្រាយធំៗ ទាក់ទងទៅនឹងផលិតកម្ម ការប្រើប្រាស់ ការបែងចែកក៏ស្ថិតនៅក្រោមការកំណត់របស់រដ្ឋ ។

ដោយហេតុសហគ្រាសជាកម្មសិទ្ធិរដ្ឋ ដូចនេះ សកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចក្នុងផលិតកម្ម ការចែកចាយ ការផ្លាស់ប្តូរទំនិញនិងសេវាកម្មផ្សេងៗ ស្ថិតនៅក្រោមការត្រួតពិនិត្យនិងត្រូវអនុវត្តតាមផែនការរបស់រដ្ឋ ។

និយាយរួម ផែនការផលិតកម្មរបស់សហគ្រាសនីមួយៗ ចាត់ចែងនិងត្រួតពិនិត្យដោយរដ្ឋដែលមានក្រុមប្រឹក្សាផែនការជាតំណាង ហើយជាទូទៅផែនការទាំងនេះ ជាអ្នកកំណត់ចំពោះសហគ្រាសនីមួយៗ អំពីបរិមាណធនធាន បរិមាណផលិតផល រហូតដល់បញ្ហាតើត្រូវផលិតអ្វី ? សម្រាប់អ្នកណា ? ចំនួនប៉ុន្មាន ? ក្នុងថ្លៃប៉ុន្មាន ?

ក្នុងសេដ្ឋកិច្ចបញ្ជា រដ្ឋចូលធ្វើអន្តរាគមន៍កាន់តែជ្រៅទៅក្នុងបញ្ហាសេដ្ឋកិច្ច ជាពិសេសក្នុងដំណើរការបង្កើត ផលិតផលសង្គមតាមរយៈរោងចក្រឬសហគ្រាសដែលប្រព្រឹត្តទៅដោយមិនស្ថិតនៅក្រោមឥទ្ធិពលក្រឹត្យក្រមតម្រូវការនិងការផ្គត់ផ្គង់ ។ ម្យ៉ាងទៀត ការអនុវត្តតួនាទីនេះ ជាទូទៅមិនប្រតិបត្តិតាមក្រឹត្យក្រមសេដ្ឋកិច្ចទេ តែស្ថិតនៅក្រោមការបញ្ជារបស់រដ្ឋ នៅពេលដែលរដ្ឋយល់ថាមានករណីចាំបាច់និងយល់ថាស្ថានភាពសេដ្ឋកិច្ចត្រូវការបទបញ្ជាដើម្បីជំរុញការអភិវឌ្ឍ ។

***ឧទាហរណ៍*** : ដូចជាប្រទេសជប៉ុន យើងតែងហៅថាជាប្រទេសសេរី ឬប្រទេសដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចទីផ្សារ ។ តែការពិតក្នុងសេដ្ឋកិច្ចជប៉ុន រដ្ឋមានតួនាទីយ៉ាងសកម្មដោយនៅក្នុងនោះ មិនត្រឹមតែប្រើតួនាទីបែបប្រយោលនិងដោយត្រង់ប៉ុណ្ណោះទេ គឺរដ្ឋប្រើបទបញ្ជាផ្សេងៗ សម្រាប់ធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ច ។

## 4. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចចម្រុះ

គួរកត់សម្គាល់ថា ក្នុងការអនុវត្តតួនាទីរបស់ខ្លួន មានករណីខ្លះ រដ្ឋប្រើដល់បទបញ្ជា ដែលសរសេរឡើងដោយសេដ្ឋវិទូនិងទស្សនវិទូ ដើម្បីធ្វើឱ្យប្រាកដថា ការសម្រេចចិត្តនោះបានបម្រើឱ្យការប្រតិបត្តិសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពនិងមានការអភិវឌ្ឍពិតប្រាកដ ។ ប្រការនេះអាស្រ័យទៅនឹងកត្តាប្រវត្តិសាស្ត្រនៃការអភិវឌ្ឍភូមិសាស្ត្រ ស្ថានភាពនយោបាយ សង្គមសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។

ក្នុងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចចម្រុះ រដ្ឋនិងភ្នាក់ងារសេដ្ឋកិច្ចឯកជនមានតួនាទីសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាជាមូលដ្ឋានរបស់សេដ្ឋកិច្ច តើត្រូវផលិតអ្វី ? ផលិតដូចម្តេច ? សម្រាប់អ្នកណា? ម្យ៉ាងទៀត ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចនីមួយៗ ច្រើនស្ថិតនៅចន្លោះតាមផ្នែក ឬ មួយនៅខាងផ្នែកសេដ្ឋកិច្ចទីផ្សារសេរី ហៅថាសេដ្ឋកិច្ចចម្រុះបែបទីផ្សារឬមួយនៅក្នុងផ្នែកសេដ្ឋកិច្ចផែនការហៅថាសេដ្ឋកិច្ចចម្រុះបែបផែនការ ។

### 4.1. សេដ្ឋកិច្ចចម្រុះបែបផែនការ

សេដ្ឋកិច្ចអតីតសហភាពសូវៀតនិងជាពិសេសសេដ្ឋកិច្ចរបស់បណ្ដាប្រទេសអឺរ៉ុបខាងកើតមានលក្ខណៈជាសេដ្ឋកិច្ចបញ្ជា ក៏ប៉ុន្តែចៀសមិនផុតពីការប្រើប្រាស់យន្តការសេដ្ឋកិច្ចទីផ្សារនិងនៅមានសេសសល់កម្មសិទ្ធិឯកជនលើមធ្យោបាយផលិតកម្មមួយចំនួន ។ តាមរយៈការធ្វើអន្តរាគមន៍ រដ្ឋអាចកែសម្រួលនិងបំពេញចន្លោះខ្វះខាតរបស់យន្តការទីផ្សារនិងផ្ទេរសកម្មភាពទីផ្សារឱ្យក្លាយទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល ។

### 4.2. សេដ្ឋកិច្ចចម្រុះបែបទីផ្សារ

ក្នុងនិយ័តកម្មសេដ្ឋកិច្ចចម្រុះបែបទីផ្សារ ក្រៅពីយន្តការទីផ្សារនៅមានយន្តការរដ្ឋដែលមានសកម្មភាពបំពេញភាពខ្វះចន្លោះនៃយន្តការទីផ្សារ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកជាសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែមានលក្ខណៈពិសេសត្រង់រដ្ឋមានតួនាទីដ៏សកម្មក្នុងការប្រើឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃ សម្រាប់ចូលរួមសម្របសម្រួលក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចមានដូចជា ជំរុញការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីរក្សាស្ថិរភាពនិងជំរុញកំណើនសេដ្ឋកិច្ច ផ្ដល់ទំនិញនិងសេវាដែលអវត្តមានក្នុងទីផ្សារ ឬមានពុំគ្រប់គ្រាន់ជាដើម ។

### 4.3. ភាពខុសគ្នារវាងសេដ្ឋកិច្ចចម្រុះបែបបញ្ជានិងសេដ្ឋកិច្ចចម្រុះបែបទីផ្សារ

ទិសដៅរបស់សេដ្ឋកិច្ចចម្រុះបែបទីផ្សារ គឺការឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសុទ្ធសាធ ឯប្រការដែលយកយន្តការរដ្ឋ មកប្រើក្នុងករណីខ្លះនោះ គឺដើម្បីបំពេញការខ្វះចន្លោះរបស់សេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ ។ ដូចគ្នានេះដែរ សេដ្ឋកិច្ចចម្រុះបែបបញ្ជាមាននៅសេសសល់ការប្រើប្រាស់យន្តការទីផ្សារដោយសារគេយល់ថាក្នុងដំណាក់កាលដែលប្រព័ន្ធសេដ្ឋកិច្ចបញ្ជាកំពុងមានដំណើរការនោះ ទាមទារការប្រើជាបណ្ដោះអាសន្ននូវយន្តការសេដ្ឋកិច្ចទីផ្សារ ។ ឯទិសដៅចុងក្រោយ គឺការកសាងឡើងនូវសេដ្ឋកិច្ចផែនការ ។

## 5. តួនាទីរដ្ឋក្នុងប្រទេសកំពុងអភិវឌ្ឍ

ជាទូទៅ តួនាទីរបស់រដ្ឋក្នុងសេដ្ឋកិច្ច ផ្អែកទៅតាមរបៀបគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចនិងអាស្រ័យទៅនឹងស្ថានភាពរួមនិងលក្ខណៈពិសេសរបស់ប្រទេសនោះ ។

ក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសក្រីក្រជាងគេនៅក្នុងពិភពលោក មានលក្ខណៈពិសេសមួយចំនួនដូចខាងក្រោមដែលតម្រូវឱ្យរដ្ឋមានការយកចិត្តទុកដាក់ជាពិសេស ។



facebook.com/moeys.gov.kh khmer.moeys.gov.kh youtube.com/moeys

## 5.1. ភាពអន់ថយនៃរបៀបផលិតក្នុងផ្នែកកសិកម្ម

របៀបផលិតក្នុងផ្នែកកសិកម្មមានលក្ខណៈយថាផលនិងពាក់កណ្ដាលយថាផល ពោលគឺសកម្មភាពផលិតកម្មប្រើបច្ចេកទេសអន់ថយ ផ្អែកទាំងស្រុកទៅលើកម្លាំងមនុស្សនិងផ្អែកទៅលើខឿនសេដ្ឋកិច្ចសាមញ្ញដែលមានលក្ខណៈបូរាណនិងប្រពៃណីនិយម ។ ក្នុងប្រទេសក្រីក្រច្រើនសតវត្សមកហើយសេដ្ឋកិច្ចច្រើនជាប្រព័ន្ធដែលមានចរិតអភិរក្សនិយម ពោលគឺស្ទើរតែគ្មានការផ្លាស់ប្ដូរ ។ ការប្រកបរបរចិញ្ចឹមជីវិតរបស់កសិករមានចរិតបេតេយ្យការ ពោលគឺគ្រប់មធ្យោបាយផលិតកម្មជារបស់សហគមន៍មានលក្ខណៈចាស់យូរយារ ច្រើនប្រមូលផ្ដុំតាមមូលដ្ឋានតូចៗ ហើយដំណើរការផលិតកម្មពឹងផ្អែកលើធម្មជាតិ ។

## 5.2. ចរិតឯកវប្បកម្មនៃសេដ្ឋកិច្ចជាតិអន់ថយ

ប្រព័ន្ធសេដ្ឋកិច្ចនៃប្រទេសក្រីក្រជាប្រព័ន្ធដែលមានសមាសភាពសេដ្ឋកិច្ចច្រើនរួមគ្នា ក្នុងនោះមានយន្តការសេដ្ឋកិច្ចទីផ្សារជាអ្នកនាំមុខ ប៉ុន្តែសមាសភាពដែលមានឥទ្ធិពលគ្របដណ្ដប់លើសង្គម គឺយន្តការសេដ្ឋកិច្ចបែបបេតេយ្យការ មានលក្ខណៈជាសេដ្ឋកិច្ចគ្រួសារតូចៗដំណើរការផលិតកម្មច្រើនប្រព្រឹត្តទៅដើម្បីបំពេញសេចក្ដីត្រូវការរបស់គ្រួសារ ។ ម្ល៉ោះហើយ សកម្មភាពសេដ្ឋកិច្ចពុំសូវមានទំនាក់ទំនងជាមួយនឹងស្ថាប័នឥណទាននិងរូបិយវត្ថុឡើយ ។ ដូចនេះ បរិបទសម្រាប់ការប្រព្រឹត្តទៅនិងការលូតលាស់នៃយន្តការទីផ្សារមិនទាន់មានសុក្រឹតភាពនៅឡើយ ។ ដូច្នេះដើម្បីញ៉ាំងឱ្យផ្នែកឯកជនរីកលូតលាស់បានល្អ តម្រូវឱ្យរដ្ឋយកចិត្តទុកដាក់ការស្ដារឡើងវិញនិងកែលំអក្នុងផ្នែកជាច្រើនទាំងលិខិតបទដ្ឋាន ទាំងរចនាសម្ព័ន្ធរបស់សេដ្ឋកិច្ចព្រមទាំងសេវាកម្មផ្នែកទ្រទ្រង់ផងដែរ ។ល ។

## 5.3. ភាពខ្ទេចខ្ទាំនិងក្រខ្សត់នៃសេដ្ឋកិច្ចជាតិ

ក្នុងបណ្ដាប្រទេសក្រីក្រមួយចំនួន ដោយសារសង្គ្រាមអូសបន្លាយ ភាពខ្ទេចខ្ទាំនិងភាពក្រខ្សត់នៃសេដ្ឋកិច្ចជាតិជាប្រការទាមទារឱ្យមានការស្ដារឡើងវិញលើគ្រប់វិស័យ ជាពិសេស ការស្ដារហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងការបណ្ដុះបណ្ដាលធនធានមនុស្ស ។ ដោយសារការងារទាំងនេះ ត្រូវការនូវប្រភពធនធានដ៏ធំធេង ដែលសមាសភាពឯកជនពុំមានលទ្ធភាពបំពេញនិងដោះស្រាយបាន ដូចនេះរដ្ឋមានតួនាទីជាគន្លឹះក្នុងការដោះស្រាយបញ្ហានេះ ។

### 5.4. ភាពខ្សោយនៃផ្នែកឯកជន

ផ្នែកឯកជនមានរចនាសម្ព័ន្ធខ្សោយ ការចាត់តាំងក្នុងសហគ្រាសនៅរយឹករយាក សហគ្រិនជាទូទៅមិនទាន់មានកម្រិតវប្បធម៌សហគ្រិនភាពខ្ពស់នៅឡើយ ។ ទំនាក់ទំនងអន្តរសហគ្រាសសម្រាប់យឹតយោងគ្នាខាងផ្នែកមុខរបរ ឬសម្រាប់ការពារនិងពង្រីកមុខរបរ ក៏ពុំទាន់មានការរីកចម្រើន ។ ដូច្នេះ ឯកជនមានភាពទន់ខ្សោយទាំងការចាត់តាំងក្នុងសហគ្រាស ទាំងការចាត់តាំងក្រៅសហគ្រាស ។

ក្នុងស្ថានភាពនេះ រដ្ឋមាននាទីជាអ្នកសម្របសម្រួលដ៏សំខាន់មួយ ដែលខុសប្លែកពីតួនាទីបែបប្រពៃណីរបស់ខ្លួននិងខុសប្លែកពីតួនាទីរបស់រដ្ឋក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដូចមាននៅក្នុងបណ្តាប្រទេសឧស្សាហកម្មជឿនលឿនមួយចំនួននៅអឺរ៉ុបខាងលិចនិងនៅអាមេរិកខាងជើង ។ រដ្ឋនៃបណ្តាប្រទេសឧស្សាហកម្មថ្មីក្នុងទ្វីបអាស៊ី ដូចជាកូរ៉េខាងជើង តៃវ៉ាន់ សិង្ហបុរី ហុងកុង និងក្រោយមកមាន ម៉ាឡេស៊ី ហ្វីលីពីន ថៃឡង់ ឥណ្ឌូនេស៊ីជាដើម មានបទពិសោធប្រកបដោយជោគជ័យក្នុងការកសាងនិងពង្រីកមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ នេះគឺជាឧទាហរណ៍ដែលបង្ហាញថារដ្ឋមានតួនាទីធានានូវប្រសិទ្ធភាពការងារក្នុងដំណើរការអភិវឌ្ឍផ្នែកឯកជននៅក្នុងខឿនសេដ្ឋកិច្ចជាតិ ។

## 6. សេចក្តីសន្និដ្ឋាន

នៅគ្រប់សង្គមទោះជាសង្គមនោះមានរបបនយោបាយអ្វីមួយក៏ដោយឬមានប្រព័ន្ធសេដ្ឋកិច្ចបែបណាក៏ដោយក៏រដ្ឋមានតួនាទីជាគន្លឹះក្នុងការសម្របសម្រួលនិងធានាកំណើនសេដ្ឋកិច្ចជាតិ ។

## សំណួរ

1. តាមការយល់ដឹងរបស់អ្នក តើរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នបានធ្វើសកម្មភាពអ្វីខ្លះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ? ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬ ជាមួយសមាជិកឯទៀតក្នុងក្រុម ដើម្បីរកចម្លើយចំពោះសំណួរខាងក្រោម

   ក. តើរដ្ឋមានតួនាទីដូចម្តេចខ្លះនៅក្នុងសង្គមជាតិមួយ ?

   ខ. ជាទូទៅ តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ច ? ចូររៀបរាប់ ។

   គ. តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចទីផ្សារ ? ចូររៀបរាប់ ។

   ឃ. តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចបញ្ជា ? ចូររៀបរាប់ ។

   ង. តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចចម្រុះ ? ចូររៀបរាប់ ។

   ច. តើសេដ្ឋកិច្ចចម្រុះបែបទីផ្សារមានន័យយ៉ាងដូចម្តេច ? ចូរផ្តល់ឧទាហរណ៍ ។

   ឆ. តើសេដ្ឋកិច្ចចម្រុះបែបបញ្ជាមានន័យយ៉ាងដូចម្តេច ? ចូរផ្តល់ឧទាហរណ៍ ។

   ជ. តើសេដ្ឋកិច្ចចម្រុះបែបទីផ្សារនិងសេដ្ឋកិច្ចចម្រុះបែបបញ្ជាមានភាពខុសគ្នាយ៉ាងដូចម្តេច ?

   ឈ. តើរដ្ឋមាននាទីអ្វីខ្លះក្នុងវិស័យសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ?
3. ចូរអ្នកអានអត្ថបទខាងក្រោមដោយយកចិត្តទុកដាក់និងដកស្រង់យកចំណុចសំខាន់ៗ ដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

មាត្រា 56 នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា “ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់” ។ តាមខ្លឹមសារនៃមាត្រានេះ តើអ្នកយល់ថារដ្ឋមាននាទីអ្វីខ្លះ ក្នុងយន្តការសេដ្ឋកិច្ច ?

youtube.com/moeys khmer.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 5 អន្តរាគមន៍រដ្ឋក្នុងទីផ្សារ

**ចប់មេរៀននេះ សិស្សអាច**

- បង្ហាញតួនាទីរដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារ ។
- រៀបរាប់តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចចម្រុះទីផ្សារ ។
- រៀបរាប់តួនាទីសំខាន់និងដោយឡែករបស់រដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារនៃប្រទេសកំពុងអភិវឌ្ឍ ។
- រកមូលហេតុនៃការដាក់បញ្ញារបស់រដ្ឋក្នុងសេដ្ឋកិច្ចចម្រុះទីផ្សារ ។

រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចទីផ្សារ ?

## 1. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចទីផ្សារ

ក្នុងសកម្មភាពសេដ្ឋកិច្ចទីផ្សារ រដ្ឋពុំចាំបាច់លូកដៃធ្វើអន្តរាគមន៍ទេ គឺរដ្ឋមានតួនាទីត្រឹមតែជាអ្នកការពារកម្មសិទ្ធិ ជាអ្នកបង្កើត និងចាត់ចែងស្ថាប័នសង្គម មូលដ្ឋានច្បាប់ផ្សេងៗ ដែលចាំបាច់សម្រាប់ជំរុញនិងសម្របសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ចទីផ្សារប៉ុណ្ណោះ ។

ក្នុងប្រទេសកំពុងអភិវឌ្ឍ ទិសដៅចំពោះមុខរបស់រដ្ឋាភិបាលគឺការកាត់បន្ថយភាពក្រីក្រ ។ ដូចនេះ អ្នកសេដ្ឋកិច្ច មានកង្វល់ខ្លាំងអំពីមូលដ្ឋាននៃការបែងចែកប្រាក់ចំណូលនិងការបង្កលទ្ធភាពឱ្យប្រជាជនក្រីក្រ បានចូលរួមក្នុងការប្រកបរបរអាជីវកម្មផ្សេងៗ តាមរយៈការបង្កើតគ្រឹះស្ថានឥណទានសម្រាប់អាជីវកម្មខ្នាតតូចឬគ្រឹះស្ថានមីក្រូឥណទានសម្រាប់ផ្តល់លទ្ធភាពឱ្យជនក្រីក្រខ្ចីប្រាក់ជាដើម ។ ដើម្បីលើកកម្ពស់ជីវភាពប្រជាជន រដ្ឋបង្កើតគម្រោងកម្មវិធីសកម្មភាព ដោយមានការបោះទុនវិនិយោគពីអន្តរជាតិ ក្នុងគ្រប់វិស័យមានដូចជា នៅវិស័យអប់រំ សុខាភិបាល សង្គមកិច្ច ។ សេដ្ឋកិច្ចផលិតកម្ម ពាណិជ្ជកម្ម និងទីផ្សារដោយអនុវត្តគោលនយោបាយចំហររបស់អ្នកវិនិយោគទុន ។

# 2. តួនាទីរដ្ឋក្នុងសេដ្ឋកិច្ចចម្រុះបែបទីផ្សារ

ក្នុងសេដ្ឋកិច្ចចម្រុះបែបទីផ្សារ និយ័តកម្មសេដ្ឋកិច្ចទ្រទ្រង់ដោយយន្តការទីផ្សារនិងយន្តការរបស់រដ្ឋដែលធ្វើសកម្មភាពបំពេញភាពខ្វះខាតនៃយន្តការទីផ្សារ ។

## 2.1. តួនាទីដោយប្រយោល

រដ្ឋធ្វើអន្តរាគមន៍ក្នុងបរិបទក្រិត្យក្រមសេដ្ឋកិច្ច ដោយការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច ។ ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច គឺជាឧបករណ៍សំខាន់ដែលរដ្ឋាភិបាលប្រើប្រាស់សម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាពកំណើនបរិមាណផលិតផលជាតិ ស្ថិរភាពកម្រិតថ្លៃ និងរក្សាតុល្យភាពពាណិជ្ជកម្មក្រៅប្រទេស ។ ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ពិតមែនតែអាចសម្របសម្រួលទៅបានដោយឯកឯង ប៉ុន្តែនៅមានភាពខ្វះខាត រដ្ឋត្រូវប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច ។

### ក. គោលនយោបាយសារពើពន្ធ

ដោយអនុវត្តគោលនយោបាយសារពើពន្ធតាមរយៈការប្រមូលពន្ធនិងចំណូលសាធារណៈ រដ្ឋាភិបាលអាចមានឥទ្ធិពលលើចំណាយសរុបក្នុងប្រទេសទាំងមូល ដែលជាប្រការអាចជំរុញឱ្យមានកំណើន ឬបន្ថយបង្អាក់ដំណើរការផលិតកម្ម ។

### ខ. គោលនយោបាយរូបិយវត្ថុ

ឥទ្ធិពលគោលនយោបាយរូបិយវត្ថុពាក់ព័ន្ធទៅនឹងសមត្ថភាពធនាគារកណ្តាល ក្នុងការផ្លាស់ប្តូរបរិមាណរូបិយវត្ថុ ដែលចរាចរក្នុងសេដ្ឋកិច្ចទាំងមូល ។ ឥទ្ធិពលគោលនយោបាយរូបិយវត្ថុអាចធ្វើឱ្យមានការផ្លាស់ប្តូរអត្រាការប្រាក់និងទីបំផុតធ្វើឱ្យប៉ះពាល់ដល់ការវិនិយោគដែលមានឥទ្ធិពលដោយត្រង់ទៅលើបរិមាណផលិតផលជាតិ ។

### គ. គោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស

តាមរយៈតារាងពន្ធគយ កូតា អាជ្ញាប័ណ្ណពាណិជ្ជកម្មក្រៅប្រទេសនិងការគ្រប់គ្រង ការនាំចេញនិងនាំចូល ជាប្រការនាំឱ្យមានឥទ្ធិពលលើបរិមាណផលិតកម្មក្នុងប្រទេស ។

គួរកត់សម្គាល់ថា តាមបទពិសោធរបស់ប្រទេសជឿនលឿននៅពេលដែលឃើញថា ការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចពុំមានប្រសិទ្ធភាពពេញលេញ រដ្ឋាភិបាលប្រើប្រាស់បន្ថែមនូវលិខិតបទដ្ឋានសម្រាប់បំពេញបន្ថែម ។

## 2.2. តួនាទីដោយចំពោះឬបញ្ញា

នៅពេលដែលរដ្ឋប្រែក្លាយជាភ្នាក់ងារសេដ្ឋកិច្ចមួយ ក្នុងចំណោមភ្នាក់ងារដទៃទៀត មានន័យថារដ្ឋមាននិន្នាការក្នុងការជំរុញឱ្យមានកម្មសិទ្ធិរដ្ឋ តាមរយៈការបង្កើនសហគ្រាសឬក្រុមហ៊ុនរដ្ឋ ។ ក្នុងន័យនេះ រដ្ឋចូលរួមដោយត្រង់ក្នុងការបង្កើតផលិតផលសង្គម (ធនធានសេដ្ឋកិច្ចមួយចំនួនជាកម្មសិទ្ធិរដ្ឋ ដូចជា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ...) ។ គួរកត់សម្គាល់ថា តួនាទីរបស់រដ្ឋក្នុងសេដ្ឋកិច្ចចម្រុះអាចមានករណីខ្លះប្រើដល់បទបញ្ជា ដោយអាស្រ័យទៅនឹងប្រវត្តិសាស្ត្រ ការអភិវឌ្ឍភូមិសាស្ត្រ ឬស្ថានភាពនយោបាយសង្គមសេដ្ឋកិច្ចជាដើមរបស់ប្រទេសនីមួយៗ ។

តួនាទីដោយចំពោះឬបែបបញ្ជារបស់រដ្ឋ មានន័យថាជាការលូកដៃកាន់តែជ្រៅរបស់រដ្ឋក្នុងសេដ្ឋកិច្ច ជាពិសេសការជំរុញដំណើរការបង្កើនផលិតផលសង្គម តាមរយៈរោងចក្រ ឬសហគ្រាសរដ្ឋដែលប្រព្រឹត្តទៅមិននៅក្រោមឥទ្ធិពលនៃក្រឹត្យក្រមតម្រូវការនិងការផ្គត់ផ្គង់ទេ ។ ម្យ៉ាងទៀត ការបំពេញតួនាទីនេះ ជាទូទៅមិនប្រតិបត្តិតាមក្រឹត្យក្រមសេដ្ឋកិច្ចទេ គឺស្ថិតក្រោមការចាំបាច់ដែលតម្រូវឱ្យមានការដាក់បញ្ជានានា ដើម្បីជំរុញការអភិវឌ្ឍ ។ *ឧទាហរណ៍* ដូចជាប្រទេសជប៉ុន ដែលយើងតែងហៅថាជាប្រទេសសេរី ឬជាប្រទេសដែលមានការរីកចម្រើនខាងសេដ្ឋកិច្ចទីផ្សារ តែការពិត ក្នុងសេដ្ឋកិច្ចជប៉ុន រដ្ឋមានតួនាទីយ៉ាងសកម្មដោយមិនត្រឹមតែប្រើតួនាទីបែបប្រយោលប៉ុណ្ណោះទេ គឺដើរតួនាទីបែបចំពោះថែមទៀត ពោលគឺក្នុងករណីចាំបាច់ រដ្ឋប្រើបទបញ្ជាផ្សេងៗសម្រាប់ធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ច ។ ម្យ៉ាងទៀត ដូចជាសេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលគេហៅថាសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែសេដ្ឋកិច្ចនេះមានលក្ខណៈពិសេសត្រង់រដ្ឋមានតួនាទីសកម្មក្នុងការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃសម្រាប់ចូលរួមសម្របសម្រួលដំណើរការអភិវឌ្ឍសេដ្ឋកិច្ច មានដូចជាអនុវត្តគោលនយោបាយសារពើពន្ធដើម្បីរក្សាស្ថិរភាពនិងជំរុញកំណើនសេដ្ឋកិច្ច និងផ្គត់ផ្គង់ទំនិញ សេវាដែលអវត្តមានក្នុងទីផ្សារ ឬមានពុំគ្រប់គ្រាន់ជាដើម ។ តាមរយៈតួនាទីនេះដែរ ការធ្វើអន្តរាគមន៍របស់រដ្ឋអាចកែសម្រួលនិងបំពេញចន្លោះឬកង្វះខាតនៃយន្តការទីផ្សារនិងប្រែក្លាយយន្តការទីផ្សារនោះឱ្យទៅជាសកម្មភាពមានប្រយោជន៍ សម្រាប់សង្គមជាតិទាំងមូល ។

## 3. សេចក្តីសន្និដ្ឋាន

ក្នុងករណីប្រព័ន្ធសេដ្ឋកិច្ចទីផ្សារត្រូវបានអនុវត្តនៅប្រទេសកំពុងអភិវឌ្ឍដែលសេដ្ឋកិច្ចនៃប្រទេសនេះមានលក្ខណៈពិសេសមួយចំនួនគឺ

- ភាពអន់ថយនៃរបៀបផលិតកម្មក្នុងផ្នែកកសិកម្ម ។
- ចរិតឯករូបកម្មនៃសេដ្ឋកិច្ចជាតិ ។
- ភាពខ្ទេចខ្ទាំដោយសារសង្គ្រាម ។
- ភាពទន់ខ្សោយនៃផ្នែកឯកជន ។

រដ្ឋត្រូវប្រកាន់យកនូវតួនាទីដ៏សំខាន់ដោយឡែក ដែលមានលក្ខណៈខុសប្លែកពីតួនាទីជាប្រពៃណីរបស់ខ្លួននិងខុសប្លែកពីតួនាទីរបស់រដ្ឋក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ពោលគឺ**ត្រូវកសាងនិងពង្រីកមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ តាមរយៈការបោះជំហានចេញពីភាពក្រីក្រ ដោយប្រើមធ្យោបាយទាំងក្នុងតួនាទីដោយប្រយោលនិងទាំងក្នុងតួនាទីដោយចំពោះ ហើយក្នុងករណីចាំបាច់ខ្លះរដ្ឋដាក់ចេញនូវបទបញ្ជា ។**

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## ? សំណួរ

1. ចូរអ្នកអានអត្ថបទខាងក្រោម រួចហើយចូរនិយាយប្រាប់សិស្សក្នុងថ្នាក់អំពីព័ត៌មានដែលអ្នកទទួលបាន

**សុន្ទរកថាស្វាគមន៍**
**របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**កិច្ចប្រជុំស្តីពី**
**ការតាមដានគម្រោងអាទិភាព**
**វិមានរដ្ឋាភិបាល ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩**

១ ខ្ញុំមានកិត្តិយសនិងមានសេចក្តីរីករាយជាអតិបរមា សូមសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក នៅក្នុងកិច្ចប្រជុំនាពេលព្រឹកនេះ ។ កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំលើកដំបូង បន្ទាប់ពីកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍ នាចុងខែមេសាកន្លងមក ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ ការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ ជាសហសេវិកក្នុងរាជរដ្ឋាភិបាល ឯកឧត្តមលោកជំទាវជាប្រធានក្រុមការងារបច្ចេកទេសចម្រុះនិងតំណាងដៃគូអភិវឌ្ឍនាពេលនេះ ។ នេះសរបញ្ជាក់ឱ្យឃើញអំពីការប្តេជ្ញាបំពេញការងាររួមជាមួយក្នុងភាពជាដៃគូ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាកលលោកមកលើកម្ពុជា ។ យើងទាំងអស់គ្នាបានឯកភាពថានឹងតាមដានរួមគ្នានូវវឌ្ឍភាពនៃកិច្ចការដែលយើងបានព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធនឹងការតាមដានអនុវត្តបណ្តុំគម្រោងកម្មវិធីអាទិភាព ដែលរាជរដ្ឋាភិបាលយល់ថា កិច្ចការនេះជាវិធានការមួយសម្រាប់ឆ្លើយតបរួមគ្នាទៅនឹងវិបត្តិកលិយុគហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកលលោក ។

២ គោលដៅចម្បងនៃកិច្ចប្រជុំរបស់យើងនាថ្ងៃនេះ គឺដើម្បីត្រួតពិនិត្យឡើងវិញនិងឯកភាពអំពីវឌ្ឍនភាពនៃកិច្ចដំណើរការរហូតមកដល់ពេលបច្ចុប្បន្ននេះ មុននឹងធ្វើការពិចារណាលើសំណើនៃការរៀបចំយន្តការសម្រាប់តាមដានបណ្តុំគម្រោងកម្មវិធីអាទិភាព ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

ឆ្លៀតឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ នីតិសម្បទានិងអភិវឌ្ឍកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍសកម្ពុជា(គ.ជ.នា/ក.អ.ក)ក្នុងការដឹកនាំគំនិតផ្តួចផ្តើម កម្រិតគោលនយោបាយនេះ ដោយបានកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយសហគមន៍ដៃគូអភិវឌ្ឍ តាមរយៈធនាគារពិភពលោកដែលជាប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍ ។

៣ ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍ នាថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ កន្លងមក រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍបានព្រមព្រៀងគ្នាថានឹង ធ្វើការរួមគ្នា ដើម្បីកំណត់គម្រោងកម្មវិធីអាទិភាពខ្ពស់មួយចំនួន សម្រាប់តាមដានវឌ្ឍនភាពនៃការ អនុវត្ត សម្រាប់ពិនិត្យលទ្ធភាពពន្លឿនល្បឿននៃការអនុវត្តគម្រោង ឬពន្លឿនល្បឿននៃការរៀបចំ គម្រោង ដើម្បីឈានទៅដល់ការអនុវត្តឱ្យបានឆាប់រហ័ស ។ គម្រោង កម្មវិធីអាទិភាពទាំងនេះត្រូវបាន ជ្រើសរើស ដោយផ្អែកលើមូលដ្ឋាននៃសក្តានុពលសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច សម្រាប់កែលំអជីវភាព រស់នៅរបស់ប្រជាជននិងផ្តល់ប្រព័ន្ធការពារសុវត្ថិភាពសង្គមជនក្រីក្រ ពិសេសនៅតំបន់ជនបទ ។

៤ ដោយបានសហការល្អជាមួយដៃគូអភិវឌ្ឍ តាមរយៈធនាគារពិភពលោក គណៈកម្មាធិការ នីតិសម្បទានិងអភិវឌ្ឍកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (គ.ជ.នា/ក.អ.ក) បានកំណត់គម្រោង កម្មវិធីអាទិភាពសរុបចំនួន៦៩សម្រាប់តាមដាន ។ គម្រោងទាំងអស់ដែលមាននៅក្នុងបញ្ជី ត្រូវបានផ្តល់ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍចំនួន ១៧ ។ សហសេវិករបស់ខ្ញុំ ឯកឧត្តម ឈៀង យ៉ាណារ៉ា អគ្គ លេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍកម្ពុជានឹងធ្វើបទបង្ហាញដោយសង្ខេបអំពីសំណើ រៀបចំកិច្ចដំណើរការនានាសម្រាប់តាមដាន គម្រោង កម្មវិធីអាទិភាពទាំងនេះ ។

ខ្ញុំជឿជាក់ថា វត្តមានរបស់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកនាពេលនេះ ទាំង ខាងរដ្ឋាភិបាល ទាំងខាងសហគមន៍ដៃគូអភិវឌ្ឍបានឆ្លុះបញ្ចាំងពីការប្តេជ្ញាខ្ពស់ ដើម្បីដំណើរការកិច្ច ការនេះប្រកបដោយប្រសិទ្ធភាព ។

៥ ការតាមដានគម្រោងកម្មវិធីអាទិភាពនេះ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតពី សំណាក់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ។ ប្រធានឬនាយកគ្រប់គ្រងគម្រោងតាមក្រសួង ស្ថាប័ន អនុវត្តគម្រោងនិងមន្ត្រីបង្គោលខាងដៃគូអភិវឌ្ឍទទួលបន្ទុកគម្រោងនីមួយៗ ដែលមានវត្តមាននា ពេលនេះ ត្រូវធ្វើការជាមួយគ្នាឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀត ។ នៅពេលណារកឃើញបញ្ហាប្រឈម និងឧបសគ្គដែលជះឥទ្ធិពលដល់ការអនុវត្តគម្រោងកម្មវិធី ពួកគេត្រូវពិភាក្សាគ្នាដើម្បីស្វែងរក ដំណោះស្រាយចំពោះបញ្ហាទាំងអស់នោះ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

ទន្ទឹមនេះ ពួកគេក៏ត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានាដែលមិនទាន់អាចដោះស្រាយជូនក្រុមការងារបច្ចេកទេសចម្រុះ ដែលមានតំណាងដៃគូអភិវឌ្ឍនៅតាមក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ឬជូនក្រសួងស្ថាប័នពាក់ព័ន្ធទទួលបន្ទុកតាមដានអនុវត្តគម្រោងកម្មវិធី ។ លើសពីនេះពួកគេក៏ត្រូវរាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍតាមរយៈគ. ជ. នាក្រ. អ. ក ដែលលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍផងដែរ ។

៦ ជាការពិតណាស់ កិច្ចការទាំងនេះបានបង្កើតអម្រែកបន្ថែមសម្រាប់ទាំងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ។ ប៉ុន្តែរាជរដ្ឋាភិបាលបានប្ដេជ្ញាខ្ពស់ក្នុងការអភិវឌ្ឍកិច្ចការនេះ ព្រោះរាជរដ្ឋាភិបាលជឿជាក់ថា នេះជាវិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងឥទ្ធិពលរបស់វិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោកមកលើកម្ពុជា ព្រោះថាការបង្កើនល្បឿននៃការអនុវត្តគម្រោងកម្មវិធីទាំងនេះនឹងជួយពន្លឿនកំណើនសេដ្ឋកិច្ច កែលំអជីវភាពរស់នៅប្រជាជននិងផ្តល់ប្រព័ន្ធការពារសុវត្ថិភាពសង្គមដល់ប្រជាជនក្រីក្រ ។ សកម្មភាពទាំងនេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងកាលៈទេសៈលំបាកនេះ ។

៧ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ជាមួយនឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍដែលយើងបានរួមគ្នាពង្រឹងកន្លងមក ដៃគូអភិវឌ្ឍនឹងបន្តគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ។ បញ្ហានៅចំពោះមុខ គឺថាទន្ទឹមនឹងការកំណត់ឈ្មោះគម្រោងកម្មវិធីដែលត្រូវតាមដាន យើងត្រូវធានាថាគម្រោង កម្មវិធីទាំងនេះត្រូវបានអនុវត្តទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព ។ សុខុមាលភាពរស់នៅរបស់ប្រជាជនដែលកំពុងទទួលផលប្រយោជន៍ពីគម្រោង កម្មវិធីទាំងនោះនឹងត្រូវពឹងអាស្រ័យទៅលើសកម្មភាពរបស់យើងទាំងអស់គ្នា ។

៨ សរុបមក ខ្ញុំអាចនិយាយថា ភាពជាដៃគូដែលបាននិងកំពុងពង្រឹងបន្ថែម បានផ្តល់ជាមូលដ្ឋានយ៉ាងរឹងមាំសម្រាប់កិច្ចខិតខំប្រឹងប្រែងបន្តទៀត ។ ភាពជោគជ័យនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍ ក៏ដូចជាភាពជាដៃគូរវាងរដ្ឋាភិបាលនិងសហគមន៍ដៃគូអភិវឌ្ឍក្នុងការកាត់បន្ថយផលប៉ះពាល់នៃវិបត្តិកលិយុគហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកលលោកមកលើកម្ពុជានឹងត្រូវពឹងផ្អែកទៅលើកិច្ចការដែលយើងព្រមព្រៀងគ្នាក្នុងថ្ងៃនេះនិងទៅលើលទ្ធផលនៃការអនុវត្តទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍលើកិច្ចការទាំងឡាយដែលឯកភាពគ្នាក្នុងថ្ងៃនេះ ។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

ក. ដូចម្តេចហៅថា សេដ្ឋកិច្ចទីផ្សារ ?

ខ. តើរដ្ឋមានតួនាទីអ្វីខ្លះក្នុងសេដ្ឋកិច្ចទីផ្សារ ?

គ. ដូចម្តេចហៅថា សេដ្ឋកិច្ចចម្រុះទីផ្សារ ?

ឃ. តើរដ្ឋមានតួនាទីអ្វីខ្លះក្នុងសេដ្ឋកិច្ចចម្រុះទីផ្សារ ?

ង. តើសេដ្ឋកិច្ចជាមូលដ្ឋានក្នុងប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈដូចម្តេច ?

ច. តើរដ្ឋមានតួនាទីបែបណាក្នុងការកសាងសេដ្ឋកិច្ចទីផ្សារក្នុងប្រទេសកំពុងអភិវឌ្ឍ ?

ឆ. ក្នុងសេដ្ឋកិច្ចទីផ្សារនៃប្រទេសកំពុងអភិវឌ្ឍ ហេតុអ្វីមានពេលខ្លះរដ្ឋដាក់បទបញ្ជា ?

3. ចូរអ្នកអានអត្ថបទមេរៀនដោយយកចិត្តទុកដាក់ បន្ទាប់មកចូរស្រង់យកចំណុចទាំងឡាយណាដែលអ្នកយល់ថាសំខាន់ យកមកចងក្រងជាមេរៀនសង្ខេបជារបស់ខ្លួនផ្ទាល់ ។

## ប្រតិបត្តិ

ក្នុងប្រទេសកំពុងអភិវឌ្ឍមួយ រដ្ឋមានបំណងឱ្យប្រជាពលរដ្ឋក្រីក្រប្រកបអាជីវកម្មឯកជនគ្រប់ៗគ្នា តើអ្នកគិតថា រដ្ឋត្រូវមានវិធានការដូចម្តេចខ្លះ ? ចូរអ្នករៀបរាប់និងបញ្ជាក់ថា តើវិធានការទាំងនេះស្ថិតក្នុងប្រព័ន្ធសេដ្ឋកិច្ចបែបណា ? អាចនឹងទទួលជោគជ័យឬទេ ? ហេតុអ្វី ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 6 ចំណូលជាតិ

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យនៃពាក្យ "ចំណូលជាតិ" ។
- ពណ៌នាពីចំណូលបុគ្គល ។
- ពន្យល់ពីចំណូលបុគ្គលក្រោយការបង់ពន្ធ ។

អ្នកធ្លាប់បានសិក្សាអំពីសកម្មភាពសេដ្ឋកិច្ច ដែលមានទំនាក់ទំនងរវាងការផ្គត់ផ្គង់ផលិតផលនិងការប្រើប្រាស់រួចមកហើយ ។ កំណើនផលិតកម្មអាចជាចំណុចមួយដែលធ្វើឱ្យប្រជាពលរដ្ឋទូទៅសង្ឃឹមថា វានឹងបង្កើនចំណូលជាតិ ?

## 1. តើអ្វីទៅជាចំណូលជាតិ ?

អ្នកបានស្គាល់រួចមកហើយ អំពីកត្តាផលិតកម្មរបស់អាជីវកម្មគ្រួសារ ដែលបង្កើតបានជាផលិតផល តាមរយៈពលកម្មរបស់មនុស្សក្នុងគ្រួសារ ។ ផលិតផលប្រចាំឆ្នាំនៃគ្រួសារមួយហៅថាចំណូលគ្រួសារប្រចាំឆ្នាំ គឺជាផលបូកសរុបនៃចំណូល ដែលបានមកពីប្រភពទាំងអស់ក្នុងរយៈពេលមួយឆ្នាំ ។ ដូចគ្នានេះដែរ នៅពេលដែលយើងគណនារកចំណូលជាតិមួយប្រចាំឆ្នាំ ជាធម្មតាយើងត្រូវតែធ្វើការបូកសរុបចំណូលពីវិស័យទាំងអស់ ។ ចំណូលជាតិអាចហៅម្យ៉ាងទៀតថា ជាផលិតផលជាតិ (NDP) ដែលក្នុងនោះមានផលិតផលក្នុងស្រុកសរុប(GDP) ផងដែរ ។ ផលិតផលក្នុងស្រុកសរុបមានប្រភពពីវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ដែលបានផលិតមុខទំនិញនិងសេវាកម្មច្រើនរាប់មិនអស់ ។ ទំនិញនិងសេវាកម្មទាំងនោះ គិតតម្លៃជាប្រាក់ចូលរួមបង្កើនចំណូលជាតិ ។

លោក ចនមេណាតកេន (J.M.Keynes) ដែលជាសេដ្ឋវិទូដ៏ល្បីល្បាញ បានឱ្យនិយមន័យថា "ចំណូលជាតិ គឺជាតម្លៃគិតជាប្រាក់នៃគ្រប់ទំនិញនិងសេវាកម្មទាំងអស់ ដែលបានផលិតក្នុងប្រទេសមួយ ក្នុងរយៈពេលមួយឆ្នាំ" ។ គេអាចគណនាប្រាក់ចំណូលជាតិតាមវិធីបីយ៉ាងដូចខាងក្រោមនេះ

- វិធីគណនាតាមប្រាក់ចំណូល ។
- វិធីគណនាតាមការចំណាយ ។
- វិធីគណនាតាមផលិតកម្ម ។

### វិធីគណនាតាមប្រាក់ចំណូល

ប្រាក់ចំណូល ទទួលបានពីកត្តាផលិតកម្មក្នុងអំឡុងពេលមួយឆ្នាំ គេរាប់ថាជាប្រាក់ចំណូលនូវថ្លៃជួលដី ថ្លៃឈ្នួលលើកម្លាំងពលកម្ម(ប្រាក់ខែ) ការប្រាក់លើមូលធនដែលបានប្រើ ប្រាក់ចំណេញរបស់សហគ្រាសផ្សេងៗនិងចំណូលពីបរទេស ។

រូបមន្តនៃការគណនាប្រាក់ចំណូលសរុបគឺ

**ចំណូលជាតិសរុប (GNI) = ប្រាក់ពលកម្ម + ការប្រាក់សុទ្ធ + ថ្លៃជួល + ប្រាក់ចំណេញ + ចំណូលពីបរទេស ។**

ចំណូលជាតិរួមផ្សំដោយបណ្តាសមាសធាតុដូចខាងក្រោម ។

## 1.1. ប្រាក់ពលកម្ម ឬសំណងទូទាត់សម្រាប់និយោជិត

សមាសធាតុទីមួយដែលរាប់ចូលជាចំណូលជាតិ គឺប្រាក់កម្រៃនិងប្រាក់ខែនៃពលកម្ម រួមមានប្រាក់កម្រៃតាមម៉ោង ប្រាក់បន្ថែមលើប្រាក់កម្រៃ និងប្រាក់ខែ ។ ប្រាក់កម្រៃនិង ប្រាក់ខែត្រូវបានគណនេយ្យករហៅថា សំណងទូទាត់សម្រាប់និយោជិត គឺជាការចំណាយសម្រាប់សេវាពលកម្ម ។ ជាទូទៅ សំណងទូទាត់សម្រាប់និយោជិតមានប្រហែល 75% នៃចំណូលជាតិ ។

## 1.2. ការប្រាក់សុទ្ធ

សមាសធាតុទីពីរដែលរាប់ចូលជាចំណូលជាតិគឺ ការប្រាក់សុទ្ធ ដែលរកបានតាមរយៈមូលធន ។ ការប្រាក់សុទ្ធ មានប្រហែលពី 5% ទៅ 10% នៃចំណូលជាតិ ។ ការប្រាក់សុទ្ធ រួមមានការប្រាក់ទទួលបានពីធនាគារ ជាការប្រាក់រកបានពីក្រុមហ៊ុនដែលបានខ្ចីមូលនិធិយកទៅវិនិយោគ ប៉ុន្តែមិនមែនជាការប្រាក់ដែលបង្កើតឡើងដោយផ្នែកគ្រួសារដែលបានខ្ចីមូលនិធិយកទៅចំណាយលើការប្រើប្រាស់ទេ ។

## 1.3. ចំណូលពីការជួល

សមាសធាតុទីបីដែលរាប់ចូលជាចំណូលជាតិ គឺចំណូលដែលរកបានដោយការជួល ដូចជាការជួលដីធ្លី ការជួលអគារ ផ្ទះ និងអចលនទ្រព្យដទៃទៀត ។ ជាទូទៅ ចំណូលពីការជួលមានប្រហែល 2% នៃចំណូលជាតិ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

### 1.4. ប្រាក់ចំណេញសាជីវកម្ម

សមាសធាតុទីបួនដែលរាប់ចូលជាចំណូលជាតិ គឺប្រាក់ចំណេញសាជីវកម្មដែលជាប្រាក់ចំណេញរបស់សហគ្រាសនិងពន្ធលើប្រាក់ចំណូលសាជីវកម្ម ។ ប្រាក់ចំណេញទាំងនេះមានប្រហែលជាពី 5% ទៅ 10% នៃចំណូលជាតិ ។ ប្រាក់ចំណេញសាជីវកម្ម អាចត្រូវបានប្រើប្រាស់ជាបីចំណែកគឺ

- ភាគលាភដែលជាចំណែកបែងចែកទៅឱ្យម្ចាស់ក្រុមហ៊ុនភាគហ៊ុន ។
- ប្រាក់ចំណេញសាជីវកម្មដែលមិនមែនបែងចែកជាផ្នែកនៃចំណូល ដែលរក្សាទុកសម្រាប់វិនិយោគនាពេលអនាគតរបស់ក្រុមហ៊ុន ។
- ពន្ធលើប្រាក់ចំណូលសាជីវកម្ម ។

### 1.5. ចំណូលរបស់ម្ចាស់កម្មសិទ្ធិ

សមាសធាតុទីប្រាំដែលរាប់ចូលជាចំណូលជាតិ គឺជាចំណូលរបស់ម្ចាស់កម្មសិទ្ធិ ដែលជាភាគរយដ៏ធំមួយរបស់ក្រុមហ៊ុន ។ វាគឺជាអាជីវកម្មមួយនៅក្នុងភាពជាម្ចាស់នៃក្រុមហ៊ុនដែលមានកម្មសិទ្ធិខុសប្លែកពីក្រុមហ៊ុនសាជីវកម្ម ដោយនៅក្នុងក្រុមហ៊ុន នោះម្ចាស់កម្មសិទ្ធិតែងធ្វើការផ្គត់ផ្គង់ទាំងអស់នូវកត្តាផលិតកម្ម ។ ជាទូទៅ ចំណូលរបស់ម្ចាស់កម្មសិទ្ធិមានប្រហែលពី 5% ទៅ 7% នៃចំណូលជាតិ ។

### 1.6. ចំណូលពីបរទេស

មានក្រុមហ៊ុនមួយចំនួន បើកសាខារកស៊ីរបស់ខ្លួននៅបណ្ដាប្រទេសជាច្រើន រួមទាំងបានបញ្ជូនបុគ្គលិកទៅបម្រើការងារនៅទីនោះទៀតផង ។ សាខានៃក្រុមហ៊ុនទាំងនោះ តែងតែបញ្ជូនការទូទាត់មកក្រុមហ៊ុនមេ ដែលតាំងក្នុងប្រទេសណាមួយ ដូច្នេះប្រាក់ចំណូលនោះត្រូវបានចាត់ទុកថា ប្រាក់ចំណូលបានមកពីបរទេស ។ ករណីផ្សេងមួយទៀត ប្រជាពលរដ្ឋនៃប្រទេសមួយដែលរស់នៅនិងបម្រើការងារនៅប្រទេសផ្សេង ការទទួលបានប្រាក់ទាំងនេះ ក៏ចាត់ចូលក្នុងចំណូលពីបរទេសដែរ ។ ករណីមួយទៀត ដែលជនបរទេសមករកស៊ី ឬបម្រើការងារនៅក្នុងប្រទេសយើង ជននោះត្រូវបង់ពន្ធដល់រដ្ឋតាមលក្ខខណ្ឌផ្សេងៗ ក៏ជាចំណូលទទួលបានពីបរទេសដែរ ។

## 2. ចំណូលបុគ្គល

ចំណូលជាតិជារង្វាស់ទីមួយ ចំណូលបុគ្គលគឺជារង្វាស់ទីពីរ ដែលមានសារប្រយោជន៍ដល់សកម្មភាពសេដ្ឋកិច្ច ។ ចំណូលបុគ្គល គឺជាចំណូលដែលបានទទួលដោយផ្នែកគ្រួសារ ខុសពីចំណូលជាតិដែលបានមកពីវិភាគទានលើការធានារ៉ាប់រងសង្គម (ពន្ធសម្រាប់ធានារ៉ាប់រងសង្គម) ។

### 2.1. ចំណូលរកបាន តែមិនបានទទួល

មានចំណូលបីប្រភេទដែលរកបានតាមរយៈកត្តាផលិតកម្ម ប៉ុន្តែក្រុមគ្រួសារមិនបានទទួលគឺ

- **វិភាគទានសម្រាប់សន្តិសុខសង្គមឬធានារ៉ាប់រងសង្គម** : គឺជាវិភាគទានសម្រាប់សន្តិសុខសង្គមដែលជាទូទៅ គឺជាពន្ធដែលបានដកហូតដោយរដ្ឋាភិបាលទៅលើចំណូលរបស់និយោជកនិងនិយោជិត ។ ដូចនេះមានន័យថា និយោជកនិងនិយោជិតជាអ្នករកបាននូវប្រាក់សម្រាប់សន្តិសុខសង្គម ។
- **ពន្ធលើប្រាក់ចំណូលនៃសាជីវកម្ម** : គឺជាពន្ធដែលបានដកហូតទៅលើប្រាក់ចំណូលដែលរកបានដោយក្រុមហ៊ុនសាជីវកម្មដើម្បីបង់ទៅឱ្យរដ្ឋាភិបាល ។
- **ប្រាក់ចំណេញសាជីវកម្មដែលមិនបានបែងចែក** : គឺជាផ្នែកមួយនៃប្រាក់ចំណេញសាជីវកម្មដែលត្រូវបានរក្សាទុកដោយក្រុមហ៊ុនសម្រាប់វិនិយោគនាពេលអនាគត ។

ដូចនេះ ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនសាជីវកម្មជាអ្នករកបានវិភាគទានសម្រាប់សន្តិសុខសង្គម ពន្ធលើប្រាក់ចំណូលនៃសាជីវកម្មនិងប្រាក់ចំណេញសាជីវកម្មដែលមិនបានបែងចែក តែគ្រួសារមិនបានទទួល ។

### 2.2. ចំណូលដែលមិនបានរក តែបានទទួល

ប្រភេទចំណូលសំខាន់ដែលមិនបានរក តែបានទទួលដោយផ្នែកគ្រួសារ គឺចំណាយផ្ទេរពីរដ្ឋាភិបាលទៅផ្នែកគ្រួសារ មានចំណាយសុខុមាលភាព សំណងសង្គមកិច្ច សម្រាប់ភាពគ្មានការងារធ្វើ ការប្រាក់ទៅលើបំណុលរដ្ឋាភិបាល និងប្រយោជន៍សន្តិសុខសង្គម ។ នៅពេលដែលចំណាយផ្ទេរកើនឡើង ចំណូលដែលបានទទួលដោយផ្នែកគ្រួសារក៏កើនឡើងដែរ តែចំណូលទាំងអស់នោះ មិនមែនជាចំណូលដែលរកបានតាមរយៈកត្តាផលិតកម្មទេ ។ ចំណាយផ្ទេរពុំអាចស្មើគ្នានឹងប្រភេទទាំងបីនៃចំណូលដែលរកបាន តែមិនបានទទួលនោះទេ ។

## 3. ចំណូលបុគ្គលក្រោយការបង់ពន្ធ

ចំណូលបុគ្គលក្រោយការបង់ពន្ធ គឺជាចំណូលដែលនៅសល់ក្រោយពីការបង់ពន្ធលើចំណូលបុគ្គល ។ ដើម្បីគណនារកចំណូលបុគ្គលក្រោយការបង់ពន្ធ គឺគ្រាន់តែយកចំណូលបុគ្គល ដកពន្ធលើចំណូលបុគ្គលតែប៉ុណ្ណោះ ។

ចំណូលបុគ្គលក្រោយការបង់ពន្ធ បង្ហាញពីបរិមាណនៃចំណូលផ្នែកគ្រួសារដើម្បីចំណាយ ។ វាគឺជាចំណូលដែលអាចយកទៅប្រើប្រាស់បានតាមតម្រូវការនិងចំណង់ចំណូលចិត្តមានការទិញទំនិញនិងសេវាកម្មសម្រាប់ប្រើប្រាស់និងយកទៅសន្សំនៅទីផ្សារហិរញ្ញវត្ថុជាដើម ។

## 4. សន្និដ្ឋាន

ចំណូលជាតិ គឺជាបរិមាណទឹកប្រាក់សរុបដែលរកបាននៅក្នុងប្រទេសបានទទួលដោយអ្នកផ្គត់ផ្គង់ធនធានសេដ្ឋកិច្ចនិងធនធានហិរញ្ញវត្ថុ។ ចំណូលជាតិរាប់បញ្ចូលទាំងចំណូលបុគ្គល ដែលជាចំណូលបានទទួលដោយផ្ទែកគ្រួសារ ។

ឯចំណូលបុគ្គលក្រោយការបង់ពន្ធ គឺជាចំណូលដែលនៅសល់ក្រោយពីការចំណាយទៅលើការបង់ពន្ធលើចំណូលបុគ្គល ។

## សំណួរ

1. ចូរអ្នកអានតារាងនិងអត្ថបទខាងក្រោម រួចហើយចូរនិយាយប្រាប់សិស្សក្នុងថ្នាក់ពីព័ត៌មានដែលអ្នកទទួលបាន




*ប្រភព : វែបសាយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ដកស្រង់ ០២ កុម្ភៈ ២០១០)*

2. ចូរឱ្យនិយមន័យនៃពាក្យ “ចំណូលជាតិ” ។

3. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. តើចំណូលជាតិមានលក្ខណៈខុសពីចំណូលបុគ្គលដូចម្តេច ?

ខ. តើចំណូលជាតិមានសមាសធាតុប៉ុន្មាន ? អ្វីខ្លះ ?

គ. តើចំណូលបុគ្គលចែកចេញជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

ឃ. ហេតុអ្វីបានជាចំណូលបុគ្គលក្រោយការបង់ពន្ធមានសារៈសំខាន់សម្រាប់គ្រួសារ ?

4. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ទូរស័ព្ទដៃមួយតម្លៃ 200$ តែអ្នកលក់បានកំណត់តម្លៃ 220$ ដោយគិតបញ្ចូលពន្ធ 5% ទៅលើការលក់ ។

ក្នុងបណ្តាតម្លៃខាងលើ តើតម្លៃមួយណារាប់ចូលក្នុងចំណូលជាតិ ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 7 គោលនយោបាយចំណាយនិងសារពើពន្ធ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់អត្ថន័យគោលនយោបាយចំណាយ ។
- ពន្យល់ពីតួនាទីគោលនយោបាយសារពើពន្ធ ។
- ពន្យល់ពីទំនួលខុសត្រូវរបស់រដ្ឋក្នុងការអភិវឌ្ឍនិងអនុវត្តគោលនយោបាយសារពើពន្ធ ។

នៅគ្រប់ប្រទេសក្នុងសកលលោក រដ្ឋាភិបាលត្រូវការប្រាក់ចំណូលជាចាំបាច់ដើម្បីប្រើប្រាស់ក្នុងការដឹកនាំនិងគ្រប់គ្រងប្រទេសជាតិឱ្យមានវិបុលភាពនិងវឌ្ឍនភាព ។ តើអ្វីខ្លះជាលទ្ធភាពក្នុងការរកថវិកាចំណូលដែលរដ្ឋាភិបាលអាចប្រតិបត្តិបាន ? តើអ្វីជាប្រសិទ្ធភាពនៃការចំណាយ ? ហើយតើមានប្រតិបត្តិការចំណាយនិងចំណូលបែបណាដើម្បីធានាការលូតលាស់រីកចម្រើនរបស់ប្រទេសជាតិ ? ចម្លើយមានចែងក្នុងគោលនយោបាយចំណាយ គោលនយោបាយសារពើពន្ធ និងគោលនយោបាយហិរញ្ញវត្ថុរបស់ប្រទេសនីមួយៗ ។

## 1. ចំណាយរបស់រដ្ឋាភិបាល

ចំណាយរបស់រដ្ឋាភិបាលនៃប្រទេសនានា ត្រូវបានប្រើប្រាស់លើការទិញទ្រព្យសម្ភារៈនិងសេវាទាំងឡាយដើម្បីទ្រទ្រង់ចលនាការពារនិងស្ថាបនាប្រទេសជាតិរបស់ខ្លួន ។ ដើម្បីឱ្យការចំណាយប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព រដ្ឋាភិបាលត្រូវមានការគ្រប់គ្រងចំណាយតាមច្បាប់ហិរញ្ញវត្ថុ ដែលរៀបចំនិងស្នើឡើងដោយក្រសួងឬស្ថាប័នជំនាញដែលមានសមត្ថកិច្ចគិតគូរខាងហិរញ្ញវត្ថុ ហើយច្បាប់នេះត្រូវឆ្លងកាត់ការពិនិត្យនិងអនុម័តពីស្ថាប័ននីតិបញ្ញត្តិគឺរដ្ឋសភានិងព្រឹទ្ធសភា ។

ជាទូទៅ ចំណាយរបស់រដ្ឋាភិបាលត្រូវបានបែងចែកជាពីរប្រភេទគឺ ចំណាយចរន្ត និងចំណាយមូលធន ។

### 1.1. ចំណាយចរន្ត

ចំណាយចរន្តគឺជាចំណាយលើសេវាទាំងឡាយ ដើម្បីទ្រទ្រង់យន្តការការពារនិងស្ថាបនាជាតិ ។ ចំណាយចរន្តត្រូវបានប្រើប្រាស់ទៅលើប្រាក់បៀវត្សបុគ្គលិក មន្ត្រីរាជការនិងទៅលើសេវាកម្មពិសេសៗដទៃទៀតដែលបម្រើកិច្ចការសាធារណៈ មានដូចជាសេវាកម្មក្នុងកម្មវិធីអប់រំ កម្មវិធីសុខាភិបាល ការផ្តល់សិទ្ធិសំខាន់ៗក្នុងវិស័យសន្តិសុខសង្គមជាដើម ។

### 1.2. ចំណាយជាមូលធន

ចំណាយមូលធនគឺជាចំណាយលើការទិញទ្រព្យសម្ភារ : ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធមាន សំណង់អគារ ផ្លូវថ្នល់ ប្រឡាយទឹកជាដើម រួមទាំងការអនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗដែលជាការវិនិយោគសាធារណៈនិងចំណាយលើការរំលស់បំណុល(ករណីប្រទេសមានជាប់បំណុល) ។ ចំណាយជាមូលធនមានគោលដៅពីរប្រភេទគឺ

- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនិង
- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស : វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស មានរូបភាពជាគម្រោងអភិវឌ្ឍនៅតាមវិស័យនានាដែលមានបង្ហាញឈ្មោះម្ចាស់ជំនួយដោយច្បាស់លាស់ ។

### 1.3. ចំណាយតាមច្បាប់ហិរញ្ញវត្ថុ

ច្បាប់ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដើម្បីធានាឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ តុល្យភាពរវាងសកម្មភាពក្នុងវិស័យផ្សេងៗនិងធានាឱ្យគ្រប់ចំណាយរបស់រដ្ឋាភិបាលមានប្រសិទ្ធភាពក្នុងការផ្តល់ផលប្រយោជន៍ប្រកបដោយសមធម៌ដល់ប្រជាពលរដ្ឋ តួយ៉ាងដូចជាគិតតាំងពីចំណាយលើការកសាងបណ្ណាល័យនិងចង្កៀងបំភ្លឺតាមផ្លូវសាធារណៈឡើងទៅ ។

ចំណាយត្រឹមត្រូវតាមការកំណត់នៃច្បាប់ហិរញ្ញវត្ថុតែងនាំមកនូវស្ថិរភាពសេដ្ឋកិច្ច ដោយចៀសផុតពីឱនភាពថវិកាជាតិនិងវិបត្តិផ្សេងៗ ថែមទាំងជំរុញឱ្យមានការសន្សំនិងពង្រីកការវិនិយោគមូលធនជាតិជាប្រចាំ ។

## 2. ចំណូលរបស់រដ្ឋាភិបាល

ប្រតិបត្តិការប្រមូលចំណូលរបស់រដ្ឋាភិបាលក៏ត្រូវស្ថិតនៅក្រោមច្បាប់ហិរញ្ញវត្ថុដែរ ដើម្បីធានាស្ថេរភាពសេដ្ឋកិច្ចនិងចៀសវាងការដាក់សម្ពាធមិនសមស្របចំពោះអ្នកបង់ពន្ធ ។

ផលទុនជាតិឬចំណូលជាតិ ជាផលបូកនៃចំណូលដែលបុគ្គលទាំងអស់ក្នុងប្រទេសមួយបានទទួលជាប្រាក់បៀវត្ស ការប្រាក់ ឈ្នួលផ្ទះ និងជាប្រាក់ចំណេញ ។ល ។ ផលទុនជាតិ គេគិតនៅមុនពេលកាត់យកពន្ធ ។ គេអាចពន្យល់ម្យ៉ាងទៀតថា ផលទុនជាតិជាតម្លៃកើតឡើងថ្មីក្នុងមាត្រដ្ឋាននៃសេដ្ឋកិច្ចជាតិទាំងអស់នៃប្រទេសមួយ ឬជាភាគនៃតម្លៃរបស់ផលិតផលសង្គមសរុប ដោយដកយកចេញនូវមធ្យោបាយផលិតកម្មប្រើប្រាស់ក្នុងរយៈពេលមួយកំណត់ (*ឧទាហរណ៍* ក្នុងរយៈពេលមួយឆ្នាំ) ។

ក្នុងប្រទេសមួយដែលស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចកំពុងអភិវឌ្ឍ ចំណូលរបស់រដ្ឋាភិបាលបានមកពីការប្រមូលពន្ធរួមផ្សំនិងការបូកបញ្ចូលជំនួយផ្សេងៗពីសហគមន៍អន្តរជាតិ ។ ចំណូលរបស់រដ្ឋាភិបាលមាន 2ប្រភេទគឺ ចំណូលចរន្តនិងចំណូលមូលធន ។

## 2.1. ចំណូលចរន្ត

ចំណូលចរន្ត ជាប្រាក់ចំណូលដែលប្រមូលបានតាមរយៈការយកពន្ធនិងអាករនៅក្នុងដំណើរសកម្មភាពសេដ្ឋកិច្ចមានដូចជា ការផលិត ការជួល ការលក់ ការធ្វើសម្បទាន និងសេវាកម្ម ។ ប្រភពសំខាន់នៃៗចំណូលចរន្តមាន

- **ពន្ធនិងអាករ** : ពន្ធគឺវិភាគទានជាកាតព្វកិច្ចខានមិនបានដែលប្រជាពលរដ្ឋ អង្គការ និងសហគ្រាសនានាត្រូវបង់ ។ ជាទូទៅ អត្រានៃពន្ធនានាតែងមានឥទ្ធិពលលើផលិតកម្មទំនិញនិងសេវាកម្ម ។ ពន្ធមាន 2ប្រភេទគឺ ពន្ធផ្ទាល់ និង ពន្ធប្រយោល ។ រីឯអាករគឺជាចំនួនទឹកប្រាក់ដែលកំណត់ដោយច្បាប់និងបទបញ្ញាជាធរមានទាំងឡាយ ដែលទីចាត់ការគយនិងរដ្ឋាករទទួលបន្ទុកធ្វើការប្រមូលនៅពេលមានការនាំចូលឬនាំចេញទំនិញផ្សេងៗ ។

  ចំណូលចរន្តរបស់រដ្ឋាភិបាលមានប្រភពពី

  - ពន្ធលើផលទុនប្រាក់ចំណេញនិងកម្រៃទុន : មានពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណេញរបស់រោងចក្រនិងពាណិជ្ជកម្ម សហគ្រាសសាធារណៈ សហគ្រាសមជ្ឈិម សហគ្រាសឯកជន ពន្ធលើទុននៃដីធ្លីផ្ទះសម្បែង ។ល ។
  - ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវា : មានអាករលើផលរបរ (សហគ្រាសសាធារណៈ សហគ្រាសមជ្ឈិម សហគ្រាសឯកជន) អាករលើតម្លៃបន្ថែម(សហគ្រាសសាធារណៈ សហគ្រាសឯកជន) អាករពិសេសលើសេវាកម្មនិងទំនិញមួយចំនួន ។
  - ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស : មានពន្ធនិងអាករគយពីការនាំចូល នាំចេញផលិតផល និង ការផាកពិន័យរបស់គយ ។
  - ចំណូលសារពើពន្ធផ្សេងៗទៀត : មានពន្ធតែមប្រិ៍ ការផាកពិន័យចំពោះទោសបញ្ញត្តិសារពើពន្ធជាដើម ។

- **ចំណូលពុំមែនសារពើពន្ធ** : ជាប្រភេទចំណូលដែលមិនមែនជាពន្ធផ្សេងៗ ។

  ចំណូលពុំមែនសារពើពន្ធមានប្រភពពី

  - ផលទុននៃទ្រព្យសម្បត្តិរដ្ឋ : មានផលទុននៃសាទ ផលព្រៃឈើ ផលទុនបានមកពីសហគ្រាសសាធារណៈ ការជួលរោងចក្រសហគ្រាស ប្រាក់ចំណេញរបស់សហគ្រាស

សាធារណៈ ចំណូលពីអាកាសចរណ៍ស៊ីវិល ផលទុននៃសកម្មភាពភាពយន្ត ការលក់ឬជួលសម្ភារៈបរិក្ខារ ការដឹកជញ្ជូនទំនិញ ការផ្គត់ផ្គង់អគ្គិសនី ការផ្គត់ផ្គង់ទឹក និងផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ ។

- កម្រៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ សម្បទានរ៉ែ សម្បទានផ្សេងៗទៀត ការជួលអចលនវត្ថុ សេវាកម្មសុរិយោដី ។ល ។

### 2.2. ចំណូលជាមូលធន

ចំណូលជាមូលធនសំដៅលើប្រាក់ចំណូលពីការលក់សម្បត្តិរដ្ឋ ពីការផ្តល់អំណោយ ឬការផ្តល់កម្ចីអំពីសហគមន៍អន្តរជាតិដែលត្រូវបានបម្រុងទុកដើម្បីការវិនិយោគសាធារណៈ ការសន្សំ ការផ្ទេរជាផ្លូវការ ដើម្បីទូទាត់កង្វះខាតក្នុងចំណាយចរន្ត និងការរំលស់បំណុល ។ ចំណូលជាមូលធនមាន 2ប្រភេទគឺ

- **ចំណូលជាមូលធនក្នុងប្រទេស :** មានប្រភពពីការលក់ដីធ្លី ផលឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋមួយចំនួននិងការខ្ចីបុលក្នុងប្រទេស ។
- **ចំណូលជាមូលធនក្រៅប្រទេសឬមូលនិធិទ្រទ្រង់ថវិកា :** មានប្រភពពីអំណោយពីបរទេស ទុនខ្ចីពីបរទេសដោយផ្ទាល់ ទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា មូលនិធិបដិភាគពីធនាគារពិភពលោក ឬពីធនាគារអភិវឌ្ឍអាស៊ីជាដើម ។

## 3. តុល្យភាពចំណាយនិងចំណូល

បើការចំណាយមានបរិមាណច្រើនជាងចំណូល ថវិកាក៏ត្រូវស្ថិតក្នុងភាពខ្វះខាត ត្រូវជំពាក់បំណុលដែលហៅថា ឱនភាពថវិកា ។ នៅពេលដែលចំណូលមានបរិមាណច្រើនជាងចំណាយ ឬចំណាយមិនអស់សាច់ប្រាក់ដែលគេគ្រោងនឹងចាយ ហៅថាអតិរេកថវិកា ។ មានអតិរេកថវិកា មានន័យថាមានការអាក់ខានសកម្មភាពការងារជាប្រយោជន៍សាធារណៈក្នុងចំនួនណាមួយ ។ ដូចនេះ ឱនភាពថវិកានិងអតិរេកថវិកា គឺជាវិបត្តិក្នុងដំណើរសេដ្ឋកិច្ច ។ ប៉ុន្តែ វិបត្តិត្រូវបានកាត់បន្ថយកាន់តែច្រើននៅពេលដែលអត្រានៃគម្លាតរវាងចំណាយនិងចំណូលមានកាន់តែតូចដែលគេហៅថាមានតុល្យភាពថវិកា ។ ដោយមានការអនុវត្តបានត្រឹមត្រូវក្នុងប្រតិបត្តិការចំណាយនិងចំណូលរបស់រដ្ឋាភិបាល គេឃើញមានតុល្យភាពថវិកាជាតិដ៏ប្រសើរជាហេតុនាំឱ្យសេដ្ឋកិច្ចជាតិមានកំណើនជាបន្តបន្ទាប់ ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh




*របាយការណ៍បង្ហាញតុល្យភាពរវាងចំណាយនិងចំណូលថវិការដ្ឋ*

## 4. បណ្ដាគោលនយោបាយក្នុងវិស័យសេដ្ឋកិច្ច

ដូចបានសិក្សាកន្លងមកពីបណ្ដាកថាខណ្ឌខាងលើ យើងឃើញថាដំណើរការទ្រទ្រង់និងអភិវឌ្ឍសេដ្ឋកិច្ចមិនមែនជាដំណើរការឯកឯង ឬជាដំណើរការផ្សងព្រេងដោយគ្មានការព្រាងទុកនោះឡើយ ។

គោលនយោបាយក្នុងវិស័យសេដ្ឋកិច្ច ត្រូវបានរៀបចំតម្រូវទៅតាមការប្រើប្រាស់ក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។ មិនមែនមានតែភាគីរដ្ឋាភិបាលតែប៉ុណ្ណោះទេ ប៉ុន្តែគឺគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាអ្នកអនុវត្តគោលនយោបាយទាំងនោះ ។ គោលនយោបាយទាំងនោះមានដូចជា

- **គោលនយោបាយមីក្រូសេដ្ឋកិច្ច :** សង្កត់ធ្ងន់លើវិធានការមីក្រូសេដ្ឋកិច្ច ដើម្បីបង្កើនផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ចទាំងមូល ។
- **គោលនយោបាយពន្ធ :** គិតគូរអំពីការផ្លាស់ប្ដូរពន្ធ កំណែទម្រង់ពន្ធ ឬការបញ្ចុះតម្លៃពន្ធសំខាន់ៗ ។
- **គោលនយោបាយថវិកា :** កំណត់ការចំណាយថវិការដ្ឋ ការប្រមូលពន្ធ និងវិធានការដោះស្រាយឱនភាពថវិការដ្ឋ ។

- **គោលនយោបាយទង្វើសេដ្ឋកិច្ច** : បម្រើការរីកលូតលាស់នៃការផ្គត់ផ្គង់រូបិយវត្ថុប្រចាំឆ្នាំ ត្រួតពិនិត្យអត្រាការបាត់បង់អាជីព អត្រាអតិផរណា ការលូតលាស់ផលិតកម្ម អត្រាប្រាក់សន្សំរបស់បុគ្គល ។ល ។
- **គោលនយោបាយសារពើពន្ធ** : ថែងអំពីការពិនិត្យឱ្យបានល្អិតល្អន់ទាំងការយកពន្ធ ទាំងឥទ្ធិពលនៃការយកពន្ធ និងទាំងកម្មវិធីចំណាយរបស់រដ្ឋាភិបាល ។
- **គោលនយោបាយចំណាយ** : កំណត់ប្រភេទនិងទំហំនៃមុខចំណាយផ្សេងៗរបស់រដ្ឋាភិបាល ។
- **គោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុ** : រៀបចំកំណែទម្រង់ដើម្បីបង្កើនប្រសិទ្ធភាពការងារហិរញ្ញវត្ថុ ។
- **គោលនយោបាយសវនកម្មជាតិ** : ណែនាំការអនុវត្តកម្មវិធីសវនកម្មជាតិ... ។ល ។

## 5. សេចក្តីសន្និដ្ឋាន

សកម្មភាពសេដ្ឋកិច្ចរដ្ឋនិងសកម្មភាពសេដ្ឋកិច្ចឯកជនមានទំនាក់ទំនងនឹងគ្នាមិនអាចផ្តាច់បាន ។ សកម្មភាពសេដ្ឋកិច្ចរដ្ឋ ជាសេវាកម្មមិនរកចំណេញ មានគោលដៅបម្រើសាធារណប្រយោជន៍ទូទៅ ។ ចំណែកសកម្មភាពសេដ្ឋកិច្ចឯកជនមានគោលដៅបង្កើនផលប្រយោជន៍ឯកជនតាមរយៈការបង្កើនប្រាក់ចំណេញបុគ្គល ប៉ុន្តែតាមរយៈនោះមានផ្តល់ផលប្រយោជន៍សាធារណៈដោយផ្នែកៗ ។ ការកើតមានសារពើពន្ធ ជាការរៃអង្គាសប្រាក់ចំណូលបុគ្គល ដើម្បីបម្រើសាធារណប្រយោជន៍ទូទៅ ។ ប៉ុន្តែប្រសិនបើការអនុវត្តសារពើពន្ធពុំមានគោលនយោបាយត្រឹមត្រូវ ការអនុវត្តនោះអាចនាំឱ្យខូចប្រយោជន៍ដល់ការលើកទឹកចិត្តចំពោះសកម្មភាពការងារឬការសន្សំប្រាក់របស់បុគ្គល ក្រុមហ៊ុន ឬសហគ្រាសឯកជន ហើយនឹងមានផលប៉ះពាល់ដល់កម្រិតនៃការកើនឡើងឬការថយចុះនៃកម្មវិធីអភិវឌ្ឍរបស់រដ្ឋាភិបាល ។

facebook.com/moeys.gov.kh youtube.com/moeys

# ? សំណួរ

1. ចូរអ្នកពិនិត្យអត្ថបទនិងតារាងខាងក្រោម រួចហើយនិយាយប្រាប់សិស្សក្នុងថ្នាក់ថា អត្ថបទនិងតារាងទាំងនេះចង់បង្ហាញពីអ្វី ។

ឆ្នាំទី ៩ លេខ ១០ សប្ដាហ៍ទី ១ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ រាជកិច្ច ទំព័រ ៧១៤

**ជំពូកទី ១**

**កិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ**

**ផ្នែកទី ១ : បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ការអនុវត្តនេះលេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ

ឯកតា:លានរៀល

| កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៦ | ការអនុវត្តថវិកាឆ្នាំ ២០០៦ | លើស(+) ខ្វះ(-) |
|---|---|---|---|
| សរុបចំណូល=( I១ + II.១) | ៣.៨១៤.១២៥ | ៤.៧២៨.០៥២ | +៩១៣.៩២៧ |
| សរុបចំណាយ=( I២ + II.២) | ៣.៨១៤.១២៥ | ៤.១៤៤.០៨៩ | +៣២៩.៩៦៤ |
| អតិរេកនៃគណនេយ្យចំណូល/ចំណាយ | ០ | ៥៨៣.៩៦៣ | |
| **I.** កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាដែលបានអនុវត្តតាមរយៈរតនាគារជាតិ | | | |
| I.១.ចំណូលថវិកា | ២.៩៥៦.៣២៥ | ៣.៣៩៧.០១០ | +៤៤០.៦៨៥ |
| • ចំណូលចរន្ត | ២.៧៤០.៧២០ | ២.៨៨១.៧២០ | +១៤១.០០០ |
| • ចំណូលមូលធនក្នុងប្រទេស | ៧២.០០០ | ៣៧៧.៤៥១ | +៣០៥.៤៥១ |
| • ចំណូលជាមូលនិធិទ្រទ្រង់ថវិកា | ១៤៣.៦០៥ | ១៣៧.៨៣៩ | -៥.៧៦៦ |
| I.២.ចំណាយថវិកា | ២.៩៥៦.៣២៥ | ២.៨១៣.០៤៧ | -១៤៣.២៧៨ |
| • ចំណាយចរន្ត | ២.៤១៤.២៥៥ | ២.៣៦៦.៥៥៣ | -៤៧.៧០២ |
| • ចំណាយជាមូលធន | ៥៤២.០៧០ | ៤៤៦.៤៩៤ | -៩៥.៥៧៦ |
| **II.** វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | |
| II.១.ធនធានជាមូលធនសម្រាប់គាំទ្រដោយហិរញ្ញប្បទានក្រៅប្រទេស | ៨៥៧.៨០០ | ១.៣៣១.០៤២ | +៤៧៣.២៤២ |
| II.២.ចំណាយជាមូលធនដោយធនធានសម្រាប់គាំទ្រដោយហិរញ្ញប្បទានក្រៅប្រទេស | ៨៥៧.៨០០ | ១.៣៣១.០៤២ | +៤៧៣.២៤២ |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

kroumoeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

ឆ្នាំទី ៩ លេខ ១០ សប្តាហ៍ទី ១ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ រាជកិច្ច ទំព័រ ៧១៦

ចំណូលចរន្ត ៖

-ច្បាប់ហិរញ្ញវត្ថុ.......................២.៧៤០.៧២០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន............២.៨៨១.៧២០ លានរៀល

-ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន..........(+)១៤១.០០០ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស ៖

-ច្បាប់ហិរញ្ញវត្ថុ...........................៧២.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន..............៣៧៧.៤៥១ លានរៀល

-ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន..........(+)៣០៥.៤៥១ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស (មូលនិធិទ្រទ្រង់ថវិកា) ៖

-ច្បាប់ហិរញ្ញវត្ថុ.........................១៤៣.៦០៥ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន..............១៣៧.៨៣៩ លានរៀល

-ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............(-)៥.៧៦៦ លានរៀល

**មាត្រា ៤.—**

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ មានចំនួនទឹកប្រាក់សរុប...............២.៩៥៦.៣២៥ លានរៀល

ត្រូវបានអនុវត្តជាក់ស្តែងមានចំនួនទឹកប្រាក់....២.៨១៣.០៤៧ លានរៀល

ដូច្នេះមានចំណាយជាក់ស្តែងទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..(-)១៤៣.២៧៨ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ៖

ចំណាយចរន្ត ៖

-ច្បាប់ហិរញ្ញវត្ថុ.......................២.៤១៤.២៥៥ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន............២.៣៦៦.៥៥៣ លានរៀល

-ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..........(-)៤៧.៧០២ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស៖

-ច្បាប់ហិរញ្ញវត្ថុ..........................៤៤៥.៩៨០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន................៣៨០.៩៦៣ លានរៀល

-ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន............(-)៦៥.០១៧ លានរៀល

ចំណាយជាមូលធននៃការវិលសំបំណុល៖

-ច្បាប់ហិរញ្ញវត្ថុ............................៩៦.០៩០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន..................៦៥.៥៣១ លានរៀល

-ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន...........(-)៣០.៥៥៩ លានរៀល

**មាត្រា ៥.-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិដូចមានចែងក្នុង មាត្រា ៣ និង មាត្រា ៤ នៃច្បាប់នេះបានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយ ដូចតទៅ៖

-ចំណូលថវិកា ដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ មានចំនួន.............................៣.៣៩៧.០១០ លានរៀល

-ចំណាយថវិកា ដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ មានចំនួន.............................២.៨១៣.០៤៧ លានរៀល

-អតិរេកពិតនៃគណនេយ្យចំណូល និង ចំណាយចំនួន..(+)៥៨៣.៩៦៣ លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ៖

-អតិរេកនៃចំណូលចរន្ត និង ចំណាយចរន្ត.....(+)៥១៥.១៦៧ លានរៀល

-និងអតិរេកនៃចំណូលមូលធននិងចំណាយមូលធន..(+)៦៨.៧៩៦ លានរៀល

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

ក. ហេតុអ្វីបានជារដ្ឋាភិបាលគ្រប់ប្រទេសត្រូវការចំណាយ ? តើមានការចំណាយទៅលើអ្វីខ្លះ ?

ខ. តើការចំណាយរបស់រដ្ឋាភិបាលមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូររៀបរាប់និងពន្យល់ ។

គ. តើរដ្ឋាភិបាលរកចំណូលដោយវិធីណា ?

ឃ. តើចំណូលរបស់រដ្ឋាភិបាលមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូររៀបរាប់និងពន្យល់ ។

ង. ដូចម្ដេចហៅថាតុល្យភាពចំណាយនិងចំណូល ? ចូរពន្យល់ ។

ច. តើមានគោលនយោបាយអ្វីខ្លះ ក្នុងវិស័យសេដ្ឋកិច្ច ?

ឆ. សេវាកម្មសាធារណៈតែងផ្គត់ផ្គង់ដោយសារពើពន្ធ ។ តើសារពើពន្ធមានឥទ្ធិពលបែបណាចំពោះសកម្មភាពការងារឬការសន្សំប្រាក់របស់បុគ្គល ក្រុមហ៊ុន ឬសហគ្រាសឯកជន ។

3. ចូរអ្នកអានអត្ថបទមេរៀនដោយយកចិត្តទុកដាក់ ហើយដកស្រង់ខ្លឹមសារដែលអ្នកយល់ថាសំខាន់ដើម្បីចងក្រងជាមេរៀនសង្ខេបផ្ទាល់របស់ខ្លួន ។

## ប្រតិបត្តិ

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន មានសកម្មភាពសេវាកម្មសាធារណៈ ដែលមានការចូលរួមជាកម្លាំងកាយនិងថវិកាប្រកបដោយសមានចិត្ត និងបីតិសោមនស្សពីសំណាក់ប្រជាពលរដ្ឋ ។ ចូរអ្នកចុះសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍របស់អ្នក តើសកម្មភាពសេវាកម្មសាធារណៈដែលប្រកបដោយប្រសិទ្ធភាពនោះមាននៅទីណា? តើសកម្មភាពនោះមានចំណុចវិជ្ជមានអ្វីខ្លះដែលទាក់ទាញបានការចូលរួម? ចូររៀបរាប់បទពិសោធន៍ល្អទាំងនោះ ។

youtube.com/moeys
facebook.com/moeys.gov.kh

មេរៀនទី

# 8 ជាតូបនីយកម្មនិងឯកជនូបនីយកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីប្រសិទ្ធភាពនៃជាតូបនីយកម្ម ។
- រៀបរាប់ពីលទ្ធផលនៃការអនុវត្តវិធីឯកជនូបនីយកម្ម ។

ក្នុងពិភពលោកបច្ចុប្បន្ន ជោគជ័យនៃការអភិវឌ្ឍសង្គមឬប្រទេសមួយចំនួនគឺអាស្រ័យលើបរិយាកាសសេដ្ឋកិច្ច នយោបាយ ហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យក្រុមហ៊ុនឬសហគ្រាសនានាធ្វើអាជីវកម្មដោយសេរី ។ យោងតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី សហគ្រិនជាអ្នកចំណាយទុននិងរៀបចំកិច្ចការជំនួញ និងជាអ្នកមានសេរីភាពក្នុងការរកចំណូល ។ ទោះបី សហគ្រិនធ្វើអាជីវកម្មដើម្បីប្រយោជន៍ឯកជន ប៉ុន្តែតាមរយៈសកម្មភាពទាំងនោះ គេមើលឃើញថា សហគ្រិនជាអ្នកជំរុញសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់អាចធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចម្រើនបាន ។

## 1. ជាតូបនីយកម្ម

**ជាតូបនីយកម្ម** មានន័យថា ការបង្វិលសហគ្រាសឬសាខាផលិតកម្មនៃកម្មសិទ្ធិឯកជនឱ្យទៅជាកម្មសិទ្ធិរបស់រដ្ឋ ។

### 1.1. ប្រសិទ្ធភាពនៃជាតូបនីយកម្ម

ជាទូទៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍ គេធ្វើជាតូបនីយកម្មដើម្បីប្រឆាំងនឹងរបបលក់ផ្ដាច់មុខរបស់បរទេស ឬប្រឆាំងនឹងនយោបាយអាណានិគមនិយមបែបថ្មី ។ ជាតូបនីយកម្មនឹងមានប្រសិទ្ធភាពទៅបានលុះត្រាតែរដ្ឋមានលទ្ធភាពនិងសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសហគ្រាសឬសាខាផលិតកម្មនោះឱ្យមានដំណើរការល្អប្រសើរនិងមានការរីកចម្រើនដោយស្របគ្នានឹងការអភិវឌ្ឍជាតិ ។ ក្នុងន័យនេះ ក្រោយពេលធ្វើការកែលំអ បំពាក់ឧបករណ៍ថ្មីៗដើម្បីបង្កើនប្រាក់ចំណេញ រដ្ឋបានបង្វិលឱ្យទៅជាកម្មសិទ្ធិឯកជនវិញ ។ បែបនេះហៅថា**ជាតូបនីយកម្ម** ។ ***ឧទាហរណ៍*** នៅឆ្នាំ 1930 មានការធ្វើជាតូបនីយកម្មសហគ្រាសឯកជនទាំងឡាយនៅប្រទេសអង់គ្លេស បារាំង និងបស្ចិមប្រទេសផ្សេងៗទៀត ។ នៅឆ្នាំ 1945 -1951 មានការធ្វើជាតូបនីយកម្មនៃសាខាផលិតកម្មនៅប្រទេសអង់គ្លេស ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

### 1.2. អប្រសិទ្ធភាពនៃជាតូបនីយកម្ម

ក្រោយពេលបានក្លាយជាកម្មសិទ្ធិរបស់រដ្ឋ ក្នុងករណីសហគ្រាសត្រូវការចំណាយហិរញ្ញវត្ថុច្រើន ហើយផលិតកម្មមិនសូវមានប្រសិទ្ធភាព នោះមានន័យថាជាតូបនីយកម្មគ្មានប្រសិទ្ធភាពទេ ។ *ឧទាហរណ៍* សហគ្រាសដែលបានធ្វើជាតូបនីយកម្មរួច ជាទូទៅច្រើនគ្រប់គ្រងដឹកនាំដោយម្ចាស់ដើមពីមុន ហើយម្ចាស់ដើមនោះបានបង្វិលប្រាក់បៀវត្សរ៍ច្រើនអំពីរដ្ឋដែលចំនួនទឹកប្រាក់នោះជួនកាលលើសតម្លៃទ្រព្យសម្ភារៈដែលទើបបានធ្វើជាតូបនីយកម្មនោះទៅទៀត ។

## 2. ឯកជនូបនីយកម្ម

**ឯកជនូបនីយកម្ម** មានន័យថាការជួលឬផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យឯកជនដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ នៅឆ្នាំ 1980 កម្មវិធីឯកជនូបនីយកម្មត្រូវបានអនុវត្តយ៉ាងទូលំទូលាយក្នុងប្រទេសជាច្រើនលើពិភពលោក ។

### 2.1. ប្រសិទ្ធភាពឯកជនូបនីយកម្ម

ឯកជនូបនីយកម្មនឹងទទួលបានជោគជ័យលុះត្រាតែ

- រដ្ឋមានទិសដៅច្បាស់លាស់ មានគោលនយោបាយជាយុទ្ធសាស្ត្រសមស្រប ។
- ធនធានមនុស្សគ្រប់គ្រាន់តាមតម្រូវការនៃជំនាញ ។
- ហិរញ្ញវត្ថុមានសក្ដានុពល ។
- ប្រព័ន្ធគណនេយ្យធនាគារមានលក្ខណៈទូលំទូលាយនិងមានច្បាប់លិខិតបទដ្ឋានត្រឹមត្រូវ ។

ជារួម ការអនុវត្តកម្មវិធីឯកជនូបនីយកម្មច្រើនទទួលបានជោគជ័យក្នុងប្រទេសអភិវឌ្ឍ ។

### 2.2. អប្រសិទ្ធភាពនៃឯកជនូបនីយកម្ម

ក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើនតែងនៅខ្វះខាតគោលនយោបាយច្បាស់លាស់អំពីកម្មវិធីនិងទិសដៅឯកជនូបនីយកម្មហើយគោលនយោបាយនានាច្រើនប្រទាញប្រទង់ទៅតាមកត្តានយោបាយ ។ បន្ថែមលើនេះ កង្វះធនធានមនុស្ស ហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យធនាគារ និងច្បាប់លិខិតបទដ្ឋានបានបង្កអប្រសិទ្ធភាពនៃឯកជនូបនីយកម្មដែលស្តែងឱ្យឃើញនូវរូបភាពការប្រែក្លាយការផ្ដាច់មុខរបស់រដ្ឋឱ្យទៅជាការផ្ដាច់មុខរបស់ឯកជនប៉ុណ្ណោះ ។

គួរកត់សម្គាល់ថាការគ្រប់គ្រងសហគ្រាសជាកត្តាគន្លឹះនៃជោគជ័យ ។ គោលបំណងរបស់វិនិយោគគឺស្វែងរកវិធីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព មានការត្រួតពិនិត្យដែលមិនស្មុគស្មាញនិងគ្មាន

លក្ខណៈការិយាល័យនិយម ។ ចំណែកឯ ឯកជនូបនីយកម្មដែលគ្មានការគ្រប់គ្រងច្បាស់លាស់និងគ្មានសេរីភាពគ្រប់គ្រាន់ក្នុងការធ្វើអាជីវកម្មនិងការប្រកួតប្រជែងពេញលេញនោះ ប្រាកដជាមិនអាចទទួលបានជោគជ័យនោះទេ ។

ឯកជនូបនីយកម្មជាផ្នែកមួយនៃកំណែទម្រង់រដ្ឋបាលសាធារណៈដែលជាកម្មវត្ថុមួយនិងស្មុគស្មាញ ។

ក្នុងតំបន់ផ្សេងៗគ្នាអត្ថន័យឯកជនូបនីយកម្មមានលក្ខណៈផ្សេងៗគ្នាដែរ ។ នៅបណ្ដាប្រទេសអឺរ៉ុបខាងលិច អាមេរិកខាងជើង និងជប៉ុន គោលបំណងសំខាន់ក្នុងការអនុវត្តកម្មវិធីឯកជននូបនីយកម្មគឺជាការធ្វើឱ្យមានបច្ចេកវិទ្យាកាន់តែទំនើបនិងឱ្យមានចំណូលកាន់តែច្រើន ។ ចំណែកក្នុងបណ្ដាប្រទេសដែលកំពុងឆ្លងពីសេដ្ឋកិច្ចបែបផែនការមកជាសេដ្ឋកិច្ចទីផ្សារ គោលដៅចម្បងរបស់ប្រទេសទាំងនេះ គឺការលើកកម្ពស់ជំនាញឯកទេសនិងការបង្កើតមូលដ្ឋានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

រួមសេចក្ដីមក ដើម្បីប្រសិទ្ធភាពនៃឯកជនូបនីយកម្ម រដ្ឋត្រូវយកចិត្តទុកដាក់

- កែលំអហេដ្ឋារចនាសម្ព័ន្ធឯកជនូបនីយកម្មដែលនៅខ្សោយ ។ *ឧទាហរណ៍* ដោះស្រាយដោយធ្វើការអភិវឌ្ឍធនធានមនុស្សលើផ្នែកច្បាប់ គណនេយ្យករ ធនាគារិក និងបុគ្គលិកជំនាញផ្សេងៗទៀតសម្រាប់អនុវត្តកំណែទម្រង់រចនាសម្ព័ន្ធសហគ្រាស ។
- បង្កើតច្បាប់និងលិខិតបទដ្ឋាននានាដែលក្នុងនោះត្រូវមានច្បាប់ស្ដីពីសិទ្ធិលើទ្រព្យសម្បត្តិកម្មសិទ្ធិឯកជន ច្បាប់សម្រាប់គ្រប់គ្រងគ្រឹះស្ថានហិរញ្ញវត្ថុ ច្បាប់ពាណិជ្ជកម្មជាដើម ។
- ការពារសិទ្ធិរបស់កម្មករនិងផ្ដល់លទ្ធភាពឱ្យកម្មករអាចការពារប្រយោជន៍របស់ខ្លួនក្នុងដំណើរការឯកជនូបនីយកម្ម ។

ទោះបីមានលក្ខខណ្ឌអនុគ្រោះក៏ដោយ ឯកជនូបនីយកម្មជាដំណើរការមួយដែលត្រូវចំណាយពេលវេលាច្រើនដែលតម្រូវឱ្យរដ្ឋមានគោលការណ៍ជាក់លាក់និងមានផែនការអភិវឌ្ឍន៍យូរអង្វែង ។

តម្រូវការកំណែទម្រង់បែបឯកជនូបនីយកម្ម ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍ ទាមទារឱ្យរដ្ឋត្រូវដោះស្រាយផ្ដល់ការងារច្រើនថែមទៀតទៅឱ្យពលរដ្ឋនិងត្រូវប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងខ្លាំងពីសំណាក់ផ្នែកឯកជនក្នុងការទាក់ទាញបុគ្គលិកដែលមានវិជ្ជាជីវៈ ។

## 3. សន្និដ្ឋាន

គួរកត់សម្គាល់ថាជាតូបនីយកម្មនិងឯកជនូបនីយកម្មសុទ្ធសឹងមានផលវិជ្ជមានដោយរៀងខ្លួន ។ ដើម្បីអនុវត្តកំណែទម្រង់ណាមួយ តាមរូបភាពណាមួយ រដ្ឋត្រូវមានកត្តាផានាប្រសិទ្ធភាពឱ្យបានគ្រប់គ្រាន់ ។

## សំណួរ

1. ក្នុងរបបប៉ុលពតមានការប្រែក្លាយទ្រព្យសម្បត្តិនិងធនធានទាំងអស់ឱ្យទៅជាសម្បត្តិរួម ។ ប្រសិនបើអ្នកបានដឹងពីព្រឹត្តិការណ៍នេះ ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. ជាតូបនីយកម្មជាទូទៅច្រើនគ្រប់គ្រងនិងដឹកនាំដូចម្ដេច ?
   ខ. ហេតុអ្វីបានជាគេធ្វើជាតូបនីយកម្មក្នុងប្រទេសកំពុងអភិវឌ្ឍ ?
   គ. តើលទ្ធផលនៃការអនុវត្តកម្មវិធីឯកជនូបនីយកម្មក្នុងប្រទេសអភិវឌ្ឍច្រើនទទួលបានលទ្ធផលដូចម្ដេច ?
   ឃ. ចូរធ្វើការប្រៀបធៀបពីលទ្ធផលនៃការអនុវត្តកម្មវិធីឯកជនូបនីយកម្មក្នុងប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ ។ តើមានលក្ខណៈខុសគ្នាដូចម្ដេច ?
3. ចូរអ្នកអាននិងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

តាមការសង្កេតរបស់អ្នក តើសេដ្ឋកិច្ចកម្ពុជាកំពុងស្ថិតក្នុងកំណែទម្រង់បែបជាតូបនីយកម្មឬឯកជនូបនីយកម្ម ? តើកំណែទម្រង់នោះមានប្រសិទ្ធភាពឬទេ ? ហេតុអ្វី ?

facebook.com/moeys.gov.kh kh.moeys.gov.kh youtube.com/moeys

មេរៀនទី

# 9 ពលកម្មនិងប្រាក់បៀវត្ស

**ចប់មេរៀននេះ សិស្សអាច**

- កំណត់និយមន័យនៃពាក្យពលកម្ម កម្លាំងពលកម្ម ។
- រៀបរាប់ពីលក្ខខណ្ឌមិនចាត់ចូលជាកម្លាំងពលកម្ម ។
- ពន្យល់ពីព្រឹត្តការណ៍លើទីផ្សារពលកម្មពាក់ព័ន្ធនឹងអត្រាប្រាក់បៀវត្ស ។
- បកស្រាយចំពោះសមតាទីផ្សារ ។

ក្នុងការរស់នៅ ទំនាក់ទំនងរវាងមនុស្សនិងមនុស្ស មនុស្សនិងធម្មជាតិមានសារៈសំខាន់មិនអាចផ្ដាច់ចេញបាន ។ ក្នុងទំនាក់ទំនងរវាងមនុស្សជាមួយធម្មជាតិ មនុស្សចេះច្នៃធនធានធម្មជាតិ ឱ្យទៅជាផលិតផលប្រើប្រាស់តាមរយៈផលិតកម្មក្នុងទំនាក់ទំនងរវាងមនុស្សនិងមនុស្សមានសកម្មភាពគ្រប់គ្រង សហការ និងបែងចែកផលចំពោះគ្នានិងគ្នា ។

## 1. ពលកម្ម

**ពលកម្ម** គឺជាសកម្មភាពប្រកបដោយមនសិការឬប្រកបដោយវិចារណញ្ញាណរបស់មនុស្ស សំដៅបំប្លែងកម្មវត្ថុណាមួយ ឱ្យទៅជាវត្ថុឬសម្ភារៈដែលបម្រើសេចក្ដីត្រូវការរបស់ខ្លួន ដូចជាទំនិញជាដើម ។ ដោយសារពលកម្ម មនុស្សអាចវិវឌ្ឍចេញពីពិភពនៃសត្វនិងអាចគ្រប់គ្រងនិងប្រើប្រាស់ធម្មជាតិ ដើម្បីបម្រើប្រយោជន៍របស់ខ្លួន ។ ឆ្លងតាមបទពិសោធដ៏ច្រើន មនុស្សបានកែច្នៃធម្មជាតិធ្វើជាឧបករណ៍ពលកម្មនិងបានអភិវឌ្ឍសម្បទានៃចំណេះដឹងទាំងឡាយរបស់ខ្លួន ។ ពលកម្មទាំងអស់នេះរួមគ្នាជំរុញឱ្យសង្គមមានការរីកចម្រើន ។ ដំណើរការពលកម្មមានធាតុបី

- សកម្មភាពសនិទានរបស់មនុស្ស ពោលគឺពលកម្មខ្លួនឯង ។
- កម្មវត្ថុពលកម្ម គឺអ្វីៗដែលមនុស្សយកទៅកែច្នៃ ឱ្យទៅជាផលិតផលថ្មី ដូចជាវត្ថុដែលមានស្រាប់ក្នុងធម្មជាតិ (ដី ព្រៃឈើ ត្រី...)និងវត្ថុដែលឆ្លងកាត់ពលកម្មកែច្នៃ (ដែក អំបោះ...) ។

- មធ្យោបាយពលកម្ម គឺជាសម្ភារៈទាំងឡាយដែលមនុស្សប្រើប្រាស់ទៅលើកម្មវត្ថុពលកម្ម មានដូចជា ដែកឈូស ពូថៅ គ្រឿងម៉ាស៊ីន ... ។ល ។

**គេអាចបែងចែកពលកម្មជាច្រើនប្រភេទដូចតទៅ**

**ពលកម្មរូបី (Travail Concret)** ៖ គឺពលកម្មចំណាយក្រោមទម្រង់ចាំបាច់និងបង្កើតជាតម្លៃប្រើប្រាស់(ផលប្រយោជន៍)នៃទំនិញ ។ ពលកម្មរូបីមានទម្រង់ផ្សេងៗគ្នាទៅតាមមធ្យោបាយពលកម្មឬផលិតកម្មដែលបានប្រើប្រាស់ ។ ***ឧទាហរណ៍*** ពលកម្មដឹកជញ្ជូន ពលកម្មត្បាញរវៃ ពលកម្មតាមបណ្ដារោងចក្រនានា ។ល ។ ចរិតនៃប្រតិបត្តិការ គោលបំណង និងលទ្ធផលនៃពលកម្មរូបី មានផ្ទាល់នៅក្នុងគ្រប់បែបផែនផលិតកម្ម ។

**ពលកម្មអរូបី (Travail Abstrait)** ៖ គឺជាពលកម្មសង្គមទូទៅមិនទាក់ទងនឹងទម្រង់រូបីរបស់ពលកម្មទេ ។ ខុសប្លែកពីពលកម្មរូបី វាគ្មានការបែងចែកខាងគុណភាពទេ ។ ពលកម្មអរូបីមិនមែនជាសញ្ញាណជីវសាស្ត្រទេ តែវាជាសញ្ញាណសង្គម ។ វាបង្កើតតម្លៃទំនិញនិងជាប្រភេទប្រវត្តិសាស្ត្រមួយនៅក្នុងផលិតកម្មទំនិញ ។

ទោះបីពលកម្មមាននៅក្នុងទម្រង់ណាក៏ដោយ វាជាការចំណាយកម្លាំងពលកម្មរបស់មនុស្សនៅក្នុងន័យសរីរសាស្ត្រ (ការចំណាយថាមពលសាច់ដុំ ថាមពលខួរក្បាល ។ល ។)

នៅក្នុងធម្មជាតិសេដ្ឋកិច្ច ចរិតសង្គមនៃពលកម្មស្ដែងឡើងដោយផ្ទាល់នៅក្នុងពលកម្មរូបីតាមរយៈសំណុំនៃកិច្ចប្រឹងប្រែងរបស់ពលករ ។ ចំណែកឯនៅក្នុងលក្ខខណ្ឌនៃផលិតកម្មទំនិញ ការទទួលស្គាល់ពលកម្មសង្គមកើតមានឡើងតែនៅក្នុងការផ្ដោះប្ដូរទំនិញ ។ ការប្រៀបធៀបទំនិញទៅតាមតម្លៃគឺប្រៀបធៀបពលកម្មដែលគេបានចំណាយដើម្បីផលិតវា ។ ***ឧទាហរណ៍*** តុមួយ ដែលធ្វើហើយក្នុងរយៈពេល 3 ថ្ងៃ មានតម្លៃប្រហាក់ប្រហែលនឹងកៅអី 2 ដែលធ្វើហើយក្នុងរយៈពេល 3 ថ្ងៃដូចគ្នា ។

## 2. កម្លាំងពលកម្ម

### 2.1. និយមន័យ

កម្លាំងពលកម្ម សំដៅលើមនុស្សអ្នកធ្វើពលកម្ម ឬផ្ដល់សេវាកម្ម មានដូចជា ពលករ កម្មករ និយោជិត ។ល ។ ក្នុងករណី ដែលកម្លាំងពលកម្មមានជំនាញ មានបច្ចេកទេស សម្រាប់ធ្វើការងារក្នុងឧស្សាហកម្ម ឬក្នុងស្ថាប័ននានា ដែលប្រើបច្ចេកទេសទាន់សម័យ គេហៅថា ធនធានមនុស្ស ។

ក្នុងការស្ដារនិងអភិវឌ្ឍសេដ្ឋកិច្ចនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍ គេត្រូវការការវិនិយោគ ដែលប្រើកម្លាំងពលកម្មក្នុងចំនួនច្រើន ។

### 2.2. លក្ខខណ្ឌមិនចាត់ចូលជាកម្លាំងពលកម្ម

ការប្រើប្រាស់កម្លាំងពលកម្មដោយសមស្របនិងប្រកបដោយមនុស្សធម៌ នាំឱ្យសេដ្ឋកិច្ចជាតិរីកចម្រើនជានិរន្តរ៍ ។ យ៉ាងណាមិញ លក្ខខណ្ឌដ៏ត្រឹមត្រូវក្នុងការប្រើប្រាស់កម្លាំងពលកម្ម មានចែងក្នុងច្បាប់ការងារ ។

ការចាត់ចូលជាកម្លាំងពលកម្ម មិនរាប់បញ្ចូលប្រជាពលរដ្ឋក្មេង ចាស់ ប្រុស ស្រី គ្រប់រូបនោះទេ ពោលគឺ មានការលើកលែងចំពោះប្រជាពលរដ្ឋ ដែលស្ថិតក្នុងស្ថានភាពដូចខាងក្រោម

- **កម្រិតអាយុ :** តាមការកំណត់នៃច្បាប់ ប្រជាពលរដ្ឋ ដែលមានអាយុចាប់ពី 18ឆ្នាំឡើងទៅរហូតដល់អាយុ 60ឆ្នាំ ត្រូវបានរាប់បញ្ចូលជាកម្លាំងពលកម្ម ។
- **ស្ថានភាពនៅសិក្សាក្នុងគ្រឹះស្ថានសិក្សា :** គេមិនរាប់ជាកម្លាំងពលកម្មទេ ចំពោះប្រជាពលរដ្ឋដែលកំពុងសិក្សានៅគ្រឹះស្ថានសិក្សាគ្រប់កម្រិត ទោះបីអ្នកទាំងនោះបានឆ្លៀតពេលធ្វើការដើម្បីយកកម្រៃផ្គត់ផ្គង់ការសិក្សាក៏ដោយ ។
- **ស្ថានភាពពិសេស :** គេក៏មិនរាប់ជាកម្លាំងពលកម្មដែរ ចំពោះប្រជាពលរដ្ឋដែលមានស្ថានភាពពិសេស ដូចជា កំពុងជាប់ក្នុងពន្ធនាគារ កំពុងសម្រាកព្យាបាលជំងឺរយៈពេលយូរ ជនវិកលចរិតជាដើម ។
- **ស្ថានភាពនៅគ្រប់គ្រងផ្ទះ :** ចំពោះប្រជាពលរដ្ឋ ដែលស្ថិតក្នុងការងារគេហដ្ឋាននិងទទួលខុសត្រូវលើការងារនោះ ពួកគេក៏មិនត្រូវបានរាប់ថាជាកម្លាំងពលកម្មដែរ ។

## 3. ប្រាក់បៀវត្ស

### 3.1. និយមន័យ

ប្រាក់បៀវត្សគឺជាប្រាក់ថ្លៃឈ្នួលពលកម្ម ដែលបុគ្គលិក ឬកម្មករទទួលបានជាប្រចាំក្នុងអំឡុងពេលដែលគេកំពុងបំពេញការងារនៅតាមគ្រឹះស្ថាន ឬក្រុមហ៊ុនណាមួយ ។

ពលកម្មរបស់កម្មករក្នុងមុខងារជាច្រើនត្រូវបានជួបការលំបាកក្នុងការវាស់បរិមាណ ។ ដូច្នេះហើយគេអាចទទួលបានប្រាក់បំណាច់ដោយផ្អែកលើមូលដ្ឋានពេលនៃវេលានិងទិន្នផលនៃការងារដែលបានធ្វើ ពោលគឺ ពុំមែនអាស្រ័យទៅលើចំនួនជាក់ស្តែងនៃការងារដែលបានធ្វើឡើយ ។

ម្យ៉ាងទៀត ថ្លៃពលកម្មដែលជាអត្រាប្រាក់បៀវត្សក៏ត្រូវទទួលបាន អាស្រ័យទៅតាមតម្រូវការនិងលទ្ធភាពផ្គត់ផ្គង់ពលកម្មក្នុងទីផ្សារ ។ នៅពេលដែលមានតម្រូវការកម្លាំងពលកម្មក្នុងចំនួនច្រើន ប្រាក់បំណាច់ពលកម្មនឹងមានកម្រិតទាប ។ ផ្ទុយទៅវិញ កាលបើលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មមានចំនួនតិចជាងតម្រូវការ ពេលនោះថ្លៃឈ្នួលពលកម្មនឹងកើនឡើង ។




*ក្រាហ្វិកនៃថ្លៃឈ្នួលនិងកម្លាំងពលកម្ម*

នៅក្នុងក្រាហ្វិកនេះ អ័ក្សអរដោណេ (OY) តាងថ្លៃឈ្នួលពលកម្ម អ័ក្សអាប់ស៊ីស (OX) តាងលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មក្នុងទីផ្សារការងារ ។ ខ្សែកោងការផ្គត់ផ្គង់កម្លាំងពលកម្ម (AB) បង្ហាញថា នៅពេលលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មក្នុងទីផ្សារការងារមានចំនួនតិច ថ្លៃពលកម្មមានកម្រិតខ្ពស់ (ចំណុច A) ។ នៅពេលលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មរបស់ទីផ្សារការងារមានចំនួនច្រើន ថ្លៃពលកម្មមានកម្រិតទាប (ចំណុច B) ។ ខ្សែកោងការផ្គត់ផ្គង់ពលកម្មឆ្ពោះទៅលើ មានន័យថាលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មថយចុះ នៅពេលប្រាក់បៀវត្សកើនឡើង ។ ប៉ុន្តែ ខ្សែកោងការផ្គត់ផ្គង់អាចចុះមកក្រោម ហើយបត់ពីចំណុច A មកចំណុច M និងហួសចំណុច M មានន័យថា កាលបើលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មកាន់តែមានចំនួនច្រើន ថ្លៃពលកម្មកាន់តែមានកម្រិតទាប ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អត្រាប្រាក់បៀវត្សនឹងមាននិន្នាការឆ្ពោះទៅរកចំណុចសមតាជាកម្រិតមួយ ដែលបរិមាណតម្រូវការពលកម្មស្មើនឹងបរិមាណការផ្គត់ផ្គង់ពលកម្ម ។

## 3.2. ប្រាក់បៀវត្សអប្បបរមា

ដូចម្តេចហៅថា ប្រាក់បៀវត្សអប្បបរមា ? ប្រាក់បៀវត្សអប្បបរមា គឺប្រាក់បៀវត្ស ដែលមានការកំណត់ក្នុងចំនួនមួយដែលអាចផ្គត់ផ្គង់តម្រូវការចាំបាច់ជាមូលដ្ឋានរបស់អ្នកធ្វើពលកម្មបានដោយសមរម្យ ។

អ្នកជំទាស់នឹងប្រាក់បៀវត្សអប្បរមានិយាយថា ភាពគ្មានការងារធ្វើ(និកម្មភាព)នឹងកើតមានឡើងទន្ទឹមគ្នានឹងការដាក់ឱ្យមានប្រាក់បៀវត្សអប្បរមា ។ ម្យ៉ាងទៀត អ្នកជំទាស់នឹងប្រាក់បៀវត្ស

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

អប្បបរមា ចាត់ទុកថាប្រាក់បៀវត្សអប្បបរមាមិនមែនជាវិធានការបែងចែកប្រាក់ចំណូលឡើងវិញដ៏មានប្រសិទ្ធភាពឡើយ ពីព្រោះការកំណត់ប្រាក់បៀវត្សអប្បបរមានឹងបង្កើនប្រាក់ចំណូលសម្រាប់មនុស្សមួយក្រុម (ដែលទទួលប្រាក់បៀវត្សអប្បបរមា) ប៉ុន្តែមនុស្សក្នុងក្រុមផ្សេងទៀតត្រូវខាតបង់ (ព្រោះគ្មានការងារធ្វើ) ។ គេបានចោទដែរថា ប្រាក់បៀវត្សខ្ពស់ មិនប្រាកដថា ធានាឱ្យមានការប្រើប្រាស់ពលកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់នោះឡើយ ។ មានន័យថា នៅពេលដែលមានប្រាក់បៀវត្សអប្បបរមានឹងមានការជ្រើសរើសរកកម្លាំងពលកម្ម ដែលប្រកបដោយគុណភាពនិងក្នុងចំនួនតិច ។ ដូចនេះ ភាពគ្មានការងារធ្វើរបស់កម្លាំងពលកម្មសាមញ្ញនឹងកើតមានឡើង ។

ចំពោះអ្នកគាំទ្រប្រាក់បៀវត្សអប្បបរមាជឿថា ក្នុងទីផ្សារប្រកួតប្រជែងដែលមានទូទៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ ប្រាក់បៀវត្សខ្ពស់មិនមានន័យថាមាននិកម្មភាពខ្ពស់ឡើយ ។ ម្យ៉ាងទៀត នៅពេលដែលបង្កើនថ្លៃដើមពលកម្ម(ប្រាក់បៀវត្ស) សហគ្រាសនឹងព្យាយាមប្រើប្រាស់កម្លាំងពលកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ផងដែរ ។

## 4. តួនាទីសហជីពក្នុងការបង្កើនសុខុមាលភាពកម្លាំងពលកម្ម

នៅក្នុងប្រទេសមួយចំនួន ពលករបានរៀបចំបង្កើតសហជីព ។ គោលបំណងសំខាន់នៃការបង្កើតសហជីពកម្មករ គឺដើម្បីការពារផលប្រយោជន៍របស់កម្មករ តាមរយៈការទាមទារឱ្យមានភាពប្រសើរឡើងនូវប្រាក់បៀវត្សរបស់កម្មករ លក្ខខណ្ឌការងារ ការគោរពច្បាប់ការងារ ការគិតគូរអំពីប្រាក់រង្វាន់ចំពោះកម្លាំងពលកម្ម ការកំណត់ពេលវេលាច្បាស់លាស់ ការរៀបចំប្រាក់ធានាសុវត្ថិភាពការងារ ភាពសមស្របនៃប្រាក់កម្រៃពលកម្មទៅនឹងថ្លៃទំនិញនៅទីផ្សារ ការបំប៉នសមត្ថភាពកម្លាំងពលកម្ម ។ល ។

## 5. សន្និដ្ឋាន

ជាទូទៅ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារសេរី កម្រៃពលកម្ម ឬអត្រាប្រាក់បៀវត្សបានប្រែប្រួលទៅតាមតម្រូវការនិងលទ្ធភាពផ្គត់ផ្គង់កម្លាំងពលកម្មក្នុងទីផ្សារការងារទាំងបរិមាណនិងគុណភាព ។ កម្លាំងពលកម្មអាចទទួលបានប្រាក់បៀវត្សទៅតាមកម្រិតជំនាញ សមត្ថភាព និងវិជ្ជាជីវៈរបស់ខ្លួន ។ នៅពេលដែលមិនទាន់មានការរៀបចំប្រាក់បៀវត្សអប្បបរមា សមូហភាពចម្រុះនៃកម្លាំងពលកម្មក្នុងចំនួនច្រើនមានការងារធ្វើ ។ ប៉ុន្តែនៅពេលដែលមានការរៀបចំប្រាក់បៀវត្សអប្បបរមា ក៏មានការបែងចែក ឬជ្រើសរើសសម្រាំងប្រភេទកម្លាំងពលកម្ម ។

ដូចនេះ កម្លាំងពលកម្មដែលមានសមត្ថភាពនិងជំនាញវិជ្ជាជីវៈកម្រិតខ្ពស់ តែងស្ថិតនៅក្នុងជម្រើសជាអាទិភាពក្នុងទីផ្សារការងារ ។

## សំណួរ

1. ចូរអ្នករៀបរាប់ពីព័ត៌មាន ដែលទទួលបានពីការសម្ភាសជាមួយនរណាម្នាក់ ដែលមានការងារធ្វើនៅក្នុងសហគមន៍របស់អ្នកថា តើគាត់មានជំនាញអ្វី ? តើគាត់បានទទួលកម្រៃពលកម្មប៉ុន្មាន ? តើគាត់ពេញចិត្តនឹងកម្រៃនោះដែរ ឬទេ ? ហេតុអ្វី ?
2. ចូរអ្នកធ្វើការពិភាក្សាក្នុងក្រុម ឬជាមួយដៃគូដើម្បីដោះស្រាយសំណួរខាងក្រោម
   ក. ដូចម្ដេចហៅថា ពលកម្ម ? ចូរពន្យល់ដោយលំអិត ។
   ខ. ដូចម្ដេចហៅថា កម្លាំងពលកម្ម ? ចូរពន្យល់ដោយលំអិត ។
   គ. ដូចម្ដេចហៅថា ប្រាក់បៀវត្ស ?
   ឃ. នៅក្នុងសង្គមទូទៅ ហេតុអ្វីបានជាមានអ្នកចូលធ្វើការងារ ដែលមានតម្លៃឈ្នួលថោក ?
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចសំខាន់ៗដើម្បីយកមកសរសេរផ្គុំគ្នាជាមេរៀនសង្ខេបរបស់អ្នកផ្ទាល់ខ្លួន ។

**ការងារប្រតិបត្តិ**

ចូរអ្នកធ្វើការពន្យល់ក្រាហ្វិកខាងក្រោមនេះត្រង់ចំណុច A និង B ។



**មេរៀនទី**

# 10 ភាពគ្មានការងារធ្វើ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីទំនាក់ទំនងរវាងអនិកម្មភាពនិងនិកម្មភាព ។
- កំណត់និយមន័យនិកម្មភាពចេតនានិងនិកម្មភាពអចេតនា ។
- រៀបរាប់ពីប្រភេទនៃនិកម្មភាព ។
- ពន្យល់ពីផលប៉ះពាល់នៃនិកម្មភាព ។

សម្រាប់យុវជនគ្រប់រូប ការបាត់បង់ ឬគ្មានការងារធ្វើមានន័យថាចំណូលរបស់គេមានការថយចុះឬគ្មានចំណូល ដែលតែងតែធ្វើឱ្យគេមានសេចក្ដីទុក្ខព្រួយ ។



ភាពមានការងារធ្វើ គឺវត្តមាននៃការប្រើប្រាស់កម្លាំងពលកម្មដែលមានឬស្ថានភាពដែលមនុស្សមានមុខរបរ ។ សកម្មភាពសេដ្ឋកិច្ចមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងភាពមានឬគ្មានការងារធ្វើ ។ នៅពេលសេដ្ឋកិច្ចកើនឡើង ភាពគ្មានការងារធ្វើថយចុះ ហើយផ្ទុយមកវិញភាពគ្មានការងារធ្វើកើនឡើង ។

ជាមួយគ្នានេះ មានមនុស្សមួយចំនួនយល់ថា នៅពេលសេដ្ឋកិច្ចធ្លាក់ចុះ ភាពគ្មានការងារធ្វើដោយសារការមិនពេញចិត្តក្នុងប្រការណាមួយ ជាពិសេសដោយសារតម្លៃឈ្នួលពលកម្មមានកម្រិត

ទាបគេមិនអាចចាត់បញ្ចូលថាជាភាពគ្មានការងារធ្វើបានទេ ព្រោះភាពគ្មានការងារធ្វើនេះគ្រាន់តែជាករណីបណ្តោះអាសន្នតែប៉ុណ្ណោះ ។




*ការស្វែងរកការងារធ្វើតាមព័ត៌មាន*

# 1. ភាពគ្មានការងារធ្វើ

## 1.1. ភាពគ្មានការងារធ្វើដោយចេតនា

ភាពគ្មានការងារធ្វើដោយចេតនា គឺជាភាពទំនេរដែលកើតឡើងនៅពេលមនុស្សមិនព្រមទទួលយកការងារ ដែលពួកគេអាចធ្វើបាន ដោយពួកគេសង្ឃឹមថានឹងរកបានការងារថ្មីមួយទៀត ដែលទទួលបានផលប្រយោជន៍ច្រើនជាង ។ ជួនកាលមនុស្សបោះបង់ការងារមួយចោល ហើយស្វែងរកការងារផ្សេងមួយទៀត ឬសម្រេចចិត្តលាឈប់ពីការងារដែលពួកគេកំពុងធ្វើ ដោយសារការងារនោះទទួលបានប្រាក់កម្រៃទាបពេក ។ កត្តានេះធ្វើឱ្យមនុស្សមួយចំនួននោះក្លាយជាអ្នកអត់ការធ្វើ ហើយដែលអ្នកសេដ្ឋកិច្ចចាត់ទុកក្រុមប្រភេទនេះជា អ្នកអត់ការងារធ្វើដោយចេតនា ។ ***ឧទាហរណ៍*** កម្មករជួសជុលរថយន្តម្នាក់គ្មានការងារធ្វើ ដោយគាត់មិនព្រមធ្វើការងារក្នុងហាងលក់រថយន្តមួយដែលគេឱ្យប្រាក់កម្រៃ 10 000 រៀលក្នុង 1 ម៉ោង ហើយគាត់នៅតែបន្តស្វែងរកការងារធ្វើនៅក្នុងឧស្សាហកម្មផលិតរថយន្ត ដែលអាចទទួលប្រាក់កម្រៃ 20 000 រៀលក្នុង 1 ម៉ោង ។ ប្រសិនបើគាត់រកបានការងារក្នុងឧស្សាហកម្មផលិតរថយន្ត គាត់នឹងក្លាយជាអ្នកមានការងារធ្វើ តែផ្ទុយមកវិញ នៅពេលបច្ចុប្បន្នគាត់ជាអ្នកអត់ការងារធ្វើដោយចេតនា ព្រោះគាត់នៅរង់ចាំរហូតបានការងារថ្មី ។

krou.moeys.gov.kh
facebook.com/moeys.gov.kh

### 1.2. ភាពគ្មានការងារធ្វើដោយអចេតនា

ភាពគ្មានការងារធ្វើដោយអចេតនា កើតមានឡើងចំពោះមនុស្សមានសមត្ថភាពពេញលេញគ្រប់គ្រាន់ ប៉ុន្តែគេមិនអាចរកការងារធ្វើបាន ។ ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើឧស្សាហកម្មផលិតរថយន្តនោះមិនទទួលគាត់ គាត់នឹងក្លាយជាជនគ្មានការងារធ្វើដោយអចេតនា ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើកម្មករនោះ ព្រមធ្វើការក្នុងរោងចក្រដែលត្រូវជំនាញរបស់គាត់ ហើយជំនាញនោះមិនត្រូវបានយកទៅប្រើប្រាស់ទេ គាត់នឹងក្លាយទៅជាជនមានការងារធ្វើមិនប្រាកដ ។ ភាពមានការងារធ្វើមិនប្រាកដ គឺជាការងារដែលកើតឡើង នៅពេលដែលការងារនោះត្រូវបានគេជួល ដើម្បីផលិតទំនិញនិងសេវាកម្មមួយ ប៉ុន្តែជននោះមិនបានប្រើប្រាស់ឱ្យអស់ពីសមត្ថភាពជំនាញនិងសក្តានុពលរបស់ខ្លួនទេ ។ ជាគោលការណ៍ភាពគ្មានការងារធ្វើមិនប្រាកដ មិនខុសគ្នាពីភាពគ្មានការងារធ្វើដោយអចេតនាប៉ុន្មានទេ ។ បើជនម្នាក់មិនធ្វើការងារអ្វីសោះ មានន័យថាគេជាជនគ្មានការងារធ្វើ តែបើជននោះមានការងារធ្វើ ហើយធ្វើមិនពេញសមត្ថភាពរបស់ខ្លួននោះ គេហៅថាជនមានការងារធ្វើមិនប្រាកដ ។

## 2. ប្រភេទនៃភាពគ្មានការងារធ្វើ

### 2.1. ភាពគ្មានការងារធ្វើតាមកាល

ភាពគ្មានការងារធ្វើប្រភេទនេះ ភាគច្រើនបណ្តាលមកពីការប្រែប្រួល ឬការផ្លាស់ប្តូរសកម្មភាពសេដ្ឋកិច្ចក្នុងទីផ្សារ ។ ដោយសារមានកម្លាំងពលកម្មថ្មីចូលស្វែងរកការងារធ្វើជំនួសកម្លាំងពលកម្មចាស់ដែលត្រូវចូលនិវត្តន៍ ឬផ្លាស់ប្តូរកន្លែងធ្វើការឱ្យបានសមស្របទៅនឹងលទ្ធភាពរបស់ខ្លួន ។

*ឧទាហរណ៍ :* នៅពេលក្រុមហ៊ុនមានដំណើរការល្អ គេនឹងពង្រីកធុរៈកិច្ចរបស់គេ ព្រមជាមួយនឹងការប្រកាសជ្រើសរើសបុគ្គលិកថ្មីនិងការបញ្ឈប់បុគ្គលិកធ្វើការ ។ ជាធម្មតា ព្រឹត្តិការណ៍បែបនេះ តែងតែមានជាប្រចាំនៅក្នុងសង្គម ។ ដោយឡែក អត្រាគ្មានការងារធ្វើនេះ អាស្រ័យទៅនឹងអត្រាចេញ ឬចូលនៃកម្លាំងពលកម្មនិងអត្រាបញ្ឈប់បុគ្គលិកធ្វើការរបស់ក្រុមហ៊ុន ឬស្ថាប័នមួយផ្សេងទៀត ។ ភាពគ្មានការងារធ្វើនេះ មានលក្ខណៈទៀងទាត់អាចដឹងមុន ***ឧទាហរណ៍*** គ្រូបង្ហាត់ការហាត់ប្រាណមានការងារធ្វើនៅរដូវត្រជាក់ ហើយអត់ការងារធ្វើនៅរដូវក្តៅ ។ ជនគ្មានការងារធ្វើតាមរដូវ ឬបណ្តោះអាសន្នចាត់ចូលជាជនគ្មានការងារធ្វើដោយចេតនា ព្រោះគេតែងដឹងមុននូវរដូវដែលមានការងារធ្វើនិងរដូវដែលគ្មានការងារធ្វើ ។

### 2.2. ភាពគ្មានការងារធ្វើដោយរចនាសម្ព័ន្ធ

ភាពគ្មានការងារធ្វើដែលបង្កដោយវិបត្តិសេដ្ឋកិច្ចនិងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ។ ភាពគ្មានការងារធ្វើនេះ កើតឡើងដោយមូលហេតុធ្លាក់ចុះនៃចំនួនការងារដែលមានស្រាប់ ហើយជាទូទៅដោយសារការផ្លាស់ប្តូរបច្ចេកវិទ្យានិងការប្រកួតប្រជែង ។ *ឧទាហរណ៍* នៅពេលដែលរោងចក្រមួយត្រូវបានបំពាក់ដោយគ្រឿងម៉ាស៊ីន ប្រកបដោយបច្ចេកវិទ្យាទំនើប រោងចក្រនោះនឹងកាត់បន្ថយចំនួនកម្មករ ។ ដោយឡែក ចំពោះឧស្សាហកម្មកាត់ដេរ មានការប្រកួតប្រជែងខ្លាំងលើទីផ្សារ បើសម្លៀកបំពាក់និងមានម៉ូតខោអាវ មិនទាន់សម័យ គុណភាពអន់ ធ្វើឱ្យមានការបាត់បង់ទីផ្សារ ដែលជាហេតុបណ្តាលឱ្យឧស្សាហកម្មកាត់ដេរនោះ បង្ខំចិត្តកាត់បន្ថយចំនួនកម្លាំងពលកម្ម ។

### 2.3. ភាពគ្មានការងារធ្វើតាមខួប

ភាពគ្មានការងារធ្វើតាមខួប ច្រើនកើតមានឡើងនៅតាមរដូវកាលនៃឆ្នាំ ប៉ុន្តែអាចស្ថិតនៅក្នុងពេលដែលសេដ្ឋកិច្ចមានស្ថិរភាពនិងពេលមានវិបត្តិផងដែរ ។ តាមធម្មតា ការងារមានការប្រែប្រួលព្រោះតម្រូវការរបស់មនុស្សប្រែប្រួលតាមរដូវដែរ ។ *ឧទាហរណ៍* នៅខែស្លឹកឈើលាស់ មនុស្សចូលចិត្តធ្វើទេសចរណ៍កំសាន្ត ព្រោះអាកាសធាតុល្អ ធម្មជាតិមានបរិស្ថានស្រស់បំព្រង ។ ចំណែកឯរដូវភ្លៀង ឬធ្លាក់ទឹកកកវិញ មនុស្សមិនសូវជាចូលចិត្តធ្វើដំណើរកំសាន្តទេ ដូច្នេះមនុស្សដែលធ្លាប់ធ្វើការងារនៅរដូវក្តៅ ឬស្លឹកឈើលាស់ ពិតជាគ្មានការងារធ្វើនៅរដូវធ្លាក់ភ្លៀង ឬធ្លាក់ទឹកកក ព្រោះខែនេះពុំសូវមានភ្ញៀវមកធ្វើទេសចរណ៍ ហេតុនេះហើយ ការដឹកជញ្ជូនមនុស្សពីកន្លែងមួយទៅកន្លែងមួយ ត្រូវកាត់បន្ថយជើង ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ មជ្ឈមណ្ឌលកំសាន្ត... ត្រូវកាត់បន្ថយចំនួនបុគ្គលិក ឬបុគ្គលិកត្រូវរកការងារថ្មីមួយទៀតសម្រាប់គេ ។

### 2.4. ភាពគ្មានការងារធ្វើដោយប៉ះទង្គិច

ភាពគ្មានការងារធ្វើប្រភេទនេះ ច្រើនកើតមានឡើង នៅពេលដែលសង្គមបានទទួលសិទ្ធិសេរីភាពក្នុងការជ្រើសរើសប្រភេទការងារថ្មី ។ ភាពគ្មានការងារធ្វើដោយប៉ះទង្គិចបានបង្កើតដោយបុគ្គលមួយចំនួនដែលស្ថិតនៅក្នុងស្ថានភាពចន្លោះនៃការងារទាំងពួង បុគ្គលខ្លះស្ម័គ្រចិត្តផ្លាស់ប្តូរ ឬបោះបង់ចោលការងារ ហើយដើរស្វែងរកការងារថ្មី ដែលអាចចំមុខជំនាញវិជ្ជាជីវៈរបស់ខ្លួននេះកើតមានឡើងនៅគ្រប់ប្រភេទសេដ្ឋកិច្ច ទោះបីប្រភេទសេដ្ឋកិច្ចនោះមានការរីកចម្រើនយ៉ាងណាក៏ដោយ ។ ករណីមួយទៀតគឺ ដោយសារក្រុមហ៊ុន ឬស្ថាប័នឯកជនណាមួយ បានបញ្ឈប់ជននោះពីការងារ ។ ជននោះក៏ក្លាយជាជនគ្មានការងារធ្វើដោយប៉ះទង្គិចអារម្មណ៍ ។

## 3. ផលប៉ះពាល់នៃភាពគ្មានការងារធ្វើ

ភាពគ្មានការងារធ្វើ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរនិងមានផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមជាតិទាំងមូល ។ នៅក្នុងទ្រឹស្ដីក៏ដូចជាការអនុវត្តជាក់ស្ដែងដែរ ភាពគ្មានការងារធ្វើ នាំឱ្យមានផលប៉ះពាល់ដូចជា

**ការបាត់បង់ធនធានមនុស្ស :** ភាពគ្មានការងារធ្វើ ធ្វើឱ្យមនុស្សបាត់បង់នូវជំនាញដែលពួកគេទទួលបានពីការបណ្ដុះបណ្ដាល ។ ជាការពិត នៅពេលដែលមនុស្សម្នាក់ទទួលបានការបណ្ដុះបណ្ដាលមុខជំនាញអ្វីមួយ ប៉ុន្តែដើម្បីបានការងារធ្វើជននោះ សុខចិត្តទទួលការងារធ្វើខុសមុខជំនាញរបស់ខ្លួន ដែលបណ្ដាលឱ្យជននោះ បាត់បង់នូវមុខជំនាញរបស់ខ្លួន ។

**ការបាត់បង់ផលិតផលការងារនិងចំណូលរបស់ពលរដ្ឋ :** គឺជាផលប៉ះពាល់ដ៏ធំមួយ ដែលនឹងបង្កើតឱ្យមានផលប៉ះពាល់ផ្សេងៗទៀតជាច្រើន ។ ***ឧទាហរណ៍*** មនុស្សម្នាក់គ្មានការងារធ្វើនាំឱ្យគ្មានចំណូល ជីវភាពរស់នៅរបស់គេធ្លាក់ចុះ ។ ទីបំផុត មនុស្សនោះអាចប្រព្រឹត្តបទល្មើសផ្សេងៗ ។ ម្យ៉ាងទៀត ដោយសារចំណូលគ្រួសារទាបនឹងធ្វើឱ្យមានភាពតានតឹង ការខូចចិត្តក្នុងក្រុមគ្រួសារ ។ ជាងនេះទៅទៀត នៅពេលមានអត្រានៃភាពគ្មានការងារធ្វើខ្ពស់ មនុស្សរស់នៅក្នុងសង្គមទាំងមូលតែងបាត់បង់ភាពថ្លៃថ្នូរនិងជំនឿលើខ្លួនឯង ។ ប្រការទាំងអស់នេះហើយ ដែលនាំឱ្យមានកំណើនអំពើហិង្សានិងឧក្រិដ្ឋកម្មផ្សេងៗនៅក្នុងសង្គមជាតិទាំងមូល ។

**ភាពលំបាកវេទនារបស់ជនដែលគ្មានការងារធ្វើ :** ជនដែលគ្មានការងារធ្វើ ធ្វើឱ្យថយចុះនូវលទ្ធភាពផលិតទំនិញនិងសេវាកម្ម ដែលផ្ដល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។ អ្នកដែលទទួលឥទ្ធិពលខ្លាំងជាងជនដែលគ្មានការងារធ្វើឬមានការងារធ្វើ តែមានចំណូលតិច ។ ***ឧទាហរណ៍*** ជនដែលទទួលចំណូលតិច ឬជនដែលទទួលការឧបត្ថម្ភស្ដួចស្ដើងពីរដ្ឋាភិបាល ឬស្ថាប័នឯកជន ពួកគេមានលទ្ធភាពទិញទំនិញនិងសេវាកម្មបានតិច ។ ដូចនេះមានន័យថាពួកគេមិនមានទំនិញ សេវាកម្មគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ទេ ។ ជនដែលគ្មានការងារធ្វើនេះ មិនគ្រាន់តែជួបប្រទះនូវការប៉ះទង្គិចផ្លូវចិត្តក្នុងការស្វែងរកការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការប៉ះទង្គិចក្នុងការផ្គត់ផ្គង់សេចក្ដីត្រូវការរបស់ខ្លួននិងគ្រួសារថែមទៀតផង ។

ភាពគ្មានការងារធ្វើ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរនិងមានផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមជាតិទាំងមូល ។ វាប៉ះពាល់ដល់ជនគ្រប់រូបនៅក្នុងសង្គមសេដ្ឋកិច្ច ដោយការថយចុះផលិតភាពទំនិញនិងសេវាកម្ម ហើយថែមទាំងធ្វើឱ្យមានការឈឺចាប់និងភាពបរាជ័យដល់ភាពគ្មានការងារធ្វើទៀតផង ។

## សំណួរ

1. ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់ តើសហគមន៍របស់អ្នកមានមនុស្សគ្មានការងារធ្វើឬទេ ? តើហេតុអ្វីបានជាគេគ្មានការងារធ្វើ ?
2. ចូរអ្នកធ្វើការពិភាក្សាក្នុងក្រុម ឬជាមួយដៃគូ ដើម្បីដោះស្រាយនូវសំណួរខាងក្រោម
   ក. តើភាពគ្មានការងារធ្វើជាអ្វី ?
   ខ. តើភាពគ្មានការងារធ្វើដោយចេតនាខុសពីភាពគ្មានការងារធ្វើដោយអចេតនាដូចម្ដេច ?
   គ. តើភាពគ្មានការងារធ្វើចែកចេញជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
   ឃ. តើភាពគ្មានការងារធ្វើ ធ្វើឱ្យមានផលប៉ះពាល់អ្វីខ្លះនៅក្នុងសង្គមសេដ្ឋកិច្ច ?
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចសំខាន់ៗ ដើម្បីយកមកសរសេរផ្ដុំគ្នាជាមេរៀនសង្ខេបរបស់អ្នក ។

## ប្រតិបត្តិ

ចូរអ្នកធ្វើការសម្ភាសជាមួយអតីតកម្មករម្នាក់នៅក្នុងសហគមន៍របស់អ្នកអំពីមូលហេតុនៃការឈប់ធ្វើការនិងជីវភាពរស់នៅរបស់គាត់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 11 វិបត្តិសេដ្ឋកិច្ច

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញនិយមន័យ និងរូបភាពនៃវិបត្តិសេដ្ឋកិច្ច ។
- ❑ បង្ហាញអន្តរាគមន៍របស់រដ្ឋក្នុងការដោះស្រាយវិបត្តិសេដ្ឋកិច្ច ។

ការបង្កើនសេដ្ឋកិច្ច មិនពិតជាបានទទួលជោគជ័យគ្រប់ជំហាននិងគ្រប់ពេលវេលានោះទេ គឺតែងជួបប្រទះនឹងបញ្ហាជាច្រើន ក្នុងនោះមានបញ្ហាកំណើនផលិតផលលើសពីសេចក្ដីត្រូវការ ដែលនាំឱ្យមានការខាតបង់ទៅវិញជាដើម ។ នៅគ្រាដែលមានវិបត្តិរាំងស្ទះដល់កំណើនសេដ្ឋកិច្ច ឬបង្កឱ្យសេដ្ឋកិច្ចមានការធ្លាក់ចុះ គេថាគ្រានោះមានវិបត្តិសេដ្ឋកិច្ច ។

## 1. និយមន័យ

វិបត្តិសេដ្ឋកិច្ច គឺជាការរងឥទ្ធិពលវិបត្តិហិរញ្ញវត្ថុដែលបណ្ដាលមកពីវិបត្តិបរិស្ថាន អស្ថិរភាពនយោបាយ ឬការរីកចម្រើនដល់កំពូលនៃការងារផលិតកម្មដែលនាំឱ្យមានផលិតផលលើស ។

## 2. រូបភាពវិបត្តិសេដ្ឋកិច្ច

វិបត្តិសេដ្ឋកិច្ចបង្កឡើងដោយបញ្ហាមួយចំនួននិងមានរូបភាពដូចខាងក្រោម

- **វិបត្តិនយោបាយ :** មានដូចជា សង្គ្រាម ការប្រកាន់យកលទ្ធិផ្ដាច់ការ របបប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។
- **គ្រោះធម្មជាតិ :** មានដូចជា ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បន្ទុះភ្នំភ្លើង ការរាំងស្ងួត ។ល ។
- **វិបត្តិក្នុងការគ្រប់គ្រងថវិការដ្ឋ :** មានន័យថា រដ្ឋមានកង្វះខាតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានសមស្រប បណ្ដាលឱ្យមានការចំណាយដ៏ធំជាងចំណូលដែលរកបាន ។
- **វិបត្តិផលិតផលលើស :** បណ្ដាលមកពីផលិតផលមានកំណើនលើសពីសេចក្ដីត្រូវការរបស់ទីផ្សារដែលនាំឱ្យមានការធ្លាក់ចុះទាំងស្រុងនៃដំណើរផលិតកម្ម ដែលអាចបណ្ដាលឱ្យមានការ

ថយចុះការវិនិយោគទុន ការកើនឡើងនៃភាពគ្មានការងារធ្វើ ការបាត់បង់ប្រាក់ចំណូលរបស់សហគ្រាសនានា ការធ្លាក់ចុះនៃអត្រាប្រាក់ហ៊ុន និងកំណើនអតិផរណា ។

- **វិបត្តិកសិកម្ម :** បណ្ដាលមកពីមានកំណើនកសិផលលើសពីសេចក្ដីត្រូវការរបស់ទីផ្សារនៅក្នុងបណ្ដាប្រទេសជឿនលឿន ។ វាស្ដែងឡើងជាដំបូងដោយការប្រមូលផ្ដុំនៃការស្ដុកទុកយ៉ាងធំនៃកសិផលដែលមិនអាចលក់ចេញបាន ។ មូលហេតុនៃវិបត្តិកសិកម្ម គឺបណ្ដាលមកពីកង្វះការស្រាវជ្រាវទីផ្សារ ។
- **វិបត្តិថាមពល :** ជាវិបត្តិសេដ្ឋកិច្ចមួយនៅក្នុងចំណោមវិបត្តិសេដ្ឋកិច្ចទាំងឡាយ ប៉ុន្តែមិនមានលក្ខណៈជាខួបទេ ។ វិបត្តិនេះ បានផ្ទុះឡើងនៅចុងឆ្នាំ 1973 ។ វាស្ដែងឡើងជាដំបូងដោយការខ្វះខាតធនធានថាមពល បន្ទាប់ពីមានការកើនឡើងយ៉ាងឆាប់រហ័សនៃតម្លៃប្រេងកាតដែលជាផលិតផលថាមពលសំខាន់នៅសម័យបច្ចុប្បន្ននេះ ។ម្យ៉ាងទៀត ការវាតទីនៃក្រុមហ៊ុនប្រេងកាតធំៗ ក៏ជាប្រភពនៃវិបត្តិថាមពលដែរ ។ នៅក្នុងឆ្នាំ 1950-1960 ដើម្បីបំបាត់និងដណ្ដើមយកទីផ្សារថាមពលអំពីអ្នកប្រជែងសំខាន់ៗ ដើម្បីយកឈ្នះលើក្រុមហ៊ុនធ្យូងថ្មទាំងឡាយ គេបានកាត់បន្ថយតម្លៃពន្ធប្រេងដែលនាំចូលពីប្រទេសកំពុងអភិវឌ្ឍ ។ ដូច្នេះហើយ ធ្វើឱ្យមានការកើនឡើងយ៉ាងសន្ធឹកសន្ធាប់នូវចំនួនប្រេងនាំចូលទៅក្នុងជញ្ជីងពាណិជ្ជកម្មថាមពលនៃប្រទេសអភិវឌ្ឍ ។ នៅចំពោះមុខទស្សនវិស័យនៃការចុះខ្សត់រ៉ែនៅអណ្ដូងប្រេង ដែលងាយចូលនិងងាយជីកបាននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ពួកក្រុមហ៊ុនផ្ដាច់មុខធំៗបានបង្ខំចិត្តត្រូវចាប់ផ្ដើមស្វែងរកអណ្ដូងប្រេងថ្មីដែលពិបាកនឹងចូលទៅបានដូចជានៅក្រោមដីនៃខ្ពង់រាប ឧបទ្វីបសហរដ្ឋអាមេរិកនិងកាណាដាជាដើម ។ ទន្ទឹមនឹងនេះ គេក៏ចាប់ផ្ដើមផលិតនូវប្រេងឥន្ធនៈរាវផ្សំឡើងអំពីជាតិធ្យូងថ្មក្រៃ ប្រេងកាត ជាតិហ្សីពីទុយមីន និងអំពីផលិតផលថាមពលផ្សេងៗទៀតដោយប្រើប្រាស់នូវប្រាក់ចំណាយសម្រាប់ផលិតកម្មយ៉ាងខ្ពស់ ។ ដូច្នេះ ផលិតផលមិនអាចបានចំណេញទេបើមិនខំដំឡើងថ្លៃប្រេងកាត ។
- **វិបត្តិបរិស្ថាន :** គឺការខូចបរិស្ថាននៃប្រទេសអភិវឌ្ឍនានា ដែលបណ្ដាលមកពីការបំផ្លិចបំផ្លាញប្រកបដោយព្យសនកម្មដែលមិនអាចប្រកែកបាន ឬដែលពិបាកនឹងជួសជុលបាន ។ ការបំផ្លិចបំផ្លាញកើតមកពីការធ្វើអាជីវកម្មជ្រុលហួស ការខ្ជះខ្ជាយឬការបន្លំលួចធនធានធម្មជាតិទាំងឡាយដោយពួកក្រុមហ៊ុនផ្ដាច់មុខធំៗនិងបង្កើនធនធានម្ហូបអាហារ និងកំណើននៃផលិតកម្មឧស្សាហកម្ម ។ វិបត្តិបរិស្ថាន ជាការស្ដែងចេញនូវគុណវិបត្តិរបស់បណ្ដាប្រទេសដែលមានការរីកចម្រើនមិនសមស្របខាងផ្នែកផលិតកម្មដែលជាកត្តាជះឥទ្ធិពលទៅលើវិស័យសេដ្ឋកិច្ច ។

អ្នកធ្វើការទាំងឡាយនៅប្រទេសអភិវឌ្ឍត្រូវប្រឈមមុខនឹងវិបត្តិភ័យមួយ គឺការថយចុះយ៉ាងខ្លាំងនៃគុណភាពរបស់ខ្យល់អាកាស ទឹកស្អាត ផលិតផល ចំណីអាហារ សំឡេងរំខានកងរំពង ការកើនឡើងនូវជំងឺសរសៃប្រសាទដែលបណ្ដាលមកពីចរាចរណ៍តាមផ្លូវខ្វាត់ខ្វែងណែនណាន់តាន់តាប់ ។ល ។

ចំណែកឯប្រទេសកំពុងអភិវឌ្ឍ នៅមានឱកាសច្រើនក្នុងការរៀបចំយុទ្ធសាស្ត្របង្ការកុំឱ្យមានការរីកចម្រើនផ្នែកផលិតកម្ម បង្កវិបត្តិដល់បរិស្ថាន ។

- **វិបត្តិរូបិយវត្ថុ :** គឺការបាត់លំនឹងទូទាត់យ៉ាងធ្ងន់ធ្ងរនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងនិងក្រៅប្រទេស ។ វិបត្តិនេះ មានឥទ្ធិពលលើវិបត្តិសេដ្ឋកិច្ច និងទំនាស់ទាំងឡាយក្នុងសង្គម ។

វិបត្តិរូបិយវត្ថុមានពីរយ៉ាងគឺ ទី 1 វាជាបាតុភូតកើតមានជាប្រចាំសម្រាប់យុគសម័យនៃវិបត្តិសេដ្ឋកិច្ចទូទៅដែលជាការលុបចំបាត់ចោលនូវខ្នាតមាសសម្រាប់រូបិយវត្ថុ ឬទី 2 វាជាការធ្លាក់ចុះដុនដាបនៃស្ថានភាពរូបិយវត្ថុមួយចំនួនដែលមិនអាចផ្ដោះប្ដូរបានដោយសារអតិផរណា ។

នៅសង្គ្រាមលោកលើកទី 1 ភាពផ្ដោះប្ដូរបាននៃក្រដាសប្រាក់របស់ធនាគារជាមួយនឹងមាសត្រូវបានលុបចោលនៅក្នុងប្រទេសជាច្រើន ហើយរូបិយវត្ថុជាច្រើនត្រូវបានចុះថ្លៃយ៉ាងខ្លាំង ។

- **វិបត្តិវប្បធម៌ :** សំដៅលើការប្រកាន់យកឥរិយាបថអវិជ្ជមានរបស់ប្រជាពលរដ្ឋមួយចំនួនដែលជាមូលហេតុនាំឱ្យរាំងស្ទះដល់ការលើកកម្ពស់សេដ្ឋកិច្ចរបស់បុគ្គលនិងគ្រួសារខ្លួនឯង ដែលជះឥទ្ធិពលដល់ការលើកកម្ពស់សេដ្ឋកិច្ចជាតិ ។

ឥរិយាបថអវិជ្ជមានដែលផ្ដល់ផលប៉ះពាល់ដល់សេដ្ឋកិច្ចមាន

- ការមិនឱ្យតម្លៃលើការសិក្សា ដោយបណ្ដែតបណ្ដោយខ្លួនឱ្យស្ថិតក្នុងគ្រោះអវិជ្ជា ឬនិយមការសិក្សាតែបន្តិចបន្តួច ។
- ការគាំទ្រវប្បធម៌ "មានបានដោយមិនបាច់ប្រឹង" (*ឧទាហរណ៍* ប្រើគំនិតកេងប្រវ័ញ្ច គឹបកេងបន្លំ បោកប្រាស់ លួចប្លន់ ដើម្បីរកទ្រព្យផ្ទាល់ខ្លួន) ។
- ការស្អប់ខ្ពើមពលកម្មផលិតកម្មនិងពាណិជ្ជកម្ម (*ឧទាហរណ៍* ចាំទិញគេស្រាប់ៗ) ។
- ការនិយមអំពើពាលា (*ឧទាហរណ៍* ស្រី ស្រា បារី គ្រឿងញៀន ល្បែង) ។
- ការនិយមប្រើអំពើហិង្សាក្នុងគ្រួសារ (*ឧទាហរណ៍* ការវាយដំ ការផិតក្បត់ ការបំផ្លាញទ្រព្យ...) ។
- ការជួញដូរមនុស្ស និងការរើសអើងភេទ (*ឧទាហរណ៍* ការនិយមទស្សនៈថា ស្ត្រីភេទជាប្រភេទមនុស្សតូចទាបទន់ខ្សោយដែលសមនឹងទទួលការប្រមាថពីបុរសភេទ) ។

- ការរើសអើងជនពិការ (*ឧទាហរណ៍* ការយល់ថា ជនពិការមិនអាចទទួលការងារនេះបានទេ) ។
- ការប្រកាន់វ័យ (*ឧទាហរណ៍* មនុស្សវ័យចាស់មិនអាចស្តាប់យោបល់មនុស្សវ័យក្មេង) ។
- ការប្រកាន់វណ្ណៈ (*ឧទាហរណ៍* ការប្រកាន់ទម្លាប់អ្នកមានទើបជាអ្នកដឹកនាំ អ្នកធំមិនអាចស្តាប់យោបល់អ្នកក្រោមបង្គាប់)និងការប្រកាន់ពូជសាសន៍ (*ឧទាហរណ៍* ពាណិជ្ជកម្មជាការងាររបស់ជនជាតិចិន ការនេសាទជាការងារជនជាតិឥស្លាមឬវៀតណាម ការងារមន្ត្រីរាជការជាការងាររបស់ជនជាតិខ្មែរ..) ។
- ការបាត់បង់អត្តសញ្ញាណជាតិ (*ឧទាហរណ៍* លក់ដីកេរមរតកដើម្បីទិញយកនិងប្រើប្រាស់សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ យានជំនិះ គ្រឿងឧបភោគបរិភោគ ភេសជ្ជៈ គ្រឿងតុបតែងខ្លួន ឧបករណ៍សិល្បៈកំសាន្តពីបរទេស...) ។
- ការដាក់ប្រយោជន៍ផ្ទាល់ខ្លួនជាចម្បងឬប្រឆាំងនឹងប្រយោជន៍ជាតិ (*ឧទាហរណ៍* ការបង្វែរសេវាសាធារណៈ ជាសេវារកកម្រៃផ្ទាល់ខ្លួន ការជ្រើសរើសយកមុខរបរផលិតឬលក់ថ្នាំញៀន) ។
- កង្វះការគោរពកម្មសិទ្ធិបញ្ញា (*ឧទាហរណ៍* លួចចម្លងស្នាដៃអ្នកដទៃដើម្បីធ្វើអាជីវកម្មផ្ទាល់ខ្លួន) ។
- កង្វះការគោរពនិងអនុវត្តច្បាប់អំពីសំណាក់ប្រជាពលរដ្ឋ ។
- កង្វះអន្តរាគមន៍របស់រដ្ឋក្នុងរូបភាពការអប់រំ ព្រមាន ទប់ស្កាត់ និងអនុវត្តច្បាប់ចំពោះបាតុភាពអសកម្មខាងលើ ។

វិបត្តិវប្បធម៌មិនត្រឹមតែបង្កឱ្យមានវិបត្តិសុខភាពផ្លូវកាយ ផ្លូវចិត្ត អារម្មណ៍ សញ្ចេតនាដល់ប្រជាពលរដ្ឋជាអ្នករងគ្រោះដ៏ច្រើនប៉ុណ្ណោះទេ ប៉ុន្តែទាំងអ្នកប្រព្រឹត្តក៏រងវិបត្តិដូចគ្នាដែរ ។ ជាលទ្ធផល វិបត្តិវប្បធម៌បង្កើតបរិយាកាសអាប់អួរដល់សង្គមជាតិ បង្អាក់ឆន្ទៈចូលរួមក្នុងភាពជាប្រជាពលរដ្ឋដោយមនុស្សម្នាក់ៗបាត់បង់ថាមពលឬសក្តានុពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិ ។

# 3. ការធ្វើអន្តរាគមន៍របស់រដ្ឋ

## 3.1. នៅប្រទេសអភិវឌ្ឍ

ជាទូទៅ នៅបណ្តាប្រទេសអភិវឌ្ឍនានា ការរឹតបន្តឹងឱ្យប្រជាពលរដ្ឋមានការសិក្សាខ្ពស់និងចូលរួមលើកកម្ពស់វប្បធម៌ អរិយធម៌ជឿនលឿន ត្រូវបានចាត់ទុកជាវិស័យអាទិភាព ។ បន្ទាប់ពីនេះរដ្ឋបានដើរតួជាអ្នកបញ្ជានិងទប់ស្កាត់បាតុភាពអវិជ្ជមានដែលកើតមានក្នុងសេដ្ឋកិច្ចទីផ្សារ មានដូចជា

ការប្រកាន់ភាពម៉ឺងម៉ាត់ ត្រឹមត្រូវ មានតម្លាភាព គណនេយ្យភាពក្នុងការប្រមូលពន្ធដារ អាករ និង ចំណូលគ្រប់ប្រភេទដើម្បីបង្កើនសេដ្ឋកិច្ចជាតិ ការកំណត់ថ្លៃពន្ធខ្ពស់ចំពោះទំនិញគ្រឿងស្រវឹង ទប់ស្កាត់ភាពផ្តាច់មុខក្នុងពាណិជ្ជកម្ម ត្រួតពិនិត្យឱ្យមានការដាក់បង្ហាញថ្លៃលក់លើទំនិញគ្រប់ប្រភេទ ចូលរួមសិក្សានិងផ្តល់ព័ត៌មានអំពីទីផ្សារជាដើម ។

## 3.2. នៅប្រទេសកំពុងអភិវឌ្ឍ

ជាទូទៅ បណ្តាប្រទេសកំពុងអភិវឌ្ឍច្រើនជាប្រទេសដែលធ្លាប់បានរងគ្រោះដោយការដាក់អាណានិគមអំពីសំណាក់ប្រទេសអាណាព្យាបាល ។ ស្ថិតក្នុងភាពជាប្រទេសក្រោមអាណានិគម រដ្ឋាភិបាលមិនមានសេរីភាពក្នុងការជំរុញការសិក្សារបស់ប្រជាពលរដ្ឋខ្លួនឡើយ ។ ដូចនេះហើយ ទោះបីទទួលបានឯករាជ្យភាពជាយូរឆ្នាំមកហើយក្តី ក៏ប្រទេសកំពុងអភិវឌ្ឍនៅមានជីតជាមបញ្ហាខ្វះខាតច្រើនបង្គួរក្នុងនោះមានបញ្ហាវិបត្តិវប្បធម៌ជាដើម ។ ដោយសារវិបត្តិវប្បធម៌នេះ គេអាចនិយាយបានថាគ្រប់ប្រទេសកំពុងអភិវឌ្ឍជាប្រទេសក្រីក្រ ឬជាប្រទេសកំពុងដោះស្រាយវិបត្តិសេដ្ឋកិច្ច ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងយុគសម័យសកលភាវូបនីយកម្មនេះ ប្រទេសកំពុងអភិវឌ្ឍមិនស្ថិតនៅជាប្រទេសឯកោទេ ពោលគឺមានការជួយឧបត្ថម្ភពីបណ្តាប្រទេសអភិវឌ្ឍ ។

## 3.3. នៅប្រទេសកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍមួយដែលកំពុងមានសកម្មភាពមមាញឹកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ខ្លួនតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលមានកម្មវិធីសកម្មភាពដ៏ច្រើនពាក់ព័ន្ធគ្នានៅគ្រប់វិស័យ ក្នុងនោះមានអភិបាលកិច្ចល្អជាស្នូល ។

មិនខុសអំពីរដ្ឋនានាដទៃទៀតក្នុងសម័យទំនើប រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសយកនិងកំពុងមមាញឹកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចាត់ទុកជាស្នូលនៃអភិបាលកិច្ចល្អ ដើម្បីធានាការអភិវឌ្ឍនិងការលូតលាស់ជានិរន្តរ៍ ។ គម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានការចូលរួមអំពីវិស័យកសិកម្ម កាត់ដេរ សំណង់ ទេសចរណ៍និងសេវាកម្ម និងអំពីសំណាក់សហគមន៍ជាតិនិងអន្តរជាតិ មានសមាសភាគចម្បងៗបួនគឺ

- ទីមួយ ការគ្រប់គ្រងធនធានសាធារណៈជាទូទៅ ។
- ទីពីរ វិភាជន៍ធនធានប្រកបដោយតម្លាភាព សម្រាប់វិស័យផ្សេងៗស្របតាមគោលដៅនៃគោលនយោបាយសេដ្ឋកិច្ច- សង្គមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើនសេដ្ឋកិច្ចលឿននិងមានចេរភាព និងកាត់បន្ថយភាពក្រីក្រ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

- ទីបី ការប្រើប្រាស់ធនធានប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងជាលក្ខណៈសេដ្ឋកិច្ច ដើម្បីគាំទ្រដល់ការផ្គត់ផ្គង់ទំនិញ និងសេវាសាធារណៈ ។
- ទីបួន ការបោះពុម្ពផ្សាយព័ត៌មានប្រកបដោយតម្លាភាពនិងទទួលបានព័ត៌មានស្តីពីការចលនា និងការប្រើប្រាស់ធនធានសាធារណៈ ។

នៅដើមឆ្នាំ 2009 ឥទ្ធិពលវិបត្តិហិរញ្ញវត្ថុសកលលោកបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចមួយចំនួនជាប់គាំង បង្កឱ្យមានការថយចុះពាណិជ្ជកម្មអន្តរជាតិ ការបាត់បង់ការងារធ្វើ និងការថយចុះចំណូលជាតិជាដើម ។ ប្រការនេះបានធ្វើឱ្យវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជានៅតែបន្តរងផលប៉ះពាល់ ជាពិសេសនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងការអនុវត្តចំណូលនិងចំណាយថវិការដ្ឋ ។

តាមរបាយការណ៍ស្តីពីប្រតិបត្តិការថវិកានៅខែឧសភា ឆ្នាំ 2009 របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណូលនៅខែឧសភា ឆ្នាំ 2009 អនុវត្តទាបជាងខែមេសាកន្លងមក ហើយជារួមចំណូល 5 ខែដើមឆ្នាំ 2009 ទាបជាងការអនុវត្តកាលពីឆ្នាំកន្លងទៅ ។ ចំណែកឯការចំណាយប្រព្រឹត្តទៅបានល្អក្នុងសន្ទុះលឿនទាំងចំណាយដែលប្រើប្រាស់ប្រភពក្នុងស្រុកនិងចំណាយដែលប្រើប្រាស់ប្រភពក្រៅស្រុក ដែលប្រការនេះ គឺទាក់ទងទៅនឹងការអនុវត្តនយោបាយវិត្តាកម្មចំណាយ ដើម្បីទប់ទល់ទៅនឹងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកលលោក ។

ដោយបានទទួលរងឥទ្ធិពលវិបត្តិហិរញ្ញវត្ថុសកលលោក កំណើនសេដ្ឋកិច្ចជាតិកម្ពុជាបានធ្លាក់ចុះពី 6% នៅឆ្នាំ 2008 មកនៅត្រឹម 3% នៅឆ្នាំ 2009 ប៉ុន្តែតួលេខនេះបញ្ជាក់ឱ្យឃើញថាសេដ្ឋកិច្ចជាតិកម្ពុជានៅតែមានកំណើននៅឡើយ ។ កំណើននេះ ត្រូវបានកត់សម្គាល់តាមរយៈសូចនាកររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានបង្ហាញថា មានកំណើនវិនិយោគលើវិស័យកសិកម្ម ការពង្រីកមូលដ្ឋាននៃវិស័យមិនមែនកសិកម្ម ស្ថេរភាពនយោបាយ ការចូលរួមយ៉ាងសកម្មក្នុងវិស័យឯកជន ការខិតខំអនុវត្តកម្មវិធីកំណែទម្រង់របស់រដ្ឋ កំណើនជំនួយជាផ្លូវការក្នុងការអភិវឌ្ឍនិងនិរន្តរភាពនៃកំណើនវិនិយោគដោយចំពោះ ។

## 4. សេចក្តីសន្និដ្ឋាន

ជាទូទៅវិបត្តិសេដ្ឋកិច្ចកើតមានដោយកត្តាជាច្រើនផ្សេងគ្នា ។ ប៉ុន្តែគេអាចរួមបញ្ចូលគ្នាជា 2 ប្រភេទគឺកត្តាបាតុភូតធម្មជាតិនិងកត្តាបាតុភូតសង្គមដែលបង្កឡើងដោយមនុស្ស ។ វិបត្តិសេដ្ឋកិច្ចដែលកើតពីកត្តាបាតុភូតធម្មជាតិសុទ្ធសាធ មនុស្សអាចបង្ការនិងអាចដោះស្រាយបានដោយអន្លើ ។ ប៉ុន្តែប្រសិនបើវិបត្តិសេដ្ឋកិច្ចកើតពីកត្តាបាតុភូតសង្គមមនុស្ស មានតែការរៀបចំខ្លួនឡើងវិញរបស់មនុស្សខ្លួន

ឯងនិងអភិបាលកិច្ចល្អរបស់រដ្ឋាភិបាលទេ ទើបអាចបញ្ចៀសនិងដោះស្រាយបានទាំងស្រុង ។ដូចនេះ ទោះបីជាស្ថិតក្នុងសេដ្ឋកិច្ចទីផ្សារសេរីក៏ដោយ ការចូលរួមរបស់រដ្ឋនិងសហគមន៍អន្តរជាតិ គឺជាការចាំបាច់ដើម្បីបញ្ចៀសវិបត្តិសេដ្ឋកិច្ច ។

## ? សំណួរ

1. ចូរអ្នកអានអត្ថបទខាងក្រោមនេះ ។ បន្ទាប់មក ចូរនិយាយប្រាប់សិស្សក្នុងថ្នាក់ថាអត្ថបទនេះនិយាយអំពីអ្វីខ្លះ ?

### អារម្ភកថា

រាជរដ្ឋាភិបាលបានអនុម័ត**ចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ** 2001-2010 នាថ្ងៃទី 24 ខែសីហា ឆ្នាំ 2001 ។ ផែនការអភិវឌ្ឍន៍នោះតម្រូវឱ្យមានប្រព័ន្ធគណនេយ្យនិងសវនកម្មដើម្បីជំរុញសហគ្រាសនិងអង្គភាពគ្រប់ប្រភេទឱ្យកាន់បញ្ជីគណនេយ្យនិងធ្វើរបាយការណ៍ហិរញ្ញវត្ថុអំពីប្រតិបត្តិការរបស់ខ្លួនព្រមទាំងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះផង ។ ដោយឡែកគោលដៅចម្បងគឺដើម្បីលើកកម្ពស់គណនេយ្យភាពរបស់សហគ្រាសឯកជននិងអង្គភាពហិរញ្ញវត្ថុដទៃទៀត ដែលជួយពង្រីកការផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបានដល់សាធារណៈជននិងវិនិយោគិន និងជួយលើកកម្ពស់អភិបាលកិច្ចល្អដែលជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងកំណើនសេដ្ឋកិច្ចជាតិ ។

តាមការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល **"ច្បាប់ស្តីពីការគណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាស និងវិជ្ជាជីវៈគណនេយ្យ"** ត្រូវបានប្រសូត្រឡើង ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/0702/011 ឆ្នាំ 2002 ។ ដោយអនុលោមតាមច្បាប់គណនេយ្យនេះ អង្គភាពសំខាន់ចំនួនពីរគឺ **"ក្រុមប្រឹក្សាជាតិគណនេយ្យ(ក.ជ.គ) និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក)"** ត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវក្នុងការរៀបចំច្បាប់បទដ្ឋានស្តង់ដារគណនេយ្យនិងស្តង់ដារសវនកម្ម និងការគ្រប់គ្រងគណនេយ្យករ សវនករ និងវិជ្ជាជីវៈគណនេយ្យទៅតាមតួនាទីនិងសមត្ថភាពរៀងៗខ្លួន ។ បន្ទាប់មកក្រោមការជួយឧបត្ថម្ភគាំទ្រពីសំណាក់អង្គទូត អង្គការជាតិនិងអន្តរជាតិនានា **ស្តង់ដារគណនេយ្យកម្ពុជាចំនួន** 15 ស្តង់ដារ និង**ស្តង់ដារសវនកម្មកម្ពុជា**ចំនួន 10 ស្តង់ដារត្រូវបានអនុម័តនិងអនុញ្ញាតឱ្យប្រើប្រាស់ ។

youtube.com/moeys fcrou.moeys.gov.kh facebook.com/moeys.gov.kh

សៀវភៅក្រោមចំណងជើងថ្លូវការថា **ស្តង់ដារគណនេយ្យកម្ពុជា (ស.គ.ក)** និង**ស្តង់ដារសវនកម្មកម្ពុជា (ស.ស.ក)** ត្រូវបានរៀបរៀងនិងចងក្រងឡើងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគ្រាសឯកជននូវស្តង់ដារគណនេយ្យនិងសវនកម្ម ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួននិងសេចក្តីត្រូវការនៃប្រទេសកម្ពុជា ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងដំណើរសកលភាវូបនីយកម្មតាមរយៈការធ្វើស្តង់ដារកម្មគណនេយ្យកម្ពុជាជាមួយនឹងស្តង់ដារគណនេយ្យអន្តរជាតិដែលកំពុងត្រូវបានអនុវត្តតាម ដោយប្រទេសជាងមួយរយនៅលើពិភពលោក។

*(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ក្រុមប្រឹក្សាជាតិគណនេយ្យ)*

2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាមួយសិស្សក្នុងថ្នាក់ដើម្បីឆ្លើយនឹងសំណួរខាងក្រោម
   ក. ដូចម្តេចហៅថាវិបត្តិសេដ្ឋកិច្ច ?
   ខ. តើវិបត្តិសេដ្ឋកិច្ចកើតឡើងដោយបញ្ហាអ្វីខ្លះ ?
   គ. តើអ្នកណាជាអ្នកមានសមត្ថកិច្ចធ្វើអន្តរាគមន៍ដោះស្រាយវិបត្តិសេដ្ឋកិច្ច ? ដោះស្រាយដោយវិធីណាខ្លះ ?
   ឃ. បច្ចុប្បន្ន តើប្រទេសកម្ពុជាមានបញ្ហាវិបត្តិសេដ្ឋកិច្ចដែរឬទេ ? តើវិបត្តិនេះ កើតមានឡើងដោយសារអ្វី ?
3. ចូរអ្នកអាន និងដកស្រង់ខ្លឹមសារសំខាន់ៗនៃមេរៀនខាងលើ រួចសង្ខេបជាមេរៀនផ្ទាល់ខ្លួន។

## ប្រតិបត្តិ

ចូរអ្នកសរសេរអត្ថបទមួយដែលនិយាយអំពីអ្វីដែលមនុស្សត្រូវធ្វើនិងមិនត្រូវធ្វើ ដើម្បីបង្ការការកើតឡើងនូវវិបត្តិសេដ្ឋកិច្ចជាតិរបស់ខ្លួន។

facebook.com/moeys.gov.kh youtube.com/moeys krou.moeys.gov.kh

មេរៀនទី

# 12 កម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញលក្ខណៈសម្គាល់ភាពប្រាកដនិយមនៃកម្មវិធី សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ ។
- ❑ បង្ហាញសារៈសំខាន់នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងកសាងធនធានមនុស្សរបស់រដ្ឋ ។
- ❑ បង្ហាញគោលនយោបាយរបស់រដ្ឋក្នុងការអភិវឌ្ឍផ្នែកពាណិជ្ជកម្មនិងការអភិវឌ្ឍជនបទ ។
- ❑ រៀបរាប់លក្ខណៈនៃការរៀបចំកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ ។
- ❑ ផ្តល់ឧទាហរណ៍អំពីការរៀបចំកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ ។


រាជរដ្ឋាភិបាលកម្ពុជា

សុន្ទរកថា

របស់សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ស្តីពី

«យុទ្ធសាស្ត្រចតុកោណ»

*ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា*

ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ

សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា

នៅទីស្តីការគណៈរដ្ឋមន្ត្រី

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤

*សៀវភៅយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា*

## 1. និយមន័យ

កម្មវិធីជាតិគឺផែនការសកម្មភាពការងារទៅអនាគត រៀបចំឡើងដោយរដ្ឋាភិបាល ដើម្បីសម្រេចឱ្យបានគោលបំណងណាមួយ ។

នីតិសម្បទា គឺការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ ឬការមានច្បាប់ដោយបរិបូរ ។

កម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ជាកម្មវិធីរបស់រាជរដ្ឋាភិបាលរៀបចំឡើងក្នុងគោលបំណងធានាការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ស្តារនិងអភិវឌ្ឍប្រទេសតាមមាគ៌ានយោបាយដែលមានចែងក្នុងច្បាប់ ។

## 2. លក្ខខណ្ឌនៃការរៀបចំ

### 2.1. ភាពប្រទាក់ក្រឡា ស៊ីសង្វាក់ និងគ្រប់ជ្រុងជ្រោយ

កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍ត្រូវមានលក្ខណៈប្រទាក់ក្រឡា ស៊ីសង្វាក់ និងគ្រប់ជ្រុងជ្រោយ ដែលក្នុងនោះមានការទាក់ទិនទៅនឹងរាល់បណ្តាផ្នែកសំខាន់ៗនៃសេដ្ឋកិច្ចជាតិនិងមជ្ឈដ្ឋានអស្ថិរភាពរបស់ប្រព័ន្ធសេដ្ឋកិច្ចទាំងមូល (ប្រព័ន្ធនយោបាយ ច្បាប់ បែបបទ និងរចនាសម្ព័ន្ធរដ្ឋបាល ហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត ការបណ្តុះបណ្តាលធនធានមនុស្ស ។ល ។) ។ កម្មវិធីនេះ ត្រូវបានរៀបចំជាមធ្យោបាយសម្រាប់អនុវត្ត ដោយកំណត់ថា អ្នកណាជាអ្នកអនុវត្ត ពេលវេលាត្រូវអនុវត្ត ដើម្បីអភិវឌ្ឍតាមទិសដៅដែលបានគ្រោងទុក ។

### 2.2. ចំណុចសំខាន់ៗនៃខ្លឹមសារកម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍

- រដ្ឋមានតួនាទីជាអ្នកគ្រប់គ្រង អ្នករៀបចំសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍ ។ រដ្ឋនិងឯកជន មានទំនាក់ទំនងជាមួយគ្នាក្នុងនាមជាគូសន្ទនា ដើម្បីសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍ឱ្យចេញជាលទ្ធផលជាក់ស្តែងតាមគោលបំណងនៃកម្មវិធី ។
- នយោបាយម៉ាក្រូសេដ្ឋកិច្ចនិងការកែលំអខាងផ្នែកលិខិតបទដ្ឋាននិងរចនាសម្ព័ន្ធរដ្ឋបាលមានទាក់ទិនជុំវិញបញ្ហានយោបាយ ឥណទាន រូបិយវត្ថុ ពាណិជ្ជកម្ម អតិផរណា ការងារអាជីព ព្រមទាំងបញ្ហាផ្សេងទៀតដែលធ្វើឱ្យមានសុក្រឹតភាពក្នុងប្រព័ន្ធច្បាប់និងប្រព័ន្ធរដ្ឋបាលជាដើម ។ នៅចំណុចនេះ រដ្ឋនិងឯកជនជាតួអង្គសំខាន់ ក្នុងការអនុវត្តកម្មវិធីស្ថិរភាវូបនីយកម្មប្រព័ន្ធសេដ្ឋកិច្ចនិងបង្កើតឡើងនូវសន្តិសុខនិងស្ថិរភាពសង្គម ។
- ការកសាងធនធានមនុស្ស គឺអប់រំមនុស្សឱ្យមានចំណេះដឹង ចំណេះធ្វើខាងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាព្រមទាំងការផ្លាស់ប្តូរឥរិយាបថផ្សេងៗស្របតាមនិន្នាការទីផ្សារសេរីនៃពិភព

អភិវឌ្ឍន៍ ។ ធនធានមនុស្សជាកម្លាំងចលករនិងជាទិសដៅនៃសកម្មភាពសេដ្ឋកិច្ច ។ តាមរយៈនេះ រដ្ឋនិងឯកជនបានសហការគ្នាធ្វើការងារហ្វឹកហ្វឺនខាងវិជ្ជាជីវៈ មុខរបរ ផ្សព្វផ្សាយបច្ចេកវិទ្យាថ្មី ដើម្បីបង្កលក្ខណៈសម្បត្តិឱ្យមនុស្សទូទៅ ជាពិសេសអ្នកដើរតួសេដ្ឋកិច្ចទាំងខាងរដ្ឋ ទាំងខាងឯកជនមានការផ្លាស់ប្ដូរនិងកែលំអឥរិយាបថ ។

- ការកសាងនិងអនុវត្តគោលនយោបាយរបស់រដ្ឋក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត មានដូចជា មធ្យោបាយដឹកជញ្ជូន គមនាគមន៍ ថាមពល ការគ្រប់គ្រង និងអភិវឌ្ឍន៍បរិស្ថាន ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ។ ដើម្បីសម្រេចបានគោលនយោបាយនេះ រដ្ឋត្រូវបង្កើតសហគ្រាសចម្រុះជាមួយឯកជន ឬប្រគល់ការងារឯកជនតាមរូបមន្តផ្សេងៗ ។ ក្នុងករណីខ្វះថវិកា រដ្ឋជាអ្នកស្វែងរកថវិកា ដើម្បីសម្របសម្រួលនិងទាក់ទាញអ្នកវិនិយោគទុនជាតិនិងអន្តរជាតិ ធ្វើយ៉ាងណាឱ្យការអនុវត្តគោលនយោបាយនោះទទួលបានជោគជ័យក្នុងការរៀបចំប្រព័ន្ធអភិវឌ្ឍន៍ប្រទេស ។
- ការកសាងនិងអនុវត្តន៍គោលនយោបាយពាណិជ្ជកម្មនិងសហប្រតិបត្តិការអន្តរជាតិ ពោលគឺសមាហរណកម្មសេដ្ឋកិច្ចដោយភ្ជាប់ប្រព័ន្ធសេដ្ឋកិច្ចជាតិទៅនឹងប្រព័ន្ធសេដ្ឋកិច្ចពិភពលោក ។ ការងារសំខាន់ក្នុងផ្នែកនេះ គឺទាក់ទាញការវិនិយោគ ។ ការទាក់ទាញការវិនិយោគនេះ ត្រូវឈរលើ
    - ការសម្របសម្រួលការអនុគ្រោះពន្ធនាំចូល និងរក្សាបានសន្តិសុខសង្គម ។
    - ការពារផលប្រយោជន៍ជាតិនិងការពារផលិតផលក្នុងស្រុក ។

តាមរយៈគោលនយោបាយនេះ រដ្ឋត្រូវអនុវត្តកិច្ចសហប្រតិបត្តិការជាមួយបរទេស ។ ដោយឡែកចំពោះការងារទំនាក់ទំនងជាមួយអ្នកវិនិយោគឯកជននិងជាមួយបរទេស រដ្ឋត្រូវយកចិត្តទុកដាក់រៀបចំឱ្យបាននូវប្រព័ន្ធការងារល្អ ដើម្បីធានានូវប្រសិទ្ធភាពការងារនិងជួយសម្រួលដល់អ្នកវិនិយោគដែលចង់បណ្ដាក់ទុន ។

- ការកសាងនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទដែលមានគោលដៅដោះស្រាយគម្លាតរវាងទីក្រុងនិងជនបទ ជួយឱ្យប្រជារាស្ត្រទូទៅមានសុខុមាលភាពនិងសន្តិសុខ ។ គោលនយោបាយអភិវឌ្ឍន៍ជនបទ មិនត្រឹមតែជាយុទ្ធសាស្ត្រដើម្បីបង្កើនសុខុមាលភាពប្រជារាស្ត្រប៉ុណ្ណោះទេ តែដើម្បីរួមចំណែកការពារសន្តិសុខជាតិនិងឯកភាពជាតិផងដែរ ។ ដូចនេះ ក្នុងក្របខ័ណ្ឌនៃការងារអភិវឌ្ឍន៍ជនបទ រដ្ឋត្រូវយកចិត្តទុកដាក់លើការងារសំខាន់ៗមួយចំនួន ក្នុងនោះមានការដោះមីន ការរានដីថ្មី ការជំរុញលើកទឹកចិត្តដល់ការវិនិយោគទុនលើផ្នែកកសិ-ឧស្សាហកម្ម ដោយការពារឱ្យបាននូវសុខភាពប្រជាជន និងបរិស្ថានល្អជាដើម ។

## 3. យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

តាមការគិតរបស់រាជរដ្ឋាភិបាលកម្ពុជា "យុទ្ធសាស្ត្រចតុកោណ" គឺជាការបន្តពី "យុទ្ធសាស្ត្រត្រីកោណ" ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី 2 នៃរដ្ឋសភា ហើយដែលមានមុខងារយ៉ាងសមស្រប ក្នុងការបង្កើតបុព្វលក្ខខណ្ឌ សម្រាប់ការងើបឈរឡើងពេញជំហររបស់កម្ពុជា ដោយសារថា មានន័យធរណីមាត្រសាស្ត្រ គេអាចដាក់វត្ថុដែលមានជើងបី ឬ "ត្រីកោណ" ឱ្យឈរបានគ្រប់ទីកន្លែងទាំងអស់ ទោះក្នុងស្ថានភាពណាក៏ដោយ ។ ចំណែក "យុទ្ធសាស្ត្រចតុកោណ" នេះត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធមុំបួននៃចតុកោណមានប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នាគ្រប់ជ្រុងទាំងអស់ ដែលនៅក្នុងផ្នត់គំនិតរបស់មនុស្សទូទៅ គឺតំណាងឱ្យ "ចិរភាព" និង "ស្ថិរភាព" ។ ក្នុងន័យនេះ ការសម្រេចបានជោគជ័យ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណនឹងនាំមកឱ្យកម្ពុជានូវស្ថិរភាពនិងការអភិវឌ្ឍដោយចិរភាព ។

"យុទ្ធសាស្ត្រចតុកោណ" គឺជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី 3 នៃរដ្ឋសភា ដែលត្រូវបានយកមករៀបចំលម្អិតបន្ថែមដោយអន្លើ ហើយសម្រិតសម្រាំងនិងរំលេចឱ្យចេញជាកញ្ចប់អាទិភាពទៅតាមបណ្តាវិស័យសំខាន់នានា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងជាប្រព័ន្ធស៊ីសង្វាក់ប្រទាក់គ្នាទៅវិញទៅមក ហើយងាយយល់និងងាយគ្រប់គ្រង អនុញ្ញាតឱ្យរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលមានការពាក់ព័ន្ធទាំងអស់ អាចប្រើប្រាស់បានជា "ឧបករណ៍គ្រប់គ្រង" សម្រាប់ការអនុវត្តរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា ដែលជាសមាសភាគចម្បងនៃ "កម្មវិធីនយោបាយ" របស់រាជរដ្ឋាភិបាល ។



គំនូសបំព្រួញស្តីពី "យុទ្ធសាស្ត្រចតុកោណ"

## សំណួរ

1. កន្លងមក តើអ្នកធ្លាប់បានដឹង ឬឮព័ត៌មានណាមួយដែលពាក់ព័ន្ធនឹងកម្មវិធីជាតិសម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ដែរឬទេ ? ចូរអ្នកនិយាយប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម
   ក. តើកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍មានន័យយ៉ាងដូចម្ដេច ?
   ខ. តើការរៀបចំកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍ត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ ?
   គ. តើខ្លឹមសារសំខាន់ៗដែលត្រូវមាននៅក្នុងកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍មានចំនួនប៉ុន្មាន ? អ្វីខ្លះ ?
   ឃ. ដើម្បីទាក់ទាញការវិនិយោគ តើរដ្ឋត្រូវយកចិត្តទុកដាក់លើបញ្ហាអ្វីខ្លះ ?
   ង. តើហេតុអ្វីបានជារដ្ឋត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍជនបទ ?
   ច. តើយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលមានផ្អែកលើលក្ខខណ្ឌនៃការរៀបចំដែរឬទេ ? ចូរបង្ហាញ ។
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចសំខាន់ៗ ដើម្បីយកមកសរសេរផ្គុំគ្នាជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ចូរអ្នកស្រាវជ្រាវរកឯកសារ "យុទ្ធសាស្ត្រចតុកោណ"របស់រាជរដ្ឋាភិបាលកម្ពុជា ហើយធ្វើការសិក្សានិងបកស្រាយរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រនេះ ។

facebook.com/moeys.gov.kh
krou.moeys.gov.kh
youtube.com/moeys

# សំណួរបញ្ចប់ជំពូកទី២

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ**

1. ការវិភាគមីក្រូសេដ្ឋកិច្ច ជាការចាំបាច់សម្រាប់ស្វែងយល់យន្តការសំខាន់ៗរបស់

☐ ក. ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ☐ ខ. ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា

☐ គ. ប្រព័ន្ធសេដ្ឋកិច្ចចម្រុះទីផ្សារ ☐ ឃ. ប្រព័ន្ធសេដ្ឋកិច្ចចម្រុះផែនការ ។

2. ប្រសិទ្ធភាពនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ចស្ថិតនៅត្រង់

☐ ក. លក្ខខណ្ឌសេដ្ឋកិច្ចមានអំណោយផល

☐ ខ. ការផ្តល់ព័ត៌មានទាន់ហេតុការណ៍

☐ គ. ជោគជ័យលើការអនុវត្តគោលនយោបាយសេដ្ឋកិច្ច

☐ ឃ. ភាពរឹងមាំនៃរដ្ឋបាលសាធារណៈ ។

3. ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការធ្វើអន្តរាគមន៍របស់រដ្ឋមានទិសដៅ

☐ ក. ជំរុញការប្រកួតប្រជែងក្នុងទីផ្សារ ☐ ខ. ជួយបែងចែកទំនិញឱ្យដល់ដៃប្រជាពលរដ្ឋ

☐ គ. ទប់ស្កាត់ទំនិញនាំចូល ☐ ឃ. បំពេញភាពខ្វះចន្លោះនៃយន្តការទីផ្សារ ។

4. ចំណាយរបស់រដ្ឋាភិបាលនៃប្រទេសនានា ត្រូវបានប្រើប្រាស់លើ

☐ ក. ការពង្រីកទឹកដី ☐ ខ. ការពង្រីកកម្មសិទ្ធិឯកជន

☐ គ. ដើម្បីអភិវឌ្ឍប្រទេស ☐ ឃ. ការបោះឆ្នោតថ្នាក់ជាតិ ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ក្នុងការរៀបចំគោលនយោបាយផ្សេងៗ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ ឬជំរុញការងារផលិតកម្មសេវាកម្មនានា គេត្រូវមានការសិក្សាក្នុងមីក្រូសេដ្ឋកិច្ចនិង ..................................... ។

2. នៅគ្រប់សង្គម រដ្ឋមានតួនាទីសំខាន់ចំនួន .......... គឺជាអ្នកបង្កើត ......................... ការពារសន្តិសុខជូនប្រជាពលរដ្ឋ ជាម្ចាស់កម្មសិទ្ធិលើ .............................. និងជាអ្នកបង្កើត រៀបចំចាត់ចែង និងគ្រប់គ្រងស្ថាប័នសម្រាប់ ........................................................... ។

3. ក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីដោយប្រយោលនិងតួនាទីដោយ .......................... ។ តួនាទីដោយចំពោះរបស់រដ្ឋមានន័យថា ជាការ ................................. ជាពិសេសការជំរុញដំណើរការបង្កើនផលិតផលសង្គម តាមរយៈរោងចក្រ ឬសហគ្រាសរដ្ឋ ដែលប្រព្រឹត្តទៅមិននៅក្រោមឥទ្ធិពលនៃ ........................................................ ទេ ។

4. កំណើនផលិតកម្មជាកត្តាបង្កើន ....................................................... ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

5. ឱនភាពថវិកាកើតមាននៅពេលដែលចំណាយមានបរិមាណ .......................ជាងចំណូល ។

6. ភាពគ្មានការងារធ្វើ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរនិងមាន ..............យ៉ាងខ្លាំងដល់ ...........ទាំងមូល ។

**III. ចូរឆ្លើយសំណួរខាងក្រោម**

1. ដូចម្ដេចហៅថា ម៉ាក្រូសេដ្ឋកិច្ច ? ចូរពន្យល់ ។
2. តើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារដូចគ្នាដែរ ឬទេ? ហេតុអ្វី ?
3. តើវិស័យណាខ្លះដែលកំណត់ការលូតលាស់នៃសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជា ?
4. ក្នុងសេដ្ឋកិច្ចទីផ្សារ តើរដ្ឋមានតួនាទីអ្វីខ្លះ ? ចូររៀបរាប់ ។
5. ក្នុងករណីប្រព័ន្ធសេដ្ឋកិច្ចទីផ្សារត្រូវបានអនុវត្តនៅប្រទេសកំពុងអភិវឌ្ឍ តើរដ្ឋត្រូវប្រកាន់យកតួនាទីអ្វីខ្លះ ? ចូរពន្យល់ ។
6. ដូចម្ដេចហៅថា ចំណូលជាតិ ? តើចំណូលជាតិមានប្រភពពីណាខ្លះ ?
7. តើសកម្មភាពសេដ្ឋកិច្ចរដ្ឋនិងឯកជនមានទំនាក់ទំនងនឹងគ្នាដូចម្ដេច ? ចូរពន្យល់ ។
8. ដូចម្ដេចហៅថា ជាតូបនីយកម្ម ? តើជាតូបនីយកម្មមានប្រសិទ្ធភាព ឬអប្រសិទ្ធភាពយ៉ាងណាខ្លះដល់សេដ្ឋកិច្ចជាតិ ?
9. ដូចម្ដេចហៅថា ឯកជនូបនីយកម្ម ? តើឯកជនូបនីយកម្មមានប្រសិទ្ធភាព ឬអប្រសិទ្ធភាពយ៉ាងណាដល់សេដ្ឋកិច្ចជាតិ ?
10. ដូចម្ដេចហៅថា ប្រាក់បៀវត្ស ? ហេតុអ្វីបានជាកម្មករភាគច្រើនត្រូវការប្រាក់បៀវត្សអប្បបរមា ?
11. ដូចម្ដេចហៅថា វិបត្តិសេដ្ឋកិច្ច ? តើវាបង្កពីបញ្ហាអ្វី ?
    តើអ្វីទៅជាកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍន៍នៅកម្ពុជា ? ចូរពន្យល់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ជំពូកទី 3 ប្រវត្តិគំនិតសេដ្ឋកិច្ច



*ហ្សង់ បាបទីសាយ* ***(Jean Bapliste,Say)***



*តូម៉ាស រ៉ូបឺត ម៉ាល់ទុស* ***(Thomas Robert Mathus)***



*ចន ស្ទូអាដ មីល* ***(John Stuard Mill)***



*សង់ទីម៉ុង ដឺស៊ីសម៉ុងឌី* ***(Jean Simonde de Sismondi)***

នៅក្នុងជំពូកនេះ សិស្សសិក្សាគំនិតផ្តួចផ្តើមដំបូងអំពីសេដ្ឋកិច្ចរបស់សេដ្ឋវិទូមួយចំនួន ហើយនឹងអាចបកស្រាយបណ្តាគំនិតទាំងនោះបានត្រឹមត្រូវ ។

មេរៀនទី

# 1 បណ្តាគំនិតផ្តួចផ្តើមដំបូង

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ទស្សនៈ "ពាណិជ្ជកម្មតែងចៀសមិនផុតពីសេចក្តីមន្ទិល" ។
- រៀបរាប់ដំណើរធម្មានុរូបកម្មចំពោះផលលាភនៅស. វ. ទី 16 - 18 ។
- បង្ហាញគំនិតណាមួយក្នុងបណ្តាគំនិត ដែលមានភាពសមស្របនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន នៅប្រទេសកម្ពុជា ។

ប្រវត្តិគំនិតសេដ្ឋកិច្ចមិនអាចបំបែកចេញពីប្រវត្តិនៃព្រឹត្តិការណ៍នានាក្នុងប្រវត្តិសាស្ត្របាន ឡើយ ។ គេអាចយល់គំនិតសេដ្ឋកិច្ចទាំងឡាយបាន លុះត្រាណាដែលគំនិតទាំងនោះមានទំនាក់ទំនងនឹង ព្រឹត្តិការណ៍ដែលកើតមានកន្លងមក ហើយគំនិតទាំងនោះបានដោះស្រាយចំណោទបញ្ហានានាដែល កើតមានឡើងនិងម្យ៉ាងទៀត គេឃើញមានការឆ្លើយតបគ្នាក្នុងបណ្តាគំនិតទាំងនោះ ។ ហេតុនេះ យើង ត្រូវលើកយកមកសិក្សានូវព្រឹត្តិការណ៍ រួមទាំងគំនិតផ្សេងៗរបស់សេដ្ឋវិទូមួយចំនួនពីស. វ. ទី 16-18 ។

ក្នុងវិទ្យាសាស្ត្រសង្គម ការជជែកវែកញែកបណ្តាគំនិតទាំងឡាយដែលប្រឈមគ្នា តែងជួបការ លំបាកក្នុងការលើកយកគំនិតណាមួយជាគំរូ សម្រាប់ជកពិសោធ ឬអនុវត្តទៅថ្ងៃមុខ ពីព្រោះ លក្ខខណ្ឌទាំងឡាយរបស់សង្គមនានា មិនដែលមានលក្ខណៈដូចគ្នាទេ ឯហេតុការណ៍ទាំងឡាយកើត មានឡើងដោយកត្តាអត្តនោម័តនិងស្វយ័ត ។ ដូចនេះការសន្មតជាមុនអំពីព្រឹត្តិការណ៍ណាមួយថាវានឹង កើតឡើងយ៉ាងណាៗនោះមិនប្រាកដជាត្រឹមត្រូវទេ ពីព្រោះហេតុការណ៍នីមួយៗអាចនឹងមានការ ប្រែប្រួល ។ ក្រៅពីនេះ នៅក្នុងព្រឹត្តិការណ៍តែមួយ អ្នកសង្កេតការណ៍ទាំងឡាយ អាចវាយតម្លៃហេតុ ការណ៍ក្នុងប្រតិបត្តិនោះផ្សេងៗពីគ្នា អាស្រ័យទៅតាមនិន្នាការនិងទស្សនៈរៀងៗខ្លួន ។ ប៉ុន្តែ ការលើក យកមកសិក្សាបណ្តាគំនិតសេដ្ឋកិច្ចដែលមានទំនាស់ប្រឆាំងនឹងគ្នាដូចខាងក្រោមនេះ គឺដើម្បីធ្វើ ការវិនិច្ឆ័យតាមលក្ខណៈវិទ្យាសាស្ត្រនិងដើម្បីធ្វើការជ្រើសរើសយកគំនិតល្អយកមកពិចារណា និង អនុវត្តក្នុងសង្គមបច្ចុប្បន្នប៉ុណ្ណោះ ។

youtube.com/moeys
facebook.com/moeys.gov.kh
krou.moeys.gov.kh

## 1. ពាណិជ្ជកម្មតែងមានជាប់នូវភាពមន្ទិល

គំនិតដែលគ្របដណ្តប់មជ្ឈិមសម័យ ជាគំនិតរបស់ព្រះ ជាមរតកទស្សនវិស័យរបស់ទស្សនវិទូក្រិក ។ ប៉ុន្តែការភាន់ប្រែបានកើតមានឡើងម្តងៗនៅស.វ.ទី 17 និងទី 18 ដូចជាការហក់ឡើងនៃពាណិជ្ជកម្មទីក្រុង ឈ្មួញនិងការយកចំណេញហួសប្រមាណ ការរានដីថ្មីនិងដំណើរថយចុះនៃទាសភាពនិងបាតុកម្មដំបូងអំពីគំនិតគ្រហស្ថនិងវិទ្យាសាស្ត្រ ។

សម្តេចប៉ាប ក្នុងជំនាន់ស្តេច គ្រេហ្គ័រទី 7 (Gregoire VII) បានប្រកាន់យកលទ្ធិមួយ "បញ្ហាសីលធម៌ត្រូវមានជាប់ជាមួយនឹងការធ្វើពាណិជ្ជកម្ម ការកាន់កាប់ទ្រព្យកម្មសិទ្ធិ ការរកប្រាក់ចំណេញ ការឱ្យខ្ចីដើម្បីយកការប្រាក់ជាដើម" ។ គំនិតទាំងនេះ ត្រូវបានចងក្រងដោយលោក សាំងតូម៉ាស ដាកាំង (1235-74) នៅក្នុងនិក្ខេបទរបស់លោកឈ្មោះ "ចំនួនប្រាក់របស់អាទិទេព" ។ ចំណុចចាប់ផ្តើមនៃគំនិតទាំងនោះគឺ "ភាពមន្ទិលដែលមាននៅក្នុងសញ្ញាណនៃទ្រព្យកម្មសិទ្ធិបុគ្គលនិងលាភ" ។

ផ្ទុយពីគំនិតរបស់លោកប្លាតុង លោកអារីស្តូតបានបដិសេធការកាន់កាប់ជាសមូហភាពលើទ្រព្យកម្មសិទ្ធិ ប៉ុន្តែលោកដាក់កំហុសការរែអង្គាសគ្មានព្រំដែនដើម្បីភាពមានបាន ការធ្វើជំនួញ កិច្ចការខាងហិរញ្ញវត្ថុ ដែលលោកប្រៀបប្រដូចទៅនឹង "បាបធម៌" ។



លោកសាំងតូម៉ាសដាកាំង បានអះអាងពីសារៈសំខាន់នៃកម្រងលទ្ធិដែលបានលើកឡើងថា "អ្នកលក់តែងចំណាយកម្លាំងរបស់ខ្លួន ដើម្បីប្រាក់ចំណេញ ដែលមានន័យប្រហាក់ប្រហែលគ្នានឹង **ការលោភលន់មាននៅក្នុងចិត្តប្រជាពលរដ្ឋ** ។ ការកាន់កាប់ទ្រព្យកម្មសិទ្ធិ ត្រូវទទួលស្គាល់ដោយច្បាប់ ពីព្រោះម្ចាស់កម្មសិទ្ធិតែងយកចិត្តទុកដាក់ខ្លាំងបំផុតក្នុងការរក្សាសម្បត្តិផ្ទាល់ខ្លួនរបស់គេ ។ ប៉ុន្តែម្ចាស់កម្មសិទ្ធិរីកចម្រើនបានដោយសារ "ទាន" មិនមែនដោយសារការវិនិយោគទេ(ផ្ទុយពីលទ្ធិកាល់វ៉ាំង) ។

ដើម្បីសម្របសម្រួលគ្នារវាងសីលធម៌និងពាណិជ្ជកម្ម គេត្រូវប្រកាន់ខ្ជាប់នូវចេតនា :

**ប្រសិនបើពាណិជ្ជករប្រាថ្នាផ្គត់ផ្គង់សេចក្ដីត្រូវការរបស់គាត់ ឬប្រាថ្នាចែកចាយធនធានរបស់គាត់ដល់អតិថិជន សកម្មភាពទាំងនោះមានការគាំទ្រដោយច្បាប់ ។ ប៉ុន្តែ ពាណិជ្ជករត្រូវតែមានការប្រើប្រាស់"ថ្លៃត្រឹមត្រូវ" ចំពោះអ្នកដែលមិនស្វះស្វែងទាញយកផលប្រយោជន៍ពីសេចក្ដីត្រូវការរបស់ខ្លួន ពោលគឺអ្នកទិញ ។ "**

## 2. ការធ្វើធម្មានុរូបកម្មធនលាភ (ពីស.វ.ទី 16-18)

### 2.1. ពាណិជ្ជនិយម

អ្នកពាណិជ្ជវិស័យនិយមនៅប្រទេសបារាំងមានលោកហ្សង់បូដាំង (Jean Bodin 1530 - 96) លោករីឆាតកង់ទីយ៉ុង (Richard Cantillon 1680 - 1733) លោកកុលប៊ែ (Colbert 1619 - 83) លោកអង់តនដឺម៉ុងក្រេសជាង (Antoine de Montchrestien 1575 - 1621) ។ នៅប្រទេសអង់គ្លេស មានលោកតូម៉ាសមុន (Thomas Mun XVII) លោកវិល្យាំប៉ិទី (William Petty 1623 - 87) និងនៅប្រទេសអេស្ប៉ាញមានលោកល្វីអទី (Luis Ortiz) ។

នៅស.វ.ទី 15 និង 16 ពាណិជ្ជកម្មត្រូវគេទទួលស្គាល់ថាជាសន្ទុះលូតលាស់ ឬជាការរកឃើញដ៏មហិមានៃបដិវត្តន៍សេដ្ឋកិច្ចនិងទស្សនវិស័យនៃពិភពលោកនាសហសម័យ ។ រីឯបដិវត្តន៍សិល្បៈនិងបដិវត្តន៍បញ្ញាញាណ ក៏មានដំណើរលូតលាស់ស្របគ្នាដែរ មានដូចជា បុនវុឌ្ឍិ ការលេចឡើងឥរិយាបថវិទ្យាសាស្ត្រ ការបញ្ចូលបច្ចេកទេសថ្មី ការកើតមានភ្លាមៗនូវឧស្សាហនីយកម្មដំបូង (ការផលិតក្នុងបរិមាណច្រើននៅក្នុងរោងសិប្បកម្មតាមជនបទ តាមការគិតរបស់ពាណិជ្ជករ-ផលិតករ) ។ ក្រុមគ្រួសារគហបតីធំៗ ដូចជាគ្រួសារ វូគឺ (Fugger) មេឌីស៊ី (Medicis) ជាដើម មានអំណាចដ៏ធំធេងនៅអឺរ៉ុប ក្នុងឋានៈជាអ្នកគ្រប់គ្រងដែលមានប្រាក់ច្រើនបំផុត ។

ពាណិជ្ជវិស័យនិយម មានកំណើតឡើងរួមគ្នាជាមួយអាណានិគមនិយមនៃពិភពលោកថ្មី ។ ពាណិជ្ជវិស័យនិយមបង្ហាញឱ្យឃើញនូវវិធានការប្រតិបត្តិច្រើនជាងវិធានការទ្រឹស្តី ។ ផ្ទុយពីអ្នកធម្មតា

ជាធិបតេយ្យនិងអ្នកតន្ត្រីនិយមដែលមានមហិច្ឆតារីករាយនឹងសណ្ដាប់ធ្នាប់របស់ធម្មជាតិនៅក្នុងសម័យរាជានិយមផ្ដាច់ការ អ្នកពាណិជ្ជវិស័យនិយមបានមើលឃើញសេដ្ឋកិច្ចថា ជាវិទ្យាសាស្ត្រនៃកិច្ចការរបស់រាជាធិរាជដែលមាន "គំនិតរដ្ឋ" ជាមគ្គុទ្ទេសក៏ជាន់ខ្ពស់ ។ មាស មានភាពសម្បូរនៅស.វ.ទី 16 ដោយសារនាវាដឹកទំនិញរបស់ជនជាតិអេស្ប៉ាញនិងព័រទុយកេស ។ មាសត្រូវបានរំលាយធ្វើជាដើមទុនរបស់គហបតីធំៗនៅខេត្តផ្លង់ (Flandres) ប្រទេសបារាំង និងប្រទេសអង់គ្លេស ។ នយោបាយពាណិជ្ជវិស័យនិយមកើតមានជាដំបូងចំពោះពាណិជ្ជកម្មក្រៅប្រទេស ។ អំណាចនៃរាជាណាចក្រក្នុងការកេណ្ឌទ័ពបានផ្អែកលើមាសដែលគេទាញយកបានតាមរយៈការនាំចេញ ឬតាមរយៈរបបអាណាព្យាបាលនិយម ។



*សំពៅឆ្លងសមុទ្រ*

ភាពមានបានសំដៅលើមាស

- រាជាធិរាជត្រូវពឹងផ្អែកលើវណ្ណៈវេស្សៈ នេះជាភាពផ្លាស់ប្ដូរមួយខុសពីសម័យមុនដែលរាជាធិរាជបានពឹងផ្អែកលើពន្ធដីធ្លី ។ ដូចនេះហើយ ព្រះរាជានៃប្រទេសបារាំងបានជ្រើសរើសពួកគហបតីជាពិសេសពាណិជ្ជករធំៗមាន កុលប៊ែជាដើមឱ្យធ្វើជារដ្ឋមន្ត្រី ។

- ផលិតកម្មត្រូវបានលើកទឹកចិត្តឱ្យមានការនាំចេញ ដើម្បីនាំមកវិញនូវលោហធាតុមានតម្លៃ ។ អ្នកតំណាងនយោបាយផលិតកម្មអាណានិគមមាសមានអ្នកពាណិជ្ជវិស័យនិយមអ្នកឧស្សាហ-កម្មនិយម និងអ្នកដើរតាមពាណិជ្ជករកុលប៊ែ ។ ប្រទេសបារាំងមាននយោបាយនេះតែមួយមុខគត់ ហើយមិនមានអ្វីក្រៅពីនេះទេ ។ កម្មន្តសាលទាំងឡាយរបស់រដ្ឋ ការផ្តល់ឯកសិទ្ធិ និងការទំនុកបម្រុងកម្មន្តសាលឯកជនរបស់ព្រះរាជា ក្រុមហ៊ុនពាណិជ្ជកម្ម នាវាជំនួញ សំណង់ធារាសាស្ត្រ និងផ្លូវគមនាគមន៍ សុទ្ធសឹងជាសមិទ្ធផលគាំទ្រដោយពាណិជ្ជវិស័យនិយម ។
- របបអាណាព្យាបាលនិយមដែលមានបំណងអភិរក្សមាស ត្រូវបានអួតបង្ហាញដោយអ្នកពាណិជ្ជវិស័យនិយមជាតិអេស្ប៉ាញ ឬជាតិព័រទុយកេស ។ មាសពីប្រទេសទាំងឡាយត្រូវបានជន្លៀសទៅទិសខាងជើងដោយមន្ត្រីធំៗនៃព្រះរាជាណាចក្រដែលបានទិញពីក្រៅប្រទេស ។ របបនេះហៅថា "*របបជុំមាស*" ។
- អតិផរណានៅស.វ.ទី 16 ត្រូវបានបកស្រាយថាបណ្តាលមកពី "ការជន់ជោរនៃមាស" ។ លោកសង់ បូដាំង (Jean Bodin) និងរីឆាតកង់ទីយ៉ុង (Richard Cantillon) រួមជាមួយទស្សនវិទូ ដេវីដ ហ៊ូម (David Hume) គឺជាអ្នកបរិមាណនិយមមុនគេ ។ តាមទស្សនៈរបស់លោកទាំងនោះ "ថ្លៃ" វិវដ្តតាមអនុគមន៍ច្រាសទៅនឹងបរិមាណនៃមាស ។ សម្បូរភាពនៃរូបិយវត្ថុបង្កើតឱ្យមានអតិផរណាដោយសារមនុស្សទាំងអស់គ្នាមានសេចក្តីរីករាយនឹងការឡើងថ្លៃនៃដីនិងពន្ធ ដែលនាំទៅរកស្ថានភាពទំនិញឡើងថ្លៃ ប្រាក់ចុះថោក ។
- ទុនសំខាន់នៃអ្នកពាណិជ្ជវិស័យនិយម ស្ថិតនៅលើការដំឡើងថ្លៃក្នុងពាណិជ្ជកម្មនិងក្នុងការលួតលាស់នៃ "ឧស្សាហកម្ម"(នៅសម័យនោះ ឧស្សាហកម្មមានន័យថាផលិតកម្មមុខរបរ) ។ ប៉ុន្តែនិក្ខេបទដែលបកស្រាយទស្សនៈនេះ ត្រូវបានប្រមាថដោយអ្នកនិយមសម្ភារៈជាងវិចារណញ្ញាណ ដើម្បីបំពេញចិត្តពាណិជ្ជករ ។ អ្នកពាណិជ្ជវិស័យនិយម គឺជាអ្នកអន្តរាគមន៍និយម ។ ព្រះរាជាត្រូវតែជាអ្នកដាក់បទបញ្ជា កំណត់ពន្ធអាករ ត្រួតពិនិត្យចរាចរណ៍ផលិតផល ។ អ្នកពាណិជ្ជវិស័យនិយមមិនមានលក្ខណៈដាច់ខាតដោយសារគេបានទទួលទណ្ឌកម្មហិង្សាពីចលនាសេរីនិយមតាំងពីពេលនោះមក ។ ដូចនេះហើយ នយោបាយសេដ្ឋកិច្ចរបស់គេ គឺដើម្បីបង្កើនប្រាក់ចំណេញ ។ គេបានស្គាល់គោលរឿងនៃពាណិជ្ជវិស័យនិយមយ៉ាងជាក់លាក់តាមរយៈអ្នកនិយមគំនិតលោកកេន (អ្នកកេននិយម) ។

## 2.2. សេរីភាពនៃពាណិជ្ជកម្ម

អ្នកធម្មជាតាធិបតេយ្យមានលោកប្រង់ស្វា កេសណាយ (Francois Quesnay 1694 - 1774) លោកវិកទ័រ មីរ៉ាបូ (Victor Mirabeau 1715 - 1789) លោកព្យែឌុយប៉ុងដឺណឺមួរ (Pierre dupont de Nemours 1739 - 1817) លោកអាន រ៉ូប៊ែរ ទួកូ (Anne Robert Turgot 1727 - 1781) ។



ផលិតកម្មក្នុងកសិកម្មនិងផលិតកម្មក្នុងសិប្បកម្ម

អ្នកធម្មជាតាធិបតេយ្យមើលឃើញសង្គមមានវណ្ណៈបីគឺ វណ្ណៈអ្នកម្ចាស់ដី វណ្ណៈអ្នកផលិត (អ្នកស្រែចម្ការ) និងវណ្ណៈអ្នកមិនផលិត (សិប្បករ សិល្បករ ពាណិជ្ជករ ...) ។ អ្នកស្រែចម្ការបង្កើតភាពសម្បូរធនធានសម្រាប់ខ្លួនឯងផង សម្រាប់អ្នកដទៃផង ។ អ្នកម្ចាស់ដីកាត់យកផលិតផលមួយភាគពីអ្នកស្រែចម្ការ ។ សិប្បករក៏ដូចជាពាណិជ្ជករ ពួកគេធ្វើការ ប៉ុន្តែពួកគេមិនមែនជាអ្នកផលិតទេ ពីព្រោះពួកគេមិនបានបង្កើនភាពសម្បូរធនធានដែលកើតមកអំពីដី ។ លោកមីរ៉ាបូបានសរសេរថា “ដីជាមាតានៃទ្រព្យទាំងអស់” ។

ទ្រឹស្តីជាទុនរបស់អ្នកធម្មជាតាធិបតេយ្យ ត្រូវបានគេយកមកគិតពិចារណា ។ តារាងសេដ្ឋកិច្ចរបស់លោកប្រង់ស្វាកេសណាយ (Francois Quesnay 1694 - 1774) គឺជាទស្សនវិស័យដំបូងបង្អស់ចំពោះពិភពលោកអំពី “ការផ្លោះប្តូរគ្នារវាងភ្នាក់ងារទាំងឡាយ” ។ តារាងនេះ បានបង្ហាញពីចរាចរណ៍នៃផលិតផលដើមរបស់កសិកម្ម ពោលគឺផលិតផលសម្រាប់ផ្គត់ផ្គង់កម្មករនិងបម្រុងធ្វើពូជ ។ តារាងបានបង្ហាញបណ្តាអ្នកមកពីវណ្ណៈនីមួយៗដែលពឹងផ្អែកលើធនធានផលិតដោយវិស័យកសិកម្ម បន្ទាប់ពីមានការទូទាត់រួចរាល់នូវចំណាយជាមុនរបស់វណ្ណៈផលិតករ ។ ការបង្ហាញនេះ ជាបុព្វបទនៃគណនេយ្យសេដ្ឋកិច្ច ឬគណនេយ្យជាតិ ។ ទស្សនវិស័យនេះ មានលក្ខណៈជឿងលឿន ព្រោះថាមានការរំលោះដើមទុននិងការបង់ជាមុនចំពោះសំណើកនៅក្នុងដំណើរការផលិតកម្មត្រូវបានបង្ហាញនៅក្នុងវិចារនពន្ធ ។ ការវិនិយោគទុន ប្រៀបបាននឹងចលករនៃការចម្រើនលូតលាស់ ។

ការវិនិយោគបង្ហូរភាពមានបានមកពីវណ្ណៈផលិតករនិងវណ្ណៈម្ចាស់ដី ៖

“ការងារកសិកម្មបង់សោហ៊ុយចំពោះសំណើក បង់ថ្លៃហត្ថពលកម្មនៃវប្បធម៌ ផ្តល់ចំណូលដល់កសិករ ហើយជាងនេះទៅទៀត គឺផ្តល់ផលទុននៃមូលនិធិទ្រព្យ (ដី-ផ្ទះ) ។ អ្នកដែលទិញរបស់របរឧស្សាហកម្មចេញថ្លៃសំណើក បង់ថ្លៃហត្ថពលកម្ម និងផ្តល់ប្រាក់ចំណេញដល់ពាណិជ្ជករ ប៉ុន្តែរបស់របរទាំងនោះ មិនផ្តល់ផលទុនហួសពីនេះទេ” ។ ប៉ុន្តែអ្នកធម្មជាតាធិបតេយ្យ ក៏ជាអ្នកផ្តួចផ្តើមដំបូងនៃរបបសេរីនិយមផងដែរ ។ អ្នកធម្មជាតាធិបតេយ្យប្រឆាំងចំពោះពាណិជ្ជវិស័យនិយម ដោយធ្វើការទិតៀនរបបនយននិយមនិងការមិនយកចិត្តទុកដាក់ចំពោះវិស័យកសិកម្ម ពីព្រោះតែការរវល់ហួសហេតុនឹងកិច្ចការក្រៅប្រទេស ។ ការទាមទាររបស់អ្នកធម្មជាតាធិបតេយ្យគឺ “សេរីភាពនៃពាណិជ្ជកម្មធញ្ញជាតិ”ដោយហេតុថាថ្លៃធញ្ញជាតិតែងបានឡើងខ្ពស់នៅពេលខ្វះត់ម្តងៗ បើទោះជាពេលនោះគេអាចទប់ទល់បានដោយការនាំចូលដ៏ជោរជន់មកពីប្រទេសក្រៅ ឬមកពីបណ្តាខេត្តផ្សេងៗក៏ដោយ ។

នៅចន្លោះឆ្នាំ 1764 និង 1789 កំណែទម្រង់ទៅរកភាពទំនើបជាបន្តបន្ទាប់ក្នុងវិស័យកសិកម្មត្រូវបានគាំទ្រពីអ្នកធម្មជាតាធិបតេយ្យទាំងឡាយ ។ ប៉ុន្តែក្នុងបណ្តាអ្នកទាំងនោះ លោក ទួកូ (Turgot) ត្រូវបានឃាត់ខ្លួននៅឆ្នាំ 1774 និងបណ្តេញចេញនៅឆ្នាំ 1776 ពីកិច្ចសហការ ក្រោមការគាបសង្កត់ពីអ្នកប្រឆាំងរបស់គាត់ ។

## 3. សេចក្តីសន្និដ្ឋាន

ផលិតកម្មប្រឈមនឹងពាណិជ្ជកម្ម សេរីនិយមប្រឈមមុខនឹងរបបនយននិយមនិងការហួតពន្ធ អ្នកធម្មជាតាធិបតេយ្យប្រឈមមុខនឹងអ្នកពាណិជ្ជវិស័យនិយម តែថាការតស៊ូរបស់ពួកគេទាំងអស់គ្នាគឺដើម្បីសេរីភាពខាងសេដ្ឋកិច្ច ។ នៅទីបំផុត ការតស៊ូរបស់អ្នកនិយមខាងនិកាយពន្លឺនិងខាងនិកាយសេរីនិយមដែលប្រឈមមុខនឹងលទ្ធិផ្តាច់ការនិងគំនិតរបស់រដ្ឋ ក៏នឹងបានជួបគ្នានៅលើផ្លូវតែមួយ ។

## សំណួរ

1. នៅពេលទិញទំនិញនៅទីផ្សារ អ្នកទិញតែងតែចង់តថ្លៃ ទោះបីទំនិញនោះ គេកំណត់ថ្លៃហើយក៏ដោយ ។ តាមការគិតរបស់អ្នកហេតុអ្វីបានជាអ្នកទិញចេះតែចង់តថ្លៃទំនិញមុននឹងទិញ ?
2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម
   ក. ពាណិជ្ជកម្មតែងចៀសមិនផុតពីភាពមន្ទិល ។ តើគំនិតនេះមានន័យដូចម្ដេច ?
   ខ. សម្ដេច ប៉ាបក្នុងជំនាន់ស្ដេច គ្រេហ្គ័រទី 7 (Gregoire VII) បានប្រកាន់យកលទ្ធិមួយ "បញ្ហាសីលធម៌ត្រូវមានជាប់ជាមួយនឹងការធ្វើពាណិជ្ជកម្ម ការកាន់កាប់ទ្រព្យកម្មសិទ្ធិ ការរកប្រាក់ចំណេញ ការឱ្យខ្ចី ដើម្បីយកការប្រាក់"ជាដើម ។ តើលទ្ធិនេះមានន័យដូចម្ដេច ?
   គ. តើលោកអារីស្តូតប្រើពាក្យ "បាបធម៌" នៅពេលនិយាយពីអ្វី ? ហើយមានអត្ថន័យដូចម្ដេច ?
   ឃ. "អ្នកលក់តែងចំណាយកម្លាំងរបស់ខ្លួនដើម្បីទទួលបានប្រាក់ចំណេញ" តើគំនិតនេះ មានន័យដូចម្ដេច ? ចូរពន្យល់ ។
   ង. តើលោកសាំងតូម៉ាសដាកាំង មានទស្សនៈយ៉ាងណាចំពោះបញ្ហាទ្រព្យកម្មសិទ្ធិ ?
   ច. តើនៅស.វ.ទី 15 និងទី 16 មានការលើកឡើងអំពីមន្ទិលក្នុងពាណិជ្ជកម្មដែរឬទេ ? ហេតុអ្វី ?
   ឆ. ចូរអ្នករៀបរាប់ព្រឹត្តិការណ៍និងគំនិតនៃអ្នកពាណិជ្ជនិយម ។
   ជ. "ភាពសម្បូរដោយធនធានកើតមានមកអំពីជីនិងសេរីភាពនៃពាណិជ្ជកម្ម" តើគំនិតនេះ មានន័យយ៉ាងដូចម្ដេច ? ចូរពន្យល់ ។
3. ចូរអ្នកអានអត្ថបទខាងលើដោយយកចិត្តទុកដាក់ រួចហើយដកស្រង់ចំណុចទាំងឡាយណាដែលអ្នកគិតថាសំខាន់ ដើម្បីកត់ត្រាទុកជាមេរៀនសង្ខេបរបស់អ្នក ។

### ប្រតិបត្តិ

ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសមួយ ក្នុងបណ្ដាទស្សនៈរបស់អ្នកធម្មជាតាធិបតេយ្យនិយមនិងអ្នកពាណិជ្ជនិយម តើទស្សនវិស័យណាមួយដែលមានភាពសមស្រប ? ចូរពន្យល់និងផ្ដល់ឧទាហរណ៍ ។

**មេរៀនទី**

# 2 បណ្ដាគំនិតតន្ដី

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់បណ្ដាគំនិតជាមូលដ្ឋាននៃលទ្ធិតន្ដីនិយម ។
- ❑ បង្ហាញនិងបកស្រាយគំនិតផ្សេងៗទៀតដែលបែកចេញពីនិកាយតន្ដី ។
- ❑ បកស្រាយនិងបង្ហាញការគាំទ្រ ឬមិនគាំទ្រចំពោះគំនិតនីមួយៗ ។



*អាដាំស្ម៊ីត (Adam Smith)*



*ដាវីដ រីកាដូ (David Ricardo)*

បដិវត្តន៍ឧស្សាហកម្មមានប្រភពពីទស្សនវិស័យពីរអំពីគំនិតតន្ដីគឺ ទីមួយ គំនិតតន្ដីនាំមកនូវគំរូបែបផែនផលិតកម្មថ្មីនៃបដិវត្តន៍ឧស្សាហកម្ម និងទីពីរគំនិតតន្ដីបង្កើតកម្មវិធីដំបូងអំពីការទាមទារសិទ្ធិសេរីភាពរបស់បណ្ដាសហគ្រិន ។

## 1. បណ្ដាគោលការណ៍ជាមូលដ្ឋាន

ជាទូទៅ គេចាត់ទុកលោក អាដាំស្ម៊ីតជាបិតាបង្កើតសេដ្ឋកិច្ចនយោបាយ ប៉ុន្ដែលោកមិនមានភាពប្រាកដនិយមដូចអ្នកសេដ្ឋកិច្ចដទៃទៀតមានដូចជា កេសណៃ (Quesnay) ប៊ិនថាម (Bentham) ឬហ៊ីម (Hume) ដែលគេបានប្រកាសគោលការណ៍របស់គេ(មានដូចជាលទ្ធិប្រយោជន៍និយម ចរាចរណ៍សេរី បរិមាណនិយម ...) ។ ចំណែកឯក្នុងបណ្ដាអ្នកតន្ដីនិយម គេរកឃើញនូវបទបង្ហាញជាប្រព័ន្ធមួយស្ដីពីបញ្ញត្តិសេដ្ឋកិច្ច(របស់ម៉ាល់ទុស រីកាដូ និងសាយ)និងបណ្ដានិក្ខេបបទសេរីនិយម បន្ថែមលើគំនិតថ្មីជាច់ខាត ។ ភាគច្រើននៃអ្នកសេដ្ឋកិច្ចនិយាយថា "អ្នកតន្ដីនិយម"ជួបគ្នាលើលទ្ធិសេរីនិយមមួយដែលនឹងនាំយកមកនូវរូបសំណាកពិសេសមួយនៃលទ្ធិមូលធននិយមផ្លូវការ ។

youtube.com/moeys
krou.moeys
facebook.com/moeys.gov.kh

## 1.1. សកលភាពនៃច្បាប់

ក្នុងលោកនេះ មានសណ្តាប់ធ្នាប់ធម្មជាតិមួយដែលធ្វើឱ្យច្បាប់ទាំងឡាយមានលក្ខណៈសកល ។ ភារកិច្ចរបស់អ្នកប្រាជ្ញគឺបកស្រាយទ្រឹស្តីច្បាប់ទាំងឡាយ ដោយឯករាជ្យទៅតាមឆន្ទៈដែលចង់ឱ្យសង្គមមានសុខសន្តិភាព ។

## 1.2. សុទិដ្ឋិនិយមរកប្រយោជន៍

មនុស្សទាំងឡាយមានឥរិយាបថជាអ្នកបង្កើតសុទិដ្ឋិនិយមរកប្រយោជន៍ពោលគឺ ខិតខំបង្កើតឱ្យបានជាអតិបរមានូវផលប្រយោជន៍(ប្រាក់ចំណេញ)និងបន្ថយឱ្យបានជាអប្បបរមានូវការខាតបង់(ថ្លៃ) ។ ដើម្បីបានដូចនេះ មនុស្សត្រូវមានការយល់ដឹងអំពីទ្រឹស្តីទីផ្សារ ។

## 1.3. ភាពស្វ័នត្ថនាំទៅរកការរីកចម្រើន

អាស្រ័យដោយអន្តរាគមន៍ទីផ្សារ ផលប្រយោជន៍ទូទៅបានហូរចែកទៅជាផលប្រយោជន៍តាមផ្នែកៗ ។ ប្រសិនបើម្នាក់ៗរត់តាមផលប្រយោជន៍ឯកជន ដៃអរូបដែលធានារៀបសម្រួលរវាងការផ្គត់ផ្គង់និងតម្រូវការនិងធានាបាននូវភាពប្រសើរឡើងជាទូទៅ ។ នៅសម័យលោក ស្ម៊ីត លោក អរិល ហេប្រូណេ (R.L.Heil Broner) បាននិយាយថា "បុព្វហេតុស្វ័នត្ថរបស់មនុស្សបាននាំល្បែងអន្តរកម្មរបស់ពួកគេទៅរកលទ្ធផលដែលទាំងអស់គ្នាមិនបានទន្ទឹងរង់ចាំគឺ ភាពសុខដុមនៃសង្គម" ។ ដើម្បីភាពមានបាន អ្នកលក់ម្នាក់ត្រូវលក់ទំនិញដែលមានគុណភាពខ្ពស់បំផុតក្នុងតម្លៃសមរម្យជាទីបំផុត ។ ទង្វើនេះនាំទៅរកការរីកចម្រើន ។

## 1.4. សេរីភាពនៃពាណិជ្ជកម្មនិងសហគ្រាស គឺជាលក្ខខណ្ឌនៃភាពសម្បូរធនធាន

តាមពាក្យបញ្ញើបែបធម្មជាតាធិបតេយ្យ "ចូរទុកឱ្យគេធ្វើចុះ ចូរទុកឱ្យគេដើរចុះ" បង្កើតនូវគោលជំនឿបែបតន្ត្រីនិយម ។ និក្ខេបបទសេរីនិយម ត្រូវបានបង្កើតឡើងដោយប្រឈមមុខនឹងលទ្ធិផ្តាច់ការនិយមនិងលទ្ធិអន្តរាគមន៍និយមរបស់ពាណិជ្ជករ ។ លោកអាដាំស្ម៊ីត អ្នកបង្ហាញរដ្ឋដែលតូចបំផុត ឬរដ្ឋយោធាដែលបែងចែកខ្លួនជាបួនវិស័យគឺ វិស័យការពារខាងក្រៅ វិស័យសន្តិសុខផ្ទៃក្នុង(មន្ត្រីយុត្តិធម៌ ប៉ូលីស) សម្បត្តិសាធារណៈ(គ្រឹះស្ថានអប់រំ ផ្លូវគមនាគមន៍ ...) និងវិស័យការពារការប្រឡងប្រជែង ។

facebook.com/moeys.gov.kh youtube.com/moeys

## 1.5. ការរីកចម្រើនកើតឡើងពីការបែងចែកការងារ

ក្នុងឧទាហរណ៍ដ៏ល្បីល្បាញអំពីផលិតកម្មម្ជុលបារាំង លោកស្ម៊ីត បានបង្ហាញថា ប្រសិនបើភារកិច្ចរបស់មនុស្សម្នាក់ៗមានភាពចាំបាច់ក្នុងការផលិតម្ជុលបារាំងមួយ ផលិតភាពនឹងកើនឡើងកាលបើកម្មករម្នាក់ៗមានទំនុកចិត្តលើគ្នាទៅវិញទៅមកដោយការបែងចែកការងារដោយច្បាស់លាស់ តួយ៉ាងដូចជា កម្មករម្នាក់បង្វិលបូប៊ីន កម្មករម្នាក់ទៀតលើកទ្រខ្សែលោហៈ អ្នកទីបីកាត់ខ្សែលោហៈនោះ អ្នកទីបួនសម្រួចម្ជុល អ្នកទីប្រាំដាក់ក្បាលម្ជុលជាដើម ។ ក្នុងមួយថ្ងៃកម្មករ 10 នាក់ អាចផលិតម្ជុលបារាំងបាន 48000 ដើម បើគិតជាប្រអប់ ម្នាក់ៗនឹងមិនផលិតឱ្យហួសពី 20 ប្រអប់ឡើយ ។ នេះគឺអ្វីដែលសព្វថ្ងៃគេហៅថា ផលនៃផលិតភាព ។ ផលនៃផលិតភាពកើតចេញពី

- "ជំនាញ" ដែលកើតមានកាន់តែខ្ពស់ ដោយសារម្នាក់ៗបង្កើនឯកទេសក្នុងភារកិច្ចតែមួយមុខ ។
- "ផលនៃពេលវេលា" ដែលកើតមានដោយពិតប្រាកដ ដោយម្នាក់ៗលុបចោលនូវការទុកចោលភារកិច្ចរបស់ខ្លួនទៅឱ្យអ្នកដទៃ ។
- "សមត្ថភាពផ្តួចផ្តើម" គឺជាគំនិតដែលមានសារៈសំខាន់ជាទីបំផុត ។

## 1.6. ការបែងចែកពលកម្មជាអន្តរជាតិ អាចជាការផ្តល់ផលចំណេញសម្រាប់ទាំងអស់គ្នា

ដោយអនុវត្តតាមទ្រឹស្តីអំពី "ផលចំណេញ" ឬអំពី "ថ្លៃធៀប" លោករីកាដូបានបង្កើនផលចំណេញចេញអំពីឯកទេសកម្មក្នុងផលិតកម្មដែលជួនកាលកាន់តែកើនឡើង ជួនកាលថយចុះ ។ ម្យ៉ាងវិញទៀត ប្រទេសមួយអាចបង្កើនភាពសម្បូរធនធានបាន ដោយសារប្រទេសនោះទទួលបានតម្លៃផ្លោះប្តូរមួយដែលមានតម្លៃធំជាងតម្លៃដែលរកបានពីការផលិតដោយខ្លួនឯង ។

## 1.7. ភាពសម្បូរធនធានទាំងអស់កើតចេញពីពលកម្ម

ថ្លៃនៅលើទីផ្សារបានជួបនឹងថ្លៃធម្មជាតិ ដែលជាផលនៃបរិមាណតម្លៃប្រមូលបានពីបរិមាណពលកម្ម ។ តម្លៃពលកម្ម ជាចំណុចរួមតែមួយនៃផលិតផលទាំងអស់ ដែលគេអាចមើលឃើញនូវតម្លៃផ្លោះប្តូរតាមរយៈការប្រៀបធៀបគ្នារវាងផលិតផលនានា ។ ប៉ុន្តែ តម្លៃប្រើប្រាស់របស់ផលិតផលមានលក្ខណៈជាក់លាក់សម្រាប់វត្ថុនីមួយៗ ។ វាបង្ហាញពីផលប្រយោជន៍ មិនមែនបង្ហាញពីថ្លៃសម្រាប់ប្តូរផ្លោះឡើយ ។ ***ឧទាហរណ៍*** ផលប្រយោជន៍នៃកៅអីមួយមិនអាចទូទាត់នឹងពហុភាពនៃផលប្រយោជន៍របស់នំប៉័ងមួយបានឡើយ ប៉ុន្តែថ្លៃកៅអីអាចធៀបគ្នាបានជាមួយថ្លៃនំប៉័ង ដោយសារវាមានចំណុចរួមមួយ គឺតម្លៃពលកម្ម ។

## 1.8. អ្នកតន្ត្រីនិយមមើលឃើញថាសង្គមជាសំណុំនៃវណ្ណៈបី(វណ្ណៈម្ចាស់ដី វណ្ណៈមូលធននិយម និងវណ្ណៈកម្មករ)

ការមើលឃើញបែបនោះ ផ្អែកលើការសម្គាល់បានទីតាំងខុសគ្នារបស់វណ្ណៈទាំងបីនៅក្នុងផលិតកម្មហើយនិងភាពខុសគ្នាតាមសភាពធម្មជាតិនៃចំណូលរបស់គេ។ លោករីកាដូ បានស្ទើបង្កើតបញ្ញត្តិ "វណ្ណៈ" ឱ្យកាន់តែមានលក្ខណៈទូលំទូលាយជាងមុន។

- កម្មករទទួលបានប្រាក់បៀវត្ស ដែលអាចដោះស្រាយជីវភាពបានក្នុងកម្រិតអប្បបរមាដោយការប្រៀបធៀបទៅនឹងថ្លៃគ្រឿងឧបភោគបរិភោគភាគច្រើនគឺអាហារអំពីធញ្ញជាតិ។
- ចំណូលរបស់សហគ្រិនគឺ ប្រាក់ចំណេញ។ វាប្រែប្រួលច្រាសសមាមាត្រនឹងប្រាក់បៀវត្សដែលជាតម្លៃ(បន្ទាប់ថ្លៃនំប៉័ងដើម្បីឱ្យកើនប្រាក់ចំណេញ)។
- ម្ចាស់ដី(ជាញឹកញាប់គឺពួកអភិជន) បានទទួលផលទុនពីធនលាភដី តាមរយៈមេភាសុី ដែលបាននាំយកទៅជូន។ ធនលាភដី គឺជាបរិមាណនៃថ្លៃខុសគ្នាពីថ្លៃលក់ភោគផលស្រូវនិងតម្លៃរបស់វាដែលក្នុងនោះមានប្រាក់ចំណេញរបស់មេភាសុី។ វាជាតម្លៃអរិកល(តម្លៃខុសគ្នា) ***ឧទាហរណ៍*** ដីត្រូវបន្ថែមដីជាតិឱ្យកាន់តែច្រើន ប៉ុន្តែតម្លៃភោគផលកាន់តែធ្លាក់ចុះហើយឈ្នួលជួលដីកាន់តែធ្ងន់។

តាមលោករីកាដូ ថ្លៃមាននិន្នាការកើនឡើង ដោយហេតុថា ដោយសារកំណើនប្រជាសាស្ត្រតម្រូវឱ្យមានការដាំដុះលើផ្ទៃដីដែលកាន់តែរួញតូច ហើយកាន់តែខ្សត់ជីជាតិ។ ជាផលវិបាក គឺអាហារឡើងថ្លៃ ប្រាក់បៀវត្សកើនឡើង ឯប្រាក់ចំណេញកាន់តែចុះទាប។

## 1.9. ការលូតលាស់រីកចម្រើនកើតមានដោយសារការបង្កើនការសំចៃ

គំនិតនេះ នាំទៅរកការអះអាងអំពីវិសមភាពនៃផលទុន។ ដើម្បីរស់ កម្មករត្រូវមានប្រាក់បៀវត្ស បញ្ជាក់អំពីកម្ពស់នៃប្រាក់ចំណេញរបស់វណ្ណៈមូលធនដែលមានទំនាក់ទំនងនឹងភាពជាកម្មសិទ្ធិលើមធ្យោបាយផលិតកម្ម។ ទាំងនេះ នាំឱ្យមានការលូតលាស់រីកចម្រើន។ ប៉ុន្តែ ក្នុងបណ្តាវណ្ណៈអ្នកមាន សហគ្រិនជាអ្នកវិនិយោគ គឺជាអ្នកត្រូវគេលើកតម្លៃ ដោយហេតុអ្នកនោះមិនមែនជាម្ចាស់ដីដែលលោករីកាដូចាត់ទុកថា មនុស្សឥតប្រយោជន៍។ ប្រសិនបើគេចង់បន្ទាបផលទុនរបស់សហគ្រិនដោយការដាក់គាត់ទៅក្នុងការប្រកួតប្រជែងភោគផលនាំចូល នោះនឹងធ្វើឱ្យថ្លៃអាហារធ្លាក់ចុះ បន្ទាប់មក ប្រាក់បៀវត្សធ្លាក់ចុះ ដូចនេះ ប្រាក់ចំណេញរបស់គាត់នឹងកើនឡើង។

### 1.10. ថ្ងៃពន្យល់តាមទ្រឹស្ដីបរិមាណនៃរូបិយវត្ថុ

ចំពោះអ្នកតន្ដី ការដាក់កំហិតជាចាំបាច់នូវការបញ្ចេញរូបិយវត្ថុឱ្យប្រើ គឺជាចំណុចមួយនៃបណ្ដាចំណុចទាំងឡាយនៃលទ្ធិទូទៅ ។

## 2. ភាពផ្សេងៗនៃក្រុមសេដ្ឋកិច្ចតន្ដី

ដោយបែងចែកពីអង្គរួមតែមួយ គេរកឃើញគំនិតមួយចំនួនដែលជាមូលដ្ឋាននៃក្រុមសេដ្ឋកិច្ចដទៃៗទៀតភាគច្រើន ។

### 2.1. វិបត្តិខ្វះកន្លែងនាំចេញ

លោកសង់ស៊ីម៉ុងដឺស៊ីសម៉ុងឌី (Jean Simonde de Sismondi) បានសម្គាល់ឃើញវិបត្តិទាំងឡាយកើតចេញពីកង្វះកន្លែងនាំទំនិញចេញទៅលក់និងកង្វះអ្នកអះអាងអំពីលទ្ធិកែទម្រង់និយម(ផានានិយម)ដ៏ត្រឹមត្រូវ ដើម្បីធានាឱ្យមានយុត្តិធម៌សង្គមតាមរយៈការការពារកម្មករពីការរំលោភបំពាន ។ ក្រោយមក គេរកឃើញថា អ្នកសង្គមប្រជាធិបតេយ្យមានគំនិតស្រដៀងគ្នានេះ ។

### 2.2. តម្លៃពិតនៃផលិតផល

ស្ថាបនិកសាលារៀនបារាំង លោកបាស្ទ្យាល (Bastial) និងលោកឌុយណូយេ (Dunoyer) ព្រមទាំងលោកហ្សង់ បាប់ទីសាយ (Jean Baptiste Say) បានបង្កើតភាពល្បីល្បាញដោយសារការបដិសេធនិក្ខេបបទស្ដីពី "តម្លៃពលកម្ម" ដោយការគិតអត្តនោម័តរបស់ពួកលោក ។ ក្រោយមក គំនិតនេះទទួលយកដោយអ្នកតន្ដីសម័យថ្មីដែលផ្ដល់គុណសម្បត្តិដល់ "តម្លៃនៃការបំពេញតម្រូវការ" ។ ផលិតផលនីមួយៗមិនមែនមានតម្លៃត្រឹមមានមុខងារបំពេញសេចក្ដីត្រូវការរបស់អ្នកប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែមានតម្លៃត្រង់ការទទួលយកការកំណត់ថ្លៃដោយសេចក្ដីត្រូវការលើទីផ្សារថែមទៀត ។

### 2.3. ការផ្គត់ផ្គង់បង្កើតសេចក្ដីត្រូវការ

មានសេចក្ដីអធិប្បាយមួយស្រដៀងគ្នានឹងច្បាប់ទីផ្សារគឺថា "ការផ្គត់ផ្គង់បង្កើតសេចក្ដីត្រូវការ" ដោយហេតុថា សហគ្រិនបែងចែកផលទុនដោយដំឡើងទៅតាមតម្លៃនៃផលិតផលជាក់ស្ដែង ។ នៅទីផ្សារសេរី "វិបត្តិគ្មានទីផ្សារ" មិនអាចកើតមានបានទេ ។ គំនិតនេះ មានរួមបញ្ចូលនូវការបកស្រាយដ៏ប៉ិនប្រសប់អំពីទ្រឹស្ដីបរិមាណនិយម "រូបិយវត្ថុគឺជាសំពត់របាំងដែលត្រូវប្រើសម្រាប់តែការបិទបាំងការពិតអំពីការផ្លោះប្ដូរប៉ុណ្ណោះ ពីព្រោះថា ផលិតផលត្រូវប្ដូរផ្លោះគ្នាដោយផលិតផល" ។ ដូចនេះ រូបិយវត្ថុបិទបាំងការផ្លោះប្ដូរ ។ ចំពោះអ្នកតន្ដីនិយមភាគច្រើន និក្ខេបបទនេះជាមូលដ្ឋាននៃទ្រឹស្ដីរួមអំពីការផ្គត់ផ្គង់ ។ ព្រមជាមួយគ្នានេះ និក្ខេបបទនេះក៏បង្កើតចំណុចរួមមួយដ៏សំខាន់ ចំពោះអ្នកសេដ្ឋកិច្ចអរតូដុកនិងផ្ដល់ភាពត្រឹមត្រូវចំពោះការបដិសេធនយោបាយកេនិយមអំពីតម្រូវការ ។

## 2.4. ការសំចៃលើសកំណត់នឹងធ្វើឱ្យរួញកន្ត្រៃងលក់ចេញ

លោកម៉ាល់ទុសនិងលោកស៊ីសម៉ុងឌីបានបង្កើតភាពល្បីល្បាញ ដោយការមិនយល់ស្របតាមច្បាប់សាយ (Say) ។ លោកជាបុព្វបុរសនៃគំនិតកេនេនិយមពីយូរលង់ណាស់មកហើយ ។ លោកបានបង្ហាញថា វិបត្តិទាំងឡាយដែលកើតឡើងអំពីផលិតកម្មលើសកំណត់មិនអាចកើតមានទេ ឯការសំចៃក៏មិនមែនផ្ដល់ចំណេញជានិច្ចនោះដែរ ភាពលើសកំណត់របស់វានឹងធ្វើឱ្យរួញកន្ត្រៃងលក់ចេញ ។ លោកស៊ីសម៉ុងឌីសរសេរថា "អ្នកមានមិនទិញផលិតផលនោះទេ ពីព្រោះគេរកប្រាក់បានច្រើន ឯអ្នកក្រមិនទិញផលិតផលនោះទេ ពីព្រោះគេមិនអាចរកប្រាក់បាន" ។

## 2.5. ចំណុចត្រូវទិតៀនរបស់លោកកាល់ម៉ាក្ស (Karl Max)

គេអាចចាត់ទុកលោកកាល់ម៉ាក្ស ជាអ្នកតន្ត្រីនិយមមួយរូបដែរ ប៉ុន្តែទាស់ត្រង់ថា លោកបដិសេធមូលធននិយម លោកជំរុញហួសហេតុទ្រឹស្ដី "តម្លៃពលកម្ម" របស់លោករីកាដូ ដើម្បីទាញសេចក្ដីសន្និដ្ឋានទៅរកទ្រឹស្ដី "ការកេងប្រវ័ញ្ចនិងការតស៊ូវណ្ណៈ ប្រាក់ចំណេញរបស់មូលធនិកត្រូវបានទាញយកចេញពីភាគរង្វាន់មួយជាតម្លៃលើស ដែលបង្កើតដោយពលកម្មមានបៀវត្ស" ។

## 2.6. អ្នកតន្ត្រីនិយមប្រឆាំងនឹងការទាយស្មាន

លោកស្មីតនិងលោកសាយ ជាអ្នកសុទិដ្ឋិនិយម ។ លោកស្មីតនិយាយថា "ការរកចំណេញរបស់បុគ្គលម្នាក់ៗនាំសង្គមទៅរកភាពសម្បូរសប្បាយ" ។ លោកសាយអះអាងថា "សេចក្ដីត្រូវការទាំងឡាយមិនអាចជាការខ្វះខាតនោះទេ" ។ ផ្ទុយគ្នានេះ លោកម៉ាល់ទុសនិងលោករីកាដូ ជាអ្នកទុទិដ្ឋិនិយម ។ លោកម៉ាល់ទុស មានគំនិតថា "មនុស្សមានកំណើនលឿនជាងកំណើនធនធាន(ច្បាប់ប្រជាករ) ដូចនេះ ការធ្វើឱ្យមានសមតាឡើងវិញដ៏រាំរ៉ៃនឹងកើតមានឡើងតាមរយៈការស្លាប់ហួសប្រមាណ ដូចនេះ គួរតែការពារជាមុនដោយបំផុសអ្នកក្រីក្រដែលមិនមានឈ្មោះទទួលជំនួយពីសង្គមឱ្យ"កំណត់ចំនួនកូន" ។ ចំណែកឯលោករីកាដូ លោកមាននិន្នាការទៅរក "ស្ថានភាពនឹងថ្កល់ មិនរីកចម្រើន មិនធាក់ថយ មិនឡើងថ្លៃ មិនចុះថ្លៃ" ពីព្រោះលោកយល់ថា ការឡើងថ្លៃដ៏ខ្ពស់នៃធញ្ញជាតិ(លើកលែងសេរីកម្មការនាំចូល)នឹងនាំឱ្យមានការដំឡើងថ្លៃឈ្នួលពុំខាន ។ ដូចនេះ ប្រាក់បៀវត្សនឹងមានការចំណេញទាបដែលទីបំផុតនាំមកនូវការរាំងស្ទះដល់ការវិនិយោគ ។

តាមរបៀបអ្នកធម្មជាតាធិបតេយ្យ អ្នកសេរីនិយមរួមសហការគ្នា ដើម្បីការពារនិក្ខេបបទរបស់គេ ។ លោកម៉ាល់ទុស តស៊ូដើម្បីការដាក់កំហិតតាមបែបសីលធម៌ "អ្នកក្រត្រូវកំណត់ចំនួនកូន" ។ លោករីកាដូ បានណែនាំឱ្យមានយុទ្ធនាការពីរគឺ ទី 1 និរាករណ៍ច្បាប់ធញ្ញជាតិ(ឆ្នាំ 1846) ដែលបានហាមប្រាមការនាំចូលធញ្ញជាតិពីបរទេស និងទី 2 រក្សាទុកគោលការណ៍ហិរញ្ញវត្ថុតាមរយៈការដាក់

កំហិតលើការបញ្ចេញប្រាក់ពីធានាគារឱ្យប្រើ(នៅប្រទេសអង់គ្លេសមានវិបត្តិបញ្ចេញប្រាក់ហួសតម្លៃមាសតម្កល់ទុកក្នុងធនាគារនៅឆ្នាំ 1844) ។ លោកសាយ តស៊ូប្រឆាំងនឹងការត្រួតពិនិត្យគ្រប់ប្រភេទដើម្បីសហគ្រាសឯកជន ។ លោករំលាយចោលកម្មន្តសាលរបស់លោកកូបឺឡាំង (Gobelins) ដែលនៅសល់ពីសម័យពាណិជ្ជកម្មនិយម ។

## 3. សន្និដ្ឋាន

បណ្តាគំនិតតន្ត្រីមានលក្ខណៈសេរីនិយមដែលបានទទួលជោគជ័យនៅសតវត្សទី 19 នៅប្រទេសអង់គ្លេសអាចនឹងផ្តល់ផលប្រយោជន៍ជាបទពិសោធចំពោះការសិក្សាវិភាគនៅទីកន្លែងសិក្សានានាក្នុងពិភពលោកនាសតវត្សទី 21 នេះប៉ុណ្ណោះគឺមិនមានន័យថា បណ្តាគំនិតទាំងនេះសុទ្ធសឹងនាំមកនូវការប្រតិបត្តិដោយជោគជ័យនាសតវត្សទី 21 នេះទេ ។ ជាទូទៅ គំនិតនីមួយៗដែលត្រូវចាត់ទុកថា ត្រឹមត្រូវនៅទីកន្លែង ស្ថានភាព និងកាលអាកាសមួយ អាចនឹងខុសឆ្គងនៅទីកន្លែង ស្ថានភាពនិងកាលអាកាសមួយផ្សេងទៀត ។ ដូចនេះ មានតែការសិក្សាឡើងវិញនៅមុនពេលប្រតិបត្តិ ដោយភ្ជាប់ជាមួយនឹងការអនុវត្តសាកល្បងប៉ុណ្ណោះ ដែលជួយឱ្យចៀសវាងបាននូវការអនុវត្តទ្រឹស្តីណាមួយក្នុងភាពប្រថុយប្រថាន ។

## សំណួរ

1. តើសិទ្ធិសេរីភាពមានតម្លៃកម្រិតណាចំពោះបុគ្គលម្នាក់ៗ ? ចូរអ្នកបង្ហាញទស្សនៈរបស់អ្នកប្រាប់សិស្សក្នុងថ្នាក់ ។
2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

   ក. តើលទ្ធិតន្ត្រីនិយមជាអ្វី ? លទ្ធិនេះកើតមាននៅទីណា ? នៅពេលណា ?

   ខ. តើគោលការណ៍នៃលទ្ធិតន្ត្រីនិយមមានប៉ុន្មាន ? អ្វីខ្លះ ?

   គ. ក្នុងបណ្ដាគោលការណ៍ជាមូលដ្ឋាននៃលទ្ធិតន្ត្រី តើគោលការណ៍ណាមួយដែលមិនសមស្រប នឹងទស្សនៈរបស់អ្នក ?

   ឃ. ចូរអ្នករៀបរាប់និងពន្យល់គោលការណ៍ជាមូលដ្ឋានណាមួយនៃលទ្ធិតន្ត្រីដែលមានភាពស្រប នឹងទស្សនៈរបស់អ្នក ។

   ង. មានគំនិតមួយចំនួនដែលបែកចេញពីក្រុមតន្ត្រី ហើយក្លាយជាមូលដ្ឋាននៃក្រុមផ្សេងទៀត ចូរអ្នករៀបរាប់គំនិតទាំងនោះ ។ ក្នុងបណ្ដាគំនិតទាំងនោះ តើគំនិតណាមួយដែលអ្នកគាំទ្រច្រើនជាងគេ ? តើគំនិតណាមួយដែលអ្នកគាំទ្រតិចជាងគេ ? ហេតុអ្វី ?
3. ចូរអ្នកអានអត្ថបទមេរៀនដោយយកចិត្តទុកដាក់ បន្ទាប់មកចូរដកស្រង់ដោយសង្ខេបនូវខ្លឹមសារដែលអ្នកយល់ថាសំខាន់ ដើម្បីចងក្រងទុកជាមេរៀនសង្ខេបរបស់អ្នក ។

## ប្រតិបត្តិ

លោកអាដាំស្ម៊ីត បាននិយាយថា “ការរកចំណេញរបស់បុគ្គលម្នាក់ៗនាំសង្គមទៅរកភាពសម្បូរសប្បាយ” ។ តើគំនិតនេះត្រឹមត្រូវឬទេ ? ចូរពិភាក្សា ។

youtube.com/moeys
facebook.com/moeys.gov.kh

មេរៀនទី

# 3 គំនិតលោកកាល់ម៉ាក្សនិងគំនិតពន្លិ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ទស្សនៈវិស័យនិងសកម្មភាពរបស់លោកកាល់ម៉ាក្ស ។
- ❑ ពន្យល់ទ្រឹស្តីសំខាន់ៗដែលជាមនោគមវិជ្ជាលទ្ធិម៉ាក្ស ។
- ❑ យល់គំនិតពិតដែលផ្តល់អត្ថប្រយោជន៍ដល់ការអភិវឌ្ឍសង្គម ។



*កាល់ម៉ាក្ស* ***(Karl Marx)***



*ហ្វ្រីឌ្រិចអង់គែល* ***(Friedrich Engels)***



*លេនីន* ***(Lenine)***

បដិវត្តន៍ឧស្សាហកម្ម ការធ្វើឱ្យរីកចម្រើនសេដ្ឋកិច្ចទីផ្សារ មានភាពត្រូវគ្នាយ៉ាងជាក់ច្បាស់ទៅនឹងគំនិតតន្តី ។ ចំណែកឯប្រព័ន្ធដែលនៅពីលើការចែកពលកម្មមានបៀវត្ស និងមធ្យោបាយផលិតកម្ម វាផ្តល់កំណើតដល់លទ្ធិម៉ាក្សនិយម ព្រមទាំងការបកស្រាយផ្សេងៗអំពីលទ្ធិសង្គមនិយម ។

## 1. ទស្សនវិស័យនិងសកម្មភាពរបស់លោកកាល់ម៉ាក្ស

ដោយប្រើប្រាស់បណ្តាបញ្ញត្តិរបស់អ្នកតន្តីនិយម ម៉ាក្សបានប្រែត្រឡប់សេចក្តីវិនិច្ឆ័យរបស់អ្នកទាំងនោះ ដោយចុចយកត្រង់ទស្សនវិស័យអំពីជនរងគ្រោះ ។ ម៉ាក្សមិនបានប្រតិបត្តិត្រង់ចំណុចសេដ្ឋកិច្ចទេ ប៉ុន្តែលោកប្រតិបត្តិត្រង់ចំណុចការទិតៀនអំពីនយោបាយសេដ្ឋកិច្ច(ដែលលោកចាត់ទុក

youtube.com/moeys
facebook.com/moeys.gov.kh

ថាជាស្នាដៃសំខាន់របស់លោក) ។ ទិដ្ឋភាពអំពីភាពក្រខ្សត់និងហិង្សានៃវិបត្តិ ដូចដែលត្រូវរៀបរាប់ដោយសហកាលិករបស់លោក(អង់គែលរៀបរាប់នៅទីក្រុងម៉ែនឆែស្ទឺ វ៉ុទ្បីមេរៀបរាប់ក្នុងការអង្កេតនៅភាគខាងជើង ស៊ូឡារៀបរាប់ក្នុងស្នាដៃប្រលោមលោកផ្នែកសង្គមរបស់លោក)ធ្វើឱ្យអ្នកមនុស្សធម៌និយមមួយចំនួនមានការតូចចិត្តរហូតដល់ពួកគេត្រូវតែធ្វើសកម្មភាពដើម្បីលុបបំបាត់ទិដ្ឋភាពទាំងនេះ ។ ចំណុចសំខាន់មួយក្នុងបណ្ដាចំណុចសំខាន់នានានៃការបះបោររបស់កម្មករ គឺអ្វីដែលបានគិតបានរៀបចំនិងបានដឹកនាំដោយអ្នកដែលរត់ចូលទៅរកវណ្ណៈដឹកនាំ ។ ក្នុងជីវិតរបស់ម៉ាក្ស ដំបូងឡើយលោកជាទ័ពម្នាក់នៅក្នុងចលនាយុវជនអាល្លឺម៉ង់ ដែលស្ថិតនៅក្នុងជួរខ្ពស់បំផុតក្នុងបដិវត្តន៍អឺរ៉ុបឆ្នាំ 1848 ។ បន្ទាប់មក លោកបង្កើតបក្សបដិវត្តន៍មួយគឺ សមាគមកម្មករអន្តរជាតិដែលលោកបានជំរុញតាំងពីពេលដែលលោកបាននិរទេសចេញពីប្រទេសអង់គ្លេស ។ បន្ទាប់មក លោកបានបោះពុម្ពផ្សាយសៀវភៅតូចៗអំពីនយោបាយ

- សេចក្ដីថ្លែងការណ៍របស់បក្សកុម្មុយនីស្ដ
- ការតស៊ូវណ្ណៈនៅប្រទេសបារាំង
- ថ្ងៃទី 18 ខែ 02 នៃប្រតិទិនសាធារណរដ្ឋបារាំង
- អំពីស្ដេចល្វីណាប៉ូឡេអុងបូណាប៉ាត ឬបោះពុម្ពផ្សាយ ឧត្ដានកម្ម(អំពីប្រាក់បៀវត្ស ថ្លៃ ប្រាក់ចំណេញ) ។ ព្រមជាមួយគ្នានោះ ម៉ាក្សក៏បានជាប់ចិត្តផងដែរ ក្នុងការនិពន្ធស្នាដៃផ្នែកទ្រឹស្ដីដ៏ធំសម្បើមអំពីមូលធន ដែលមិនទាន់សម្រេចលទ្ធផលនៅឡើយ ។

## 2. មនោគមវិជ្ជាលទ្ធិម៉ាក្ស

### 2.1. លទ្ធិរូបធាតុនិយមនិងការឆ្លុះបញ្ចាំងស្ថានភាពការងាររបស់កម្មករ

តាមទ្រឹស្ដី "អត្ថិភាពបង្កើនញ្ញាណ"មានន័យថា "រូបធាតុជាអ្នកកំណត់ស្មារតី" ម៉ាក្សបង្ហាញថា "ពិភពលោកកើតមានរួចហើយទើបមានអាទិទេព" មនុស្សកើតមានជារូបរាងមានជីវិតរួចហើយទើបមានវិញ្ញាណ ស្មារតី និងការគិតគូរ" ឬ "ក្នុងលោកនេះមានហេតុទើបមានផល" ។ ដូចនេះ ទាសភាពរបស់កម្មករបាននាំកម្មករទៅរកការទទួលលក្ខខណ្ឌនានាក្នុងការងារឧស្សាហកម្ម មានការបែងចែកជាដើម ហើយការបែងចែកការងារនេះនាំឱ្យកើតមានវណ្ណៈពលជីវី(ពលករ)ដែលមិនយល់អំពីសកម្មភាពដែលជារបស់ខ្លួន ។ ផ្ទុយពីស្ថានភាពនេះ ចំពោះកម្មករខាងសិប្បកម្ម សកម្មភាពរបស់គេមិនបានទទួលការគាបសង្កត់ទេ ប៉ុន្តែផលនៃការងាររបស់គេត្រូវបានដកហូតយកដែលធ្វើឱ្យគេមើលឃើញការគាបសង្កត់ផ្ទៃក្នុងលើការងាររបស់គេផ្ទាល់ ជាហេតុនាំឱ្យគេបង្អាក់ការបញ្ចេញសកម្មភាពច្នៃប្រឌិតរបស់គេ ។

## 2.2. ទ្រឹស្តីវិចារវិទ្យានិងប្រវត្តិសាស្ត្រ

លោកកាល់ម៉ាក្សសរសេរថា "ប្រវត្តិសាស្ត្ររបស់មនុស្សជាតិ គឺជាប្រវត្តិនៃការតស៊ូវណ្ណៈ ជាដំណើរបន្តមិនដាច់នៃបែបផែនផលិតកម្ម(បែបទាសករ បែបសក្តិភូមិ បែបមូលធននិយម បែបសង្គមនិយម)ដែលបង្ហាញឱ្យឃើញច្បាស់តាមរយៈទំនាស់ទាំងឡាយដែលលេចឡើងឆ្លងកាត់សម័យកាលនីមួយៗ" ។ គេមើលឃើញថា ឥទ្ធិពលនៃទ្រឹស្តីវិចារវិទ្យាដែលម៉ាក្សដើរតាមលោក ហេកែល (Hegel) បាននាំឱ្យម៉ាក្សបង្កើតគណបក្សក្រុមអ្នកប្រឆាំងរបស់ "យុវជនអ្នកដើរតាមលោកហេកែល" ដែលក្រោយមកមានការបែកបាក់ដោយសារមនោគមវិជ្ជាថៅហ្វាយនាយ ។ លោកកាល់ម៉ាក្សពន្យល់ថា តថភាពទាំងអស់ត្រូវបានកំណត់ដោយទំនាស់ផ្ទៃក្នុងរវាងកម្លាំងបដិបក្ខ ។ សង្គមនីមួយៗត្រូវបានសម្គាល់ដោយទំនាស់ដោយហេតុថា អ្នកកេងប្រវ័ញ្ចមួយក្រុមតូចរស់ដោយសារពលកម្មរបស់អ្នកដ៏ច្រើនដែលត្រូវគេកេងប្រវ័ញ្ច ។ ការតស៊ូប្រឆាំងនាំទៅរកបដិវត្តន៍ ហើយដោយសារបដិវត្តន៍ វណ្ណៈកាន់អំណាចថ្មីប្រាកដខ្លួនឡើង ។ ដោយហេតុនេះហើយ ទើបមានការកើតឡើងរបបមូលធននិយមបន្ទាប់ពីមានជ័យជំនះរបស់វណ្ណៈគហបតីលើវណ្ណៈអភិជន(ក្នុងរបបរាជានិយម) ។ ដំណាក់ចុងក្រោយនៃប្រវត្តិសាស្ត្រ តាមចក្ខុវិស័យនៃការរំដោះមនុស្សជាតិ របបសង្គមនិយមនឹងកើតឡើងដោយសារជ័យជំនះរបស់វណ្ណៈពលជីវីលើវណ្ណៈហាបតី ហើយគឺជាលើកទីមួយដែលវណ្ណៈមួយនឹងគ្រប់គ្រងអំណាចក្នុងគោលដៅផ្តល់សិទ្ធិសេរីភាពដល់មនុស្សជាតិពោលគឺ មិនមែនជាការគ្រប់គ្រងអំណាចដើម្បីការគាបសង្កត់វណ្ណៈណាមួយផ្សេងទៀតឡើយ ។ លទ្ធិផ្តាច់ការរបស់វណ្ណៈពលជីវី(ឬលទ្ធិសង្គមនិយម) គឺជាអន្តរកាលឆ្ពោះទៅរកការលុបបំបាត់មិនឱ្យមានវណ្ណៈទាំងឡាយដែលហៅថាលទ្ធិកុម្មុយនីស្ត ។

## 2.3. ការកេងប្រវ័ញ្ច

ការបង្រៀនរបស់អ្នកតន្តិនិយមនៅប្រទេសអង់គ្លេស គឺជាទីប្រជុំនៃការកសាងអ្នកដើរតាមលទ្ធិម៉ាក្សនិយម ។ ដោយទាញចេញពីទ្រឹស្តីតម្លៃពលកម្ម ម៉ាក្សបានទាញចេញនូវសញ្ញាណនៃការកេងប្រវ័ញ្ចដែលដេកសម្ងំនៅពីលើភាគពិសេសនៃកិច្ចសន្យាការងារ ។ មូលធនិកប្រកាន់យកជារបស់ខ្លួននូវតម្លៃការងារដែលបានផ្តត់ផ្គង់ពលជីវី(ដែលធ្វើការ 12 ម៉ោង) ប៉ុន្តែគេមិនបានទូទាត់សងមកវិញនូវតម្លៃនៃកម្លាំងក្នុងការងារដើម្បីឱ្យមានសមតុល្យទេ ពោលគឺគេកាត់ថ្លៃផលិតផលដោយមានបន្ថែមថ្លៃលើស ដែលហៅថាកម្រៃសម្រាប់ខ្លួនគេនិងគ្រួសារគេ(ដែលសន្មតថាបានធ្វើការ 12 ម៉ោងដែរ) ។ ពល

ជីវីមិនមានការលួចទេ ពីព្រោះគេបានគោរពកិច្ចសន្យាជាមួយមូលធនិក កម្លាំងធ្វើការងាររបស់គេត្រូវបានជួលនិងបង់ឈ្នួលឱ្យទៅតាមតម្លៃត្រឹមត្រូវ(ថ្លៃការងារ) ប៉ុន្តែកម្លាំងពលកម្មរបស់គេនោះជាប្រភពនៃការបង្កើតតម្លៃលើស ។ ការផ្តោះប្តូរពលកម្ម ប្តូរយកប្រាក់ឈ្នួលបង្កើតបាននូវប្រាក់ចំណេញសម្រាប់មូលធនិក ។ ម៉ាក្សពន្យល់ថា តម្លៃលើសនេះគឺជាការកេងប្រវ័ញ្ចពេលគឺ ជាតម្លៃបង្កើតចេញដោយកម្មករដែលបានផ្តល់ត្រឡប់ទៅមូលធនិកវិញ ។ នៅពេលដែលផលិតផលត្រូវលក់ចេញ តម្លៃពលកម្មក៏ប្រែក្លាយជារូបិយវត្ថុដែលក្នុងនោះមានតម្លៃលើសជាប្រាក់ចំណេញ ។ សមីការខាងក្រោមបង្ហាញបញ្ជាក់នូវសញ្ញាណនេះ

| |
|---|
| M = C + V + PI |

**M :** ថ្លៃទំនិញសរុប

**C :** មូលធនថេរ មានមូលធនអចល័ត(ឧបករណ៍ គ្រឿងម៉ាស៊ីន)និងមូលធនចល័ត (ប្រើប្រាស់ជាចរន្តសម្រាប់ពូជ ជី ប្រេងឥន្ធនៈ)

**V :** មូលធនអថេរ(ប្រាក់បៀវត្ស)

**Pl :** តម្លៃលើស(ការងារមិនបានប្រាក់)

***ឧទាហរណ៍ :*** M = 100 = 40 + 30 + 30 អត្រានៃការកេងប្រវ័ញ្ច Pl/(C+V) គឺ 30/(40+30) = 42%

## 2.4. ការប៉ាន់ប្រមាណមួយ

តាមការប៉ាន់ប្រមាណរបស់លទ្ធិម៉ាក្ស វិបត្តិដ៏ទៀងទាត់ទាំងឡាយកើតមានក្នុងរយៈពេលខ្លី ប៉ុន្តែការខូចខាតជាស្វ័យប្រវត្តិកើតមានក្នុងរយៈពេលវែង ។

- **វដ្តវិបត្តិស្ថិតនៅជាមួយនឹងប្រព័ន្ធ :** ដំណាក់រីកចម្រើននីមួយៗ តែងទាក់ទាញបន្ថែមនូវការវិនិយោគទុនជាហេតុបណ្តាលឱ្យមានកំណើនដ៏លើសលុបនៃអំពើកេងប្រវ័ញ្ច ដែលដំណោះស្រាយទីផ្សារមិនអាចដោះស្រាយបាន ។ ដោយមិនមានទីប្រជុំទំនាក់ទំនងកណ្តាល មូលធនិកទាំងឡាយមិនអាចមានការចុះសម្រុងនិងមិនមានការស៊ីសង្វាក់នឹងគ្នា ។ ម្នាក់ៗធ្វើការវិនិយោគដ៏លើសលុបក្នុងរយៈពេលមានការរីកចម្រើន ។ ដោយមានការលក់មិនដាច់ តម្លៃលើសទាំងឡាយមិនប្រាកដជាកើតមាន(មិនអាចប្រែក្លាយជាប្រាក់ចំណេញ) ដូចនេះ មូលធនិកត្រូវតែជម្រុះចោលកម្លាំងផលិតកម្មដែលលើស(ជាលទ្ធផល ភាពអត់ការងារធ្វើ ការដួលរលំ... កើតមានឡើង) ។

- **និន្នាការស្រកចុះនៃអត្រាប្រាក់ចំណេញ ៖** កំណើនផលិតផលនាំឱ្យមានការរីកចម្រើន ប៉ុន្តែកំណើននេះដឹកនាំមូលធនទៅរកការខាតបង់ ។ ដើម្បីជាដំណោះស្រាយនិងដើម្បីការប្រកួតប្រជែង សហគ្រិនមាននិន្នាការបន្ទាបថ្លៃទំនិញ ដោយការបន្ទាបចំណាយលើមូលធនប្រើប្រាស់ក្នុងការងារ V ប៉ុន្តែគេបង្កើនមូលធនថេរ C ។ ក្នុងសមីការ $M = C + V + P1$ បើ C កើនឡើងនោះ V ត្រូវធ្លាក់ចុះ ។ ដោយហេតុថា មានតែពលកម្មទេដែលបង្កើតតម្លៃ ដូច្នេះនៅពេល V ធ្លាក់ចុះ អត្រាប្រាក់ចំណេញ P1/(C+V) មាននិន្នាការធ្លាក់ចុះ ។ ប្រសិនបើគេបន្ថែមនូវការសន្និដ្ឋានបែបទំនាស់មួយ ដោយការប្រមូលផ្ដុំការគិតរបស់វណ្ណៈពលករដែលជាវណ្ណៈមានទំនាស់នឹងមូលធន គេនឹងឈានដល់ការគិតអំពីអ្វីដែលត្រូវប្រឈមមុខជាចុងក្រោយបំផុតគឺ "មូលធន" ដែលម៉ាក្សគិតថាជាឧបសគ្គកើតមានឯកឯងចំពោះការលូតលាស់របស់មូលធនខ្លួនឯងផ្ទាល់(តថភាពទាំងអស់តែងផ្ទុកដោយទំនាស់ខាងក្នុងដ៏ស្រួចស្រាល់) ។
- **ការយកមធ្យោបាយផលិតកម្មដាក់ជាសម្បត្តិសមូហភាព គឺជាដំណោះស្រាយ ៖** ជនជាតិបារាំងអ្នកគាំទ្រលទ្ធិម៉ាក្សនិយមគឺ លោកភូរីយេ (Fourier) កាបេ (Cabet) និងលោកសាំង ស៊ីម៉ុង (Saint Simon) ជាអ្នកបំផុតគំនិតនេះ ប៉ុន្តែគំនិតនេះនៅតែស្ថិតនៅក្នុងលំហនៅឡើយ ។

## សំណួរ

1. ចូរនិយាយប្រាប់សិស្សក្នុងថ្នាក់អំពីគំនិតណាមួយដែលអ្នកពេញចិត្តក្នុងបណ្ដាគំនិតតន្ត្រីនិយម ។
2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម
   ក. តើលោកកាល់ម៉ាក្សមានទស្សនវិស័យយ៉ាងណានិងមានសកម្មភាពអ្វីខ្លះ ?
   ខ. តើលោកកាល់ម៉ាក្សបានមើលឃើញស្ថានភាពការងាររបស់កម្មករមានលក្ខណៈដូចម្ដេចខ្លះ?
   គ. តាមទ្រឹស្ដីវិចារវិទ្យារបស់លទ្ធិម៉ាក្ស តើប្រវត្តិសាស្ត្រជាអ្វី ?
   ឃ. ក្នុងលទ្ធិម៉ាក្ស អ្វីជាការកេងប្រវ័ញ្ច ?
   ង. តើលទ្ធិម៉ាក្សមានការប៉ាន់ប្រមាណទៅអនាគតយ៉ាងដូចម្ដេចខ្លះ ?
   ច. ក្នុងបណ្ដាទ្រឹស្ដីរបស់លទ្ធិម៉ាក្ស តើទ្រឹស្ដីណាមួយដែលមានអត្ថប្រយោជន៍ដល់ការអភិវឌ្ឍសង្គមបច្ចុប្បន្ន ?
3. ចូរអ្នកអានមេរៀនដោយយកចិត្តទុកដាក់និងដកស្រង់យកចំណុចណាដែលអ្នកគិតថាសំខាន់ដើម្បីចងក្រងជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

### ប្រតិបត្តិ

លោកកាល់ម៉ាក្សគិតថា “មានតែពលកម្មដែលបង្កើតតម្លៃ” ប៉ុន្ដែសហគ្រិនសម័យថ្មីគិតថា “មិនមានពលកម្មក៏គេអាចបង្កើតតម្លៃបានដែរ” ។ ចូរអ្នកពន្យល់គំនិតទាំងពីរដោយឱ្យឧទាហរណ៍បញ្ជាក់ ។

khmou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

មេរៀនទី

# 4 បណ្ដាគំនិតតន្ដីថ្មីនិងសមតាទូទៅ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់បណ្ដាគំនិតជាមូលដ្ឋាននៃលទ្ធិតន្ដីនិយមសម័យថ្មី ។
- បង្ហាញនិងបកស្រាយគំនិតផ្សេងៗទៀតដែលបែកចេញពីនិកាយតន្ដី ។
- បកស្រាយនិងបង្ហាញការគាំទ្រ ឬមិនគាំទ្រចំពោះគំនិតនីមួយៗ ។



*លោកឡេអុងវ៉ាល់រ៉ាស់*



*លោកស្ដង់ឡេហ្សឺវ៉ុង*



*លោកកាលម៉ង់សេ*

**អ្នកតន្ដីនិយមសម័យថ្មី ៖** ស្ថាបនិក 3 នាក់នៅដើមទសវត្សរ៍ឆ្នាំ 1870 មានលោកឡេអុងវ៉ាល់រ៉ាស់ (Leon Walras, 1834-1910) លោកស្ដង់ឡេហ្សឺវ៉ុង (Stanley Jevons, 1835-82) កាល់មង់សេ (1840-1921) ។ លោកវីលហ្វ្រ៊ីដូប៉ារ៉ឺតូ (Vilfredo Pareto,1848-1923) បាននាំយកស្នាដៃរបស់លោកវ៉ាល់រ៉ាស់ទៅទីក្រុងឡូសាន ។ លោកហ្វ្រាំងស៊ីអិដវ៉ឺស (Francis Edgeworth,1845-1926) អាល់ហ្វ្រ៊ីដម៉ាសាល់ (1842-1924) អាតឺសឺស៊ីលពីហ្គូ (1877-1959) បានបង្កើតសាលារៀននៅខែមប្រ៊ីដបន្ទាប់ពីលោកហ្សឺវ៉ុង ។ លោកបូមបាវើក (Bohm Bawerk,1851-1914) វ៉ុនវីសេ (Von Wieser,1851-1926) វ៉ុនមីស (Von Mises,1851-1926) និងលោកវ៉ុនហាយេក (Von Heyek,1899-1992) បានកសាងសាលារៀនអូទ្រីសបន្ទាប់ពីលោកម៉ង់សេ ។

ចរន្ដតន្ដីនិយមសម័យថ្មីបាននាំយកមកជាថ្មីនូវនិក្ខេបបទតន្ដីនិយម "អំពីភាពសេរី" ប៉ុន្ដែបានធ្វើការសម្រួលនូវជម្រើសជាច្រើន ជាពិសេស ចំពោះនិក្ខេបបទដែលគាំទ្រម៉ាក្សដែលបង្កើតទ្រឹស្ដីអំពីការកេងប្រវ័ញ្ចនិងគាំទ្រតម្លៃការងារ ។

# 1. គោលការណ៍ស្លាបនិក

## 1.1. ម៉ាក្រូសេដ្ឋកិច្ចនិងមីក្រូសេដ្ឋកិច្ច

ក្នុងនាមជាភារៈមានការពិចារណាមនុស្សមានការប្រព្រឹត្តក្នុងលក្ខណៈបង្កើនឱ្យបានជាអតិបរមានូវសេចក្តីរីករាយ(ផលប្រយោជន៍)និងបន្ថយឱ្យនៅជាអប្បបរមានូវការឈឺចាប់(ការខាតបង់)របស់គេ ។ សកម្មភាពផ្សេងៗរបស់មនុស្សម្នាក់ៗសរុបមកនៅត្រឹមសកម្មភាពចម្លងការនៃទីផ្សារ មានដូចជា ទិញ ឬលក់ទ្រព្យសម្បត្តិ ការមានការងារធ្វើ ការតម្កល់ទុកមូលធន ឬធ្វើវិនិយោគទុន ។ ទាំងអស់នេះគឺជាសេចក្តីសម្រេចចិត្តដែលគេបានធ្វើបន្ទាប់ពីបានគិតគូរអំពីផលចំណេញនិងការខាតបង់នៅក្នុងលំដាប់ប្រៀបធៀបទៅនឹងផលប្រយោជន៍របស់គេ ។ ការពិចារណាថ្លឹងថ្លែងតាមបែបមីក្រូសេដ្ឋកិច្ចនីមួយៗសិក្សាអំពីកិរិយាមារយាទរបស់បុគ្គលនីមួយៗ ដែលត្រូវចាត់ទុកដូចជាមូលរូប (*ឧទាហរណ៍* កិរិយាមារយាទជាផលិតករ ជាអ្នកប្រើប្រាស់ ជាអ្នកសន្សំសំចៃ ឬជាកម្មករជាដើម) ។ រីឯទូទៅនីយកម្មម៉ាក្រូសេដ្ឋកិច្ច(ដើម្បីបានមកនូវការសន្សំ ផលទុន ផលិតកម្ម ការងារ)កើតមានមកអំពីការគណនាដ៏សាមញ្ញ ។

## 1.2. តម្លៃ ផលប្រយោជន៍ ភាពខ្សត់

ទ្រឹស្តីអំពី "ការផ្តល់មកវិញនូវផលប្រយោជន៍" របស់លោកសាយ (Say) បាននាំឱ្យមានការបដិសេធការកេងប្រវ័ញ្ច ។ កាលបើគេចាត់ទុកថារបស់មួយមានប្រយោជន៍ ឬឥតប្រយោជន៍គឺអាស្រ័យតាមការគិតរបស់មនុស្សម្នាក់ៗ (សញ្ញាណប្រធានវិស័យ) ។ ភាពស្មុគស្មាញនេះអាចដោះស្រាយដោយមធ្យោបាយទីមួយ យោងទៅលើភាពខ្សត់(ទ្រព្យមួយមានតម្លៃកាន់តែខ្ពស់ នៅពេលដែលវាកាន់តែខ្សត់)និងទីពីរ ការសម្រុះសម្រួលតាមបែបទីផ្សារ(ទ្រព្យមួយមានតម្លៃកាន់តែខ្ពស់នៅពេលដែលមានមនុស្សចង់បានវាយ៉ាងខ្លាំងកាន់តែច្រើន) ។ ប៉ុន្តែ តើបុគ្គលនីមួយៗអាចសង់មាត្រដ្ឋានតម្លៃយ៉ាងដូចម្តេច ? តាមលោកប៉ារ៉ីតូ (Pareto) គេស្គាល់ផលប្រយោជន៍នៃទ្រព្យតាមបែបលំដាប់នៃផលប្រយោជន៍ ដូចជា ការនិយមស្រាបៀជាងភេសជ្ជៈកូកា មិនរួមបញ្ចូលនូវការចេះគូសគំនូសតាងការនិយមទេ) ។

## 1.3. គំរូកិរិយានៃអ្នកផ្តល់ប្រយោជន៍

ភ្នាក់ងារទាំងឡាយជាអ្នកគ្រប់គ្រងដ៏ត្រឹមត្រូវនូវធនធានដ៏កម្រដែលគេបានចាត់ចែង ។ ពួកគេបានទាញយកផលប្រយោជន៍ជាអតិបរមាពីធនធានទាំងនោះនៅក្នុងការផ្តោះប្តូរលើទីផ្សារផ្សេងៗ (ពលកម្ម មូលធន ទ្រព្យប្រើប្រាស់) ។ ពួកគេរិះរកមធ្យោបាយកាត់បន្ថយថ្លៃដើមរបស់គេឱ្យនៅកម្រិតអប្បបរមា ហើយបង្កើនការចំណេញ(ផលប្រយោជន៍)ឱ្យបានជាអតិបរមា ។ ការផ្តោះប្តូរកើតមាន

ឡើងបាននៅពេលដែលម្នាក់ៗបានបង្កើនផលប្រយោជន៍រៀងខ្លួនឱ្យបានជាអតិបរមា អតិថិជនទិញរហូតដល់ដែននៃផលប្រយោជន៍(ថ្លៃប្រើប្រាស់) ថយចុះស្មើនឹងថ្លៃ ឯអ្នកលក់ លក់រហូតដល់ថ្លៃដើម(កើនឡើង)ស្មើនឹងថ្លៃ ។ ចម្លងការមានសកម្មភាពរហូតមាន"សមតា"(ថ្លៃដើម = ថ្លៃប្រើប្រាស់ = ថ្លៃ) ហើយសមតានេះមិនអាចជាអ្វីក្រៅពីការសមចិត្ត ។ ចេញអំពីនោះ អ្នកដែលទិញតាម "ថ្លៃ > ថ្លៃប្រើប្រាស់" និងអ្នកដែលលក់តាម "ថ្លៃដើម>ថ្លៃ" នឹងទទួលរងនូវការខាតបង់ ។ នៅករណី "ថ្លៃ < ថ្លៃប្រើប្រាស់,ថ្លៃ>ថ្លៃដើម" ពួកគេនឹងខាតបង់ឱកាសមានចំណេញកាលបើមានការផ្ដោះប្ដូរដោយមានការថែម ។ ការផ្ដោះប្ដូរមិនមែនជាអ្វីក្រៅពីសមតាទេ ពោលគឺការផ្ដោះប្ដូរកើតមាននៅចំណុចមួយដែលឯកតាចុងក្រោយនាំមកឱ្យអ្នកលក់នូវអ្វីដែលគេបានចំណាយនិងយកកម្រៃពីអ្នកទិញនូវអ្វីដែលជាប្រយោជន៍ដល់គេ ។ ការដាក់បន្ថែមលើការផ្ដោះប្ដូរនូវឯកតាមួយនឹងបង្ហាញពីការបង់ខាតមួយកម្រិត ការដកចេញនូវឯកតាមួយពីការផ្ដោះប្ដូរនិងបង្ហាញពីកង្វះការចំណេញមួយកម្រិតដែរ ។

| | | |
|---|---|---|
| | ការផ្ដោះប្ដូរមានសមតា | |
| ការលក់ | | ការទិញ |
| ថ្លៃ = ថ្លៃដើម | ⟷ | ថ្លៃ = ថ្លៃប្រើប្រាស់ |

## 1.4. កត្តាផលិតកម្មទាំងឡាយត្រូវទទួលការទូទាត់ទៅតាមផលិតភាពដើមរបស់វា

តាមគំនិតអ្នកតន្ត្រីនិយមសម័យថ្មី មានភ្នាក់ងារតែមួយប្រភេទគត់ ដែលប្រភពធនធានរបស់វាបង្កើតជាមូលធន ។ ភ្នាក់ងារនោះ គឺមនុស្សដែលបម្រើប្រយោជន៍គេរាល់គ្នា មនុស្សដែលរស់ដោយប្រាក់បៀវត្ស មនុស្សអ្នកផ្ដល់ហិរញ្ញកិច្ចសម្រាប់អ្នកដទៃ គេគឺជាមូលធនិក ពោលគឺអ្នកឱ្យគេខ្ចី ។ មូលធនិកនេះផ្ដល់សេវាផលិតដែលកម្រៃសេវានោះ នៅជាប់ជាមួយនឹងផលប្រយោជន៍និងភាពខ្វះខាត ។ អ្នកផ្ដល់សេវាម្នាក់ៗត្រូវបានផ្ដល់កម្រៃទៅតាមផលិតភាពដើមរបស់គេ ដូចនេះគេមិនមានការកេងប្រវ័ញ្ចទេ គឺមានតែការទូទាត់ដ៏ត្រឹមត្រូវ ។ បើនិយាយអំពីសមតា គឺគ្មានការចំណេញ ។ សហគ្រាសសងត្រឡប់ទៅឱ្យគេម្នាក់ៗវិញនូវតម្លៃស្មើគ្នានឹងអ្វីដែលគេបានធ្វើ ពោលគឺផលិតភាពនៃការងារសម្រាប់មនុស្សរាល់គ្នា(គឺប្រាក់បៀវត្ស) ឯផលិតភាពនៃមូលធនសម្រាប់អ្នកឱ្យគេខ្ចី ឬម្ចាស់កម្មសិទ្ធិ(គឺការប្រាក់) ។ ការមើលឃើញថ្មីនេះត្រូវទាល់គំនិត ក្នុងករណីរបស់អ្នករស់នឹងបៀវត្ស គឺថាតាំងពីពេលនេះតទៅ ដោយចាត់ទុកដូចជាអ្នកគ្រប់គ្រង អ្នករស់នឹងបៀវត្សមិនដូចគ្នាទាំងស្រុងនឹងកម្មកររបស់អ្នកតន្ត្រីនិយមសម័យថ្មីទៀតទេ ដោយប្រាក់បៀវត្សរបស់គេត្រូវបន្ទាបដោយសារប្រកួតប្រជែងឱ្យដល់កម្រិតអប្បបរមាត្រឹមតែរស់ (ច្បាប់អំពីប្រាក់បៀវត្សនៅយុគសិរីទ្ធឬទ្រឹស្ដីប្រាក់បៀវត្សធម្មជាតិ) ។ អ្នករស់នឹងប្រាក់បៀវត្សនេះ ត្រូវបានសន្មតថាស្ថិតនៅជាអាជ្ញាកណ្ដាលរវាងភាពទំនេរនិងភាពមានគេប្រើដើម្បីសម្រេចចិត្តអំពីចំនួនម៉ោងធ្វើការរបស់ខ្លួន ។

### 1.5. សមតាទូទៅ កើតមានពិតប្រាកដនៅលើទីផ្សារដែលគេសន្មតថាល្អឥតខ្ចោះ

នៅក្នុងការប្រកួតប្រជែងដ៏បរិសុទ្ធ និងត្រឹមត្រូវគេទទួលបានការពេញចិត្តដែលមាននិយមន័យដូចជា"ស្ថានភាពមួយដែលនៅក្នុងនោះគេមិនអាចធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរបស់បុគ្គលម្នាក់ដោយផ្គត់ផ្គង់បុគ្គលនោះក្នុងកម្រិតមួយទាបជាងបុគ្គលម្នាក់ទៀតបានឡើយ" ។ សមតាទីផ្សារការងារអាចកើតមានបានប្រសិនបើម្នាក់ៗត្រូវបានផ្តល់នូវ"ការផ្គត់ផ្គង់ដើម្បីរស់"ពោលគឺធនធានតូចបំផុតអាចឱ្យគេបដិសេធមិនធ្វើការងារដូចគ្នាដែរចំពោះអត្រាប្រាក់បៀវត្សមិនសមនឹងចិត្ត ។ តើគេពន្យល់យ៉ាងដូចម្តេចពីជោគជ័យនៃគំរូសេដ្ឋកិច្ចភាគច្រើនបានអនុវត្ត? ជោគជ័យនេះសំដៅទៅរកការរៀបរាប់ច្បាប់ធម្មជាតិ ដែលប្រតិបត្តិក្នុងពិភពនៃឧត្តមគតិ(គ្មានការរឹតត្បិត គ្មានការតឹងរឹង) ដើម្បីឱ្យច្បាប់នេះក្លាយទៅជាវិធាន យើងត្រូវទុកឱ្យទីផ្សារមានភាពសេរី ទីផ្សារនឹងនាំមកឱ្យយើងនូវការគាប់ចិត្ត ។

### 1.6. យុត្តិធម៌សង្គម

ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទ្រព្យធនរបស់អ្នកក្រីក្រ ទ្រព្យធននោះនឹងត្រូវហូតយកមកយ៉ាងហោចណាស់ពីអ្នកមានម្នាក់ ។ រាល់ការផ្ទេរកម្មសិទ្ធិនឹងតម្រូវឱ្យមានភាពអមិត្ត ដែលមិនអាចអធ្យាស្រ័យបានខាងសីលធម៌ ប្រសិនបើស្ថានភាពចាប់ផ្តើមត្រូវបានវិនិច្ឆ័យថាមិនយុត្តិធម៌ ។ បច្ចុប្បន្នគេត្រូវកត់សម្គាល់ថាលោកប៉ារ៉ីតូ បានធ្វើឱ្យសម្រេចនូវទ្រឹស្តី "ផលប្រយោជន៍"របស់លោកវ៉ាល់រ៉ាស់ដែលបង្ហាញអំពីតម្លៃសីលធម៌ ប្រសិនបើនីតិវិធីវិនិច្ឆ័យដែនកំណត់អតិបរមាមិនអាចទទួលយកបាននៅចំពោះមុខលក្ខណៈវិនិច្ឆ័យយុត្តិធម៌ដែលត្រូវប្រកាន់ខ្ជាប់ ។ ជួនកាល លោកវ៉ាល់រ៉ាស់មិនបានមើលឃើញទំនាស់រវាងគំរូរបស់អ្នកសេដ្ឋកិច្ចភាគច្រើន "អំពីសេដ្ឋកិច្ចសុទ្ធ"ជាមួយនឹងសំណើរបស់លោកអំពីកំណែទម្រង់សង្គមទាំងស្រុង សំដៅធ្វើឱ្យមានលក្ខណៈស្មើគ្នាក្នុងការចេញដំណើរដូចគ្នា ដូចជាការលុបចោលមរតកនិងការធ្វើជាតូបនីយកម្មដីធ្លី ៖ "អ្នករត់ប្រណាំងទាំងអស់ ត្រូវមានចំណុចចេញដំណើរដូចគ្នា ហើយម្នាក់ៗត្រូវទទួលការឱ្យរង្វាន់ទៅតាមភាពរហ័សរហួនរបស់គេ" ។

## 2. ការរីកចម្រើនដ៏ធំធេងនៃអ្នកគន្លឹនិយមសម័យថ្មីបែបស្រពេចស្រពិល

### 2.1. សេដ្ឋកិច្ចសុខុមាលភាពនិងការដួលរលំទីផ្សារ

សាលារៀនខេមប្រ៊ីជបានផ្តាច់ខ្លួនចេញពីដំបូង ដោយហេតុលោកស្តានឡេសឺវ៉ុន (Stanley Jevone) បានសង្ស័យថា ពលកម្មត្រូវបានគេចាត់ទុកដូចជាទំនិញមួយ ។ លោកអាល់ហ្វ្រីដម៉ាសាល់ (Alfred Marshal) បានកត់សម្គាល់ឃើញថា អ្នកក្រីក្រមិនមានប្រភពធនធាន ដើម្បីផ្គត់ផ្គង់ការរៀនសូត្រដែលទៅអនាគតនឹងបន្ថែមកម្លាំងឱ្យគេបានទទួលមរតកពីសង្គម និងអាចធ្វើឱ្យប្រសើរឡើងនូវការ

បម្រើសេវាកម្មសាធារណៈដែលទទួលបានពីការអប់រំឡើយ ។ លោកបានសម្គាល់ឃើញថា អត្ថិភាពនៃផ្នែកទាំងឡាយដែលមានថ្លៃធ្លាក់ចុះ ត្រូវតែដាក់ក្រោមការត្រួតពិនិត្យជាសាធារណៈ ពីព្រោះថារបបផ្ដាច់មុខនឹងកើតមានដោយចៀសមិនរួច ។ នៅទីបញ្ចប់ លោកបានមើលឃើញមុនគេនូវសំណើកេនិយមដែលមានគំនិតអំពីការរីកចម្រើនលូតលាស់ ដែលជំរុញដោយការបែងចែកផលទុនគួរជាទីគាប់ចិត្តដល់អ្នកបម្រើការងារយកបៀវត្សទាំងឡាយ ។ ដោយមានគោលគំនិតអំពីផលប៉ះពាល់ខាងក្រៅ (ឧ. ការបំពុលនៃបរិយាកាស)និងអំពីទ្រព្យសម្បហភាព(ឧ. ភ្លើងបំភ្លឺតាមទីសាធារណៈ) លោកម៉ាសាល់និងលោកពីហ្គូ បានលើកឡើងនូវករណីបរាជ័យជាបន្តបន្ទាប់នៃទីផ្សារ នៅពេលដែលមនុស្សនៅក្នុងសង្គមបានទទួលខុសគ្នានូវផលប្រយោជន៍បុគ្គល ដែលជាអ្នកសម្របសម្រួលកិច្ចអន្តរាគមន៍ ។ លោកពីហ្គូ បានចងក្រងគំនិតនេះឱ្យទៅជាទ្រឹស្ដីសេដ្ឋកិច្ចសុខុមាលភាព( 1912-33 ) ដើម្បីនាំមកនូវ "ការគាប់ចិត្ត"តាមគំនិតរបស់ប៉ារ៉ឺតូ រដ្ឋ(ដោយសន្មតថា មានការចេះដឹងសព្វគ្រប់និងមានមេត្តាធម៌) ត្រូវដាក់ចេញនូវឧបករណ៍កែសម្រួល(ជាពិសេស ប្រព័ន្ធពន្ធដារ ឬឧបត្ថម្ភធន) ។

## 2.2. ការប្រកួតប្រជែងមិនត្រឹមត្រូវ

ចាប់តាំងពីឆ្នាំ 1930 មានការខិតខំយកចិត្តទុកដាក់គិតពិចារណាអំពីភាពគ្មានប្រាកដនិយមនៃសម្មតិកម្មរបស់ថ្លៃដើម-ថ្លៃ-ប្រាក់ចំណេញ ពោលគឺបណ្ដាស្ថានភាពដែលសហគ្រាសអាចមានឥទ្ធិពលលើទីផ្សារ ។ ប្រសិនបើថ្លៃនិងបរិមាណសមតា មិនត្រូវបានលើកជាប្រធានរឿងទៀតទេ ជម្រើសទាំងឡាយនឹងប្រែទៅជាមានលក្ខណៈយុទ្ធសាស្ត្រ ។ ថ្លៃមិនមានលក្ខណៈជាប៉ារ៉ាម៉ែត្រទៀតទេ វាប្រែប្រួលនៅផ្ទៃក្នុងនៃគម្លាតរវាងចំនួនពីរ ។ សហគ្រាសទាំងឡាយមិនមែនជាអ្នកទទួលយកថ្លៃទៀតទេ ប៉ុន្តែ ជាអ្នកបង្កើតថ្លៃ ។ សហគ្រាសទាំងនោះបង្កើតបានអំណាចទីផ្សារដែលគេអាចវាស់វែងបានដោយមានជំនួយអំពី "លក្ខណវិនិច្ឆ័យរបស់លោកឡឺណឺ (Lerner)"ដែលវាស់វែងប្រាក់ចំណេញជាសមាមាត្រធៀបនឹងថ្លៃដើមម៉ាស៊ីណាល់ ។ សេចក្ដីស្នើខាងក្រោមនេះ នាំទៅរកសេដ្ឋកិច្ចឧស្សាហកម្មជាវិជ្ជាដែលសិក្សាអំពីសហគ្រាសទាំងឡាយនិងសាខារបស់វាដែលសង្កត់ធ្ងន់លើ "រចនាសម្ព័ន្ធ"នៃទីផ្សារ ដោយផ្សារភ្ជាប់ជាមួយចរិតលក្ខណៈរបស់សហគ្រាសទាំងឡាយនិងប្រតិបត្តិការរបស់វា

- **ការគ្មានចរិតចំណុះមុខងារទីផ្សារ :** អ្នកសេដ្ឋកិច្ចកេននិយមជាតិអង់គ្លេស លោកស្រីជនរ៉ូប៊ីនសុន (Joan Robinson, 1903-83) បានធ្វើការគិតគូរតាំងពីឆ្នាំ 1933 នូវករណីគម្លាតដ៏ច្រើនអនេកនៃថ្លៃដើម-ថ្លៃ-ប្រាក់ចំណេញដែលនៅជាប់ជាមួយនឹងអត្ថិភាពនៃសហគ្រាសដែលអាចគ្របសង្កត់ទីផ្សារបាន ។ លោកស្រីបានប្រើប្រាស់បញ្ញត្តិ "ការប្រកួតប្រជែងមិនត្រឹមត្រូវ"ជាលើកដំបូង ។ បច្ចុប្បន្ន គេប្រើប្រាស់ប្រភេទវិទ្យាដែលបង្ហាញឡើងនៅក្នុងតារាងរបស់លោកស្តាកកិលប៊ែរ (Stackelberge) ។

- **ការញែកភាពខុសគ្នានៃផលិតផល :** នៅឆ្នាំដដែល លោកអិដវ៉ឺត អេច ឆែមបឺលីន (Edward H.Chamberlin, 1899-1967) បាននិយាយអំពី "ការប្រកួតប្រជែងផ្តាច់មុខ" ដើម្បីចង្អុលបង្ហាញស្ថានភាពមួយ ដែលក្នុងនោះសហគ្រាសទាំងឡាយផ្គត់ផ្គង់ទំនិញដែលអាចជំនួសគ្នាបាន ប៉ុន្តែមានលក្ខណៈផ្សេងៗពីគ្នា ។ ដូចនេះ គឺមានព្រមគ្នានូវការផ្តាច់មុខ(សហគ្រាសជ្រើសយកថ្លៃរបស់គេដើម្បីបង្កើនឱ្យបានជាអតិបរមានូវប្រាក់ចំណេញរបស់គេ)និងការប្រកួតប្រជែង(ប្រាក់ចំណេញមានភាពវិជ្ជមាន សហគ្រាសថ្មីៗធ្វើដំណើរចូលទីផ្សារ) ។ គំរូនេះនាំឱ្យមានការយល់ដ៏ទូលំទូលាយអំពីតថភាពសហសម័យដែលកំណត់ដោយ "យុទ្ធសាស្ត្រសិក្សាទីផ្សារ" អំពីការញែករកភាពខុសគ្នា ។ សហគ្រាសនីមួយៗខិតខំញែកឱ្យឃើញភាពខុសប្លែកពីគេនៃផលិតផលរបស់ខ្លួនដែលនៅលើនោះគេនឹងធ្វើការផ្គត់ផ្គង់តាមបែបផ្តាច់មុខ ពោលគឺគេបង្កើតបានគម្លាតថ្នាក់ខ្ពស់ពីផលិតផលអ្នកដទៃ ។ ពេលនោះលក្ខខណ្ឌអំពីការរួបរួមគ្នាមិនមានការគោរពទៀតទេ ថ្លៃមិនមែនជាលក្ខណវិនិច្ឆ័យតែមួយដែលត្រូវជ្រើសរើសទេ ។ ដូច្នេះហើយ អតិថិជនរបស់ក្រុមហ៊ុនមែកសឺដែស (Mercedes) ត្រៀមខ្លួននឹងចំណាយយ៉ាងច្រើនចំពោះម៉ាកនេះ ដែលគេគិតថាជា "ស៊េរីខ្ពស់" ។
- **ឧបសគ្គចំពោះការនាំចូល :** លោកជេអេសបែន (J-S Bain) បានលើកឡើងករណីជាច្រើនដែលបានកត់សម្គាល់រួចកន្លងមកដោយលោកអាម៉ាសាល់ អំពីឧបសគ្គនៃការប្រកួតប្រជែងដែលបង្កឡើងដោយការរារាំងក្នុងរូបភាពជាស្ថាប័ន(បទបញ្ជា) ឬជាសកម្មភាពសេដ្ឋកិច្ច(ផលិតកម្មលើស ការវិនិយោគលើស ការលក់បង្ខូចថ្លៃ ...) ដែលត្រូវដោះស្រាយដោយសហគ្រាសទាំងឡាយតាមរបៀបឈរពាំងមុខច្រកចូល ។

## 2.3. មីក្រូសេដ្ឋកិច្ចថ្មី

អ្នកវិភាគមួយក្រុមបម្រុងនឹងទុកចោលសម្មតិកម្មគ្មានប្រាកដនិយមជាច្រើនដែលធ្វើឱ្យបាត់បង់ជំនឿទុកចិត្តលើគំរូនេះ ។ ករណីនេះនាំមកនូវទ្រឹស្តីមួយចំនួនមានភាពប្លែកដោយសារតែលទ្ធផលរបស់វាដោយហេតុថា ជាញឹកញាប់ណាស់ការរៀបចំច្រកនាំចេញមិនអាចធ្វើទៅបាន ដើម្បីមានសមតាពិសេសមួយ ។

- **ស្ថិរភាពនៃការនិយម :** ទ្រឹស្តីតាមបែបប្រពៃណីបានពន្យល់អំពីការវិវត្តនៃតម្រូវការតាមរយៈការប្រែប្រួលនៃថ្លៃ ឬនៃផលទុន ប៉ុន្តែបានបដិសេធទិដ្ឋភាពនៃការផ្លាស់ប្តូរចំណង់ចំណូលចិត្តដោយហេតុថានិន្នាការក្នុងការពន្យល់អំពីចំណង់ចំណូលចិត្តនេះមានភាពយឺតយ៉ាវលើនិន្នាការគ្មានលក្ខណៈវិទ្យាសាស្ត្រនៃចិត្តវិទ្យា ។ នៅឆ្នាំ 1966 ជនជាតិអាមេរិកាំងឈ្មោះ កែវវីន ជេឡែនកាស្ទ័រ (Kelvin J.Lancaster) បានរកឃើញដំណោះស្រាយមួយដោយលើកសំណើថា

ស្ថិរភាពនៃការនិយមស្ថិតនៅលើសេចក្តីត្រូវការជាមូលដ្ឋាន ។ ជំនួសឱ្យការបង្កើនឱ្យបានជាអតិបរមានូវមុខងារនៃផលប្រយោជន៍ទៅលើទំនិញ អ្នកប្រើប្រាស់នឹងបង្កើនឱ្យបានជាអតិបរមានូវមុខងារនៃផលិតកម្មដែលធ្វើឱ្យខ្លួនពេញចិត្ត ដែលទំនិញរូបីទាំងឡាយមិនមែនជាអ្វីក្រៅពីមធ្យោបាយសម្រាប់ប្រើប្រាស់ដែលមានជាប់ជាមួយនូវបច្ចេកទេសនិងទម្លាប់នៅក្នុងការវិវត្តជាអលជ្ជី ។

- **តម្លៃនៃពេលវេលា :** ចំពោះលោកសារី អេស បិកឺ (Giary S.Becker, Nobel 1992) ការប្រើប្រាស់ទាមទារដាច់ខាតនូវការចាយពេលវេលាដែលជាធនធានដ៏កម្រដូចគ្នានឹងទ្រព្យធនទាំងឡាយដែរ ដូចនេះ ថ្លៃគឺជាថ្លៃដើមនៃពេលវេលា ។ ***ឧទាហរណ៍*** ការខាតបង់ផលប្រយោជន៍មួយមានន័យថាគេនឹងត្រូវទទួលការទូទាត់សងវិញចំពោះការលះបង់ពេលវេលាទៅលើសកម្មភាពមួយនោះ ។ ដូច្នេះ "ថ្លៃដើមពេញលេញ" នៃអាហារមួយពេលត្រូវតែយល់ឱ្យដូចគ្នាអំពីថ្លៃដើមនៃពេលវេលាក្នុងការរៀបចំ ។ បញ្ហានេះត្រូវបានដាក់ជាមូលដ្ឋាននៃការបង្កើតច្បាប់ស្តីពីថ្លៃដោយឡែក ពីព្រោះថា ថ្លៃដើមនេះប្រែប្រួលទៅតាមទុនរបស់មនុស្សម្នាក់ៗ ។ ការបង្កើនទុននាំឱ្យផលទុនកើនឡើង ប៉ុន្តែនៅពេលមានការបង្កើនផលិតភាពផលិតកម្មថ្លៃទិញបែរជាធ្លាក់ចុះ ឯអតិថិជនដែលមានការគិតគូរត្រូវការការសន្សំពេលវេលា ។ ដូច្នេះហើយ កម្ពស់នៃថ្លៃដើមអាហារបានពន្យល់យើងអំពីសមិទ្ធផលអាហារដែលបានចំអិន ឬអំពីឧបករណ៍ប្រើប្រាស់ដែលជួយសន្សំពេលវេលា ។ ***ឧទាហរណ៍*** ថ្លៃដើមនៃនំអន្សមមួយដុំ ខ្ពស់ជាងថ្លៃដើមនៃដំឡូងស្ងោរមួយដុំ ។ លោកសារីបិកឺ (Giary Becker) បានពង្រីកការគិតនេះទៅដល់បាតុភូតសង្គម(ដែលពីមុនមកគេសន្មតថា)ដែលមិនមែនជាបញ្ហាសេដ្ឋកិច្ចមានដូចជា ការកាត់បន្ថយការផ្តល់កំណើតជាដើម ។ ថ្វីត្បិតការចំណាយក្នុងការបង្កើតទារកមានកម្រិតទាបក៏ដោយ ប៉ុន្តែការចំណាយពេលវេលា (លើការផ្គត់ផ្គង់ចំណីអាហារ ការថែទាំ ការអប់រំកូន ...) ។ មានកំណើនស្របគ្នាជាមួយនឹងការបង្កើនផលទុននិងការបង្កើនការងាររបស់ស្ត្រី ។
- **ធនធានមនុស្ស :** បញ្ញត្តិនេះអធិប្បាយលម្អិតដោយលោកបិកឺ (Becker) សំដៅលើសំណុំនៃបទពិសោធ ចំណេះដឹង និងសមត្ថភាព ដែលបុគ្គលទទួលបានក្រោយពេលកើតមក ។ មានការអធិប្បាយអំពីនានាភាពនៃបាតុភូតនៅក្រៅទ្រឹស្តីបទដ្ឋាន ។ ការប្រើប្រាស់ឧបករណ៍និងសេវាទាំងឡាយដែលនៅជាប់ជាមួយនឹងតន្ត្រីប្រែប្រួលទៅតាមការអនុវត្តគំនិតផ្នែកតន្ត្រីរបស់បុគ្គលទាំងឡាយ ផលិតភាពរបស់ពួកគេមានជាប់ជាមួយនូវការបណ្តុះបណ្តាល ហើយនឹងបទពិសោធវិជ្ជាជីវៈរបស់គេ ។ ការអប់រំ គឺជាការវិនិយោគលើវិស័យធនធានមនុស្សដែលមានដំណើរការលើអត្ថិភាពនៃផលទុនពីប្រភពច្រើនរូបភាពសមាមាត្រទៅនឹងការបរិច្ចាគព្រមគ្នាពីជំហានដំបូងមក ផលដ៏ប្រសើរបានទៅអ្នកទាំងឡាយដែលមានការប្រឹងប្រែងច្រើន ។

- **ថ្លៃចម្លងការនិងថ្លៃចាត់ចែង :** តាំងពីឆ្នាំ 1937 លោករ៉ូណាល់ខូស(Ronald coase, Nobel 1991) ក្រោយមកមានលោកអូអ៊ីវីលិយ៉ាំសុន(O.E.Williamson)បានលើកឡើងអំពីអត្ថិភាពនៃថ្លៃប្រើប្រាស់ទីផ្សារ គេត្រូវតែតាមពិនិត្យលើការផ្គត់ផ្គង់បច្ចុប្បន្ន ការជជែកអំពីកិច្ចសន្យា ការទទួលយកការប្រថុយប្រថាន ។ ការទិញ"ដោយការពេញចិត្ត"ត្រូវបានសន្មតថាជាការចាប់ផ្តើមជាថ្មីនៃលំនាំចម្លងការនីមួយៗ ។ គេរីករាយដោយការវាយតម្លៃសរុបលើទំនិញផ្គត់ផ្គង់ត្រូវបានទទួលយក ហើយគេកម្រនឹងប្តូរអ្នកផ្គត់ផ្គង់ ។ ថ្លៃចម្លងការនិងថ្លៃចាត់ចែងតាងឱ្យឯកទេសកម្ម និងការបង្កើតក្រុមហ៊ុន ពោលគឺជាវិស័យមួយដែលស្ថិតនៅក្រៅទីផ្សារ ដែលការផ្លោះប្តូរទាំងឡាយប្រព្រឹត្តទៅតាមការបញ្ជាទិញ ។ ប៉ុន្តែការចាត់ចែងក៏ដូចជាបង្ហាញផងដែរអំពីថ្លៃដើមដែលត្រូវកើនឡើងដោយត្រូវចំណាយទៅតាមទំហំនិងភាពស្មុគស្មាញនៃសហគ្រាស ។ ដូច្នេះផលិតកម្មរាប់បញ្ចូលផងដែរនូវភាពជាអាជ្ញាកណ្តាលរវាង "ការផលិត"(ការចាត់ចែង, ការរៀបចំផ្ទៃក្នុង)និង"ការជំរុញការផលិត"(ទីផ្សារ, ការចាត់ចែងខាងក្រៅ) ។

## 2.4. សេដ្ឋកិច្ចតន្ត្រីនិយមសម័យថ្មី

នៅក្រោមស័ព្ទពិសេសនេះ ចាប់តាំងពីឆ្នាំ 1970 អ្នកម៉ាក្រូសេដ្ឋកិច្ចនៅក្នុងក្រុមអ្នកតន្ត្រីនិយមឡូសិកគិតថាគឺមានតែគោលគំនិតអំពីម៉ាក្រូសេដ្ឋកិច្ចប៉ុណ្ណោះដែលត្រូវវិនិច្ឆ័យថាសមស្រប ។ ជាមួយគ្នានោះ ទ្រឹស្តីផ្តួចផ្តើមធំៗពីរត្រូវបានបង្ហាញ

- **ទ្រឹស្តីអំពីការប្រមើលមើលជាមុនតាមការពិចារណា** សរសេរដោយលោកលូកាស សាហ្សង់និងមុត (Lucas, Sargent, Muth) បានបង្ហាញថា ពីសម័យកាលខាងដើមរហូតមកដល់បច្ចុប្បន្នជាសម័យកាលដែលគ្មានការវិភាគ ។ ភ្នាក់ងារទាំងឡាយត្រូវបានវិនិច្ឆ័យថាអាចទទួលការវិភាគ និងធ្វើបុរេវិនិច្ឆ័យផងដែរដើម្បីជ្រើសរើសយកតែអ្នកសេដ្ឋកិច្ច គឺអ្នកដែលមានដំណោះស្រាយចុងក្រោយប្រឆាំងនឹងលទ្ធិចេតនានិយមសាធារណៈ(Volontarisme public) ។ ដូច្នេះហើយ ភ្នាក់ងារទាំងឡាយបានមើលឃើញជាមុននូវអតិផរណា រហូតឈានដល់ការបង្កើតនយោបាយរូបិយវត្ថុកេននិយម ។ ដោយដឹងថាអំណាចនៃការទិញរបស់គេនឹងត្រូវរងការខូចខាតដោយការឡើងថ្លៃទំនិញនោះ គេនឹងមិនចំណាយទៀតទេ ។ ធ្វើបែបនេះ គឺបំបាត់ចោលផលនៃការបោះចំណាយថ្មីទៀត ។ បច្ចុប្បន្ន នៅចំពោះមុខការប្រកាសមោឃភាពនៃករណីទីផ្សារហិរញ្ញវត្ថុ សមាជិកទាំងឡាយបានបោះបង់គំនិតនេះនៅឆ្នាំ 1990 ។
- **ទ្រឹស្តីអំពីការរីកចម្រើនកើតឡើងពីខាងក្នុង** សរសេរដោយលោកលូកាស បារ៉ូ និងរ៉ូមេ (Lucas, Barro, Romer) ចាប់កំណើតឡើងនៅទសវត្សរ៍ឆ្នាំ 1980 ។ ទ្រឹស្តីនេះ បានកំណត់ទុកថា កត្តាទាំងឡាយដែលនាំឱ្យមានការរីកចម្រើនមិនមានរាប់បញ្ចូលនូវធនធានមនុស្ស ការ

facebook.com/moeys.gov.kh
krou.moeys.gov.kh
youtube.com/moeys

ស្រាវជ្រាវ ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈទេ គឺមានតែការគិតទៅលើការបង្កើនទិន្នផលតែប៉ុណ្ណោះដែលរហូតមកដល់សព្វថ្ងៃទ្រឹស្តីនេះបានទទួលការបដិសេធ ។ ទ្រឹស្តីនេះនាំមកនូវគំនិតប្រតិមតិចំពោះចរន្តសេរីនិយមដែលតែងតែហៅរកការចូលរួមនៃអន្តរាគមន៍សាធារណៈដោយប្រកាន់យកនូវទស្សនៈថាមានតែការចូលរួមនេះទេដែលផ្តល់ប្រសិទ្ធភាពដល់ការអប់រំបណ្តុះបណ្តាលការសិក្សាស្រាវជ្រាវ ឬការកសាងហេដ្ឋារចនាសម្ព័ន្ធ ។

## 2.5. លទ្ធិផ្លាស់ប្តូរវិធានទាំងស្រុងកាន់តែមានភាពសកម្ម

- **លទ្ធិរូបិយវត្ថុនិយមរបស់លោកមីលតុនហ្រ៊ីដមែន** (Milton Friedman,Nobel 1976) បានចោទប្រកាន់លើលទ្ធិអន្តរាគមន៍និយមរបស់វិបត្តិទាំងអស់ ។ លទ្ធិនេះហៅរកការផ្លាស់ប្តូរនៅផ្នែកខាងក្រៅ និងការត្រួតពិនិត្យដ៏តឹងរ៉ឹងទៅលើបរិមាណរូបិយវត្ថុ ដោយហេតុថាការវិវត្តទៅរកបរិត្តផរណា (ឆ្នាំ 1929) ឬអតិផរណា (ឆ្នាំ 1970) បាននាំឱ្យមានផលភយន្តរាយ ។ នៅទសវត្សរ៍ឆ្នាំ 1970 លោកមីលតុនហ្រ៊ីដមែន បានទទួលជោគជ័យដោយអនុសាសន៍របស់លោកត្រូវបានគេទទួលយកគ្រប់ទីកន្លែង ។ ប៉ុន្តែ នៅទសវត្សរ៍ឆ្នាំ 1980 គេបែរត្រឡប់មករកទ្រឹស្តីកេនេនិយមវិញអំពីអត្រាប្រាក់ចំណេញ ។
- **ទ្រឹស្តីអំពីការផ្គត់ផ្គង់** លោកបានចោទប្រកាន់អ្នកកេនេនិយមថា បានផ្តួចផ្តើមឱ្យមានវិបត្តិបង្អាក់ការផ្គត់ផ្គង់ក្រោមបុព្វកថាទប់ទល់នឹងតម្រូវការ ។ ដូចនេះហើយ ប្រាក់បំណាច់និកម្មភាពក៏បានបង្កើនការនិយមជ្រើសយកនិកម្មភាព(និកម្មភាពចេតនា) ហើយសារពើពន្ធបានបង្អាក់ការប្រឹងប្រែង ។ ខ្សែកោងដ៏ល្បីល្បាញរបស់លោកឡាហ្វេបានរំលេចឱ្យឃើញថា ដល់ដំណាក់កាលដែលត្រូវជំរុញឱ្យមានដំណោះស្រាយបញ្ហា គ្រប់កម្ពស់នៃអត្រាពន្ធបន្ថយសកម្មភាពផលិតកម្ម និងធ្វើឱ្យមានការធ្លាក់ចុះចំណូលសារពើពន្ធ ដោយហេតុថា អ្នកត្រូវបង់ពន្ធពេញចិត្តនឹងធ្វើការតិចជាងមុន ឬលាក់បំពួនចំណូល ។ ក្រុមនេះ បានផ្តល់កម្លាំងចិត្តដល់ការងាររដ្ឋបាលរបស់លោករីហ្គែន (Reagan) នៅទសវត្សរ៍ឆ្នាំ 1980 ការបន្ទាបពន្ធដារនិងការជួយសង្គម ។
- **ទ្រឹស្តីអំពីទីផ្សារដែលអាចប្រកួតប្រជែងបាន** សរសេរដោយលោកបែលល្បូជេបាវម៉ុល (W.J Baumol) : ទីផ្សារមួយអាចប្រកួតប្រជែងបាន កាលបើលក្ខខណ្ឌនៃការនាំចូលនិងការនាំចេញដោយសេរីត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ។ វិនិយោគទាំងអស់អាចមានទ្រព្យសម្ភារៈ ហើយនាំចូលមកប្រកួតប្រជែងជាមួយសហគ្រាសទាំងឡាយដែលនៅឈរជើងនិងទីបំផុត អាចបញ្ឈប់ការនាំចូល ដើម្បីឱ្យការលក់ទ្រព្យសម្ភារៈរបស់ខ្លួនគ្មានការខាតបង់ ។ ក្នុងករណីនេះ គឺមានក្រុមហ៊ុនលក់ផ្តាច់មុខពីរ ឬបីប៉ុណ្ណោះជាអ្នកមកដល់ថ្មី ដើម្បីចូលប្រកួតប្រជែង ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## សំណួរ

1. មានករណីមួយកើតមានដូចខាងក្រោមនេះ

នៅផ្លូវចូលទីផ្សារមួយ មានភ្នាក់ងារសន្តិសុខទីផ្សារពីរ បីនាក់ឈរចាំហាមឃាត់មិនឱ្យឈ្មួញពីក្រៅដឹកត្រីចូលលក់ក្នុងទីផ្សារនោះ ។ ឈ្មួញដឹកត្រីទាំងនោះ ដោយមិនចង់ឱ្យកើតមានជម្លោះ ក៏បង្ខំចិត្តដឹកត្រីរបស់ខ្លួនត្រឡប់ក្រោយវិញ ។

ចូរអ្នកបង្ហាញទស្សនៈយល់ឃើញរបស់អ្នកអំពីករណីខាងលើនេះប្រាប់សិស្សក្នុងថ្នាក់ ។

2. ចូរពិភាក្សាជាគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម

ក. តើការគិតពិចារណារបស់ក្រុមអ្នកតន្តីនិយមសម័យមុននិងនិយមសម័យថ្មី ខុសគ្នាត្រង់ណា?

ខ. ចូរពន្យល់តម្លៃនៃទ្រព្យសម្ភារៈតាមគំនិតលោកសាយ លោកប៉ារ៉ឺតូ និងលោកម៉ង់សេ ។

គ. ក្នុងករណីណាដែលការផ្តោះប្តូរអាចកើតឡើងបាន? ចូរពន្យល់ ។

ឃ. ហេតុអ្វីបានជាគេថា "ការងារជាទំនិញ"? ចូរពន្យល់ ។

ង. អ្នកតន្តីនិយមសម័យថ្មី យល់ថា "ភាពរលាស់បាននៃថ្លៃជាអ្នកធានាឱ្យមានសមតាលើគ្រប់ទីផ្សារដោយព្រមគ្នា" ។ តើគំនិតនេះមានន័យយ៉ាងដូចម្តេច? ចូរពន្យល់ ។

ច. លោកប៉ារ៉ឺតូនិងលោកវ៉ាល់រ៉ាស់ចង់បានយុត្តិធម៌សង្គមដោយវិធីធ្វើកំណែទម្រង់សង្គមទាំងស្រុងសំដៅធ្វើឱ្យមានលក្ខណៈស្មើគ្នាក្នុងការចេញដំណើរ ដូចជាការលុបចោលមរតកនិងការធ្វើជាតូបនីយកម្មដីធ្លី ប៉ុន្តែគំនិតនេះទទួលការរិះគន់ច្រើន ។ តើគំនិតរិះគន់នោះមានអត្ថន័យដូចម្តេច?

ឆ. តើលោកអាល់ហ្វ្រឺដម៉ាសាលមានគំនិតយ៉ាងណាខ្លះទាក់ទងនឹង"សេដ្ឋកិច្ចសុខុមាលភាព"?

ជ. តើធនធានមនុស្សមានន័យយ៉ាងដូចម្តេច តាមគំនិតរបស់លោកបិកឺ(Becker)?

3. ចូរអ្នកអានអត្ថបទមេរៀនដោយយកចិត្តទុកដាក់និងស្រង់យកខ្លឹមសារដែលអ្នកយល់ថាសំខាន់យកចងក្រងជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

ចូរអ្នកដកស្រង់គំនិតរបស់អ្នកស្រាវជ្រាវណាម្នាក់ក្នុងមេរៀននេះយកមកសរសេរក្នុងក្រដាសផ្ទាំងធំហើយព្យួរទុកនៅជញ្ជាំងថ្នាក់រៀនរបស់អ្នក ។

facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeys

មេរៀនទី

# 5 កេនជាមួយនឹងគំនិតបូរាណនិយោជន៍

**ចប់មេរៀននេះ សិស្សអាច**

- ❑ បកស្រាយបណ្ដាគោលការណ៍ជាមូលដ្ឋាននៃគំនិតសេដ្ឋកិច្ចកេននិយម ។
- ❑ រៀបរាប់ចលនាមួយចំនួនដែលកើតឡើងក្រោយការបែកបាក់និយាយកេននិយម ។
- ❑ ចង្អុលបង្ហាញទ្រឹស្ដីណាមួយនៅក្នុងមេរៀនដែលគេយល់ស្របតាម ។

## 1. បណ្ដាគោលការណ៍ជាមូលដ្ឋាន



*ចនមេណាតកេន*
*(John MeynardKynes 1883-46)*

លោកចនមេណាតកេន (John Menard Keynes 1883-46) រៀននៅសាលាខែមប្រ៊ីដ(នៅប្រទេសអង់គ្លេស) ជាសិស្សរបស់លោកម៉ាសាលនិងលោកពីហ្គូ (Mashall et Pigou) ជាសិស្សដំបូងគេដែលមានការប្រតិបត្តិប្រាសចាកទ្រឹស្ដី ។ គំនិតរបស់លោកជាដំបូងបានបង្ហាញនៅក្នុងប័ណ្ណផ្ទត់នៅបណ្ដាឆ្នាំនៃទសវត្សរ៍ឆ្នាំ 1920 បន្ទាប់មក ត្រូវបានចងក្រងនៅក្នុងស្នាដៃធំៗរបស់លោកនៅបណ្ដាឆ្នាំនៃទសវត្សរ៍ ឆ្នាំ 1930 (សន្ធិសញ្ញារូបិយវត្ថុឆ្នាំ 1930 ទ្រឹស្ដីទូទៅអំពីភាពមានការងារធ្វើ អំពីអត្រាការប្រាក់ និងអំពីរូបិយវត្ថុឆ្នាំ 1936) ។ និក្ខេបបទដ៏ល្បីល្បាញរបស់លោកអំពី "ផលសេដ្ឋកិច្ចអំពីសន្តិភាព" បានទាមទារឱ្យមានការដាក់កំហិតឱ្យប្រទេសអាល្លឺម៉ង់ធ្វើឱ្យប្រសើរឡើងនូវការជួសជុលឡើងវិញនិងមានការគិតគូរអំពីហិរញ្ញវត្ថុ ពីព្រោះថាដំណោះស្រាយទាំងនេះផ្ដល់ផលប្រយោជន៍ដល់មនុស្សទាំងអស់ ។ គំនិតរបស់លោក គឺជាប្រភពនៃវិធានការសេដ្ឋកិច្ចអង់គ្លេសនៅឆ្នាំ 1967 ដែលបានបង្កើតមូលធនសម្រាប់ការស្ដារឡើងវិញសហគមន៍និងសន្តិភាព ។ និកម្មភាពនៅប្រទេសអង់គ្លេស នៅបណ្ដាឆ្នាំក្នុងទសវត្សរ៍ឆ្នាំ 1920 ហើយដែលកើតមានជាទូទៅនៅក្រោយឆ្នាំ 1929 បានធ្វើឱ្យលោកជំទាស់នឹងទ្រឹស្ដីអំពី "សមតាកើតឡើងដោយសារភាពអាចឡើងចុះបាននៃថ្លៃ" ។

## 1.1. សមតាកើតមានអាស្រ័យបរិមាណ មិនអាស្រ័យថ្លៃទេ

លោកកេន (Keynes) ថ្លៃមានលក្ខណៈទន់ភ្លន់ឡើងចុះបាន តែអ្នកធ្វើការមានលក្ខណៈរឹងស្ងួក ។ ភាពលើសកំណត់នៃការផ្គត់ផ្គង់ត្រូវដោះស្រាយដោយកំណើននៃសេចក្ដីត្រូវការ មិនមែនដោយការបន្ទាបថ្លៃទេ ។ ក្នុងករណីប្រាក់បៀវត្សត្រូវបន្ទាប តម្រូវការអាចទទួលមកនូវលទ្ធផលច្រាស ។ កម្រិតទាបនៃប្រាក់បៀវត្ស រុញច្រានឱ្យសហគ្រិនធ្វើការប៉ាន់ប្រមាណអំពីការធ្លាក់ចុះនៃការប្រើប្រាស់ ហើយបន្ទាប់មក ក៏កាត់បន្ថយការផ្គត់ផ្គង់និងការជួលកម្មករ ។

## 1.2. ការរីកចម្រើនជំរុញដោយតម្រូវការ

ដោយផ្ទុយគ្នានឹងច្បាប់របស់លោកសាយ លោកកេនទទួលយកគំនិតនេះតាមលោកម៉ាល់ទុស (Malthus) ហើយគំនិតនេះបានបង្ហាញរួចហើយនៅក្នុងស្នាដៃរឿងល្បើកអំពីសត្វឃ្មុំរបស់លោកប៊េណាដឌឺម៉ង់ដឺវីល (Bernard de Manderville 1670-1733) ។

## 1.3. ការជួលកម្មករ

ការជួលកម្មករមិនអាស្រ័យលើថ្លៃនៃការងារទេ ប៉ុន្តែអាស្រ័យលើតម្រូវការប្រសិទ្ធភាព ទីផ្សារការងារមិនមែនជាទីផ្សារពិតប្រាកដទេ ។ កម្មករមិនមែនជាទំនិញដែលគេអាច ផលិតបាននៅពេលដែលមានភាពខ្វះមនុស្សសំខាន់ធ្វើការក្នុងទីផ្សារការងារនោះទេ ។

- ការផ្គត់ផ្គង់ការងារមិនធ្លាក់ចុះទេ ក្នុងពេលដែលមាននិកម្មភាព និកម្មជនបង្ហាញខ្លួន ចំពោះមុខការប្រកាសជួលណាមួយដែលមានប្រាក់បៀវត្សអាចផ្គត់ផ្គង់ជីវភាពរបស់គេបាន ។
- តម្រូវការជួលអ្នកធ្វើការងារមិនកើនឡើងស្របគ្នានឹងការធ្លាក់ចុះនៃប្រាក់បៀវត្សទេ ពីព្រោះវាជាតម្រូវការប្រសិទ្ធភាព តួយ៉ាងដូចជា អាជីពដែលសហគ្រាសទាំងឡាយបានកំណត់ការជួលរបស់គេ។ ដូចគ្នានេះដែរ ចំពោះបៀវត្សស្ដួចស្ដើង អ្នករកការងារមិនទៅរកការងារនៅតាមទីផ្សារដែលសម្បូរដោយកម្មករនោះទេ ។

## 1.4. មិនមានសមតាម៉ាក្រូសេដ្ឋកិច្ចណាមួយមិនបង្ខំការងាររបស់បុគ្គលទេ

តាមគំនិតរបស់លោកវ៉ាល់រ៉ាស់ (Walras) សមតាទូទៅ ជាលទ្ធផលនៃភាពឡើងចុះព្រមគ្នានៃថ្លៃទាំងអស់ ។ លោកកេនបោះបង់ចោលចក្ខុវិស័យមីក្រូសេដ្ឋកិច្ច ពីព្រោះលោកយល់ថា ផលប្រយោជន៍ដោយឡែកអាចប្រឆាំងនឹងផលប្រយោជន៍ទូទៅ ។ ក្នុងន័យនេះ បុគ្គលនិយោជក(អ្នកប្រើ)បានផល

ចំណោញពីការផ្តល់ប្រាក់បៀវត្សទាបដល់កម្មករ ប៉ុន្តែជារួម កម្រិតទាបនៃប្រាក់បៀវត្សទាំងអស់ នាំឱ្យមានកម្រិតទាបនៃតម្រូវការនិងការប្រើប្រាស់របស់អ្នកធ្វើការ ទីបំផុតវាឃ្លាតកាន់តែឆ្ងាយពីសមតាក្នុងម៉ាក្រូសេដ្ឋកិច្ច ។

## 1.5. ការវិនិយោគទុននិងការនិយមរបស់អ្នកប្រើប្រាស់

ទំនាក់ទំនងទាំងឡាយក្នុងសង្គមត្រូវបាននាំមុខដោយតម្រូវការដែលចំណុះការវិនិយោគទុននិងការនិយមរបស់អ្នកប្រើប្រាស់ដែលចំណុះការថយចុះផលទុន (ច្បាប់ចិត្តវិទ្យាមូលដ្ឋាន : គេរកបានកាន់តែច្រើន គេកាន់តែប្រយ័ត្នប្រយែងក្នុងការប្រើប្រាស់) តម្រូវការមានឥទ្ធិពលលើអ្នកមានបៀវត្សតែគ្មានឥទ្ធិពលលើមូលធនិក ។

## 1.6. ការវិនិយោគទុនគឺជាផ្នែកមិននឹងននៃតម្រូវការ

វាប្រែប្រួលខ្លាំងទាក់ទងនឹងទីផ្សារនាំចេញ មុខរបរជំនាញ និងអត្រាការប្រាក់ដែលកំណត់ថ្លៃដើមក្នុងការខ្ចីប្រាក់ ។ មានតែការលើកកម្ពស់ការវិនិយោគទុនប៉ុណ្ណោះ ដែលអាចធ្វើឱ្យមានដំណើរការឡើងវិញនូវតម្រូវការនិងការប្រើប្រាស់ ។ ការវិនិយោគទុន គឺជាការចាយវាយ ។ គំនិតផ្តួចផ្តើមនេះ នាំឱ្យមានការចែកចាយផលទុនទៅភាគីអ្នកផ្គត់ផ្គង់ ។ ចំណាយទាំងអស់មានយន្តការដូចគ្នា ប៉ុន្តែមានតែការវិនិយោគទុនទេដែលជាផ្នែកមួយប្រែប្រួលតាមតម្រូវការ មិនមែនប្រែប្រួលតាមការប្រើប្រាស់ទេ ។

## 1.7. រូបិយវត្ថុមិនមានលក្ខណៈអព្យាក្រឹត

ការបញ្ចេញប្រើរូបិយវត្ថុ(ប្រាក់)មានលទ្ធផលដ៏ជាក់លាក់ ។ ប្រាក់មានកំណើនចាប់ពីបច្ចុប្បន្នរហូតដល់អនាគត បង្កឱ្យមានលំហូរទៅរកឥណទេយ្យ(ការឱ្យខ្ចី) ប្រសិនបើរូបិយវត្ថុមានច្រើនអត្រាការប្រាក់ថយចុះ កត្តានេះសម្រួលដល់ការវិនិយោគ ប៉ុន្តែ គឺតម្រូវការប្រសិទ្ធភាពជាអ្នកកំណត់ ។ អតិផរណាមិនមែនជាបាតុភូតនៃរូបិយវត្ថុទេ វាកើតឡើងអាស្រ័យដោយកត្តាផ្សេងៗ ។

## 1.8. សមតាមិនកើតមានឡើងដោយស្វ័យប្រវត្តិ

គំនិតរបស់លោកកេនគឺការអន្តរាគមន៍របស់រដ្ឋដែលមានតួនាទីនៅក្នុងតម្រូវការ ។ លោកកេនបានទាមទារឱ្យមាននយោបាយសកម្មមួយគឺ

youtube.com/moeys facebook.com/moeys.gov.kh krou.moeys.gov.kh

- នយោបាយថវិកា(ចំណាយនិងការទាមទារប្រាក់ជំពាក់សាធារណៈ) ៖ ក្នុងករណីដែលសេដ្ឋកិច្ច មានការធ្លាក់ចុះ រដ្ឋអាចអនុវត្តដំណោះស្រាយថវិកាហិរញ្ញវត្ថុតាមរយៈការខ្ចីបុល និងការទារឱ្យសងត្រឡប់វិញដែលនឹងធានាដល់ការងើបបំពេញការងារឡើងវិញ ដែលនឹងនាំមកនូវកំណើននៃផលទុននិងការចំណាយសារពើពន្ធលើផលទុននិងលើការប្រើប្រាស់ ។ រដ្ឋគឺជាស្ថាប័នតែមួយគត់ដែលបម្រើគោលបំណងសាធារណៈ ។ ចំណែកសហគ្រិន គេមិនអាចដាក់ទុនវិនិយោគទៅលើអ្វីដែលមានលក្ខណៈផ្ទុយនឹងនិន្នាការរបស់គេទេ ។ គោលការណ៍សំខាន់នៃថវិកាគឺសមតា អព្យាក្រឹតភាពនៃថវិកា ។
- នយោបាយថវិកាត្រូវរក្សាឱ្យបាននូវអត្រាការប្រាក់នៅកម្រិតមួយទាប ដើម្បីទ្រទ្រង់ការវិនិយោគទុនដោយការដាក់ទុនរាល់ថ្ងៃដែលអាចផ្តល់ធនលាភជាជាងផ្តល់ការប្រាក់(ប្រសិទ្ធភាពម៉ាស៊ីណាល់នៃមូលធនមានដូចជា អត្រាប្រាក់ចំណេញខ្ពស់ជាងការប្រាក់) ។

បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ប្រទេសជាច្រើនបង្កើតឡើងនូវរដ្ឋឧបត្ថម្ភ ។ ប្រទេសទាំងនោះប្រើប្រាស់គណនេយ្យជាតិដែលជាឧបករណ៍ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចកេននិយម ។

## 2. ការបែកបាក់ក្រុមកេននិយម

ក្រោយការបែកបាក់និកាយកេននិយម មានចលនាមួយចំនួនបានកើតឡើង ។

### 2.1. ក្រុមសំយោគ

លោកចនហ៊ីក (John Hicks 1904-1989 ទទួលរង្វាន់ណូបែលឆ្នាំ 1972) បានបោះពុម្ពផ្សាយនៅឆ្នាំ 1937 នូវកម្រងអត្ថបទមួយដែលបង្ហាញស្នាដៃវិភាគរបស់លោកកេន ។ ស្នាដៃវិភាគនេះ ត្រូវបានចាត់ទុកជាករណីពិសេសនៃគំរូអ្នកនិយមសម័យថ្មី ។ រួមជាមួយនឹងសេចក្តីបន្ថែមរបស់លោកអាអិមហាង់សិន (A.M.Hansen) ឬលោកប៉េអាសាមុអេលសុង (P.A.Samuelson) អត្ថបទផ្តល់កំណើតដល់ក្រុមសំយោគ ។ ចំណុចរួមនៃអត្ថបទដែលមាន គឺបង្ហាញអំពីការធ្វើបទបង្ហាញរបស់លោកកេនអំពីគោលនយោបាយសេដ្ឋកិច្ច ដែលជាការលាយចម្រុះរវាងសកម្មភាពថវិកានិងសកម្មភាពរូបិយវត្ថុដែលមានអាជ្ញាកណ្តាល គឺអត្រាការប្រាក់ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## 2.2. ក្រុមក្រោយកេនេនិយម

នីកូឡាកាលដូ (Nicolas Kaldor) មីឆែលកាឡិកគី (Michael Kalecki) ចូនរ៉ូប៊ីនសុន (Joan Robinson) ប្រកាន់យកចក្ខុវិស័យដែលកាន់តែខិតទៅជិតគំនិតលោកកេន ។ លោកទាំងនោះបដិសេធគំនូសបំព្រួញទាំងអស់ ដែលមានប្រើពាក្យសមតា ហើយប្រកាន់គំនិតគាំទ្រតួនាទីនៃការបែងចែកផលទុននៅក្នុងពេលមានការរីកចម្រើន ។ តាមគំនិតលោកកាលដូ គឺការរីកចម្រើនដែលមានភាពសមស្របគ្នារវាងប្រាក់បៀវត្សនិងប្រាក់ចំណេញ បានបង្ហាញជោគជ័យនៅបណ្តាឆ្នាំនៃទសវត្សរ៍ឆ្នាំ 1930 តាមរយៈយន្តការមួយដែលនិយ័តករទាំងឡាយត្រូវបានទទួលស្គាល់ថា ជាអ្នកសម្របសម្រួលបៀវត្សតាមបែបសម័យទំនើប ។

## 2.3. ក្រុមអ្នកកេនេនិយមថ្មី

បណ្តាអ្នកស្រាវជ្រាវជាលក្ខណៈប្រព័ន្ធអំពីគំនិតបញ្ញាសរបស់សមាជិកក្រុមសម័យថ្មី ដើម្បីស្នើឡើងយកមីក្រូសេដ្ឋកិច្ចជាមូលដ្ឋាននៃម៉ាក្រូសេដ្ឋកិច្ចកេនេនិយម ។ ចំណុចរួមរបស់លោកទាំងនោះមានលក្ខណៈសំខាន់ត្រង់សិក្សាស៊ីជម្រៅលើសញ្ញាណទាំងឡាយដែលបកស្រាយដោយលោកកេនអំពី "អនុសញ្ញា" (កិច្ចព្រមព្រៀងលំអិត) និងអំពីភាពមិនពិតប្រាកដ ។

### ក. តម្លៃនៃពត៌មាននិងថ្លៃប្រសិទ្ធភាព

- **តម្លៃនៃពត៌មាន :** ទ្រឹស្តីតាមបែបប្រពៃណីបានយកចិត្តទុកដាក់លើភាពសកលនៃពត៌មានត្រឹមត្រូវ (តម្លាភាព) ។ សម្មតិកម្មលើកឡើងថា "ការពិត (តថភាព) ប្រែទៅជាមានភាពសាំញ៉ាំ" ។ ច្បាប់អំពីថ្លៃពិសេសត្រូវបានចាត់ជាមូលហេតុនៃការស្រាវជ្រាវអំពីតម្លៃនៃពត៌មាន ។ ***ឧទាហរណ៍*** ប្រសិនបើទស្សនាវដ្តីចំនួន 50 កំពុងស្ថិតក្នុងការប្រកួតប្រជែងលើអត្ថបទតែមួយ អ្នកជាវទស្សនាវត្តីនឹងត្រូវតែថែមថ្លៃទៅលើការផលិត ដើម្បីរកឱ្យឃើញនូវទស្សនាវដ្តីណាមួយ ដែលមានអត្ថបទមានលក្ខណៈត្រឹមត្រូវច្រើនជាងគេ ។ តែពេលវេលាដែលបានចំណាយនោះ គេមិនអាចដឹងបាន ធ្វើឱ្យគេមានការលំបាកក្នុងការផ្តល់តម្លៃ ។ តម្លៃរបស់ពេលវេលាមានភាពខុសគ្នាទៅតាមភាពប៉ិនប្រសប់របស់មនុស្សម្នាក់ៗ ។
- **ថ្លៃប្រសិទ្ធភាព :** សញ្ញាណនៃថ្លៃប្រសិទ្ធភាព បំភ្លឺអំពីប្រតិកម្មរបស់ប្រតិបត្តិករទាំងឡាយក្នុងសេដ្ឋកិច្ចទីផ្សារ ចំពោះពត៌មានមិនពិត ។ ជំនួសឱ្យការស្វែងរកផលិតផលដែលគេត្រូវការក្នុង

តម្លៃសមរម្យ ជំនួសឱ្យការទទួលយកពត៌មានមិនត្រឹមត្រូវអំពីគុណភាព ។ លោកជ្រើសយកថ្លៃមួយដែលធានាកម្រិតជាក់លាក់មួយនៃគុណភាព(ការទិញដោយសួររកលិខិតធានា) ។ ដូច្នេះហើយ នៅឆ្នាំ 1957 លោកហាវេ លេបិនស្តេន (Harvey Leibenstein) ពិចារណាឃើញថាក្នុងប្រទេសក្រីក្រ មានតែការដំឡើងអត្រានៃប្រាក់បៀវត្សទេ ទើបមានការបង្កើនផលិតភាពដែលអាចធ្វើទៅបានដោយសាររសជាតិប្រសើរនៃអាហារ(បៀវត្សមានប្រសិទ្ធភាព) ។ ទ្រឹស្តីអំពីបៀវត្សប្រសិទ្ធភាពត្រូវបានទទួលស្គាល់ថា ជាការពន្យល់ដ៏ត្រឹមត្រូវអំពីភាពខុសប្លែកគ្នានៃការទូទាត់ថ្លៃពលកម្ម(ឧ.ក្រុមហ៊ុនហ្វត Ford ក៏ដូចជាក្រុមហ៊ុនម៉ៃក្រូសូហ្វ Microsoft បច្ចុប្បន្នកំពុងតែចំណាយប្រាក់ដ៏ច្រើនលើសលុប ដើម្បីរក្សាទុកបុគ្គលិកដែលមានភក្តីភាពនិងមានសមត្ថភាពខ្ពស់ក្នុងការផលិត ។ អ្នកទិញត្រូវតែសម្រេចចិត្តលើការជ្រើសរើសថ្លៃ ពីព្រោះគេមិនអាចមើលដឹងអំពីគុណភាព ។

លោកសាណេត យេលិន(Janet Yallen) ចកអាកឺឡុត(George Akerlot) បានអនុវត្តទ្រឹស្តីនេះជាទូទៅ ដោយការដាក់កំណត់ថ្លៃទាំងឡាយយ៉ាងជាប់លាប់ ។ ករណីមានបញ្ហាមិនទុកចិត្តចំពោះតម្លាភាព(ចំពោះពត៌មានច្របូកច្របល់) និងសភាគភាព(ភាពចុះសម្រុងគ្នា) អ្នកទិញត្រូវតែសម្រេចចិត្តលើការជ្រើសរើសថ្លៃ ពីព្រោះគេមិនអាចមើលដឹងអំពីគុណភាព ។

ឧទាហរណ៍ដ៏ល្បីល្បាញនៃទីផ្សារលក់រថយន្តក្នុងទីផ្សារផ្សេងៗបានបង្ហាញច្បាស់ ។ គឺមានតែអ្នកលក់ប៉ុណ្ណោះដែលដឹងអំពីថ្លៃរថយន្ត(ទោះបីគេក៏អាចទទួលពត៌មានប្រាសចាកការពិតក៏ដោយ) ។ ឯអ្នកទិញវិញពិនិត្យតែថ្លៃប៉ុណ្ណោះ ។ គេមានការបារម្ភថា រថយន្តនេះថោក ប៉ុន្តែអ្នកលក់បានប្រឹងដំឡើងថ្លៃរួចហើយ ។ សញ្ញាណនៃការប្រកួតប្រជែង ត្រូវបាត់បង់អត្ថន័យតន្តិនិយមសម័យថ្មីដែលធ្លាប់មាន ។ វាមានភាពប្រសើរជាងមុន ប៉ុន្តែឥរិយាបថរបស់ប្រតិបត្តិករមានលក្ខណៈរាវស្ទាបនៅក្នុងភាពប្រថុយប្រថានផ្សេងៗ ។

## ខ. ភាពមិនពិតប្រាកដ

លោកអាសារីយ៉ាឌី (Asariadis) ដោយប្រកាន់យកទ្រឹស្តីអំពីកិច្ចសន្យាវាទរហិត(មានការសន្យាដោយមិនបាច់សរសេរ) បានពន្យល់ពីការបំពានមួយចំនួនទៅនឹងច្បាប់ទីផ្សារ ដោយសារកិច្ចព្រមព្រៀងគ្មានសំណេរ ។ ដូច្នេះហើយ ប្រាក់បៀវត្សមិនប្រែប្រួលទៅតាមផលិតភាពដើមទេ ប៉ុន្តែវាកើនឡើងដោយសារអតីតភាព ដោយហេតុនិយោជិតមានការភ័យខ្លាចចំពោះភាពប្រថុយប្រថាន ហើយ

នយោជកភ័យខ្លាចចំពោះការបាត់បង់បុគ្គលិក ពួកគេក៏ព្រមព្រៀងគ្នាធ្វើឱ្យមានកិច្ចសន្យាបៀវត្សរយៈពេលវែងជាជាងស្ថិតនៅចំណុះដំណើរជោរនាចនៃទីផ្សារ ។

## 2.4. ទ្រឹស្តីសមតាចំពោះតម្លៃថេរ

ផ្តួចផ្តើមដោយលោកសង់ភ្វែបេណាស៊ី (Jean Pierre Benassy) អិដម៉ុងម៉ាឡាំងវ៉ូ (Edmond Malinvaud) និងសង់ជ្រែ (Jean Drege) ក្រុមនេះសិក្សាពីលទ្ធផលនៃការកំណត់រយៈពេលក្នុងការរៀបសម្រួលថ្លៃ ពោលគឺជាករណីទូទៅនៃទីផ្សារដែលគ្មានស្នងការប៉ាន់តម្លៃ(ភ្នាក់ងារទទួលបន្ទុកការងារដេញថ្លៃ) ។ ក្រុមនេះផ្សះផ្សារក្រុមអ្នកនិយមសម័យថ្មីនិងក្រុមកេននិយម ដោយចង្អុលប្រាប់តាមកាលៈទេសៈនូវក្របខ័ណ្ឌទ្រឹស្តីរបស់ក្រុមនីមួយៗថា មានភាពសមហេតុផល ។ នៅក្នុងរយៈពេលខ្លី តម្លៃទាំងឡាយមិនមានលក្ខណៈប្រែប្រួលទេ លើកលែងតែនៅលើទីផ្សាររៀបចំឡើងតាមរបៀបទីផ្សារតម្លៃ ។ ការផ្លាស់ប្តូរបានប្រព្រឹត្តទៅតាមតម្លៃថេរ (***ឧទាហរណ៍*** តម្លៃមានកំណត់នៅក្នុងផលប័ត្រវត្ថុរលីឬកាតាឡុក)ទីផ្សារមិនអាចដាក់កំហិតថ្លៃសមតាទេ ។ ដូច្នេះហើយ ទីផ្សារមានទីតាំងនៅត្រង់ភាពលើស ឬភាពខ្វះខាតនៃតម្រូវការ ។ សមតាតម្លៃថេររបស់ទីផ្សារនាំឱ្យមានការចែកចាយទៅតាមការកំណត់ចំនួន ជួនកាលចែកចាយទៅតាមតម្រូវការ ជួនកាលចែកចាយទៅតាមការផ្គត់ផ្គង់ គឺជា "យោបល់ដ៏ខ្លី" ដែលទីផ្សារមានការផ្គត់ផ្គង់ប្រសិនបើមានការខ្វះខាត ការប្រាប់ពីតម្រូវការ ប្រសិនបើមានការផ្គត់ផ្គង់លើស ។ វិសមតាធ្វើបំលាស់ទីពីទីផ្សារមួយទៅទីផ្សារមួយទៀត "ប្រសិនបើមិនសូវមានតម្រូវការទ្រព្យសម្ភារៈ សហគ្រាសទាំងឡាយនឹងកាត់បន្ថយតម្រូវការរបស់គេលើកម្លាំងពលកម្មនេះហៅថា និកម្មភាពតាមទ្រឹស្តីលោកកេន (ឆ្នាំ 1930-1990)" ។

## 2.5. ក្រុមនិយ័តកម្ម

នៅទសវត្សរ៍ឆ្នាំ 1970 អ្នកសេដ្ឋកិច្ចជាតិអាមេរិកកាំងមួយចំនួនមានដូចជា លោកមីសែលព័រ (Michael Piorre) លោកភីប៊ីដូរិនជើ (P.B.Doringer) អ្នកសេដ្ឋកិច្ចជាតិបារាំងមានដូចជាលោកអឹមអាគ្លីតា (M.Aglietta) អ៊ែប៊ុយេ (R.Boyer) អាលីពីត (A.Lipietz) បេកូរីយ៉ា (B.Coriat) បានស្នើឡើងនូវស្នាដៃវិភាគថ្មីៗមួយចំនួន ***ឧទាហរណ៍*** ការវិភាគលើភាគខណ្ឌទីផ្សារការងាររវាងការជ្រើសរើសផ្ទៃក្នុងរបស់សហគ្រាសធំៗដើម្បីរកនិយោជិតមានជំនាញ មានលំនឹងក្នុងការងារ សមគួរនឹងទទួលបៀវត្សសមរម្យ (ភាគខណ្ឌទីផ្សារទី 1)និងការប្រើប្រាស់នៅខាងក្រៅនូវបុគ្គលិកអថាវរៈ(បុគ្គលិកដែលអាចរំសាយនៅពេលណាក៏បាន) គ្មានជំនាញសមនឹងទទួលបៀវត្សតិចតួច សម្រាប់បំពេញការងារមិនស្ថិតស្ថេរ(ភាគ

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

ខណ្ឌទីផ្សារទី 2) ។ ការចោទជាបញ្ហាលើរឿងមិនពិតអំពីចរិតមានតែឯងនៃទីផ្សារបែបនេះ បាននាំទៅរកគោលគំនិតជាច្រើន ដែលបានជួបប្រទះនូវជោគជ័យដ៏ធំមួយគឺ

## ក. ចំណងទាក់ទងរវាងចំណុច 3

មានចំណងទាក់ទងរវាងចំណុច 3 គឺ

ចំណុចដើរតាមលោកម៉ាក្ស (Marx) (តួនាទីសំខាន់នៃកម្រៃផលទុន ប្រាក់បៀវត្ស ការប្រាក់នៅក្នុងប្រវត្តិសាស្ត្រ) ចំណុចដើរតាមលោកកេន (តួនាទីនិយ័តកម្មរបស់រដ្ឋ តម្រូវការរបស់អ្នកស៊ីឈ្នួលនៅក្នុងពេលមានការរីកចម្រើន) និងចំណុចដើរតាមសមាជិកស្ថាប័នតួយ៉ាង លោកកាលប្រេ (Galbreith) (អង្គការនានាដែលបង្ខូចទ្រង់ទ្រាយទីផ្សារ ដូចជាសហគ្រាស សហជីព រដ្ឋ ក្រុមសង្គម បំបែរការប្រកួតប្រជែង) ។

## ខ. ការវិភាគមួយអំពីប្រវត្តិសាស្ត្រនិងសង្គម

ច្បាប់សេដ្ឋកិច្ចមានអត្ថិភាពតែនៅក្នុងសម័យកាលមួយនិងនៅក្នុងសង្គមជាក់លាក់មួយ ។ ដូច្នេះនៅដំណាក់កាលនិយ័តកម្មប្រកួតប្រជែង (មុនឆ្នាំ 1914) កម្មករមិនបានប្រមូលផ្តុំគ្នាជាសហជីពទេ (កង្វះខាតស្ថាប័ននីយកម្ម) ។ នៅដំណាក់កាលនិយ័តកម្មផ្តាច់មុខ ឬប្រណីតភាព (ក្រោយឆ្នាំ 1945) មានការកត់សម្គាល់អំពីឥទ្ធិពលនៃក្រុមសហជីពដែលមានការជួបមុខគ្នាជជែកគ្នា (កិច្ចព្រមព្រៀងជាសមូហភាព) ហើយបម្រុងរំដោះខ្លួនចេញពីការប្រកួតប្រជែង ។

## គ. សារៈសំខាន់នៃប្រាក់បៀវត្សខ្ពស់

ដោយព្រមព្រៀងចំពោះប្រាក់បៀវត្សកម្រិតខ្ពស់ឱ្យស្មើនឹងកម្រិតនៃអតិផរណានិងកម្រិតផលចំណេញនៃផលិតភាព គឺមានការធានាទីផ្សារ ចំពោះការផ្គត់ផ្គង់ទាំងឡាយណាដែលមានកំណើនស្របគ្នាបែបនោះ ។ ករណីនេះគេរកឃើញវិធានរបស់លោកវីកសែល (Wicksell) ដែលបណ្តារដ្ឋាភិបាលកេននិយម ទទួលយកទុកជាមូលដ្ឋាននៃនយោបាយផលទុន ពោលគឺចាត់ចែងប្រាក់បៀវត្សនិងថ្លៃដោយធានាការរីកលូតលាស់ជាលំដាប់នៃថ្លៃនិងបង្កើនល្បឿននៃការប្រើប្រាស់និងការជួលកម្មករ ។ រាល់ភាពខ្វែងគ្នាពីប្រាក់បៀវត្សឡើងខ្ពស់ជាងផលិតភាពឬប្រាក់ចំណេញឡើងខ្ពស់ជាងប្រាក់បៀវត្សនាំឱ្យកើតមានវិបត្តិនៃផលិតកម្មលើស (បានដល់និកម្មភាព) ឬផលិតកម្មទាប (បានដល់អតិផរណា) ។ ស្របគ្នានេះ ផលិតកម្មតៃល័រនិយម (ពលករមានជំនាញតិច បរិមាណច្រើន ប្រមូលផ្តុំនៅផ្នែកឧស្សាហកម្មនិងទទួលបៀវត្ស) បានបង្ហាញប្រសិទ្ធភាពក្នុងការបញ្ចេញទំនិញប្រកបដោយស្ថិរភាព ប៉ុន្តែ

ផលិតកម្មនេះគ្មាននិរន្តភាពនៅគ្រាដែលកម្មករ ឬពលករ ឈប់ធ្វើការតូចតាច ដែលនាំឱ្យការប្រើប្រាស់ត្រូវបានផ្អាក ដោយសារទ្រព្យសម្ភារៈផលិតមិនទៀងទាត់ ហើយសេវាកម្មពិបាកនឹងគ្រប់គ្រងតាមបែបតៃល័រនិយម ។

### ឃ. វិធីនិយ័តកម្ម

គឺជាសំណុំនៃចរិតលក្ខណៈដែលធ្វើឱ្យប្រព័ន្ធសេដ្ឋកិច្ចមួយមានស្ថេរភាពនៅសម័យកាលមួយ ឧទាហរណ៍ការប្រកួតប្រជែងលើភាពផ្តាច់មុខនៅសតវត្សទី 19 (អធិកភាពទីផ្សារ វដ្តលូតលាស់) ឬអធិកភាពនៃស្ថាប័ន ។ តាមទស្សនៈម៉ាក្ស វដ្តវិបត្តិនៃទម្រង់ប្រណាំងប្រជែងគឺ ភាគីរួមបញ្ចូលរបស់ប្រព័ន្ធដែលនាំមកវិញនូវសមតា ក្រោយដំណាក់កាលបរិបូរ ។ នៅពេលដែលវិធីនិយ័តកម្មមិនមានដំណើរការតទៅទៀត វិបត្តិនៃការផ្លាស់ប្តូរបានមកដល់ ហើយការប្រកួតប្រជែងក៏កើតមានជាថ្មី ។ ការប្រកួតប្រជែងនៅឆ្នាំ 1929 បានផ្តល់កំណើតដល់លទ្ធិប្រណីតនិយម ។ ការប្រកួតប្រជែងក្នុងបណ្តាឆ្នាំនៃទសវត្សរ៍ឆ្នាំ 1980 នាំមកនូវសំឡេងជួងប្រកាសអាសន្ន ។ និយ័តកម្មថ្មីមិនមានប្រសិទ្ធភាពទៀតទេ ពោលគឺ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាមនុស្សយន្ត ការទាមទារថ្មីៗរបស់អ្នកប្រើប្រាស់ ការបដិសេធការងារតូចតាចដោយកម្មករដែលមានការសិក្សាខ្ពស់ ។

### ង. ផលទុនបៀវត្ស

គឺជាសំណុំនៃចរិតលក្ខណៈគ្រប់គ្រងទំនាក់ទំនងរវាងអ្នកជួលនិងអ្នកស៊ីឈ្នួល ។ ដូច្នេះ នៅក្នុងលទ្ធិទំនើបនិយម ផលទុនបៀវត្សមានជជែកជាសមូហភាព លក្ខណៈជាសង្គម ។ ការចោទជាបញ្ហាពិតប្រាកដទៅលើផលទុនបៀវត្សប្រណីតនិយមបានកើតមានឡើងនៅលើទិសដៅពីរផ្ទុយគ្នា ។ អ្នកជួលចង់ឱ្យមានភាពរលាស់ឱ្យកាន់តែច្រើន(អាចតថ្លៃបាន) ប៉ុន្តែក៏ត្រូវឱ្យមានផលច្រើនដល់អ្នកស៊ីឈ្នួលដែលជាជនត្រូវបានសន្មតថាមានសមត្ថភាព ។ អ្នករស់នឹងបៀវត្ស បដិសេធកិច្ចសន្យាប្រគល់ការងារនិងការបែងចែកភាគការងារ ចង់អភិរក្សការធានាទាំងឡាយតាមសម័យប្រណីតនិយម ប៉ុន្តែបង្ហាញការមិនពេញចិត្តនៅពេលចូលខ្លួនធ្វើការងារ ។

### ច. ការរីកចម្រើនមានភាពខុសគ្នាពីសម័យកាលមួយទៅសម័យកាលមួយ

- **នៅដំណាក់ប្រកួតប្រជែង :** ការរីកចម្រើនមានលក្ខណៈរាលដាលលើការពង្រីកកត្តាផលិតកម្ម (ការជួលកម្មករ ការបង្កើនម៉ោងធ្វើការ ការវិនិយោគទុន)ជាងការពង្រីកផលិតភាព ទីផ្សារនាំចេញមានទំនាក់ទំនងនឹងរចនាសម្ព័ន្ធជាងមានទំនាក់ទំនងនឹងការប្រើប្រាស់ដោយហេតុផលទុនទាបបានរក្សាទុកកម្មករឱ្យស្ថិតនៅត្រង់តួនាទីក្នុងកត្តាផលិតកម្ម ។

- **នៅដំណាក់ប្រណីតនិយម** ៖ ការរីកចម្រើនមានលក្ខណៈពិត ពោលគឺ ផលចំណេញខ្ពស់បានមកពីផលិតភាពនៃភាគីផ្គត់ផ្គង់ គោលការណ៍នៃការប្រើប្រាស់(ទ្រព្យសម្ភារៈ ផ្ទះ រថយន្ត ... មានគុណភាព)ហើយការកើនឡើងយ៉ាងលឿនផលទុននៃភាគីតម្រូវការបង្កឱ្យមានការរីកចម្រើនដ៏ខ្លាំងក្លា ដោយក្នុងនោះអ្នករស់ដោយបៀវត្សក្លាយទៅជាទីផ្សារនាំចេញដ៏សំខាន់ ។

## 2.6. សេដ្ឋកិច្ចនៃកិច្ចព្រមព្រៀង

បណ្តាអ្នកនិពន្ធជាតិបារាំង (A.Orlean.J.P.Duputy, Eymard-Duvernay, O.Faverau, L.Thevenot) បានសិក្សាស្រាវជ្រាវដើម្បីសម្គាល់បណ្តាកិច្ចព្រមព្រៀងក្រៅទីផ្សារទាំងឡាយដែលជាមូលដ្ឋាននិងជាអ្នកបង្កឱ្យមានបណ្តាទំនាក់ទំនងនៃទីផ្សារ(មានដូចជារូបិយវត្ថុ កិច្ចព្រមព្រៀងកេននិយមអំពីផលិតភាពជាដើម) ។

# 3. សេចក្តីសន្និដ្ឋាន

ភាគច្រើន គេស្គាល់អ្នកនិពន្ធសេដ្ឋកិច្ចតាមរយៈការឈរឈ្មោះនៅតាមក្រុមនីមួយៗ ។ និន្នាការសង្គមជាក់ស្តែងមានដំណើរឆ្ពោះទៅប្រកាន់យកទ្រឹស្តីដែលមានចែងអំពីអាកប្បកិរិយារបស់ក្រុមនីមួយៗ ។ ដូច្នេះ ទ្រឹស្តីនៃអង្គការទាំងឡាយប្រឹងប្រែងបញ្ចូល "ការត្រួតពិនិត្យការគ្រប់គ្រង"ដើម្បីពន្យល់បានអាកប្បកិរិយារបស់អង្គការទាំងនោះ ។ សហគ្រាសទាំងឡាយមិនមែនជាភ្នាក់ងារសេដ្ឋកិច្ច ឬជាអង្គភាពអន្តរាគមន៍ទីផ្សារទេ ។ សកម្មភាពចម្រុះនៃទីផ្សារកើតឡើងដោយទំនាក់ទំនងផ្ទៃក្នុងរបស់ទីផ្សារ គឺមិនកើតឡើងដោយភាពមានវិចារណញ្ញាណរបស់ទីផ្សារទេ ។

## សំណួរ

1. ចូរអ្នករៀបរាប់ប្រាប់សិស្សក្នុងថ្នាក់អំពីចំណេះដឹងអំពី "និកម្មភាព" ដែលអ្នកបានសិក្សា ។
2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

   ក. តើលោកកេនជានរណា ?

   ខ. តើលោកកេនគិតពីអ្វី ?

   គ. តើមានទ្រឹស្តីអ្វីខ្លះជាគំនិតរបស់លោកកេន ? ចូរពន្យល់ទ្រឹស្តីនីមួយៗ ។

   ឃ. ក្រោយពីការបែកបាក់ក្រុមកេននិយម តើមានចលនាអ្វីខ្លះកើតឡើង ?

   ង. តើក្រុមដែលកើតឡើងក្រោយក្រុមកេននិយមមានអ្វីខ្លះ ? តើក្រុមនីមួយៗមានទស្សនៈដូចម្តេចខ្លះ ?

   ចូរអ្នកអានអត្ថបទមេរៀនដោយយកចិត្តទុកដាក់ ហើយដកស្រង់បណ្តាចំណុចដែលអ្នកគិតថាសំខាន់ ដើម្បីយកមកចងក្រងជាមេរៀនសង្ខេបផ្ទាល់ខ្លួន ។

## ប្រតិបត្តិ

តាមទស្សនៈរបស់លោកម៉ាសាល់ "ប្រាក់បៀវត្សត្រូវឱ្យមានកម្រិតទាប ដើម្បីរំលែកដល់មនុស្សគ្រប់រូប" ប៉ុន្តែលោកកេនមានទស្សនៈថា "ប្រាក់បៀវត្សត្រូវធានាឱ្យបាននូវប្រសិទ្ធភាពការងារ មិនមែនសម្រាប់ធានាឱ្យមនុស្សគ្រប់រូបមានការងារធ្វើទេ" ។ ចូរពិភាក្សា ។

## សំណួរបញ្ចប់ជំពូកទី៣

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ**

1. តើហេតុអ្វីបានជាគេថា សម័យវិស័យពាណិជ្ជកម្មជាប់ការមន្ទិលសង្ស័យ ?

- ☐ ក. ការធ្វើពាណិជ្ជកម្មដោយមិនគិតពីសីលធម៌និងបាបកម្ម
- ☐ ខ. ការធ្វើនយោបាយពាណិជ្ជកម្មគិតតែផលចំណេញនិងគ្មានសមធម៌
- ☐ គ. ពាណិជ្ជកម្មជាអ្នកធ្វើអន្តរាគមន៍ក្នុងការចែកចាយផលិតផលដល់អ្នកក្រ
- ☐ ឃ. សេរីភាពនៃការធ្វើពាណិជ្ជកម្មនាំចេញច្រើន នាំឱ្យមានវិបត្តិក្នុងប្រទេស ។

2. ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អ្នកធម្មជាធិបតេយ្យយកចិត្តទុកដាក់លើ

- ☐ ក. ដីជាប្រភពទ្រព្យសម្បត្តិតែមួយគត់
- ☐ ខ. កសិកម្មជាប្រភពនៃវត្ថុធាតុដើមសម្រាប់ផលិតកម្ម
- ☐ គ. ឧស្សាហកម្មនិងពាណិជ្ជកម្មជាប្រភពនៃការរីកចម្រើនរបស់សង្គម
- ☐ ឃ. ទីផ្សារសេរីនាំជាប្រភពនៃការរីកចម្រើនរបស់សង្គម ។

3. តើក្រុមអ្នកសេដ្ឋកិច្ចតន្តីនិយមបានសិក្សាលើអ្វីសំខាន់ជាងគេ ?

- ☐ ក. កំណើនសេដ្ឋកិច្ចនិងសេរីភាពសេដ្ឋកិច្ច
- ☐ ខ. ការប្រកួតប្រជែងដោយសេរីលើទីផ្សារ
- ☐ គ. ការកើនឡើងចំនួនប្រជាជននាំឱ្យរំខានដល់ការរីកចម្រើននៃសេដ្ឋកិច្ច ។
- ☐ ឃ. មូលដ្ឋានគ្រឹះនៃបាតុភូតសេដ្ឋកិច្ច(ធនធានមនុស្ស ធម្មជាតិ និងទំនិញ) ។

4. តើលោកកាល់ម៉ាក្សបានធ្វើការសិក្សាលើអ្វីខ្លាំងជាងគេក្នុងទ្រឹស្តីរបស់គាត់ ?

- ☐ ក. ការតស៊ូរបស់នយោជិកនិងនយោជកក្នុងវិស័យផលិតកម្ម
- ☐ ខ. ការកេងប្រវ័ញ្ចលើតម្លៃការងារនយោជិត
- ☐ គ. ប្រវត្តិសាស្ត្រនៃការរីកចម្រើនបែបផែនផលិតកម្ម
- ☐ ឃ. នយោបាយដើម្បីសេរីភាពច្រើនជាងសេដ្ឋកិច្ច ។

5. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចតាមគំនិតលោកកេន

- ☐ ក. រដ្ឋត្រូវតែធ្វើអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ដើម្បីរក្សាសេដ្ឋកិច្ចឱ្យមានស្ថិរភាព
- ☐ ខ. ទីផ្សារជាអ្នកសម្របសម្រួលនិងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- ☐ គ. រដ្ឋជាអ្នកបង្កើតឱ្យមានតម្រូវការសេដ្ឋកិច្ចក្នុងសង្គម
- ☐ ឃ. រដ្ឋជាអ្នកធានាឱ្យមានសមធម៌ក្នុងការរីកចម្រើននៃសង្គម ។

youtube.com/moeys khmer.moeys.gov.kh facebook.com/moeys.gov.kh

6. ការអន្តរាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ចនាំឱ្យ

☐ ក. ប្រជាជនមានការងារពេញលេញនិងទទួលផលប្រកបដោយសមធម៌

☐ ខ. មានវិបត្តិតម្រូវការនិងការផ្គត់ផ្គង់របស់សេដ្ឋកិច្ច

☐ គ. ទីផ្សារមិនមានដំណើរការល្អក្នុងការជំរុញប្រតិបត្តិផលិតកម្មនិងការលក់ទំនិញនានា

☐ ឃ. ការសង្គ្រោះសេដ្ឋកិច្ចបានក្នុងពេលមានវិបត្តិ ។

**II. ចូរអ្នកបកស្រាយគំនិតរបស់លោកកេន**

សេដ្ឋវិទូ កេនយល់ច្បាស់ថា កម្លាំងទីផ្សារពិតជាមានអំណាចខ្លាំងណាស់ ។ ទីផ្សារពេលខ្លះ ពិតជាមិនមានកម្លាំងគ្រប់គ្រាន់សម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានតុល្យភាពយូរអង្វែងឡើយ ។ វាអាចកើតមានវិបត្តិក្នុងការផ្តោះប្តូរផលិតផល ដោយសារចំនួនមនុស្សចេះតែកើនឡើងជារៀងរាល់ថ្ងៃនិងមានសេចក្តីត្រូវការឥតព្រំដែន ចំណែកឯធម្មជាតិមានកំណត់និងចេះតែរេចរិលជារៀងរាល់ថ្ងៃ ។ សេដ្ឋវិទូកេនមានការព្រួយបារម្ភយ៉ាងខ្លាំង តើគេធ្វើយ៉ាងណាដើម្បីឱ្យតម្លៃទំនិញមានស្ថិរភាពហើយប្រជាជនមានការងារធ្វើពេញលេញ ។

លោកកេនបានសង្កត់ធ្ងន់ថា តម្លៃទំនិញថេរ ឬកើនឡើងនោះ វាអាស្រ័យនឹងអ្នកធ្វើជំនួញនិងអង្គការពលកម្ម ចុះដើម្បីធ្វើឱ្យប្រជាជនមានការងារធ្វើពេញលេញនោះ តើតាមទស្សនៈរបស់លោកកេន គាត់មានយុទ្ធសាស្ត្រអ្វីដែរ ហើយត្រូវធ្វើដូចម្តេច ?

**III. ចូរឆ្លើយសំណួរខាងក្រោម**

1. ហេតុអ្វីបានជាគេថា ការរីកចម្រើនសេដ្ឋកិច្ចអាស្រ័យលើការធ្វើពាណិជ្ជកម្មនាំចេញច្រើន ?
2. តើសីលធម៌និងសមធម៌មានន័យយ៉ាងដូចម្តេចក្នុងន័យពាណិជ្ជកម្ម ? ចូរពន្យល់ ។
3. តើមានន័យយ៉ាងដូចម្តេចចំពោះពាក្យថា បាបកម្មក្នុងន័យពាណិជ្ជកម្ម ? ចូរពន្យល់ ។
4. ហេតុអ្វីវិស័យពាណិជ្ជកម្មនិយមនាសតវត្សទី 15 ដល់ទី 17 ចាត់ទុកមាសនិងប្រាក់សំខាន់ជាងគេ ?
5. ហេតុអ្វីបានជាអ្នកធម្មជាធិបតេយ្យនិយាយថា "ដីជាប្រភពនៃទ្រព្យសម្បត្តិរបស់មនុស្សជាតិ" ?
6. ហេតុអ្វីវិស័យពាណិជ្ជកម្មជាវិស័យមួយគ្រាន់តែជាការប្តូរទីតាំងផលិតផលគ្នាប៉ុណ្ណោះ ?
7. តើក្រុមសេដ្ឋកិច្ចក្លាសិកបានសិក្សាលើអ្វីខ្លះ ដែលជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ?
8. ហេតុអ្វីបានជាលោកកាល់ម៉ាក្សសិក្សាលើការកេងប្រវ័ញ្ចនៃតម្លៃពលកម្មនិងការតស៊ូវណ្ណៈ ?
9. តើកេនបានពន្យល់ដូចម្តេចចំពោះ "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ" ?
10. តាមគំនិតរបស់លោកកេន តើរដ្ឋគួរមានតួនាទីដូចម្តេចខ្លះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ?
11. តើសេដ្ឋកិច្ចសម័យក្រោយលោកកេន សិក្សាអំពីអ្វីខ្លះ ?

facebook.com/moeys.gov.kh youtube.com/moeys